ធម្មទាន

# កំណាព្យអធិប្បាយស្រាយ
# មង្គលសូត្រ



ឧបាសក **ឆាយ មាស**　　ភិក្ខុ **ឆេន ចន្ទសេដ្ឋា**

វត្ត ឯករស្មី ហៅ ទួលតាឯក ព.ស. ២៥៥៦ គ.ស. ២០១៣

# កំណាព្យអធិប្បាយ

## ស្រាយ

# មង្គលសូត្រ

### សូត្រស្ដីពីសេចក្ដីចម្រើន ៣៨ ប្រការ

និពន្ធកំណាព្យ

ឧបាសក **ឆាយ មាស**

រៀបរៀងអត្ថបទ និងកិច្ចការទូទៅ

សមណនិស្សិត បញ្ញាវរោ **ឆេន ចន្ទសេដ្ឋា**

**ឯករស្មី ហៅ ទួលតាឯក ព.ស ២៥៥៦**

# អារម្ភកថា

ខ្ញុំព្រះករុណាខ្ញុំបាទយល់ឃើញថាធម៌មង្គលសូត្រជាដំបូន្មាននៃព្រះមហាមុនីដែលមានតម្លៃ តម្លាភាពនិងសារៈប្រយោជន៍ដ៏ក្រៃលែងទៅនឹងសង្គមមនុស្សគ្រប់ៗសម័យកាល ជាពិសេសគឺជាឱវាទទាន់សម័យបំផុត សម្រាប់យុវជន យុវនារី ក្នុងសម័យកាលបច្ចុប្បន្ននេះតែម្តង ដើម្បីនឹងប្រតិបត្តិឲ្យបានល្អគ្រាន់បានសេចក្តីសុខ និងប្រយោជន៍ទូទៅទាំងអស់គ្នា។ ម្យ៉ាងទៀតដោយឃើញថា សម័យនេះ ប្រជាពលរដ្ឋខ្មែរទាំងស្រីទាំងប្រុសចាស់ក្មេង ច្រើនចូលចិត្តសិក្សាកំណាព្យ តែង អត្ថបទកំណាព្យ ឬ សូត្រអត្ថបទកំណាព្យ ជាញឹកញាប់ដោយមានសូត្រផ្សាយនៅតាមស្ថានីយវិទ្យុនានា ដែលដឹកនាំផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនាដោយព្រះភិក្ខុសង្ឃទាំងឡាយផងនោះ ទើបខ្ញុំព្រះករុណាខ្ញុំបាទព្យាយាម និពន្ធអត្ថបទកំណាព្យ ដើម្បីធ្វើអត្ថាធិប្បាយនូវន័យសេចក្តីនៃព្រះមង្គលសូត្រនេះឡើង ដោយដាក់ចំណងជើងថា**កំណាព្យអធិប្បាយស្រាយមង្គលសូត្រ**។

កំណាព្យអធិប្បាយស្រាយមង្គលសូត្រ មិនមែនជាវណ្ណកម្មអ្វីប្លែកនោះទេ គឺជាមង្គលសូត្រដែលព្រះតថាគតទ្រង់បានសម្តែងទុកមកជាពាក្យទូន្មានស្រាប់លើសបន្តិចត្រង់ថា ពេលនេះយើងយកកាព្យបែបអក្សរសាស្រ្តខ្មែរមករំគាយសេចក្តីតាមអត្ថន័យ នៃព្រះពុទ្ធោវាទ គឺហាក់ដូចជាបានធ្វើខេមរូបនីយកម្មមង្គលសូត្រ បែបបាលីឲ្យមកជាបែបខ្មែរដោយមិនមានចេតនាណាមួយធ្វើឲ្យខុសពីព្រះពុទ្ធដីកាឡើយ។

ដោយសារតែសទ្ធាជ្រះថ្លាជួយឧបត្ថម្ភគាំទ្ររបស់ពុទ្ធបរិស័ទទាំងឡាយព្រមទាំងការជួយជ្រោមជ្រែងពិនិត្យផ្ទៀងផ្ទាត់ ជួយទាំងបច្ចេកទេសកុំព្យូទ័រដោយបញ្ចេញទាំងកម្លាំងកាយ ចិត្ត ក្នុងកិច្ចការធម្មទានរបស់ព្រះករុណាគុណម្ចាស់គ្រប់ៗអង្គ ជាពិសេស ព្រះមហា បញ្ញាវរោ **ឆេន ចន្ទសេដ្ឋា** មានព្រះទ័យព្យាយាមជួយបន្ថែមសំណេរ និងជួយចាត់ចែងទូទៅផ្សាយជាធម្មទានផង ទើប

កូនសៀវភៅនេះបានបង្ហាញជារូបរាងឡើង ជូនលោកអ្នកអាន (ស្តាប់) ដោយមានការរអៀសខ្លួនជាមួយផង ព្រោះដឹងថាសំណេរនេះ ច្បាស់ជាមានការខុសឆ្គងខ្វះខាតច្រើនអន្លើជាពុំខានឡើយ។

អាស្រ័យហេតុនេះសូមលោកអ្នកអាន (ស្តាប់) ជាទីមេត្រី ប្រណីផ្តល់អធ្យាស្រ័យដល់ខ្ញុំព្រះករុណា អាត្មាភាព ខ្ញុំបាទ ហើយជួយរិះគន់ស្ថាបនាឲ្យទានដោយក្តីអនុគ្រោះ។

សូមពុទ្ធបរិស័ទទូទៅបានប្រកបដោយសុខសន្តិភាពក្នុងម្លប់ព្រះពុទ្ធសាសនា។

សរសេរចប់ថ្ងៃពុធ ១៥ កើត ខែស្រាពណ៍ ព.ស២៥៥៤

ត្រូវនឹងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១០

ឧបាសក **ឆាយ មាស** បញ្ញាវរោ ភិក្ខុ **ឆេន ចន្ទសេដ្ឋា**



បញ្ញាវរោ ភិក្ខុ **ឆេន ចន្ទសេដ្ឋា** សមណនិស្សិតនៃពុទ្ធិក

សាកលវិទ្យាល័យព្រះសីហនុរាជ សាខាខេត្តបាត់ដំបង (ទស្សនវិជ្ជា ពុទ្ធសាសនា)



ឧបាសក **ឆាយ មាស** កវីនិពន្ធកំណាព្យ

អតីតបុគ្គលិកសិក្សានៃក្រសួងសិក្សាធិការជាតិ

ទស្សនទានរបស់ព្រះចៅអធិការវត្តបាត់ដំបង.

- ព្រះធម៌ដែលបកស្រាយ ជា ស្រោយ និងកំណាព្យ.

ចិត្តល្អ [illegible] ងាយ ស្រួល [illegible] ចិត្តចូលរួម [illegible].

មកពីអ្នក [illegible] ព្រោះ [illegible] ព្រះពុទ្ធ -

សាសនា [illegible] នានានិកាយ [illegible] ធ្វើ

ព្រះវិហារ. ។

ក្រុងបាត់ដំបង ថ្ងៃទី [illegible] ខែ [illegible] ២០១៣

ព្រះចៅអធិការវត្ត -

[illegible]
[illegible]
[illegible]
[illegible]
[illegible]
[illegible]

[illegible]
[illegible]

[illegible]

[illegible]

ក្រុងប៉ារីស / ថ្ងៃទី 31.05-2013

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[signature]

បណ្ឌិតច្ឆោ សាន_អ៊ីន

[illegible]

[illegible]

[illegible]

ភ្នំពេញ ថ្ងៃទី 30 ខែ[illegible] ឆ្នាំ[illegible]

ឈួន ប៊ុនធឿន

មតិចូលរួម

ខ្ញុំព្រះករុណា ខ្ញុំបាទ យល់ឃើញថា ៖ “កំណាព្យអធិប្បាយស្រាយពុទ្ធិស្ត្រី
នេះ ពិតជាផ្ដល់ប្រយោជន៍ច្រើន ក្នុងការអប់រំ ក៏ដូចជាគ្រួសារ បណ្ដាញ
ក្នុងការប្រព្រឹត្ត ស្រីដែលជាមនុស្ស និងស្រីដែលមិនមែនជាមនុស្ស សម្រាប់
ជាស់តឿនក្រុមគ្រួសារ ឲ្យយល់ច្បាស់ពីលក្ខណស្ត្រី
ក៏មាន ៣៥ ប្រការ ដោយយកទៅអនុវត្ត សម្រាប់ការរស់នៅប្រកបដោយ
ភាពសុខសប្បាយ ក្នុងក្រុមគ្រួសារដើម្បីជាតិ សង្គមជាតិ ។

ធ្វើនៅ ថ្ងៃទី ៣១ ខែ ឧសភា ព.ស.២៥៥៧
គ.ស.២០១៣

គឹម-ប៊ុនថា

# ឧទ្ទិសកថា

ដោយអំណាចផលានិសង្សនៃកូនសៀវភៅនេះ និងមហាកុសលថ្នាក់ បព្វជ្ជា អស់រយៈកាល ១៣ ឆ្នាំ របស់ខ្ញុំ ព្រមទាំងបុណ្យកុសលដទៃទៀត មាន ការសម្ដែងធម៌ តាមស្ថានីយ៍វិទ្យុនានា ការបំពេញកិច្ចការស្ម័គ្រចិត្ត ក្នុងកម្មវិធីបំបួសអប់រំសីលធម៌ ជាគ្រូបង្គោល ទាំងក្នុងប្រទេសកម្ពុជា និងប្រទេសថៃ អស់រយៈពេល៤ ឆ្នាំ ការកសាងគម្ពីរអដ្ឋកថា ផ្កាប្រាក់ កឋិន និង ការចូលរួមសកម្មភាព ជំនួយមនុស្សធម៌នានា ជាធម្មទានក្ដី និងអាមិសទានក្ដី សម្រេចបានជាមហាកុសល សូមកើតមានដល់មាតាបិតា គ្រូឧបជ្ឈាយាចារ្យ ព្រះមហាក្សត្រ រួមទាំងបព្វជិត គ្រហស្ថ នាហ្មឺនសព្វមុខមន្ត្រី បងប្អូនជនរួមជាតិ ដែលបានបំពេញកាតព្វកិច្ច ដើម្បីបុព្វហេតុជាតិ សាសនា និងលោកអ្នកទាំងឡាយដែលបានចាប់កាន់អានសៀវភៅនេះ សូមឲ្យកើតកើនចម្រុងចម្រើន លាភ យស សរសើរ សុខ ពុទ្ធពរ ៤ សម្បត្តិ ៣ ប្រការ អនាគតព្រះពុទ្ធត្រាស់ដឹងនូវធម៌ណា សូមឲ្យបានសម្រេចក្នុងចំណែកនៃធម៌នោះ តាមសមគួរគ្រប់ៗគ្នាកុំបីអាក់ខានឡើយ។

សូមឲ្យព្រះពុទ្ធសាសនារុងរឿងចម្រើន ផ្សាយទូទៅពេញសកលលោក សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព៕

វត្តឯករស្មី ហៅទួលតាឯក,ភូមិទួលតាឯក សង្កាត់ទួលតាឯក ក្រុង និងខេត្តបាត់ដំបង, ថ្ងៃ ១២ រោច ខែចេត្រ ឆ្នាំម្សាញ់ ព.ស ២៥៥៦, ត្រូវនឹងថ្ងៃទី ៧ ខែឧសភា គ.ស ២០១៣

បញ្ញាវរោ ភិក្ខុ ឆេង ចន្ទសេដ្ឋា

***(សមណនិស្សិតពុទ្ធិកសាកលវិទ្យាល័យ ព្រះសីហនុរាជ សាខាខេត្តបាត់ដំបង
មហាវិទ្យាល័យទស្សនវិជ្ជា និងសាសនា ឯកទេសៈ ទស្សនវិជ្ជា ពុទ្ធសាសនា,ជំនាន់ទី ៥)***

## នាមអ្នកមានឧបការៈក្នុងកិច្ចការធម្មទាន

### វាយអត្ថបទ

| | | |
|---|---|---|
| ព្រះមហា កល្យាណធម្មោ | **ឆយ នៃឡឿត** | បេក្ខសមណៈអនុបណ្ឌិត (ជុំឡាឡុងកន) |
| ព្រះមហា បញ្ញាវរោ ភិក្ខុ | **ឆេន ចន្ទសេដ្ឋា** | សមណនិស្សិត(ព.ស.ស.ប.ប) |
| សាមណេរ | **ឃុន មន្នី** | វត្តឯករស្មី ហៅទួលតាឯក |
| សាមណេរ | **ដែន សុខជា** | វត្តឯករស្មី ហៅទួលតាឯក |

### ឧបត្ថម្ភថ្លៃភ្លើង ចង្ហាន់ ភេសជ្ជៈ

| | | | |
|---|---|---|---|
| ឧបាសិកា | **ឱ ម៉ិច** | និងកូនចៅ | (ក្រចេះ) |
| ញោម ប្រុស | **អ៊ុក កែវ (ធី)** | ញោមស្រី | **អេង ខន** និងកូនចៅ (ក្រចេះ) |
| ឧបាសិកា | **ថៃ៊ត ង៉ូយ** | និងកូនចៅ | (អូរចារ,បាត់ដំបង) |
| ឧបាសិកា | **ព្រឹង តិះ** | និងកូនចៅ | (អូរតាគាំ ១,បាត់ដំបង) |
| ញោមស្រី | **រិន រ៉េន** | និងកូនចៅ | (អូរតាគាំ ១,បាត់ដំបង) |
| ដូនជី | **ពេជ្រ សារឿន** | និងកូនចៅ | (ទួលតាឯក,បាត់ដំបង) |
| ដូនជី | **មុត រ័ត្ន** | និងចូកចៅ | (ទួលតាឯក,បាត់ដំបង) |
| ដូនជី | **ជា សុភី** | និងកូនចៅ | (ទួលតាឯក,បាត់ដំបង) |
| ដូនជី | **កង សារឿន** | និងកូនចៅ | (ទួលតាឯក,បាត់ដំបង) |
| ឧបាសិកា | **ប្រាក់ ស៊ីថា** | និងកូនចៅ | (ទួលតាឯក,បាត់ដំបង) |
| ឧបាសិកា | **ម៉ិន រឿន** | និងកូនចៅ | (បរវេល,បាត់ដំបង) |
| ឧបាសិកា | **ស៊ុន សោភា** | និងបុត្រី **ថុង សោភារ័ត្ន** | (ទួលតាឯក,បាត់ដំបង) |
| ឧបាសិកា | **ហម សាមេត** | និងក្រុមគ្រួសារ | (ទួលតាឯក,បាត់ដំបង) |
| ឧបាសិកា | **នូ សារី** | និងក្រុមគ្រួសារ | (ទួលតាឯក,បាត់ដំបង) |
| ញោមស្រី | **អយ** | ចុងភៅវត្តទួលតាឯក | |

**ពុទ្ធបរិស័ទក្រុង បាត់ដំបង**

**ពុទ្ធបរិស័ទចំណុះជើងវត្ត ទួលតាឯក**

## ក្រុមផ្ទៀងផ្ទាត់

ព្រះមហាកល្យាណធម្មោ **ឆយ ឆៃលឿត**

ព្រះមហាបញ្ញាវរោ ភិក្ខុ **ឆេន ចន្ទសេដ្ឋា**

លោក **គឹម ងួនជា** ប្រធានការិយាល័យកិច្ចការសាសនា (ខេត្តបាត់ដំបង)

## ក្រុមពិនិត្យអក្ខរាវិរុទ្ធ

| | | |
|---|---|---|
| ព្រះមហាបញ្ញាវរោ ភិក្ខុ | **ឆេន ចន្ទសេដ្ឋា** | |
| សុភវណ្ណោ ភិក្ខុ | **តឹក តែម** | |
| សាមណេរ | **ឡាយ សារី** | សមណសិស្សពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង |
| ឧបាសក | **ឆាយ មាស** | |
| លោកគ្រូ | **ង៉ាន សារេត** | នាយកសាលាបឋមសិក្សា ទួលតាឯក |

## ចាត់ចែងផ្សាយជាធម្មទាន

ព្រះមហាបញ្ញាវរោ ភិក្ខុ **ឆេន ចន្ទសេដ្ឋា**

## ឯកសារវិគ្រោះ

| | |
|---|---|
| - បិដកលេខ | ៥២ និង ៥៤ |
| - មង្គលត្ថទីបនី | ពុទ្ធសាសនបណ្ឌិត្យ |
| - វចនានុក្រមខ្មែរ | សម្ដេច ជួន ណាត ភាគ ១ + ២ |
| - ប្រជុំភាណវារៈ | បាលី ប្រែពិសេស សែម សូ |
| - អធិប្បាយមង្គលសូត្រ | ឯក ញឹម ព.ស ២៤៩៩ គ.ស ១៩៥៦ |
| - មង្គលជីវិត | ភិក្ខុ គូ សុភាព ព.ស ២៥៥១ គ.ស ២០០៧ |

# មាតិកា


| មាតិកានុក្រម | | ទំព័រ |
| --- | --- | --- |
| ព្រះគាថាផ្ដើម ពហូទេវា | ទេវតាព្រមទាំងមនុស្សដ៏ច្រើន | 1 |
| មង្គលទី ១ អសេវនា ច ពាលានំ | កិរិយាមិនសេពគប់នូវបុគ្គលពាល | 3 |
| មង្គលទី ២ បណ្ឌិតា នញ្ច សេវនា | កិរិយាសេពគប់នូវបណ្ឌិត | 4 |
| មង្គលទី ៣ បូជា ច បូជនីយានំ | បូជាដល់បុគ្គលដែលគួរបូជា | 6 |
| មង្គលទី ៤ បដិរូបទេសវាសោ | កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ | 9 |
| មង្គលទី ៥ បុព្វេ ច កតបុញ្ញតា | កិរិយាបានធ្វើបុណ្យទុកមក | 11 |
| មង្គលទី ៦ អត្តសម្មាបណីធិ | កិរិយាតម្កល់ខ្លួនបានល្អប្រពៃ | 18 |
| មង្គលទី ៧ ពាហុ សច្ចញ្ច | រៀនសូត្រច្រើន | 25 |
| មង្គលទី ៨ សិប្បញ្ច | សិល្បសាស្ត្រល្អ ឬការងារឈ្លាសវៃ | 28 |
| មង្គលទី ៩ វិនយោ ច សុសិក្ខិតោ | អប់រំវិន័យបានល្អ | 30 |
| មង្គលទី ១០ សុភាសិតា ច | ប្រើសម្ដីពីរោះ | 33 |
| មង្គលទី ១១-១២ មាតាបិតុ ឧប.. | កិរិយាបម្រើមាតា..... កិរិយាបម្រើបិតា | 37 |
| មង្គលទី ១៣ បុត្តទារស្ស | សង្គ្រោះកូនប្រពន្ធ | 42 |
| មង្គលទី ១៤ អនាកុលា ច | មិនធ្វើការច្របូកច្របល់ | 46 |
| មង្គលទី ១៥ ទានញ្ច | ការធ្វើទាន | 50 |
| មង្គលទី ១៦ ធម្មចរិយា | ការប្រតិបត្តិធម៌ | 57 |
| មង្គលទី ១៧ ញាតកានញ្ច | កិរិយាសង្គ្រោះញាតិ | 61 |
| មង្គលទី ១៨ អនវជ្ជានិ កម្មានិ | មិនធ្វើការដែលមានទោស | 65 |
| មង្គលទី ១៩ អារតី វិរតី បាបា | កិរិយាមិនត្រេកអរនិងកិរិយាវៀរចាកបាប | 71 |
| មង្គលទី ២០ មជ្ជបាណា | កិរិយាសង្រួមក្នុងទឹកស្រវឹង | 77 |

| | | |
|---|---|---|
| មង្គលទី ២១ អប្បមាទោ | មិនប្រមាទក្នុងធម៌ | 80 |
| មង្គលទី ២២ គារវោ | កិរិយាគោរពដល់បុគ្គលដែលគួរគោរព | 87 |
| មង្គលទី ២៣ និវាតោ | កិរិយាចេះបន្ទាបខ្លួនល្អ | 90 |
| មង្គលទី ២៤ សន្តុដ្ឋី | សម្រប ឬសន្តោសចិត្តទៅក្នុងការប្រើ | 95 |
| មង្គលទី ២៥ កតញ្ញុតា | ភាពជាមនុស្សកតញ្ញូ | 99 |
| មង្គលទី ២៦ កាលេន ធម្មស្សវន | កិរិយាស្តាប់ធម៌តាមកាល | 103 |
| មង្គលទី ២៧ ខន្តី | សេចក្តីអត់ធន់ | 108 |
| មង្គលទី ២៨ សោវចស្សតា | ភាពជាអ្នកត្រូវប្រដៅងាយ | 112 |
| មង្គលទី ២៩ សមណានញ្ច | កិរិយាបានឃើញសមណៈ | 114 |
| មង្គលទី ៣០ កាលេន ធម្មសាក... | កិរិយាសន្ទនាធម៌តាមកាល | 116 |
| មង្គលទី ៣១ តបោ | សេចក្តីព្យាយាមដុតនូវបាបធម៌ | 123 |
| មង្គលទី ៣២ ព្រហ្មចរិយញ្ច | ការប្រព្រឹត្តនូវព្រហ្មចរិយធម៌ | 126 |
| មង្គលទី ៣៣ អរិយសច្ចាន... | កិរិយាបានឃើញនូវអរិយសច្ច | 132 |
| មង្គលទី ៣៤ និព្វានសច្ឆិកិរិយា | កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន | 135 |
| មង្គលទី ៣៥ ផុដ្ឋស្ស លោក.. | ចិត្តជាបុគ្គលដែលឈប់រវល់ | 138 |
| មង្គលទី ៣៦ អសោកំ | គ្មានក្តីសោក | 140 |
| មង្គលទី ៣៧ វិរជំ | មិនមានរាគៈ | 142 |
| មង្គលទី ៣៨ ខេមំ | ក្សេមក្សាន្ត | 143 |
| សរុប មង្គលគាថាទី ១០ | | 146 |
| បត្តិទានវាចារបស់ស្មេរ | | 149 |
| សន្លឹកចង្អុលបង្ហាញ មង្គលគាថា | | 151 |

## ព្រះគាថាផ្ដើម

**ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ**
**អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ[១]។**

បទពាក្យ៧

| | |
|---|---|
| ទេវតាព្រមទាំងមនុស្សដ៏ច្រើន | នាំគ្នាក្រវើនព្យាយាមខ្លាំង |
| ពិភាក្សាមង្គលជាប្រចាំ | ដល់ដប់ពីរឆ្នាំក៏មិនយល់។ |
| ទើបបានចាត់ទេវតាមួយអង្គ | ឲ្យយាងតម្រង់ព្រះមណ្ឌល |
| គាល់សួរអារាធនាព្រះទសពល | កម្ចាត់ក្ដីឆ្ងល់គឺកង្ខា។ |
| គ្រានោះឯងអង្គព្រះភគវន្ត | ទទួលនិមន្តនៃទេវតា |
| ទ្រង់បានសម្ដែងយ៉ាងពិស្ដារ | មង្គលនោះណាសាមប្រាំបី។ |

### សេចក្ដីសម្រាយ

សម័យមួយព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេតពន ទៀបក្រុងសាវត្ថី លំដាប់នោះឯងទេវតាមួយអង្គកាលដែលវេលារាត្រីបឋមយាមកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធទ្រង់គង់ក្នុងទីណា ទេវតាក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយថ្វាយបង្គំចំពោះព្រះអង្គ ហើយឈរក្នុងទីដ៏សមគួរ បានទូលសួរថា ទេវតានិងមនុស្សទាំងឡាយប្រាថ្នានូវសិរីមង្គលបានគិតរកនូវមង្គលទាំងឡាយអស់១២ឆ្នាំហើយ សូមព្រះអង្គទ្រង់មេត្តាសម្ដែងប្រាប់នូវមង្គលដ៏ឧត្ដម ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងដោយភាសិតគាថាយ៉ាងនេះថា



១.បាលី មង្គលសូត្រគាថាទាំងអស់ស្រង់ចេញពី ព្រះត្រៃបិដក ភាគ ៥២ ទំព័រ ៤-៦

## ព្រះគាថាទី ១

មាន ៣ មង្គល

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**

**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ។**

(បទពាក្យ៧)

កិរិយាមិនសេពគប់ជនពាល ដែលនាំរោលរាលមោហៈបាំង
សេពគប់បណ្ឌិតមិត្តល្អខ្លាំង ជួយនាំរារាំងអកុសល។
បូជាដល់បុគ្គលគួរបូជា ដោយចិត្តសទ្ធាបានមគ្គផល
បីនេះគួរគិតឲ្យបានយល់ ជាឧត្តមមង្គលដ៏ថ្លៃថ្លា។

## សេចក្ដីសម្រាយ

ការមិនសេពគប់បុគ្គលពាលទាំងឡាយ១ ការសេពគប់បណ្ឌិតទាំងឡាយ១ ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ១ ទាំង៣នេះជាមង្គលដ៏ឧត្តម។

## ១.១ បុគ្គលពាលមាន ៣

-ពាលោ បុគ្គលគ្រាន់តែល្ងង់

-ពាលោខោ បុគ្គលល្ងង់ហើយប្រព្រឹត្តិអំពើទុច្ចរិតផង (អាក្រក់)

-អតិពាលោខោ បុគ្គលល្ងង់ផងប្រព្រឹត្តិទុច្ចរិតដោយ កាយ វាចា ចិត្ត យ៉ាងខ្លាំងក្លាក្រៃលែងផង។

## ១. **អសេវនា ច ពាលានំ** ការមិនសេពគប់នូវបុគ្គលពាល

**អត្ថបទកំណាព្យ** (បទពាក្យ៧)

អ្វីទៅហៅពាលយើងគួរដឹង គាត់ប្រព្រឹត្តិហ្នឹងតែងអាក្រក់
ទាំងចិត្តទាំងកាយតែងកខ្វក់ សម្ដីគាត់នោះមិនពីរោះ។
ដាច់សីលប្រចាំគឺសីលប្រាំ បើតាមចំណាំគ្មានល្អសោះ
កាប់ចាក់ទាត់ធាក់អួតអាងស្មោះ សព្វថ្ងៃអាងឈ្លោះមិនចាលចាញ់។
ចូលចិត្តប្រព្រឹត្តិអបាយមុខ ល្បែងពាលគ្រប់មុខហើយប្រវ័ញ្ច
រកស៊ីទុច្ចរិតចិត្តទោម្នេញ គាត់ពិតជាពេញចិត្តគាត់ស្មោះ។
សប្បុរសចង់ជួយអូសទាញដែរ សាកល្បងហួរហែមិនព្រមសោះ
ដូច្នេះគួរជៀសវាងរំលងផ្លោះ ការទាក់ទងនោះកុំឱ្យមាន។
មិនមែនយើងស្អប់គាត់នោះទេ តែយើងខ្វះស្នេហ៍ខ្វះរបៀន
សមត្ថភាពយើងអន់មិនអាចហ៊ាន តែខំប៉ះពាននាំមានទុក្ខ។
ពាលតែងអាក្រក់បីប្រការ ទាំងកាយវាចាចិត្តផងនោះ
គួរកុំសេពគប់ពាលឲ្យសោះ បើសេពគប់នោះនឹងទុក្ខា។

## ផលនៃការមិនសេពគប់ជនពាល

ទីមួយបើមិនសេពគប់ពាល មិនដោយរោលរាលនូវទោសា
ខុសដូចជាពាលនោះឯងណា ព្រោះបានផ្ដាច់ការទាក់ទងមុន។
ទីពីរនឹងមានកិត្តិយសល្អ មុខមាត់បវរល្អលើសលន់

ព្រោះគ្មានបក្ខពួកនាំស៊យស៊ុន នោះមកពីបុណ្យមិនគប់ពាល។
ទីបីមិនមានគេនិន្ទា អ្នកផងរាល់គ្នាទាំងអម្បាល
តែងលើកសរសើរល្អវាល់វាល គេមិនតិះដៀលដូចពាលឡើយ។
ទីបួនតែងមានចិត្តសប្បាយ គ្មានក្តីអន្តរាយមកជិតឡើយ
មានតែសប្បុរសនៅកៀកកើយ តែងតែរកឲ្យប្រយោជន៍ល្អ។
ហេតុនេះបានជាមានពុទ្ធដីកា ដែលព្រះសាស្តាទូន្មានមក៏
បើសេពគប់ពាលនោះមិនល្អ នាំឲ្យវឹកវរវណ្ណនឹងទុក្ខ។
គួរកុំសេពគប់នឹងពួកពាល ទើបមិនរោលរាលដោយក្តីទុក្ខ
រស់នៅសព្វថ្ងៃតែងបានសុខ នេះគឺចាត់ទុកជាមង្គល។

**១.២ បុគ្គលជាបណ្ឌិតប្រតិបត្តិ**

-ធ្វើល្អដោយខ្លួនឯងផង
-ជួយដឹកនាំអ្នកដទៃឲ្យល្អផង
-ជួយសង្គ្រោះអ្នកដទៃផង
-ជាអ្នកមានកតញ្ញូកតវេទិតាធម៌

**២. បណ្ឌិតានញ្ច សេវនា** កិរិយាសេពគប់នូវបណ្ឌិត

**អត្ថបទកំណាព្យ** (បទពាក្យ៧)

គួរតែលៃលកពេលវេលា ឱកាសល្អជាកែអផ្សុក
កាត់ជួបសប្បុរសមិនស្មាញស្មុគ លោកតែងនាំសុខដល់យើងគេ។
លោកអ្នកបណ្ឌិតគិតខាងល្អ ចិត្តត្រង់ស្មោះសមិនវៀចវេរ
មួយថ្ងៃៗតែងរិះរេ ចិត្តលោកជាប់ស្នេហ៍នឹងកុសល។
លោកតែងជាប់សីលនិងមានធម៌ ប្រតិបត្តិខាងល្អមិនមានខ្វល់
ផ្តល់សុខប្រយោជន៍យ៉ាងរចល់ ជូនដល់ញាតិមិត្តជិតឬឆ្ងាយ។
ប្រតិបត្តិបានល្អឈ្នះខ្លួនឯង ហើយលោកខ្នះខ្នែងប្រឹងខ្វល់ខ្វាយ

ជូននូវធម្មទានផងទាំងឡាយ    លៃពេលអធិប្បាយសម្តែងធម៌។
សម្តែងធម៌អាថ៌ព្រះជិនស្រី    ជាធម៌មានន័យល្អបវរ
ដឹកនាំអស់មនុស្សសត្វនិករ    កំដរដាក់ដល់ត្រើយសុខសាន្ត។
**វុឌ្ឍិធម៌**ព្រះសម្តែងថា    មួយសេពគប់ណាកុំឲ្យខាន
គប់នឹងបណ្ឌិតមិត្តកល្យាណ    ជួយរុញជួយច្រានឲ្យយើងសុខ។
ទីពីរបានស្តាប់ធម៌បណ្ឌិត    ធម៌ល្អធម៌ពិតមិននាំស្មុគ
ជាធម៌លៃលករកខាងសុខ    សំរុកធ្វើល្អសថ្លៃថ្លា។
ទីបីពិចារណាខុសត្រូវ    ស្គាល់អត្ថស្គាល់ផ្លូវនៃធម្មា
ស្គាល់កិច្ចស្គាល់កលដែលហៅថា    យោនិសោមនសិការយ៉ាងហ្មត់ចត់។
ទីបួនយល់ធម៌បានច្បាស់ហើយ    សទ្ធាមិនស្បើយហើយអនុវត្តន៍
ប្រតិបត្តិតាមធម៌បានប្រាកដ    សន្មតថាជាសប្បុរស។
សប្បុរសតែងបានសុខលោកីយ៍    សុខនេះពេលខ្លីក្នុងពេលរស់
ស្លាប់ទៅក៏នៅតែមានឈ្មោះ    បានសុខពីរោះតទៅមុខ។
បណ្ឌិតតែងប្រព្រឹត្តិចរិយា    ល្អបីប្រការល្អដោយស្មោះ
ល្អកាយល្អចិត្តពាក្យពីរោះ    លោកតែងអនុគ្រោះគេរាល់គ្នា។
មិនមែនល្អត្រឹមសញ្ញាបត្រ    មានល្បិចមកស្កាត់រកទ្រព្យា
បណ្ឌិតពិតនោះល្អសោភា    ពណ៌នាមានធម៌បួនប្រការ ។
**ទីមួយកតញ្ញូ**គឺដឹងគុណ    តបព្រះដើមមុនគុណមហិមា
ដឹងគុណតបគុណគេគ្រប់គ្នា    មានទាំងឧបជ្ឈាយ៍បុព្វាចារ្យ។
**ទីពីរមានអត្តសុទ្ធិ**[២]    គឺជាតំរិះចេះជ្រះថ្លា
ព្យាយាមប្រតិបត្តិធម៌កុសលា    ប្រព្រឹត្តិធ្វើការតែខាងល្អ។
មិនគិតធ្វើអ្វីដែលមានទោស    មិនធ្វើឲ្យខុសនឹងច្បាប់ធម៌
មិនកេងយករស់ដោយត្រដរ    មកជិះជាន់កអ្នកដទៃ។
**ទីបីគឺបរិសុទ្ធិ** [៣]    លោកមានគំនិតជួយលកលៃ



២.អត្តសុទ្ធិ  ប្រតិបត្តិល្អខ្លួនឯង ៣.បរសុទ្ធិ   ញុំាងអ្នកដទៃឲ្យធ្វើល្អ

ព្យាយាមនាំឲ្យអ្នកដទៃ ប្រព្រឹត្តិប្រពៃគ្រប់ៗគ្នា។
ចង់ឲ្យគេបានសុខក្សេមក្សាន្ត ជំរះខ្មៅបានសល្អជា
មូលមិត្តចិត្តថ្លើមមានសាមគ្គា ស្រស់ស្រាយគ្រប់គ្នាក្នុងសង្គម។
**ទីបួនមានធម៌សង្គហៈ** មិនទល់ភ្នែកជាក់ហើយសម្ងំ
ឃើញញាតិមានទុក្ខតែងខិតខំ តែងតែផ្សែផ្សំជួយសង្គ្រោះ។
មានក្តីមេត្តាករុណា ជួយយកអាសាជនរងគ្រោះ
អ្នកក្រតោកយ៉ាកមិនសូវហួស តិចច្រើនរំលោះរំដោះទុក្ខ។
បណ្ឌិតគឺល្អៗដូច្នេះ គំរូល្អនេះតទៅមុខ
សេពគប់បណ្ឌិតពិតបានសុខ ព្រះសម្តែងទុកថាមង្គល។

**១.៣ បុគ្គលដែលគួរបូជា**

-ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ
-មាតាបិតា
-គ្រូឧបជ្ឈាយាចារ្យ
-សម្មតិទេព (ព្រះរាជា)
-អ្នកមានសីល
-ចាស់ព្រឹទ្ធាចារ្យ
-ស្វាមី និងភរិយា
-ត្រកូលរៀមច្បង

**៣. បូជា ច បូជនីយានំ** បូជាដល់បុគ្គលគួរបូជា

**អត្ថបទកំណាព្យ** (បទពាក្យ៧)

មួយទៀតហៅថាកិច្ចបូជា យើងគួរវន្ទាធ្វើឲ្យល្អ
បូជាដល់បុគ្គលដ៏កម្រ ដែលប្រតិបត្តិល្អយ៉ាងត្រឹមត្រូវ។
ប្រតិបត្តិលះកាត់នូវកិលេស ឬអ្នករៀនរិះកំចាត់ខ្លៅ
កំចាត់អវិជ្ជាជាគោលដៅ សំដៅប្រព្រឹត្តិតាមធម្មា។
មានទាំងព្រះពុទ្ធនិងព្រះសង្ឃ កុលបុត្រដ៏ត្រង់នៃពុទ្ធា
អ្នកមានសីលទានឬភាវនា គួរតែបូជាកុំឱ្យខាន។
បូជាដល់លោកអ្នកមានគុណ ឪពុកម្តាយមុនដោយស្មោះស្មាន

ព្រោះគុណលោកធំអបរិមាណ
អ្វីក៏មិនបានស្មើគុណនេះ។
ចិញ្ចឹមបីបាច់ថែរក្សា
មាតាបិតាដែលជាចាស់
បុណ្យនេះបុណ្យធំខ្លាំងពេកណាស់
កូនគួររូតរះធ្វើទាន់ពេល។
ធ្វើទាន់គាត់រស់បុណ្យខែភ្លឺ
បុណ្យធំស៊ីៗមិនប្រហែល
បើសិនប្រហែសយើងមិនដែល
យើងនឹងខាតក្រៃលខាតបុណ្យធំ។
ចាំដល់គាត់ស្លាប់ទើបបានធ្វើ
ជាបុណ្យសើៗខាងតបគុណ
បានឬមិនបានមិនដឹងមុន
គ្មានអ្នកមានគុណណាមកប្រាប់។
បុណ្យនេះជាបុណ្យខែរនោច
ធ្វើបុណ្យឲ្យខ្មោចក្រោយពេលស្លាប់
ទោះបីខំរៀបគ្រប់រណ្ដាប់
លោកមិនអាចចាប់បានស្តែងឡើយ។
បានឬមិនបានមិនអាចដឹង
វាគ្មានដំណឹងនៅពេលក្រោយ
មិនបានដូចកាលនៅរស់ឡើយ
បើកូនដឹងហើយគួរតែគិត។
នេះការបូជាដល់បុគ្គល
ដែលយើងគួរយល់ជាគំនិត
បូជាបុគ្គលប្រសើរពិត
បូជាយ៉ាងស្និទ្ធអ្នកមានគុណ។
បូជាយ៉ាងហោចដល់រៀមច្បង
អស់លោកអ្នកផងល្អមកមុន
ដែលខំប្រតិបត្តិល្អដោយគុណ
សីលគុណ សមាធិ បញ្ញា។
បើសិនបូជាដល់បុគ្គល
ដែលយើងគួរយល់ថាបូជា
នឹងបាននូវបុណ្យល្អសោភា
រាប់ជាមង្គលដ៏ថ្លៃថ្លា។
សរុបទាំងបីមកថ្លាថ្លែង
សម្តែងទៅតាមព្រះគាថា
មិនសេពគប់ពាលបានសុខា
គប់បណ្ឌិតណាមានប្រយោជន៍។
បូជាដល់បុគ្គលគួរបូជា
ដោយក្តីសទ្ធាមិនមានហោច
បីនេះគឺបានជាប្រយោជន៍
នាំឲ្យរុងរោចន៍កើតមង្គល។

## ព្រះគាថាទី ២

មាន ៣ មង្គល

**បដិរូបទេសវាសោ ច　　បុព្វេ ច កតបុញ្ញតា**
**អត្តសម្មាបណិធិ ច　　ឯតម្មង្គលមុត្តមំ។**

(បទពាក្យ៧)

កិរិយាក្នុងការបានរស់នៅ　　ប្រទេសដែលហៅថាសមគួរ
កិរិយាធ្វើបុណ្យទុកមុនយូរ　　និងកិរិយាស៊ូអប់រំប្រាណ។
តម្កល់ខ្លួនបានល្អប្រពៃ　　បីនេះមានន័យជាលំអាន
ជាឧត្តមមង្គលដ៏ថ្កើងថ្កាន　　នាំឲ្យសុខសាន្តក្សាន្តជីវ៉ា។

### សេចក្តីសម្រាយ

ការនៅក្នុងប្រទេសដ៏សមគួរ១ ភាពនៃបុគ្គលបានធ្វើបុណ្យទុកក្នុងកាលមុន១ ការតម្កល់ខ្លួនដោយប្រពៃ១ ទាំង៣នេះជាមង្គលដ៏ឧត្តម។

## ២.១ ប្រទេសដ៏សមគួរ

-នីតិរដ្ឋ (ជាប្រទេសដែលប្រជាពលរដ្ឋទាំងអស់គោរពច្បាប់ពិតប្រាកដ)

-ប្រទេសដែលប្រតិបត្តិធម៌អាថ៌ព្រះពុទ្ធសាសនា មានអ្នកប្រាជ្ញ បណ្ឌិត សប្បុរស ជួយដឹកនាំរកសុខនិងប្រយោជន៍

-ប្រទេសដែលមានធនធានមនុស្សល្អប្រកបដោយកាយសម្បទា (សុខភាពល្អ) វិជ្ជាសម្បទា (ចេះដឹងច្រើន) ចិត្តសម្បទា (អប់រំចិត្តល្អ)

-ប្រទេសដែលមានសន្តិភាពស្ថិតស្ថេរ

## ៤. **បដិរូបទេសវាសោ** កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| អ្វីជាប្រទេសដ៏សមគួរ | គួរយើងគិតគូរហើយចំណាំ |
| ទីស្ថានសុខសាន្តជាប្រចាំ | រាល់ថ្ងៃខែឆ្នាំសន្តិភាព។ |
| ប្រទេសមានច្បាប់មានទំលាប់ | មានសណ្តាប់ធ្នាប់ល្អរៀងរាប |
| ចាត់ចែងកិច្ចការបានសុភាព | ជំរាបថាជានីតិរដ្ឋ។ |
| ប្រទេសយកច្បាប់ជាធំដុំ | គ្មានស៊ុំគ្រលុំគ្មានល្បិចក្បត់ |
| បម្រើតែជាតិពិតប្រាកដ | សន្មតគិតរាស្ត្រយកជាធំ។ |
| មិនមានពុតត្បុតពុករលួយ | មិនឲ្យរាស្ត្រព្រួយទ្រហោយំ |
| ដឹកនាំចាត់ចែងការបានហំ | សន្សំក្តីសុខបានយ៉ាងល្អ។ |
|ម្យ៉ាងទៀតជាធម្មាធិបតេយ្យ | ជារៀងរាល់ថ្ងៃពេញដោយធម៌ |
| ជឿបុណ្យជឿបាបគ្មានកករ | ល្អក់កើតវឹកវរអនាចារ។ |
| ដោះស្រាយបញ្ហាដោយធម៌ពិត | គឺជាគំនិតមានមនសិការ |
| ច្រើនជាសប្បុរសចិត្តរាបសា | ទទួលចាត់ការកិច្ចនគរ។ |
| បញ្ចៀសវិបត្តិនៃសង្គ្រាម | ដែលនាំវីមវាមនាំអន្តរ- |
| ធានដល់ជាតិសាសន៍និងនគរ | ដែលនាំត្រដររស់មិនបាន។ |
| បញ្ចៀសទាំងអសន្តិសុខ | មានក្នុងភូមិស្រុកនាំរំខាន |

រស់នៅក្រោមច្បាប់ស្មើៗប្រាណ រស់ដោយសុខសាន្តយុត្តិធម៌។
មានសិទ្ធិសេរីស្មើមុខច្បាប់ ភាគច្រើនចំណាប់ចេះខាងធម៌
ឧស្សាហ៍ព្យាយាមប្រតិបត្តិល្អ មានធម៌កំដរល្អជីវិត។
ម្យ៉ាងទៀតហៅស្ថានដ៏សមគួរ ទីនោះគឺគួររស់នៅពិត
បើស្រង់យកមកជាគំនិត ឃើញពិតថាមានជាច្រើនយ៉ាង។

**លក្ខណៈទីស្ថានដ៏សមគួរ**

**ទីមួយអាវាសទីសប្បាយ** គួរស្នាក់អាស្រ័យនៅនាស្ថាន
មានសន្តិសុខមិនរំខាន មានទាំងបរិស្ថានល្អសោភា។
ព្រមទាំងល្អដោយអនាម័យ គ្មានរោគចង្រៃឆ្លងពាធា
បានសុខប្រយោជន៍គ្រប់វេលា មានអ្វីនានាជាប្រក្រតី។

**ទីពីរអាហារទីសប្បាយ** កន្លែងស្រួលងាយរកចំណី
ធ្វើការរកស៊ីធ្វើអ្វីៗ បើសិនលកលៃទៅងាយស្រួល។
ឧស្សាហកម្មកសិកម្ម សម្បូណ៌ដំណាំគ្រាន់សម្រួល
បើរកស៊ីអ្វីក៏ងាយស្រួល សូម្បីប្រាក់ឈ្នួលក៏បានខ្ពស់។

**បីបុគ្គលទីសប្បាយ** នៅជិតរៀងអាយសប្បាយព្រោះ
អ្នកនៅជិតគ្នាមានចិត្តខ្ពស់ តែងជួយសង្គ្រោះដល់គ្នីគ្នា។
ច្រើនជាបណ្ឌិតច្រើនសប្បុរស មានសីលមានឈ្មោះពីរោះជា
ចេះគោរពសិទ្ធិគ្នាគ្រប់គ្រា មិនធ្វើវេរាឲ្យគ្នាឡើយ។
មិនអូសទាញឲ្យប្រព្រឹត្តិខុស អំពើអាក្រក់តែងបានស្បើយ
ទាំងអបាយមុខក៏គ្មានឡើយ អស់រលីងហើយជនអន្ធពាល។

**ទីបួនធម៌ជាទីសប្បាយ** ទីស្ថានជិតឆ្ងាយល្អរន្ទាល
ព្រោះមានព្រះធម៌រះភ្លឺច្រាល ចែងចាំងត្រកាលគ្រប់វេលា។
មានទាំងព្រះពុទ្ធសាសនា ព្រមដោយធម៌អាចំព្រះភគវា
វត្តអារ៉ាគ្រឹះស្ថានផងនានា សុទ្ធតែបូជាសេចក្តីល្អ។

អប់រំផ្លូវចិត្តបានជ្រះថ្លា ប្រតិបត្តិសិក្ខាជ្រះថ្លាល្អ
ហើយបាននូវសុខសមបវរ ហៅថាមានធម៌ក្នុងទីស្ថាន។
ទីស្ថាននេះហើយជាទីល្អ ដែលឲ្យរស់មកគ្មានរំខាន
ទីនេះគឺទីបានក្សេមក្សាន្ត បានសុខសំរាន្តក្នុងជីវិត។
ហៅថាជាទីល្អថ្លៃថ្លា បើតាមដីកាព្រះទ្រង់ឫទ្ធិ
ទីស្ថានដែលល្អប្រាកដពិត នាំឲ្យជីវិតមានមង្គល។

**២.២ បុណ្យដែលបានធ្វើទុកក្នុងកាលមុន**

-ជាបុណ្យចាស់ពីកាលមុនឬជាតិមុន ដែលយើងបានកសាងរួចមកហើយបុណ្យនេះគឺជាអំពើល្អមានការធ្វើទានរក្សាសីលឬកសាងអំពើកុសលផ្សេងៗ បុណ្យនេះនឹងឲ្យផលមិនភ្លេចយើងឡើយ ។ បុណ្យចាស់ដែលយើងធ្វើមកនេះកើតឡើងពីហេតុ៣យ៉ាង:

១.**បសាទោ** គឺជាបុណ្យកើតដោយចិត្តជ្រះថ្លា ព្រោះបានពិចារណាយល់ធម៌។

២.**សំវេគោ** គឺជាបុណ្យកើតដោយសេចក្តីតក់ស្លុត ព្រោះបានយល់នូវធម៌ប្រចាំជីវិត (មិនទៀងជាទុក្ខ មិនអាចបង្គាប់បញ្ជាបាន)។

៣.**តេសុចរិតា** គឺជាបុណ្យកើតដោយបញ្ញាដែលឃើញទោសក្នុងអំពើទុច្ចរិត និងឃើញគុណក្នុងអំពើសុចរិតប្រកបដោយចិត្តជាសម្មាទិដ្ឋិ យល់ត្រូវតាមសច្ចធម៌ គឺយល់ថាធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប។

**៥. បុព្វេ ច កតបុញ្ញតា** កិរិយាបានធ្វើបុណ្យទុកមក

**អត្ថបទកំណាព្យ** (បទពាក្យ៧)

**បុព្វេ ច កតបុញ្ញតា** គឺជាកិរិយាដែលមានផល
បុណ្យចាស់ដែលបាននៅសេសសល់ សម្ដំឱ្យផលពីអតីត។
បុណ្យធំឲ្យកើតសុគតិ ឲ្យបានកើតមកជាមនុស្សនេះ
សល់បុណ្យខ្លះទៀតដែលបានចេះ កសាងមុននេះមកដោយធម៌។
បុណ្យល្អឯទៀតបានឲ្យផល បានជូនដាក់ដល់នូវផលល្អ

| | |
|---|---|
| នាំឲ្យជីវិតស្រស់បវរ | មិនមានត្រដររលំបាកឡើយ។ |
| ធ្វើអ្វីច្រើនបានតាមប្រាថ្នា | រស់នៅហ៊ឺហាមានកោះត្រើយ |
| មិនមានក្រខ្សត់លំបាកឡើយ | បានសុខល្ហែល្ហើយពេញចិន្តា។ |
| មកពីបុណ្យចាស់ដែលបានធ្វើ | គឺជាអំពើបុញ្ញវណ្ណា |
| កម្មល្អឲ្យផលល្អថ្លៃថ្លា | លោកអាចចាត់ថាជាមង្គល។ |

**បុញ្ញកិរិយា (កិរិយាធ្វើបុណ្យ) មាន១០ប្រការ៖**

(បទកាកគតិ)

| | | |
|---|---|---|
| ក្នុងពុទ្ធសាសនា | បុញ្ញកិរិយា | មានដល់ទៅដប់ |
| ចង់ធ្វើណាមួយ | ឲ្យតែប្រសប់ | ធ្វើបានគួរគាប់ |
| | បុណ្យធំមហិមា។ | |

**ក)ទាន**

| | | |
|---|---|---|
| បើសិនមានទ្រព្យ | ត្រូវតែខំអប់- | រំចិត្តឲ្យមាន |
| ចេតនាលះបង់ | ផ្ចង់ធ្វើនូវទាន | ហៅចិត្តល្អមាន |
| | នូវក្ដីសង្គ្រោះ។ | |
| បណ្ដានូវទាន | ទាំងអាមិសទាន | ធម្មទានផងនោះ |
| គឺមានធម្មទាន | បើរាប់សង្គ្រោះ | ផលថ្លៃថ្លាហួស |
| | លើសអាមិសទាន។ | |

**ខ)សីល**

| | | |
|---|---|---|
| បើគ្មានអ្វីទេ | មិនអាចរិះរេ | បានធ្វើនូវទាន |
| គួរសាងនូវសីល | លាងមន្ទិលបាន | សីលល្អថ្កើងថ្កាន |
| | សីលជាមេធម៌។ | |
| សីលនោះឯងណា | តមកាយវាចា | ប្រតិបត្តិតែល្អ |
| មិនធ្វើអាក្រក់ | គាំទ្រពណ៌ស | ប្រព្រឹត្តិតែល្អ |

ឲ្យសុខក្សេមក្សាន្ត។

| | | |
|---|---|---|
| | ឲ្យសុខគ្នីគ្នា។ | |
| មិនលួចមិនប្លន់ | ប្រព្រឹត្តិរហន់ | កាន់យកទ្រព្យគេ |
| មិនធ្វើឲ្យខុស | នូវធម៌កាមេ | មិនមានជាប់ស្នេហ៍ |
| | សុរាមេរ័យ។ | |
| មិនពោលប៉ប៉ាច់ | ប្រើនូវពាក្យពេចន៍ | អាក្រក់អាក្រី |
| កុហកបោកប្រាស | ពោលពាក្យចង្រៃ | ដល់អ្នកដទៃ |
| | ក្នុងន័យផ្គន្ទា។ | |

**គ)ភាវនា**

| | | |
|---|---|---|
| ភាវនាមយៈ | ចូលចិត្តជឿជាក់ | នឹងព្រះធម្មា |
| ត្រិះរិះពិចារណ៍ | បានយល់ធម៌អាថ៌ | យល់ហើយជ្រះថ្លា |
| | ប្រតិបត្តិឥតឆ្គង។ | |
| រៀនយកបញ្ញា | រឹតតែជ្រះថ្លា | ចិត្តអស់សៅហ្មង |
| បង្កើនចំណេះ | ចេះចាំច្រើនដង | ក្នុងក្តីបំណង |
| | ប៉ងយកសុខា។ | |
| រំពឹងគន់គិត | តាមអត្ថធម៌ពិត | នៃព្រះសាស្តា |
| ឃើញច្បាស់ក្រឡែត | ឆ្អែតដោយបញ្ញា | អស់នូវកង្ខា |
| | ប្រហារអាសវក្ខ។ | |
| ក្រោយពីយល់ធម៌ | ចិន្តាស្អាតល្អ | ល្អពិតប្រត្យក្ស |
| ជំរះកិលេស | តូចធំតាមថ្នាក់ | បណ្តើរបណ្តាក់ |
| | តាមថ្នាក់ចិន្តា។ | |

**ឃ)អនុមោទនា**

| | | |
|---|---|---|
| អនុមោទនា | មានចិត្តគាំពារ | បូជាធម៌អាថ៌ |
| ឃើញគេធ្វើបុណ្យ | តាំងហឫទ័យថា | សាទរជ្រះថ្លា |
| | អស្ចារ្យពេកក្រៃ។ | |

ព្រោះមានចិត្តបុណ្យ ប្រកបដោយគុណ- ធម៌ដ៏ថ្លាថ្លៃ
ឃើញគេធ្វើល្អ ក៏គាប់ហឫទ័យ ហៅចិត្តប្រពៃ
និស្ស័យដូចគ្នា។

ទាំងអ្នកធ្វើបុណ្យ ទាំងអ្នកដឹងបុណ្យ សុទ្ធមានសទ្ធា
ព្រោះចិត្តគេល្អ ល្អស្រដៀងគ្នា សុទ្ធតែចិត្តជា
ចិត្តល្អពិតៗ។

ហៅទទួលបុណ្យ បុណ្យនេះជាគុណ មាននៅក្នុងចិត្ត
បើចិត្តល្អហើយ គឺបុណ្យពិតៗ ផ្ដើមចេញពីចិត្ត
ដល់កាយវាចា។

បើចិត្តធ្លាប់ល្អ អំពើធ្វើមក តែងតែល្អជា
ទាំងកាយវិការ សម្ដីជានា នាំក្ដីរមនា
មកស្រេចជាមុន។

**ង)បត្តិទាន**

នេះហៅបត្តិទាន សទ្ធាដែលមាន ចែកជូននូវបុណ្យ
ជូនដល់អ្នកផង បុណ្យធ្វើគ្រាមុន ដោយបានធ្វើបុណ្យ
បុណ្យល្អប្រពៃ។

ឲ្យគេទទួល តាំងចិត្តឲ្យមូល ជាប់ក្នុងហឫទ័យ
ទទួលនូវផល ថ្លៃថ្លាប្រពៃ ដែលបានលកលៃ
ធ្វើបុណ្យជាក់ស្ដែង។

ជូនបុណ្យប្រាកដ មិនដោយសន្មត ឬជូនលេងៗ
ជូនដំណឹងល្អ ជូនចាស់ឬក្មេង ឲ្យផលធំធេង
ជាប់ក្នុងចិន្ដា។

ធ្វើបុណ្យរួចហើយ ចិត្តមិនកន្តើយ នៅមានចេតនា
ជូនបុណ្យទៅគេ បង្កើតអបរា- បរចេតនា

មួយសារទៀងទៀត។

បុណ្យកាន់តែកើន កាន់តែចម្រើន ដោយកិច្ចជាស្នៀត
ដូចអុជប្រទីប តច្រើនទៅទៀត ពន្លឺភ្លឺជ្រៀត-
ជ្រែកសព្វទិសទី។

**ច)ធម្មទេសនា**

បើចេះធម៌អាថ៌ ធ្វើធម្មទេសនា បុណ្យល្អកន្លង
បុណ្យនេះហៅបុណ្យ បុណ្យដ៏ចម្បង ព្រោះបានប្រាប់ប្រង
នូវផ្លូវសុខា។

ប្រាប់នូវដំណើរ ផ្លូវដែលត្រូវដើរ ប្រសើរថ្លៃថ្លា
បង្ហាញតម្រិះ បង្ហាត់វិជ្ជា ឲ្យគេរាល់គ្នា
បានចេះដឹងផង។

វិជ្ជាដ៏ល្អ ចេះដ៏កម្រ នាំសុខកន្លង
កុំទុកដល់ស្លាប់ ហើយយកទៅផង គួរតែប្រាប់ប្រង
ចែកចាយគ្នីគ្នា។

ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ដឹងច្បាស់ នូវព្រះធម្មា
និយ្យានិកធម៌ ផ្តល់ផលសុខា ក៏ទ្រង់ករុណា
ទេសនាទូន្មាន។

នេះមហាករុណា- ទិគុណថ្លៃថ្លា នៃព្រះទ្រង់ញាណ
ទ្រង់ចង់ឲ្យសត្វ បានសុខនិព្វាន ទើបទ្រង់ប្រទាន
បង្រៀនធម៌អាថ៌។

**ឆ)ធម្មស្សវន**

ធម្មស្សវនៈ បានស្តាប់ជឿជាក់ លើព្រះធម្មា
ដោយបានពិនិត្យ ហើយពិចារណា ប្រតិបត្តិជ្រះថ្លា
ប្រាថ្នាសុខៈ។

ខំស្តាប់ញឹកញាប់ ស្តាប់ច្រើនបានជាប់ បានចេះជឿជាក់
ចេះធម៌ចេះអាថ៌ វិជ្ជាអស់ថ្នាក់ ស្គាល់ក្តៅត្រជាក់
ស្គាល់អស់ថ្នាក់ធ្នើរ។

ស្គាល់មធ្យោបាយ ស្គាល់កិច្ចទាំងឡាយ ស្គាល់សព្វសារពើ
ស្គាល់នូវផ្លូវល្អ ដែលគួរតែធ្វើ ហើយគួរសើរើ
កំចាត់អកុសល។

អកុសលផ្តេសផ្តាស មានច្រើនពេញពាស ដែលមានសេសសល់
ជម្រះឲ្យអស់ ផ្តាច់នូវឫសគល់ ព្រោះតែបានយល់
ដោយស្តាប់ព្រះធម៌។

**សុស្សូសំ លភតេ បញ្ញំ** ការស្តាប់ដោយល្អនាំមកនូវបញ្ញា

**ជ)អបច្ចាយន**

អបច្ចាយនៈ បន្ទាបខ្លួនជាក់ មិនចេះឆ្មើងឆ្មៃ
មិនតម្កើងខ្លួន ថាខ្លួនប្រពៃ ចេះអធ្យាស្រ័យ
គោរពគ្នីគ្នា។

តែងចេះគោរព រាប់អានគ្នាគ្រប់ ជនផងនានា
គោរពរៀមច្បង ទាំងកាយវិការ ឬពោលវាចា
ប្រពៃរាក់ទាក់។

បូជាព្រះពុទ្ធ ព្រះសង្ឃបរិសុទ្ធ ព្រមទាំងធម្មៈ
តែងតែប្រតិបត្តិ បូជាជឿជាក់ មិនមានអន់អាក់
បង្អាក់សទ្ធា។

គោរពស្គាល់គុណ ព្រះមាតាមុន ព្រមទាំងបិតា
និងអ្នកឯទៀត មានគុណូបការ មិនមានចិន្តា
បំភ្លេចគុណឡើយ។

## ឈ)វេយ្យាវច្ច

វេយ្យាវច្ចៈ យកចិត្តទុកដាក់ បម្រើប្រពៃ
ទំនុកបម្រុង ទោះនឿយហត់ក្ដី ក៏ខំលកលៃ
ដោយក្ដីមុះមុត។

បម្រើព្រះសង្ឃ ប្រសើរសីលទ្រង់ ជាបុត្រព្រះពុទ្ធ
លះកាត់តណ្ហា ចិន្ដាបរិសុទ្ធ មានសីលវិសុទ្ធ
គួរគាប់បូជា។

អ្នកជាសិស្សគណ គប្បីផ្ដាប់ផ្ដុន បម្រើឧបជ្ឈាយ៍
គឺលោកនេះហើយ ឲ្យនូវវិជ្ជា ឲ្យធម៌នានា
មាគ៌ាសួស្ដី។

វេយ្យាវច្ចៈ គួរតែថ្នមថ្នាក់ ឲ្យល្អប្រពៃ
បម្រើមាតា បិតាល្អក្រៃ ប្រណិប័តន៍ក្នុងន័យ
ហ្ញទ័យកតញ្ញូ។

## ញ)ទិដ្ឋុជុកម្ម

ទិដ្ឋុជុកម្ម ចិត្តតែងចងចាំ មិនភ្លេចកម្មទេ
ជឿកម្មជឿផល កម្លាំងម្ល៉េះទេ គួរខំរិះរេ
សាងតែកម្មល្អ។

យល់ថារីបុណ្យ ឲ្យផលមកមុន ព្រោះសាងកម្មល្អ
កម្មជាកុសល ពណ៌សបវរ កម្មនេះផ្ដល់មក៏
ឲ្យសុគតិ។

ឯកម្មអាក្រក់ កម្មដ៏កខ្វក់ ឬកម្មអប្រិយ
កម្មអកុសល ផ្ដល់ទុក្ខផ្ដល់ភ័យ ឯសុខសិរី
គ្មានក្នុងជីវិត។

| | | |
|---|---|---|
| ស្គាល់នូវកម្មផល | ហើយទទួលស្គាល់ | កម្លាំងកម្មពិត |
| មិនធ្វើផ្តេសផ្តាស | ខ្លាចក្នុងជីវិត ខ្លាំងក្លាដូច្នេះ។ | ព្រោះកម្មវិចិត្រ |
| នេះបុញ្ញកិរិយា | សង្ខេបមកណា | ដែលត្រូវរៀនរិះ |
| ចូលចិត្តខាងណា | គួរមានគំរិះ ដោយត្រូវទំនង។ | ប្រតិបត្តិដោយចេះ |
| ទាំងដប់ប្រការ | កិរិយាមួយណា | ក៏ល្អហ្មត់ហ្មង |
| ប្រតិបត្តិធ្វើទៅ | បានផលកន្លង ប្រាថ្នាធ្វើល្អ។ | សុទ្ធតែបំណង |
| បើធ្វើល្អហើយ | ផលល្អនឹងឲ្យ | ឲ្យសុខបវរ |
| សុខទាំងជាតិនេះ | ហើយផ្តល់បន្ត តទៅជាតិមុខ។ | សុខសាន្តដ៏ល្អ |

### ២.៣ ការតម្កល់ខ្លួនដោយប្រពៃ

-ទង្វើត្រូវកសាងក្នុងពេលបច្ចុប្បន្ន គឺ  កាយសុចរិត វចីសុចរិត មនោសុចរិត

-អប់រំបណ្តុះឧបនិស្ស័យឲ្យមានសទ្ធា សីល ចាគ បញ្ញា។

## ៦. **អត្តសម្មាបណីធិ** ការតម្កល់ខ្លួនប្រពៃ

**អត្ថបទកំណាព្យ**  (បទសរភញ្ញ)

អត្តសម្មាបណីធិ  គឺជាតម្រិះកសាងខ្លួន
កើតមកជាមនុស្សគួរគិតគន់  កុំបីទម្រន់សោះឡើយណា។
គួរតម្កល់ខ្លួនឲ្យប្រពៃ  គួរតែកែខៃហើយរចនា
ព្យាយាមប្តូរផ្តាច់ក្នុងជីវ៉ា  កសាងអាត្មាកុំបណ្តោយ។
កុំពឹងកុំផ្អែកលើបុណ្យចាស់  ព្រោះបុណ្យចំណាស់ឲ្យផលហើយ
កុំអាងកុំអួតក្អេងគេឡើយ  ត្រូវគិតមុខក្រោយខំព្យាយាម។

ព្យាយាមសិក្សាវិជ្ជាសាស្ត្រ ឲ្យបានចេះច្បាស់កុំទីមទាម
វិជ្ជាឯកទេសរៀនយកភ្លាម កុំឲ្យរីមរាមក្នុងជីវិត។
ព្រោះថាបើមិនចេះវិជ្ជា ឯកទេសនានាពិបាកពិត
ឬមួយថាចេះស្ទើរកម្រិត អនាគតខ្វល់ចិត្តជាមិនខាន។
វិជ្ជាសិល្បសាស្ត្រប្រពៃហើយ កុំបីបណ្តោយឲ្យខកខាន
រៀនធម៌រៀនអាថ៌ល្អកល្យាណ គ្រាន់ប្រតិបត្តិបាននូវក្តីសុខ។
នេះហៅថារៀនសព្វវិជ្ជា ដែលមនុស្សគ្រប់គ្នាសន្សំទុក
កើតមកដឹងក្តីមិនស្រណុក នាំគ្នាសម្រុករស់ដោយរៀន។
រៀនតាមមាតានិងបិតា រួចហើយអាចារ្យគ្រប់ទីស្ថាន
ចេះច្រើនល្អច្រើននឹងថ្កើងថ្កាន សម្រេចសម្រាន្តបានសុខា។
រៀនធម៌រៀនអាថ៌ព្រះសម្ពុទ្ធ គឺមិនស្រយុតថ្កើងថ្លៃថ្លា
ប្រតិបត្តិតាមធម៌តាមសិក្ខា នោះល្អអស្ចារ្យពេកកន្លង។
អប់រំកែប្រែចិត្តសន្តាន អនុវត្តកសាងបានល្អផង
ធ្វើសេចក្តីល្អគ្មានសៅហ្មង ជាកិរិយាច្បងក្នុងជិវិត។
អ្នកប្រាជ្ញសរសើរមនុស្សធ្វើល្អ ប្រតិបត្តិស្មោះសចេញពីចិត្ត
វិជ្ជាលោកីយ៍ដល់កម្រិត សង្ឃឹមលើចិត្តឲ្យល្អផង។
បើចិត្តមិនល្អមិនបានការ ប្រព្រឹត្តិអសារឥតការហោង
បំផ្លាញគេឯងញាតិប្អូនបង ដោយក្តីបំណងរកប្រយោជន៍។
ឲ្យតែបានផលដល់ដៃខ្លួន អាក្រក់ផ្ទួនៗខ្លាំងអសោច
មិនចេះគិតគូរមិនផ្សាខ្លោច គិតតែប្រយោជន៍ខ្លួនប្រាថ្នា។
មកតែពីចិត្តជួសាមាន្យ ដូចព្រះទ្រង់ញាណបានត្រាស់ថា
**មនោបុព្វង្គមា ធម្មា** **មនោសេដ្ឋា មនោមយា**
**នមសា ចេ បទុដ្ឋេន** **ភាសតិ វា ករោតិ វា**
**តតោ នំ ទុក្ខមន្វេតិ** **ចក្កំវ វហតោ បទំ**[៤]។



៤.បិដកលេខ ៥២.ទំព័រ ២១, ព្រះពុទ្ធភាសិត ទំព័រ ២,  គាថាធម្មបទប្រែ.ទំព័រ ៤

ប្រែថា អ្វីៗកើតពីចិត្ត ចិត្តបានកម្រិតហើយសម្រាំង
សម្រេចលើចិត្តព្រោះចិត្តខ្លាំង បើចិត្តបែរផាំងទៅខាងណា។
បើចិត្តអាក្រក់ធ្វើអាក្រក់ និយាយអាក្រក់មានមុសា
បង្កើតទុក្ខទោសសព្វប្រការ ដូចមានឧបមាគាថានេះ។
ចិត្តយើងប្រៀបដូចជាជើងគោ កំពុងទឹមមកអូសរទេះ
ជើងគោដើរទៅដោយគេចវេះ នោះកង់រទេះក៏វៀចតាម។
រទេះនឹងភ្លូកធ្លាក់ប្រឡាយ បែកធ្លាយខ្ទាត់ខ្ទាយយ៉ាងរហាម
ដោយសារជើងគោដើរខុសស្នាម រសេមរសាមគេចពីផ្លូវ។
ដូច្នេះទោះចេះកម្រិតណា តែចិត្តគេវ៉ាវ៉ាអាស្រូវ
មិនបានអប់រំប្រតិបត្តិត្រូវ ឲ្យដើរតាមផ្លូវព្រះសាស្តា។
ហាក់ពិតជាល្ងង់អវិជ្ជា ប្រតិបត្តិប៉ះពារអកុសលា
ធ្វើតែអាក្រក់មិនរាបសា កាន់នាទីណាខូចការធំ។
ទាល់តែធ្វើចិត្តឲ្យល្អថ្លា មានទាំងបញ្ញាផងគួបផ្សំ
ទើបបានលទ្ធផលល្អសមរម្យ បានផលសក្តិសមទាំងអស់គ្នា។
សប្បុរសត្រូវតែធ្វើចិត្តល្អ ប្រព្រឹត្តិធម៌សរាល់វេលា
បើធ្វើអាក្រក់មានវេរា ឲ្យទុក្ខវេទនាជាពុំខាន។
កម្មថ្មីជួនកាលឲ្យផលថ្មី នៅនាលោកីយ៍វារំខាន
បើនាលោកីយ៍ឲ្យមិនបាន វាបានរុញច្រានទៅមុខទៀត។

## សារៈសំខាន់នៃកម្មថ្មីនៅនាបច្ចុប្បន្ន

**ជោតិតមោ បរាយិនោ** កើតមកភ្លឺទៅវិញងងឹត

គួរពិចារណាព្រះពុទ្ធដីកា មួយកើតមកណាល្អប្រពៃ
ដល់ពេលទៅវិញអាក្រក់ក្រៃ ព្រោះមិនលកលៃនៅបច្ចុប្បន្ន។

**តមោ ជោតិ បរាយិនោ** កើតមកងងឹតទៅវិញភ្លឺ

ទីពីរកាលមកអាក្រក់ទេ តែទៅវិញប្រែជាមិនអន់

ព្រោះប្រព្រឹត្តិល្អនាបច្ចុប្បន្ន ទៅវិញបានគ្រាន់ល្អប្រសើរ។

**ជោតិជោតិ បរាយិនោ** កើតមកភ្លឺទៅវិញក៏ភ្លឺ

ទីបីកាលមកក៏ល្អដែរ ទៅវិញមិនប្រែនៅគ្រាន់បើ
ព្រោះប្រព្រឹត្តិល្អជាបណ្ដើរ បច្ចុប្បន្នប្រសើរដូចអនាគត។

**តមោ តម បរាយិនោ** កើតមកងងឹតទៅវិញងងឹត

ទីបួនកាលមកវាអាក្រក់ កំណើតមានទុក្ខលំបាកផ្ទួន
ធំដឹងក្ដីហើយមិនកែខ្លួន ប្រព្រឹត្តិថែមជួនអាក្រក់ច្រើន។
ដល់ពេលទៅវិញអាក្រក់ទៀត ព្រោះតែមានស្មៀតអាក្រក់កើន
ផលខ្មៅសាងទុក្ខឲ្យចម្រើន ព្រោះបច្ចុប្បន្នកើនតែខាងបាប។
ព្រះពុទ្ធសាសនាឲ្យសន្សំ សាងល្អបច្ចុប្បន្នជាដរាប
ឲ្យខំព្យាយាមដោយសង្វាត តម្កល់ខ្លួនស្អាតបាតសក្តិសម។
ម្យ៉ាងទៀតហៅតាំងខ្លួនប្រពៃ តាំងនេះមានន័យថ្លៃឧត្តម
គួរតម្កល់ខ្លួនឲ្យបានមាំ ដោយប្រឹងសន្សំយកផលា។

**ការកសាងសន្សំផ្សេងៗក្នុង សម្មាបណិធិ**

ទីមួយគួរតែរិះរេផ្សំ រៀនសូត្រសន្សំយកបញ្ញា
រៀនសព្វរៀនគ្រប់វិជ្ជាការ រៀនទាំងធម៌អាចបញ្ញាកើន។
ឲ្យចេះដឹងច្រើនគាប់ប្រសើរ គ្រាន់ធ្វើដំណើរឲ្យជឿនលឿន
រស់នៅចង់សុខត្រូវតែលឿន រត់ឲ្យទាន់ល្បឿនពិភពលោក។
ឲ្យបានយល់ស្គាល់ការរាក់ជ្រៅ ត្រជាក់ឬក្ដៅថ្លៃឬថោក
វាច្បាស់ជាចោទនៅលើលោក ឧបសគ្គគោកនឹងមានមក៏។
ទីពីរចិត្តត្រូវមានសទ្ធា ការជឿល្អជាតាមព្រះធម៌
ជឿកម្មជឿផលអាក្រក់ល្អ ត្រូវចេះសាទរធ្វើល្អបាន។
គួរជឿថាកម្មរបស់ខ្លួន មិនអាចបំពួនខំលាក់ប្រាណ

វាពិតជាឲ្យផលមិនខាន មិនមានខកខានកុំបិទបាំង។
**យាទិសំ វប្បតេ ពិជំ តាទិសំ លភតេ ផលំ**
បណ្តុះពូជណាដោយសម្រាំង ពូជនោះវាតាំងឲ្យនូវផល។
បើបណ្តុះស្វាយបានកូនស្វាយ មិនអាចប្រែក្លាយឲ្យបានខ្នុរ
ផលនោះវាពិតជានឹងផ្តល់ មិនជុះទេខ្នុរគឺជុះស្វាយ។
បើធ្វើអាក្រក់បានអាក្រក់ ធ្វើល្អវិញនោះបានសប្បាយ
បើឲ្យសុខគេៗរីករាយ យើងក៏ស្រស់ស្រាយដូចគេដែរ។
ម្យ៉ាងទៀតក៏បានយល់ជឿថា ព្រះពុទ្ធនោះណាមានហូរហែ
ជឿថាមានលោកខាងមុខដែរ ជឿដឹងគុណម៉ែដឹងគុណឪ។
ទីបីតាំងខ្លួនល្អប្រពៃ តាំងនោះល្អន័យកាន់តែជ្រៅ
គឺខំធ្វើសីលបានល្អទៅ យ៉ាងហោចត្រឹមត្រូវត្រឹមសីលប្រាំ។
បានល្អដោយកាយនិងវាចា ល្អគួរដែរណាតាមចំណាំ
ឲ្យអភ័យគេជាប្រចាំ អកុសលកម្មមិនធ្វើអី។
ទីបួនចិត្តល្អជាប់ ចាគៈ ទានៈធ្វើជាក់ជាប្រក្រតី
គឺជាចិត្តបុណ្យល្អប្រពៃ ចិត្តមាននិស្ស័យក្តីមេត្តា។
ករុណាអាណិតអាសូរផង ដល់អស់ប្អូនបងមានទុក្ខា
គ្នាមានវិបត្តិក្នុងគ្រួសារ មហន្តរាយយ៉ាងណាគួរស្រោចស្រង់។
ជនក្រតោកយ៉ាកហើយពិការ មានច្រើនណាស់ណានៅរហង់
យើងមានសមត្ថភាពគួរផ្ចិតផ្ចង់ តម្រង់យកបុណ្យដោយជ្រះថ្លា។
នេះគឺតាំងខ្លួនល្អប្រពៃ ល្អនេះក្នុងន័យមានសទ្ធា
សីលៈ ចាគៈ និងបញ្ញា សុទ្ធតែជ្រះថ្លាក្នុងកុសល។
ធ្វើល្អដូច្នេះនឹងបានល្អ កម្មនេះគាំទ្រឲ្យនូវផល
បានសុខសួស្តីគ្មានកង្វល់ ព្រោះចិត្តបានដល់សុចរិតធម៌។
អ្នកផងតែងតែលើកតម្កើង កិត្តិយសខ្ពស់ថ្កើងល្អបវរ

ជាទីស្រឡាញ់យ៉ាងស្មោះស នៃប្រជាករទាំងអស់គ្នា។
ព្រោះបានធ្វើខ្លួនឲ្យប្រពៃ ប្រព្រឹត្តិអ្វីៗក៏ល្អជា
បានសុខចម្រើនឥតគណនា ដែលគួររាប់ថាជាមង្គល។
សរុបទាំងបី សិរីគាថា អង្គព្រះសាស្តាចង់ឲ្យយល់
រស់ក្នុងរដ្ឋល្អមិនអំពល់ បុណ្យចាស់ឲ្យផលតាមជួយផង។
ព្រមទាំងធ្វើខ្លួនល្អប្រពៃ សន្សំនិស្ស័យបច្ចុប្បន្នផង
ហៅថាមានបុណ្យល្អកន្លង ធ្លាប់សាងច្រើនដងរៀងៗមក។
នេះជាអំពើដ៏ប្រសើរ ដែលជាដំណើរធ្លាប់កាន់យក
កើតជាមង្គលល្អរត់រក តាមផ្តល់ឲ្យមកក្នុងជីវិត។

## ព្រះគាថាទី ៣

មាន ៤ មង្គល

**ពាហុ សច្ចញ្ច សិប្បញ្ច     វិនយោ ច សុសិក្ខិតោ**

**សុភាសិតា ច យា វាចា     ឯតម្មង្គលមុត្តមំ។**

(បទសរភញ្ញ)

កិរិយាក្នុងការបានសិក្សា     ចេះវិជ្ជាការច្រើនមុតមាំ
ចេះសិល្បសាស្ត្រស្ទាត់មិនច្រឡំ     ធ្វើការអ្វីហំហើយប្រសប់។
ព្រមទាំងអប់រំខ្លួនបានល្អ     វិន័យស្មោះសមិនមានល្អក់
សម្តីសំដៅក៏ពីរោះ     បួនមង្គលនោះល្អឧត្តម។

**សេចក្តីសម្រាយ**

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនច្រើន១ សិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាស់ក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលល្អ១ ទាំង៤ នេះជាមង្គលដ៏ឧត្តម ។

**៣.១ បានស្តាប់ បានរៀនចេះចាំច្រើន**

-បានស្តាប់ បានរៀនពីសប្បុរសមានបណ្ឌិត និងគ្រហស្ថ

-បានស្តាប់នូវពាក្យប្រកបដោយប្រយោជន៍

-បណ្ឌិតបានរៀនចេះចាំនូវពុទ្ធវចនៈ

-គ្រហស្ថ ជាអ្នកបានសិក្សារៀនសូត្រចេះចាំនូវវិជ្ជាផ្សេងៗ

-ការចេះចាំច្រើនអាចញុំាងប្រយោជន៍ និងសេចក្តីសុខឲ្យកើតឡើង

-ការសិក្សារៀនសូត្រក្រេបយកវិជ្ជាទូទៅ គឺជាគោលដៅនៃសតិបញ្ញា

**បញ្ញាកើតឡើងដោយសារហេតុ ៣ យ៉ាងគឺ ៖**

-ការស្តាប់ ហៅថា **សុត្តាមយបញ្ញា**

-ការគិត ហៅថា **ចិន្តាមយបញ្ញា**

-ស្វាធ្យាយ ហៅថា ***ភាវនាមយបញ្ញា***

**ពហុស្សូត ប្រកបដោយអង្គ ៤ គឺ :**

១.**សុ** មកពីពាក្យថា **សុត្ត** រៀនស្តាប់

២.**ចិ** មកពីពាក្យថា **ចិន្ត** រៀនគិត

៣.**បុ** មកពីពាក្យថា **បុច្ឆា** ឆ្ងល់សួរ

៤.**លិ** មកពីពាក្យថា **លិខិត** កត់ចំណាំ

**៧. ពាហុ សច្ចញ្ច** ការរៀនសូត្រច្រើន

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

កិរិយាក្នុងការបានសិក្សា ចេះវិជ្ជាការនោះបានច្រើន
ចេះធម៌ចេះអាថ៌បញ្ញាកើន នាំឲ្យជឿនលឿនក្នុងជីវិត។
ព្រោះថាបើសិនសិក្សាល្អ យកវិជ្ជាមកផ្សំគំនិត
បញ្ញាអារកាត់ឧបសគ្គពិត សម្រួលជីវិតកាត់វិបត្តិ។
បើបានយល់ធម៌ល្អជ្រាលជ្រៅ ចេះនេះនាំទៅបដិបត្តិ

បដិបត្តិបានត្រូវយ៉ាងមធ្យ័ត ព្រោះតែយល់អត្ថនៃព្រះធម៌។
ស្គាល់កិច្ចស្គាល់កលស្គាល់ហេតុការណ៍ ស្គាល់អស់ស្គាល់អាចបានយ៉ាងល្អ
ស្គាល់ទាំងអ្វីៗសព្វគ្រប់មក ដើម្បីគាំទ្រតែជីវិត។
បើល្ងង់ធ្វើអ្វីគ្មានហេតុផល មិនសូវបានយល់នូវការពិត
លទ្ធផលបានមកមិនសុក្រិត្យ រឿងពិតផលកើតដោយផ្សងព្រេង។
ច្នោះហើយបានជាអស់ទាំងមនុស្ស ប្រឹងប្រែងខំស្ទុះទាន់ខ្លួនក្មេង
ហាត់រត់រករៀនរបៀនផ្សេង មិនធ្វើលេងៗព្រោះចង់ចេះ។
ខំហាត់ខំពត់កាយសម្បទា ឲ្យបានសុខជា ហើយរៀនរិះ
សព្វមុខវិជ្ជាឲ្យបានចេះ យកវិជ្ជានេះគ្រាន់ប្រើការ។
នេះហើយហៅវិជ្ជាសម្បទា គេយើងរាល់គ្នាតែងប្រាថ្នា
ចង់បានចេះដឹងយកជាការ កុំឲ្យអសារឥតការឡើយ។
ចេះដឹងបានច្រើនចម្រើនខ្លួន ប៉ះឧបសគ្គផ្ជួនមិនរាឡើយ
ព្យាយាមដោះស្រាយមិនបណ្តោយ ទោះមុនទោះក្រោយយកជោគជ័យ។

## **ករណីដែលគួរធ្វើខ្លួនឲ្យក្លាយជាពហុស្សូត**

ដើម្បីធ្វើខ្លួនជាពហុស្សូត គួរប្រឹងប្រែងស្រូតហើយឧស្សាហ៍
ព្យាយាមស៊ូក្នុងការសិក្សា ដោយធ្វើកិរិយាដូចតទៅ ៖
ទីមួយ បើហៅកាត់ថា "សុ" គឺពាក្យសុត្តៈពាក្យបាលី
ប្រែមកថាស្តាប់ជាប្រក្រតី ស្តាប់ឲ្យយល់ន័យនៃព្រះធម៌។
ព្រះធម៌សម្តែងដោយសប្បុរស ធម៌សច្ចៈស្មោះជាធម៌ល្អ
ធម៌មានប្រយោជន៍ដ៏កម្រ បានស្តាប់ដោយល្អដុះបញ្ញា។
ទីពីរ បើបានស្តាប់ធម៌ហើយ **ចិ** ចេះគិតហើយពិចារណា
ចិ នេះកាត់មកពីចិន្តា ត្រិះរិះអស់អាចយកអត្ថន័យ។
ទីបី បើសិនមានរឿងឆ្ងល់ **បុ** សាកសួរដល់បណ្ឌិតក្តី

អ្នកប្រាជ្ញព្រាហ្មណ៍ព្រឹទ្ធមិត្តករី ព្រោះ **ឬ** កាត់ន័យពាក្យបុច្ឆា។
ទីបួនហៅ **លិ** ពាក្យក្រោយគេ បើសិនសរសេរឲ្យពិស្តារ
ហៅថា លិខិត ពាក្យនោះណា គឺឲ្យកត់ត្រាចារចម្លង។
អង្គទាំងបួននេះគេសិក្សា ស្ទិតស្ទាញណាស់ណាទើបបានឆ្លង
បានទៅជាអ្នកចេះដឹងផង គឺជាគន្លងពហុស្សូត។
ម្យ៉ាងទៀតបើចង់ផ្សំឲ្យលឿន ត្រូវបង្កើនល្បឿនប្រឹងប្រែងស្រូត
សេចក្តីចម្រើនកើនរហូត ដោយចេះរៀនសូត្រតាមឧបាយ។
**មួយសប្បុរិសូបសំសេវ** គឺសេពគប់ច្បាស់កុំក្លែងក្លាយ
សេពគប់សប្បុរសប្រាជ្ញទាំងឡាយ នោះបានសប្បាយដោយស្តាប់ធម៌។
**ទីពីរ**បើបានស្តាប់ធម៌ហើយ ត្រូវកុំបណ្តោយស្តាប់ឲ្យល្អ
ហៅ**ធម្មស្សវនៈ** គឺស្តាប់ធម៌ ស្តាប់បានដោយល្អកើតជ្រះថ្លា។
ស្តាប់ដោយផ្ចិតផ្ចង់ផ្ចង់ស្មារតី ក្រេបយកអត្ថន័យនៃធម្មា
ប្រណិប័តន៍ធម្មកចិកសមសោភា អានិសង្សមុខជាល្អថ្លៃថ្លា។
**បី យោនិសោមនសិការៈ** ស្តាប់ធម៌ឲ្យជាក់ពិចារណា
ឲ្យបានល្អិតល្អន់នូវសិក្ខា ដោយមានបញ្ញាអាចសេចក្តី។
ដោយឧបាយឆ្លាតនៃបញ្ញា យល់នូវធម៌អាចច្បាស់អស់ន័យ
ច្បាស់មានពន្លឺអស់សង្ស័យ ដោយសារនិស្ស័យស្តាប់ព្រះធម៌។
**ទីបួន ធម្មានុធម្ម៍**-(៥) **ប្បដិបត្តិ**ឲ្យត្រូវតាមព្រះធម៌
យល់ឃើញថាធម៌ថ្លៃបវរ ធម៌នេះនាំមកសុខសន្តិភាព។
ក៏ខំប្រតិបត្តិតាមធម៌ពិត ធម៌ព្រះទ្រង់រិទ្ធពិតគ្រប់ស្មៀត
ញ៉ាំងចិត្តញ៉ាំងកាយឲ្យសុភាព វាចារាបទាបល្អសមរម្យ។
ប្រព្រឹត្តិកិច្ចការជួយខ្លួនឯង ព្រមទាំងរអែងជួយសង្គម
ទោះធ្វើអ្វីៗក៏ស័ក្តិសម ជាសរសរស្តម្ភជាតិសាសនា។
ករណីទាំងអស់នៃពហុស្សូត នាំប្រយោជន៍សុទ្ធល្អថ្លៃថ្លា



៥. ធម្មានុធម្មប្បដិបត្តិ អានថា ធ័ម មា នុ ធ័ម ម័ប ប៉ាក់ ដិ បាត់

ព្រមទាំងឧបាយការសិក្សា សុទ្ធជាកិរិយាល្អប្រពៃ។
ទាំងការប្រតិបត្តិសព្វបែបយ៉ាង ដែលមានភស្តុតាងច្រើនករណី
អធិប្បាយមកបានជាសេចក្តី គឺជាបច្ច័យនាំឲ្យសុខ។
សុខទាំងខ្លួនឯងសុខអ្នកផង មិនមានប៉ុនប៉ងចម្លងសុខ
លួចលាក់តែឯងជាត្រីមុខ គឺធ្វើយកសុខទាំងអស់គ្នា។
នេះហៅកិរិយាសិក្សាច្រើន ចេះចាំចម្រើនសព្វវិជ្ជា
ចេះទាំងកិច្ចការប្រសើរជា សេពគប់ជាគ្នាមានប្រយោជន៍។
ព្រមទាំងជាអ្នកប្រតិបត្តិធម៌ ប្រព្រឹត្តិបានល្អៗរុងរោចន៍
សុទ្ធជាអំពើនាំប្រយោជន៍ មិនឲ្យហិនហោចអសោចគុណ។
ប្រព្រឹត្តិតែអំពើដែលល្អ យើងគេសាទរទុកជាបុណ្យ
ព្រោះប្រតិបត្តិល្អមកពីមុន បានជាដើមទុននៃមង្គល។

**៣.២ សិប្ប គឺការរៀនសូត្រ ឲ្យស្ទាត់ជំនាញក្នុងការងារ**

-រៀនជ្រើសរើសយកវិជ្ជាឯកទេស ឲ្យចេះប្រាកដ ដើម្បីបម្រើឲ្យចំតម្រូវការនៃសង្គម តាមសម័យកាល

-ជ្រើសរើសយកមុខរបរដែលខ្លួនទុកចិត្តថាចេះ គឺមិនប្រកបការងារដោយស្មានហើយច្របូកច្របល់

-ប្រកបតែការងារដែលមានប្រយោជន៍ដល់ខ្លួន និងសង្គម មិនប្រកបការងារណាដែលទុច្ចរិត

-មានទេពកោសល្យក្នុងការផ្លាស់ប្តូរការងារ គឺមិននៅងប់ជ្រប់ក្នុងកិច្ចការដដែលៗ ដែលមហាជនមិនគាំទ្រ

**៨. សិប្បញ្ច** សិល្បសាស្ត្រល្អឬការងារឈ្លាសវៃ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

វិជ្ជាសិល្បសាស្ត្រច្បាស់ក្នុងចិត្ត ដែលរៀនមកពិតជាថ្លាថ្លៃ
រៀនឯកទេសមួយកំដរដៃ ធ្វើការយកជ័យនៃជីវិត។

បើចេះសើៗធ្វើមិនកើត ឬថាមិនឆើតមិនល្អពិត
លទ្ធផលក៏អន់តាមកម្រិត ដែលយើងផលិតមិនត្រឹមត្រូវ។
មួយមុខក៏ដោយចេះឲ្យច្បាស់ ចេះឲ្យស្រទ្បះច្បាស់មានផ្លូវ
ធ្វើបានភ្លាមៗទាន់ចិត្តក្តៅ តម្រូវទៅតាមគេត្រូវការ។
បើធ្វើតម្រូវត្រូវខ្លួនឯង មិនបាច់តាក់តែងនូវកិច្ចការ
វាគ្មានតម្លៃល្អទេណា មិនចំប្រាថ្នាដល់គេឡើយ។
ដូច្នេះបើរៀនរកវិជ្ជា សិល្បសាស្ត្រនានាគិតមុខក្រោយ
ឲ្យបានច្បាស់សិនកុំឲ្យធ្លោយ រៀនខុសវាស៊ិយមួយជីវិត។
បើរៀនត្រូវវិញវាប្រសើរ រៀនតាមដំណើរសង្គមពិត
គេត្រូវការអ្វីយើងប្រឌិត តម្រូវតាមចិត្តគេទាំងឡាយ។
អតិថិជនមិនមានខ្វះ នាំមកប្រាក់កាសរត់ប្រញាយ
ប្រញាប់ពឹងយើងឲ្យដោះស្រាយ ធ្វើដោយសប្បាយគ្មាននឿយហត់។
រីឯការរៀនយកតម្រិះ បើយើងបានចេះល្អហ្មត់ចត់
ជិវិតយើងនេះមិនកំសត់ លាភនឹងប្រាកដដង្ហោយហៅ។
ជីវិតរុងរឿងល្អប្រសើរ រស់ក្នុងដំណើរមានគោលដៅ
ហេតុនេះព្រះពុទ្ធទ្រង់ប្រដៅ បង្ហាញទិសដៅនៃមង្គល។
ការពិតបើធ្វើការអ្វីល្អ តាមសំណូមពរគ្រប់មណ្ឌល
បំរើពួកគេមិនឲ្យខ្វល់ លាភនឹងមានដល់មិនកំសត់។
ដូចបុរាណថាបើសិនចេះ ចេះនូវតម្រិះពិតប្រាកដ
ចេះច្បាស់ឲ្យបានត្រូវកំណត់ ប្រាក់មុខជារត់តាមហៅយើង។
មានពាក្យមួយទៀតបានប្រាប់ថា បើចេះអ្វីណាចេះឲ្យថ្មើង
ច្បាស់ឲ្យដាច់គេមានតែយើង បើចេះស្មើរភ្លើងមិនបានការ។
រីអ្នកចេះច្រើនដល់ទៅដប់ មិនស្មើអ្នកប្រសប់តែមួយណា
តែម្នាក់ពិតមែនតែច្បាស់ការ លទ្ធផលឆ្លើយថាមានសង្ឃឹម។

### ៣.៣ វិន័យដែលបុគ្គលរក្សាដោយប្រពៃ

វិន័យគឺជាច្បាប់សម្រាប់អប់រំទូន្មាន កាយ ចាវា ចិត្ត ឲ្យមានរបៀបបែបផែនល្អ កាលបើបុគ្គលរក្សា វិន័យ វិន័យនឹងរក្សានូវបុគ្គលមិនឲ្យធ្លាក់ទៅកាន់ទីថោកទាប។ វិន័យមានពីរ យ៉ាងគឺ

១.អគារិយវិន័យ ជាវិន័យសម្រាប់គ្រហស្ថ (មានសីល ៥ កុសលកម្មបថ ១០)។

២.អនាគារិយវិន័យ ជាវិន័យសម្រាប់បព្វជិត (ភិក្ខុ សាមណេរ)។

## ៩. **វិនយោ ច សុសិក្ខិតោ** អប់រំវិន័យបានល្អ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| វិន័យមានន័យថាជាផ្លូវ | បែបបទនាំទៅដល់ក្តីល្អ |
| នាំសុខចម្រើនល្អបវរ | សណ្តាប់ធ្នាប់ល្អព្រោះវិន័យ។ |
| វិន័យផ្តល់សុខស្មើៗគ្នា | សេរីភាពល្អជាតាមសំណៅ |
| មិនឲ្យសេរីហួសគោលដៅ | នាំឲ្យកើតក្តៅគ្រប់គ្នីគ្នា។ |
| សម្រិតសម្រាំងខ្លាំងវិន័យ | បានល្អប្រពៃថ្លៃអស្ចារ្យ |
| ល្អចិត្តល្អកាយល្អវាចា | នោះប្រាជ្ញចាត់ថាល្អវិន័យ។ |
| បើវិន័យល្អគឺធ្វើល្អ | អ្វីៗក៏សល្អសួស្តី |
| មិនប្រព្រឹត្តិខ្មៅខ្មៅអប្រិយ | នឹងបានសិរីជោគជ័យហើយ។ |
| ប្រព្រឹត្តិតែល្អតាមធម៌ព្រះ | ដែលមានតេជៈនៅបង្ហើយ |
| ព្រះទ្រង់បរិនិព្វានហើយ | បន្សល់ទុកឲ្យនូវព្រះធម៌។ |
| ជាព្រះបរិយត្តិសទ្ធម្ម | ដែលប្រមូលផ្តុំទុកកៀរគរ |
| ព្រះត្រៃបិដកជាជំហរ | ចារជាគំនរគរព្រះធម៌។ |
| ប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធ | បរិស័ទបានកាន់ហើយរៀនយក |
| ចាត់ជាសាស្តាតរៀងមក | ប្រតិបត្តិរិះរកក្តីសុខា។ |
| ក្នុងព្រះធម៌នោះមានវិន័យ | ប្រតិបត្តិរាល់ថ្ងៃតាមពុទ្ធដីកា |

វិន័យជាគ្រឹះនៃសាសនា វិន័យនេះណាកើតព្រះសង្ឃ។
ព្រមទាំងកើតគ្រប់បរិស័ទ មានសទ្ធាច្បាស់ហើយផ្ចិតផ្ចង់
ប្រតិបត្តិធម៌ព្រះរះត្រចង់ តម្កើងដល់អង្គព្រះសាសនា។

**សព្វ បាបស្ស អករណំ កុសលស្សូបសម្បទា**

**សចិត្ត បរិយោទ បនំ ឯតំ ពុទ្ធា ន សាសនំ**

តមបាបទាំងឡាយកុំសាងទុក កុសលគ្រប់មុខគួរអប់រំ
ជម្រះសន្តានចិត្តរមទម្យ នេះចំជាសាសនាព្រះពុទ្ធ។
នេះជាព្រះពុទ្ធវចនៈធំ ដែលព្រះបរមសព្វញ្ញូពុទ្ធ
ទ្រង់បានទូន្មានថ្លៃវិសុទ្ធ ទុកជាបែបបទផ្លូវប្រតិបត្តិ។
ឲ្យប្រព្រឹត្តិត្រូវតាមគន្លង កុំឲ្យឆ្គាំឆ្គងហើយប្រយ័ត្ន
តាមក្រឹត្យវិន័យដោយម៉ឺងម៉ាត់ មុខជាកំចាត់ក្តីទុក្ខា។
ដោយសារតែការប្រព្រឹត្តិល្អ ថ្លៃថ្លាបវរសល្អថ្លា
រឿងខ្មៅប្រទុស្តខ្លៅឫស្សា អសារឥតការជៀសឲ្យបាន។
វិន័យផ្តល់នូវក្តីត្រជាក់ មិនឲ្យអន់អាក់គ្រប់ៗប្រាណ
ដោយសារវិន័យទើបសុខសាន្ត កុំបីប្រែប្រាណច្រានវិន័យ។
វិន័យមានច្រើនបែបពេកណា ព្រោះគេប្រើការតាមទិសដៅ
តាមសព្វមូលដ្ឋានគេរស់នៅ ទើបគេបានដៅជាវិន័យ។
តែបើចែកចេញឲ្យបានខ្លី យើងគួរវិនិច្ឆ័យថាវិន័យ
មានតែពីរបែបយកមកស្តី ចាត់ចែងវិន័យតាមនិយម។
**ទីមួយវិន័យខាងផ្លូវលោក** មានច្រើនគគោកក្នុងសង្គម
គ្រឹះស្ថានសិក្សាទាំងតូចធំ ទីប្រមូលផ្តុំជននានា។
ក្រសួងមន្ទីរជាច្រើនទៀត សុទ្ធតែគេឆ្លៀតឲ្យបញ្ញា
សូម្បីកីឡាឋាននានា ក៏មានចែងជាវិន័យដែរ។

គឺគេចែងឡើងឲ្យអនុវត្ត ដើម្បីកំណត់បទហូរហែ
ឲ្យទីស្ថាននោះសុខស្ថិតស្ថេរ កុំឲ្យភ័ន្តប្រែកើតអាសន្ន។
ព្រមទាំងបង្កើនសណ្តាប់ធ្នាប់ នឹងការដែលអប់រំអារម្មណ៍
ឲ្យអនុវត្តល្អៗសមរម្យ កុំបីបង្ខំចិត្តផងគ្នា។
កុំឲ្យប្រមាថអ្នកដទៃ បៀតបៀនដល់សិទ្ធិសេរីគ្នា
ត្រូវតែប្រព្រឹត្តិឲ្យល្អជា វិន័យមាគ៌ាដ៏ថ្លៃថ្លា។
**ទីពីរវិន័យខាងផ្លូវធម៌** បញ្ញត្តិដ៏ល្អពុទ្ធសាសនា
ដែលចែកទៅជាពីរប្រការ អធិប្បាយបានថាជាសេចក្តី។

**ក គឺវិន័យឃរាវាស** ហៅថាអាគារិយៈវិន័យ
បានដល់សីលប្រាំសីលប្រាំបី សម្រាប់កែច្នៃឃរាវាស។
ឲ្យអប់រំកាយវាចាចិត្ត បានប្រសើរពិតកុំឲ្យខុស
មិនត្រូវប្រព្រឹត្តិអ្វីប្រទូស ឲ្យក្តីអាក្រក់អ្នកដទៃ។
ត្រូវប្រព្រឹត្តិយកតែខាងល្អ ជាសប្បុរសធម៌រៀងរាល់ថ្ងៃ
ឲ្យនូវប្រយោជន៍អ្នកដទៃ នឹងចេះលកលៃឲ្យសុខគេ។
មានមិនសម្លាប់មិនលួចទ្រព្យ មិនធ្វើឲ្យខុសធម៌កាមេ
មិនពោលកុហកពាក្យវៀចវេរ មិនផឹកផងដែរទឹកស្រវឹង។
មិនប្រើគ្រឿងញៀនថ្នាំយ៉ាម៉ា ហេរ៉ូអ៊ីនផងណាទាំងអស់ហ្នឹង
កុំឲ្យប្រព្រឹត្តិកុំឲ្យប្រឹង កុំឲ្យសម្លឹងនាំចង្រៃ។
កុំឲ្យសេពគប់អបាយមុខ ធ្វើអ្វីសព្វគ្រប់ឲ្យគេភ័យ
មិច្ឆាជីវៈមិនប្រពៃ របរអប្រិយផ្តល់ក្តីទុក្ខ។

**ខ គឺជាវិន័យបព្វជិត** វិន័យល្អពិតដ៏ខ្ពង់ខ្ពស់
ហៅអនាគារិយវិន័យនោះ សីលដប់ចំពោះតែសាមណេរ។
ឯចតុបារិសុទ្ធសីល ជម្រុះមន្ទិលខ្លាំងស្ថិតស្ថេរ

| | |
|---|---|
| ជាសីលភិក្ខុរក្សាថៃ | សិក្ខាបទផងដែរពីររយម្ភៃប្រាំពីរ។ |
| គឺល្អវិន័យប្រពៃពិត | នាំសាងសុចរិតល្អគ្រប់ទី |
| ហើយបានសិរីក្តីរមណី | ជូនដល់គ្នាគ្នីរាល់រូបា។ |
| យើងឲ្យសុខគេៗឲ្យយើង | បានសុខរុងរឿងល្អថ្លៃថ្លា |
| រស់នៅផុតកម្មផុតវេរា | ពណ៌នាថាជាមង្គលល្អ។ |

### ៣.៤ វាចាដែលបុគ្គលពោលដោយប្រពៃ ប្រកបដោយប្រយោជន៍

វាចាដែលបុគ្គលពោលដោយប្រពៃនោះ សំដៅយកវាចាទន់ភ្លន់ ពោលដោយកថាវត្ថុ ១០ យ៉ាងគឺ

**១. អប្បិច្ឆកថា** ពោលអំពីហេតុដែលនាំឲ្យមានសេចក្តីប្រាថ្នាតិច

**២. សន្តុដ្ឋិកថា** ពោលអំពីសេចក្តីសន្តោស

**៣.វិវេកកថា** ពោលអំពីសេចក្តីស្ងប់កាយ ស្ងប់ចិត្ត

**៤. អសំសគ្គកថា** ពោលដោយការមិននៅច្រឡូកច្រឡំដោយពួក

**៥. វីរិយារម្ភកថា** ពោលអំពីការតាំងប្រារព្ធសេចក្តីព្យាយាម

**៦. សីលកថា** ពោលអំពីសីល

**៧. សមាធិកថា** ពោលអំពីសមាធិ

**៨. បញ្ញាកថា** ពោលអំពីបញ្ញា

**៩. វិមុត្តិកថា** ពោលអំពីព្រះនិព្វាន

**១០. វិមុត្តិញាណ ទស្សនកថា** ពោលអំពីការដឹង ឃើញនូវធម៌ជាគ្រឿងរំលត់ទុក្ខ គឺ ព្រះនិព្វាន។

ការពោលនូវពាក្យមិនមែនជាសុភាសិតរមែងសាបសូន្យចាកលាភសក្ការៈដែលត្រូវបាន។

**១០. សុភាសិតា ច យា វាចា** ការប្រើសម្តីពីរោះ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| **សុភាសិតា ច យា វាចា** | គឺប្រើវាចាល្អសំខាន់ |
| ដើម្បីប្រាស្រ័យគ្នារួសរាន់ | ប្រើជាបន្ទាន់គឺសម្តី។ |
| សម្តីទៅមុនការទៅក្រោយ | បើសិនបណ្តោយបោះសម្តី |
| ទ្រគោះបោះបោកមិនដឹងអី | ការងារអ្វីៗក៏គ្មានផល។ |
| គេមិនជឿយើងព្រោះនិយាយ | យើងមិនចេះរ៉ាយរ៉ាប់កិច្ចកល |
| សម្តីមិនល្អគេមិនខ្វល់ | ចាប់អារម្មណ៍ដល់កិច្ចការយើង។ |
| បើសិនវាចាយើងល្អឯក | ពីរោះចម្លែកដាស់គេឡើង |
| គេក៏ចូលចិត្តនឹងរូបយើង | អ្វីក៏វាឡើងទៅតាមហ្នឹង។ |
| សម្តីឲ្យសុខឬឲ្យទុក្ខ | តទៅខាងមុខមិនអាចដឹង |
| សំខាន់ក៏គួរតែខំប្រឹង | ចេះថ្លាថ្លែងថ្លឹងនូវសម្តី។ |
| បើនិយាយល្អផលនឹងល្អ | កំដរជីវិតសុខសួស្តី |
| និយាយអាក្រក់ពោលអប្រិយ | ឧត្បាតចង្រៃនឹងកើតមាន។ |
| សម្តីជាឯកលេខជាទោ | យើងធ្លាប់ឮមកពីបុរាណ |
| គួរប្រើវាចាឲ្យល្អថ្កាន | នឹងបានសុខសាន្តក្នុងជីវិត។ |
| សម្តីមានចែងក្នុងសីលប្រាំ | គួរតែចងចាំចំណាំពិត |
| ចាំហើយលើកយកមកពិនិត្យ | គួរគិតហើយប្រើរបៀបណា។ |

**១- មុសាវាទ**

| | |
|---|---|
| មួយគួរប្រើប្រាស់នូវសម្តី | ឲ្យបានប្រពៃកុំមុសា |
| និយាយកុហកបោកប្រាស់គ្នា | ឲ្យគេវេទនាខូចកិច្ចការ។ |

**២- បិសុណាវាចា**

ទីពីរកុំពោលនូវវចី	បិសុណានោះនៃឲ្យខ្លោចផ្សា
ចាក់រុកឆ្កើះឆ្កៀលគេរាល់គ្នា	ឲ្យបែកសាមគ្គាសាមគ្គីផង។

**៣- ផរុសវាចា**

ទីបីកុំពោលនូវវាចា	អសុរសផងណាមិនទំនង
បើពោលអាក្រក់តាមចិត្តចង់	អស់ញាតិមិត្តផងមិនចូលចិត្ត។

**៤- សម្ផប្បលាប**

ទីបួនហៅថាសម្ផប្បលាប	ពាក្យមិនសុភាពមិនប្រណីត
ចេះតែពោលទៅស្រេចតែចិត្ត	មិនមានគន់គិតថាបានការ។
គឺពោលរោយរាយពាក្យកំប្លែង	ស្រកីអណ្ដែងអកសុរា
ចំអេសចំអាសសព្វប្រការ	ពាក្យនោះត្រូវការច្រើនខាងពាល។
ពាក្យបួនបែបនេះពាក្យឫស្យា	មិនគួរពោលថាឲ្យរោលរាល
អ្នកប្រើពាក្យនេះហៅអន្ធពាល	ចង្រៃចណ្ឌាលនឹងមានដល់។
ឲ្យទុក្ខឲ្យទោសដល់គេឯង	ចង្រៃជាក់ស្ដែងនឹងឲ្យផល
ឲ្យទុក្ខខ្លួនវិញមិនបាច់ឆ្ងល់	នាំតែឲ្យខ្វល់ព្រោះសម្ដី។
បើសិនប្រើប្រាស់តែពាក្យល្អ	មធុរសបវរល្អវចី
និយាយពាក្យល្អជាប្រក្រតី	សិរីសួស្ដីពិតជាមាន។
ដូចបានរៀបរាប់ច្រើនមកហើយ	ពាក្យល្អដង្ហើយនាំឲ្យបាន
កើតលាភប្រយោជន៍ល្អថ្កើងថ្កាន	រស់នៅសុខសាន្តមានមង្គល។
សរុបទាំងបួនចេះដឹងល្អ	ការងារឆ្លាតល្អក៏ឲ្យផល
វិន័យអប់រំក៏ជិតដល់	មិនសូវឲ្យខ្វល់ក្នុងជីវិត។
ផ្សំនឹងចេះប្រើសម្ដីល្អ	ប្រាស្រ័យស្មោះសញ្ញាតិឆ្ងាយជិត
ញ៉ាំងឲ្យជីវភាពប្រសើរពិត	សុខដុមមូលមិត្តមានមង្គល។

## ព្រះគាថាទី ៤

មាន ៤ មង្គល

**មាតា បិតុ ឧបដ្ឋានំ បុត្តទារស្ស សង្គហោ**
**អនាកុលា ច កម្មន្តា ឯតម្មង្គល មុត្តមំ។**

(បទសរភញ្ញ)

កិរិយាបម្រើនូវមាតា បិតាមានគុណអនន្តំ
សង្គ្រោះប្រពន្ធកូនបានមាំទាំ ហើយចេះខិតខំធ្វើការងារ។
មិនធ្វើការណាច្របូកច្របល់ តែងចេះខ្វាយខ្វល់គ្រប់វេលា
ចាត់ចែងកិច្ចការបានល្អជា បួននេះពណ៌នាជាមង្គល។

### សេចក្ដីសម្រាយ

ការបម្រើនូវមាតា១ ការបម្រើនូវបិតា១ សេចក្ដីសង្គ្រោះដល់បុត្រ និងភរិយា១ ការងារទាំងឡាយ ដែលមិនច្របូកច្របល់១ ទាំង៤ នេះជាមង្គលដ៏ឧត្ដម។

## ៤.១ - ៤.២ ការបម្រើមាតា និងបិតា

តួនាទីរបស់កូនប្រុសស្រី ចំពោះមាតាបិតា មាន៥ យ៉ាង

១.ចិញ្ចឹមមាតាបិតា ដូចលោកចិញ្ចឹមខ្លួន។

២.ជួយធុរៈការងារលោក។

៣.ប្រតិបត្តិឲ្យបានល្អតាមការទូន្មានរបស់លោក។

៤.ប្រតិបត្តិខ្លួនឲ្យសមជាអ្នកទទួលកេរ្តិ៍មត៌ក។

៥.ធ្វើទក្ខិណានុប្បទានឧទ្ទិសកុសលជូនក្រោយពេលដែលលោកចែកឋានទៅ។

តួនាទី១ ទី២ ទី៣ និងទី៤ ដែលកូនត្រូវតែបំពេញជាមួយព្រះកន្លោងគឺជាបុណ្យប្រត្យក្សច្បាស់នឹងភ្នែកមាតាបិតាដែលកំពុងនៅរស់ បុណ្យនេះ ហៅថា បុណ្យខែភ្លឺ ឯបុណ្យទក្ខិណានុប្បទានជាបុណ្យខែងងឹត ។ គុណមាតាបិតាមានទម្ងន់ធ្ងន់ធ្ងរណាស់ ដោយសារចិត្តលោកមានព្រហ្មវិហារធម៌ចំពោះកូនប្រុសស្រី។

**១១. មាតា ឧបដ្ឋានំ** កិរិយាបម្រើមាតា

**១២. បិតុ ឧបដ្ឋានំ** កិរិយាបម្រើបិតា

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

មាតាបិតាព្រះប្រមុខ ខ្ញុំបានច្នៃទុកជាកាព្យ
ដោយបទសរភញ្ញខ្ញុំពណ៌នា ឲ្យយើងគ្រប់គ្នាស្គាល់លោកពិត។
ស្គាល់ម៉ែស្គាល់ពុកទឹកចិត្តស្មោះ ស្គាល់ក្ដីសប្បុរសលោកអាណិត
ស្គាល់សកម្មភាពលោកប្រព្រឹត្តិ ម៉ែពុកផ្ដេកផ្ចិតដល់រូបកូន។
តាំងពីកាលដែលនៅក្នុងផ្ទៃ លោកបានលកលៃរក្សាគ្រង
កូនកើតមកហើយថៃហ្មត់ហ្មង ថៃក្នុងបំណងឲ្យកូនសុខ។
ថៃនេះហៅថាពិតជាថៃ ថៃគ្មានទំនេរថៃទៅមុខ
ថៃមិនធួនល្ហមថៃសព្វគ្រប់ ថៃថ្ងៃថៃយប់លុះមរណា។
កូនដឹងហើយនេះចិត្តពុកម៉ែ កូនរកគ្មានទេលើលោកា

ស្រឡាញ់កូនស្មើមាតុបិតា មើលសព្វទិសាពុំមានឡើយ ។
ឥឡូវនេះកូនបានយល់ដឹង រៀបរាប់គុណហ្នឹងបានខ្លះហើយ
ទោះរាប់ម្ដេចម្ដាមិនអស់ឡើយ គុណពុកម៉ែអើយខ្លាំងណាស់ន៎។
ព្រះពុទ្ធជាម្ចាស់បានត្រាស់ថា **ព្រហ្មា តិ មាតាបិតរោ**
**បុព្វាចារិយាតិ វុច្ចរេ** **អាហុនេយ្យា ច បុត្តា នំ។**
ទ្រង់ប្រសិទ្ធិនាមជូនមាតា បិតាផងណាមានគុណខ្លាំង
ទៅនឹងព្រះព្រហ្មមានបុណ្យធំ ព្រោះលោកសន្សំចិត្តជួយកូន។
ព្រះព្រហ្មតែងមានធម៌**មេត្តា** **ករុណា**ផងណាឲ្យរលូន
**មុទិតា** ចិត្តទោរទន់ព្រោះកូន **ឧបេក្ខា**ដូចក្បូននឹងន់ល្អ។
បុព្វាចារ្យ គឺអាចារ្យដើម ជាលោកគ្រូដើមកាលរៀនមក៍
ឲ្យចេះនិយាយកកែកករ សព្វគ្រប់ចេះមកពីមាតា។
បិតាកាលណាស្ថិតនៅផ្ទះ ក៏បានរួតរះផ្ដល់សិក្ខា
ឲ្យកូនបានចេះកែចរិយា គាត់តែងជ្រះថ្លានឹងរូបកូន។
ព្រះអាហុនេយ្យ គឺព្រះអរហន្ត ព្រះពុទ្ធទ្រង់ផ្សំមកនឹងកូន
មាតាបិតាចិត្តរលូន សន្ដោសសណ្ដានរូបកូនខ្លួន។
អរហន្តចិត្តធ្ងន់ដូចផែនដី កូនខុសម្ដេចក្ដីមិនគុំគួន
រស់នៅការពារតែរូបកូន សុខចិត្តប្ដូរខ្លួនឲ្យកូនរស់។
ព្រះព្រហ្មផ្សាយមន្តព្រហ្មវិហារធម៌ បុព្វាចារ្យល្អអប់រំខ្ពស់
អាហុនេយ្យ ទឹកចិត្តលោកធ្ងន់ហួស ព្រះកន្លោងឈ្មោះព្រះច្បងគេ។
ព្រះប្រមុខក៏ទុកជានាមម៉ែ ពុកយើងផងដែរអ្នកទាំងទ្វេ
ព្រះប្រមុខជានាមកើតក្រោយគេ ទុកជូនកូនខ្មែរបានយល់ដឹង។
ព្រោះលោកមានគុណដំបូងគេ បង្កើតហើយថែថ្នមព្រលឹង
ឲ្យកូនបានសុខជីវិតហ្នឹង អ្នកណាក៏ដឹងថាដើមដែរ។
គុណលោកធំណាស់មហិមា មិនអាចពណ៌នាឲ្យអស់ទេ

ជាអនន្តគុណបើរិះរេ
អសមគុណដែរគួរកូនយល់។
បើតបឧបការគុណបាន
កូនដឹងប្រមាណកាលពីមុន
កាលលោកថៃយើងវិសេសលន់
តើយើងតបគុណបានដូចទេ?
ដូចឬមិនដូចមិនបាច់ថា
គួរពិចារណាទាំងយើងគេ
ត្រូវតែចិញ្ចឹមបម្រើម៉ែ
ឪយើងផងដែរយកបុណ្យធំ។
ចិញ្ចឹមប្តូរផ្តាច់ថែរក្សា
មាតាបិតាឲ្យបានមុន
មុនអស់អាយុឬអស់បុណ្យ
កុំខាននាំស៊ុននាំស្តាយក្រោយ។
ព្រោះថាបើគាត់ស្លាប់បាត់ទៅ
អស់ពេលនឹងហៅជួបទៀតហើយ
គួរតបកតញ្ញូគំរូអើយ
បានបុណ្យធំហើយរាប់ពុំបាន។
កូនគួរបំពេញតួនាទី
ត្រូវតែសំភីកុំខកខាន
ធ្វើអំពើល្អនេះឲ្យបាន
នឹងបានក្សេមក្សាន្តដូចប្រាថ្នា។

**កតញ្ញុតា ធម្មមូលា**
**កតញ្ញុតា បធានតា**

ព្រះពុទ្ធត្រាស់ដឹងនូវធម៌អាថ៌
ទ្រង់បានត្រាស់ថាជាសេចក្តី។
ថាធម៌កតញ្ញូ ជាធម៌ដើម
ធម៌ឲ្យដង្ហើមផ្តើមមានន័យ
ជាឫសជាគល់ ធម៌ដទៃ
ជាប្រធាននៃធម៌ទាំងពួង។
បើចិត្តយើងមានធម៌កតញ្ញូ
ជាធម៌គំរូមានឥទ្ធិពល
កុសលទាំងឡាយនឹងកើតដល់
ចិត្តយើងឈប់ខ្វល់នឹងអកុសល។
ហើយក៏ស្រឡាញ់អំពើល្អ
រស់នៅត្រេកអរនឹងកុសល
ចៀសបាបអាក្រក់លែងខ្វាយខ្វល់
ចិត្តនឹងដាក់ដល់សប្បុរសធម៌។
បណ្តាលឲ្យបានសុខសួស្តី
សិរីកើតមានជាបន្ត
ព្រោះបានសន្សំកុសលធម៌
ជាហេតុបានមកពីកតញ្ញូ។
កូនខ្លះមិនគិតឪម៉ែទេ
រវល់ជាប់ស្នេហ៍ហើយខំប្តូរ
ដាច់ខែម្តងៗចេះតែថ្ងូរ
មិនដែលគិតគូរដល់ម៉ែចាស់។

បើម៉ែសួរទៅឆ្លើយថាម៉ែ　　　រីឯប្រាក់ខែខ្ញុំតិចណាស់
បើដកឲ្យម៉ែខ្ញុំនឹងច្បាស់　　　ជាអស់ស្រឡះមិនខានឡើយ។
និយាយប្រាប់ម៉ែថាអញ្ចឹង　　　អាងម៉ែមិនដឹងរឿងខ្លួនហើយ
ស្នេកឡើងឲ្យស្រីអស់បណ្ដោយ　　　មិនគិតមុខក្រោយដូចឲ្យម៉ែ។
នេះហៅមិនចេះខំធ្វើបុណ្យ　　　កូននេះទុរជនមិនល្អទេ
មិនធ្វើបុណ្យទេជាមួយម៉ែ　　　តែបើស្រីស្នេហ៍មិនខ្លាចខាត។
បុណ្យម៉ែមិនដែលចេះធ្វើសោះ　　　តែចេះហួសស្មោះហើយឱហាត
បើធ្វើបុណ្យខួបជូនស្រីស្អាត　　　នោះតែងសង្វាតចេញលុយឲ្យ។
កូននេះជាកូនល្ងង់អស់ថ្នាក់　　　ជាកូនអប្បលក្ខណ៍ខ្លាំងពេកហើយ
លទ្ធផលអាក្រក់នឹងបានក្រោយ　　　បើសិនបណ្ដោយតែដូច្នេះ។
និយាយរៀបរាប់ច្រើនមកហើយ　　　ពណ៌នាបណ្ដោយតាមពុទ្ធតម្រាស់
និយាយការពិតក៏ឃើញច្បាស់　　　ឲ្យកូនដឹងណាស់ពីកតញ្ញូ។
ចេះដឹងតបគុណមាតុបិតា　　　ចិញ្ចឹមរក្សាដោយគិតគូរ
កូននេះជាកូនល្អគំរូ　　　អ្នកផងតែងស៊ូរករាប់អាន។

## តួនាទីកូនចំពោះឪពុកម្ដាយ

កូនល្អតែងទទួលនាទី　　　ព្យាយាមសំភីកុំឲ្យខាន
**ទីមួយ** ចិញ្ចឹមដោយកល្យាណ　　　ម៉ែឪគ្រប់ប្រាណលោកមានគុណ។
**ទីពីរ** តែងជួយនូវកិច្ចការ　　　ជំនួសហត្ថាលោកជាមុន
មិនមានគេចវេះចេះទម្រន់　　　តែងជួយបានមុនកិច្ចការខ្លួន។
**ទីបី** កូនល្អចេះរក្សា　　　វង្សត្រកូលណាល្អមាំមួន
ដឹកនាំបងប្អូនល្អរលូន　　　ការកេរ្តិ៍តាដូនក្រអូបសាយ។
**ទីបួន** ប្រតិបត្តិខ្លួនបានល្អ　　　មានចិត្តស្មោះសស្ដាប់អភិប្រាយ
ស្ដាប់ដំបូន្មានឪពុកម្ដាយ　　　ប្រព្រឹត្តិចៀសឆ្ងាយពីអកុសល។
**ទីប្រាំ** កាលបើលោកបានស្លាប់　　　កូនល្អប្រញាប់ចាប់ខ្វាយខ្វល់

ចាត់ចែងធ្វើបុណ្យឧទ្ទិសផល ឲ្យបានជូនដល់អ្នកមានគុណ។
នេះហៅចិញ្ចឹមនូវមាតា បិតាផងណាមានគុណធំ
ដឹងតួនាទីថ្លៃឧត្តម គឺនេះស័ក្តិសមជាកូនល្អ។

## អានិសង្សនៃការដឹងគុណ

បើបានចិញ្ចឹមមាតុបិតា ដោយចិត្តជ្រះថ្លាថ្លៃបវរ
ហៅបានធ្វើបុណ្យខ្មើតភ្លឺល្អ ពុកម្តាយត្រេកអរទាន់ភ្លឺភ្នែក។
បុណ្យនេះហៅបុណ្យធំអស្ចារ្យ ដែលកូនជ្រះថ្លាល្អអនេក
ធ្វើនឹងព្រះអរហន្តច្បាស់ណាស់ពេក ជាបុណ្យចម្លែកមិនងាយបាន។
កូននេះតែងបាននូវផលបុណ្យ គេចាត់ហៅមុនថាកល្យាណ
ជនជាសប្បុរសរុងរឿងថ្កាន ព្រោះបានចិញ្ចឹមមាតុបិតា។
ទោះនៅទីណាមានកិត្តិយស មានទាំងកេរ្តិ៍ឈ្មោះល្អថ្លៃថ្លា
រុងរឿងចម្រើនទាំងភោគា រស់គ្រប់ពេលាបានសុខសាន្ត។
បានជាគំរូក្នុងសង្គម អ្នកផងជួបជុំសុំរាប់អាន
ទោះនៅទីណាបានក្សេមក្សាន្ត អនាគតក៏បានដល់សុខសួគ៌។
ច្នេះហើយបើបានចេះរក្សា មាតាបិតាបានដោយល្អ
បុណ្យនេះឲ្យសុខល្អបវរ បានមង្គលល្អដ៏ឧត្តម។

### ៤.៣ ការសង្គ្រោះបុត្រ និងភរិយា

សង្គ្រោះបុត្រដោយធម៌ ៥ យ៉ាង

១.ហាមឃាត់កូនមិនឲ្យធ្វើអំពើទុច្ចរិត
២.ណែនាំកូនឲ្យធ្វើអំពើសុចរិត
៣.ដឹកនាំកូនឲ្យសិក្សាយកវិជ្ជាល្អៗ
៤.រកគូស្រករឲ្យបានសមសួន
៥.ចែកទ្រព្យសម្បត្តិតាមលទ្ធភាព និងតាមកាលគួរ

**សង្គ្រោះភរិយាដោយធម៌ ៥ យ៉ាងៈ**

១.ពោលពាក្យផ្អែមល្ហែម

២.មិនមើលងាយភរិយា ចាត់ទុក ដូចជាទាសី

៣.មិនក្បត់ចិត្តភរិយាទៅមានស្រីថ្មី

៤.ផ្គាប់ចិត្តភរិយាដោយគ្រឿងប្រដាប់តាក់តែងកាយ

៥.ប្រគល់កិត្តិយសជាធំក្នុងផ្ទះ

**១៣. បុត្តទារស្ស សង្គហោ** សង្គ្រោះកូនប្រពន្ធ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| កើតមកជាមនុស្សទោះស្រីប្រុស | នាទីធំនោះជាដំបូង |
| គួរចេះសង្គ្រោះប្រពន្ធកូន | ឲ្យបានសមសួនក្នុងសង្គម។ |
| ដំបូងអប់រំខ្លួនឲ្យល្អ | ចិត្តល្អកាយល្អសម្តីសម |
| ប្រតិបត្តិផ្លូវចិត្តបានរម្យទម | ធ្វើអ្វីសមរម្យកុំប្រទូស។ |
| និយាយស្រស់ស្រាយពាក្យរាក់ទាក់ | ឲ្យបានល្អល្អះមិនប្រឈ្លោះ |
| កុំប្រើសម្តីបែបទ្រគោះ | ពាក្យពោលទៅហួសឥតប្រយោជន៍។ |
| កុំធ្វើអ្វីៗដោយប្រមាទ | វានាំខូចខាតនាំហិនហោច |
| ត្រូវចេះគិតគូរឲ្យបានខ្លោច | ឲ្យបានប្រយោជន៍ពីការងារ។ |
| គួរតែព្យាយាមហើយឧស្សាហ៍ | ប្រកបកិច្ចការតាមមុខងារ |
| កុំបីជ្រៀតជ្រែកគេរាល់គ្នា | នាំឲ្យវេទនាកើតរឿងរ៉ាវ។ |
| គួរតែព្យាយាមហើយតស៊ូ | ខំប្រឹងផ្តាច់ប្តូរហើយស្រាវជ្រាវ |
| ការងារសំខាន់កុំព្រាវៗ | ត្រូវតែរេរាវដោយហ្មត់ចត់។ |
| គួរតែឧស្សាហ៍កុំសំចៃ | ធ្វើការចេះលៃឲ្យទៀងទាត់ |
| មិនមែនធ្វើលេងដោយសន្មត | ធ្វើឲ្យប្រាកដទើបបានផល។ |
| យកផលកម្រៃឲ្យគ្រួសារ | ចិញ្ចឹមជីវ៉ាឲ្យបានស្រួល |

សេដ្ឋកិច្ចចម្រើនវាសម្រួល ជីវភាពឲ្យស្រួលបានថ្កើងថ្កាន។
ចេះទុកចេះដាក់របស់ទ្រព្យ ដែលប៊ិនប្រសប់រកមកបាន
ទោះចាយត្រូវចាយឲ្យដឹងដាន យកល្អត្រូវខានកុំខ្ជះខ្ជាយ។
គួរចេះចាត់ចែងពួកកូនចៅ ប្រដៅឲ្យល្អកុំពាយងាយ
កុំឲ្យប្រព្រឹត្តិរឿងរាយមាយ ដែលជាប្រឡាយនាំទុក្ខា។
ឲ្យកូនរៀនសូត្រចំណេះដឹង គ្រាន់បានទីពឹងយកអាសា
ទៅមុខនឹងបាននូវផ្លែផ្កា ព្រោះតែកិរិយាកូនប្រព្រឹត្តិ។

## តួនាទីមាតាបិតាចំពោះបុត្រធីតា

តួនាទីមាតានឹងបិតា ក្រៅពីកិរិយាជាក់ស្ដែងពិត
បង្កើតចិញ្ចឹមយ៉ាងស្នេហ៍ស្និទ្ធ ចិត្តគាត់នៅគិតសង្គ្រោះកូន។
មានភារកិច្ចប្រាំយ៉ាងទៀត ដែលត្រូវតែឆ្លៀតធ្វើយ៉ាងធ្ងន់
**មួយ** អប់រំកូនជាបន្ទាន់ កុំឲ្យវាភាន់ធ្វើអាក្រក់។
កុំឲ្យអាក្រក់កាយវាចា ចិត្តផងនោះណាបែបស្មោកគ្រោក
កុំឲ្យប្រព្រឹត្តិរឿងទុក្ខសោក វានាំឲ្យខូចវង្សវែងឆ្ងាយ។
**ទីពីរ** ណែនាំឲ្យធ្វើល្អ ប្រតិបត្តិធម៌សល្អស្រស់ស្រាយ
ធ្វើតែកិច្ចការនាំសប្បាយ ការណាអន្តរាយចៀសឲ្យបាន។
អប់រំឲ្យធ្វើអំពើល្អ ប្រឹងកុសលធម៌នាំសុខសាន្ត
ចៀសអស់ពុតពាលនាំរំខាន វាអាចរុញច្រានចូលជ្រោះជ្រៅ។
**ទីបី** ឲ្យកូនរៀនសូត្រល្អ សព្វវិជ្ជាមកកំដរដៃ
រៀនទាំងធម៌អាថ៌ជាប្រក្រតី គ្រាន់ជានិស្ស័យបានទីពឹង។
ព្រោះវិជ្ជានេះជាមិត្តល្អ ជាមិត្តគាំទ្រជំហររឹង
មិត្តស្និទ្ធជាងគេគួរតែដឹង ពិតជាអាចពឹងពាក់ជីវិត។
**ទីបួន** កូនមានការធ្វើហើយ នៅតែមិនស្បើយនៅតែគិត
គិតគួរជ្រើសរើសគូជីវិត ឲ្យកូននៃបនិត្យស្និទ្ធស្នេហា។

កាលបើឃើញកូនសុខប្រសើរ នៅក្នុងដំណើរនៃគ្រួសារ
មាតាបិតាសោមនស្សា តែបើថ្លោះការក៏អាក់អន់។
**ទីប្រាំ** បើសិនមានទ្រព្យខ្លះ ក៏ខំរូតរះចែកឲ្យកូន
ទោះបីតិចតួចក៏សណ្ដូន សន្ដោសរូបកូនបានសុខា។

**តួនាទីស្វាមីចំពោះភរិយា**

តទៅចារចែងថ្លែងវាចា តួនាទីណារបស់ប្ដី
ប្រព្រឹត្តិជាមួយភរិយាស្រី ដោយនូវសេចក្ដីប្រាំប្រការ។
**ទីមួយ ហៅថា សមានតា** លើកតម្កើងណានូវភរិយា
ឲ្យមានមុខមាត់ស្មើល្អជា បានប្រហែលគ្នានឹងស្វាមី។
មិនមានបន្ថោកឲ្យអន់ចិត្ត នាំកើតវិបរិតអាក់មេត្រី
ភរិយាអារកាត់រឿងអ្វីៗ ជាសិទ្ធិសេរីស្រីមេផ្ទះ។
**ទីពីរ ហៅ អវិមានៈ** មិនមើលងាយជាក់ឲ្យអន់អាក់
ចេះលើកសរសើរយ៉ាងថ្នមថ្នាក់ ពោលពាក្យរាក់ទាក់ល្អវថី។
មិនឲ្យប្រទេចជេរផ្ដាសា ភរិយាផងណាដោយសម្ដី
បង្អាប់បន្ទុះឥតប្រណី គួរចេះលកលែលើកឲ្យសម។
**ទីបី អនតិ ចរិយា** ត្រូវស្ម័គ្រស្នេហាស្មោះសុខដុម
កុំឲ្យក្បត់ចិត្តទៅសម្ងំ សន្សំរកស្នេហ៍តែខាងក្រៅ។
**បួន ឥស្សរិយ វោសគ្គៈ** ផ្ដល់ភាពឥស្សរឲ្យជ្រាលជ្រៅ
ផ្ដល់ភាពជាធំក្នុងគោលដៅ ក្ដាប់ការរាក់ជ្រៅក្នុងគេហា។
នឹងលើកតម្កើងផ្ដល់កិត្តិយស ឲ្យបានធំខ្ពស់សមប្រាថ្នា
ឲ្យត្រូវតាមពេលជាផ្លូវការ ឲ្យអស់ចិន្ដាកុំសង្ស័យ។
**ប្រាំ អលង្ការុប្បទាន** អលង្ការត្រូវមានទុកដាក់ដៃ
ទុកគ្រាន់បំពាក់ជូនអ្នកស្រី ដើម្បីលកលែលើកទឹកចិត្ត។
ព្រោះស្ត្រីចូលចិត្តតុបតែងខ្លួន គាប់ជួនបានប្ដីទិញឲ្យពិត

គឺធ្វើឲ្យបានរីករាយចិត្ត កើតក្ដីស្នេហ៍ស្និទ្ធអស់ចិត្តថ្លើម។

**តួនាទីភរិយាចំពោះស្វាមី**

ឯភរិយាវិញដូចគ្នាដែរ ធ្វើការដង្ហែតាមស្វាមី

មានតួនាទីនារីស្រី កិច្ចការលកលៃមានប្រាំយ៉ាង។

ទីមួយ ចាត់ចែងនូវកិច្ចការ ក្នុងនាគ្រឹហាត្រូវស្អិតស្អាង

រៀបចំសម្អាតស្អាតថ្កើងថ្កាន សម្រិតសម្រាំងល្អប្រពៃ។

ទីពីរ ត្រូវចេះជួយសង្គ្រោះ ចេះរំដោះទុក្ខញាតិដទៃ

ញាតិប្ដីញាតិខ្លួនឲ្យស្មើដៃ ត្រូវតែលកលៃកុំអគតិ។

ទីបី ចិត្តល្អនឹងស្វាមី ស្មោះត្រង់នឹងប្ដីមិនវៀចវេរ

ស្ម័គ្រទាំងកាយចិត្តមិនក្បត់ទេ ស្មោះស្និទ្ធស្មោះស្នេហ៍មួយជានិច្ច។

ទីបួន ត្រូវចេះប្រុងប្រយ័ត្ន រក្សាសម្បត្តិកុំភ្លាំងភ្លេច

ទោះទុកឬចាយត្រូវមានកិច្ច បានល្អជានិច្ចកុំខ្វះខ្វាយ។

ទីប្រាំឧស្សាហ៍ក្នុងការងារ ចរិយាសោភាមិនរាយមាយ

ធ្វើអ្វីមធ្យ័តខ្លាចអន្តរាយ ធ្វើការទាំងឡាយដោយប្រយ័ត្ន។

ការសង្គ្រោះកូនប្ដីប្រពន្ធ ជាភារៈធ្ងន់គួរចេះគិត

បើសង្គ្រោះល្អបានសុខពិត គឺជាជីវិតមានមង្គល។

**៤.៤ ការងារដែលមិនច្របូកច្របល់** គឺយល់ពីកិច្ចបំពេញការងារដោយធម៌ ៤ យ៉ាងៈ

១.**ឆន្ទ** ពេញចិត្តនឹងការងារ

២.**វិរិយ** ព្យាយាមធ្វើការងារដោយមិនខ្លាចនឿយហត់

៣.**ចិត្ត** យកចិត្តទុកដាក់ប្ដូរផ្ដាច់ហើយសង្ឃឹមថាបានជោគជ័យ

៤.**វិមំសា** មានបញ្ញាចេះលៃលកឲ្យបានទទួលលទ្ធផលប្រសើរដោយប្រើវិធីសាស្ត្រប្រកបដោយទេពកោសល្យ។

**១៤ - អនាកុលា ច កម្មន្តា** មិនធ្វើការច្របូកច្របល់

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

ធម្មតាប្រុសស្រីលើលោកា ត្រូវមានកិច្ចការកុំងឿងឆ្ងល់
ត្រូវធ្វើការងារដោយខ្វាយខ្វល់ ព្រោះជាជន្មល់ក្នុងគ្រួសារ។
បើសិនដួលហើយពិតជាយ៉ាប់ គួរកុំឲ្យភ្លាត់ចំណាប់ណា
ដូច្នេះរបរឬកិច្ចការ ត្រូវតែឧស្សាហ៍ខំផ្ចៀងផ្ចាត់។
គួរមានគម្រោងការរកស៊ី គួរតែសំភីឲ្យហ្មត់ចត់
បើសិនប្រហែសវានឹងភ្លាត់ ត្រូវតែប្រាកដក្នុងចិន្តា។
សូវធ្វើការងារត្រឹមតូចសោះ តែរឿងពិតនោះវាបានការ
ល្អជាងកិច្ចការធំអស្ចារ្យ តែមិនកើតការបានតែមុខ។
ត្រូវចេះចាត់ការឲ្យងាយស្រួល ធ្វើតាមសម្រួលដោយប្រសប់
ធ្វើអ្វីត្រូវគិតឲ្យសព្វគ្រប់ កុំធ្វើបង្គ្រប់តែពេលា។
ត្រូវចេះគ្រប់គ្រងតួនាទី ត្រូវតែសំភីប្រឹងគ្រប់គ្រា
ត្រូវចេះបែងចែកគ្រប់ការងារ ឲ្យដល់គ្នីគ្នាសហការី។
ហើយត្រួតពិនិត្យឲ្យហ្មត់ចត់ កុំជឿតាមមាត់តាមសម្តី
ត្រូវតាមដានមើលអចិន្ត្រៃយ៍ កុំធ្វើហីៗវាហិនហោច។
បើសិនកាន់ការមិនច្បាស់សោះ មានរឿងចន្លោះនាំឲ្យខូច
យើងស្តាយស្រណោះចិត្តផ្សាខ្លោច ជួនកាលវាខូចធំទាំងស្រុង។
ដូច្នេះគួរតែចេះប្រយ័ត្ន ត្រូវចេះរាំងស្កាត់ឬបម្រុង
ចាត់ចែងសម្រួលឲ្យគ្រប់ជ្រុង កុំឲ្យវាផុងធ្លាក់ជ្រោះជ្រៅ។
គួរចេះសម្រួលសព្វកិច្ចការ ក្តោបក្តាប់នោះណាច្បាស់ក្រឡៅ
កុំធ្វើការណាដែលជ្រុលជ្រៅ ដែលអាចនាំទៅច្របូកច្របល់។
ធម្មតាការងារដែលមិនច្បាស់ វានឹងក្រឡាស់នាំឲ្យខ្វល់
យើងធ្វើវាទៅច្របូកច្របល់ អាចនឹងនាំដល់ក្តីអន្តរាយ។

និយាយច្រើនហើយពីការងារ ប្រយ័ត្នគ្រប់គ្រាគ្មានរសាយ
រៀបរាប់ជាកាព្យអធិប្បាយ ខ្លាចមានអន្តរាយដល់ការងារ។
គួរកុំធ្វើការច្របូកច្របល់ ដែលយើងមិនយល់បានល្អជា
គ្រប់គ្រងមិនបានគ្រប់ៗគ្រា ការនោះវេទនានាំស្មុគស្មាញ។
គួរធ្វើការណាយើងក្តាប់បាន ចេះបានយល់បានដឹងប្រមាណ
ទោះចំណេះតិចគួរធ្វើបាន កុំបីធ្វើស្មានព្រគេថា។
តទៅទៀតនេះមានវិធី ដែលគួរសំភីគួរសិក្សា
ធ្វើឲ្យសម្រេចនូវកិច្ចការ គួរពិចារណាដូចតទៅ។
ទីមួយគឺហៅថា **ឆន្ទះ** មានចិត្តស្មោះស្ម័គ្រប្រាថ្នាជ្រៅ
ពេញចិត្តការអ្វីច្បាស់ក្រឡៅ គ្មានចិត្តទោរទៅអ្វីទៀតឡើយ។
ក្រៅពីការនេះមិនធ្វើទេ ស៊ូខំឡើងទ្វេប្រឹងបង្ហើយ
ប្តូរផ្តាច់ដាច់ខាតត្រង់នេះហើយ មិនព្រមបណ្តោយរត់ចោលការ។
ទីពីរហៅថា **វិរិយៈ** ព្យាយាមអស់ថ្នាក់នឹងធ្វើការ
ប្រឹងទាំងកាយចិត្តទាំងបញ្ញា ប្រឹងឲ្យមានការរីកចំរើន។
ធ្វើការប្រយ័ត្នយ៉ាងហ្មត់ចត់ ធ្វើលើសកំណត់ឲ្យបានលឿន
ប្រឹងអស់ពីចិត្តអស់ពីថ្លើម ប្រឹងប្រែងសំបើមយកជោគជ័យ។
ទីបីគឺហៅថា **ចិត្តៈ** យកចិត្តទុកដាក់ខ្លាំងប្រពៃ
ចិត្តមិនខ្ជីខ្ជាសោះឡើយនៃ អ្វីៗលកលៃតាមបញ្ញា។
តាំងចិត្តដាច់ខាតមិនចុះចាញ់ ត្រូវតែបំពេញធ្វើកិច្ចការ
ទោះមានឧបសគ្គអ្វីក្តីណា ត្រូវតែចាត់ការធ្វើឲ្យបាន។
ទីបួនហៅថា **វិមំសា** ពុះពារធ្វើការយ៉ាងក្លាហាន
រកមធ្យោបាយដោះឲ្យបាន គន្លឹះប៉ុន្មានត្រូវបានដឹង។
វិធីទាំងបួនថ្លៃប្រសើរ យើងគួរតែដើរតាមក្បួននឹង
ដើរទៅដោយក្តីខំប្រឹតប្រឹង អាចនឹងបានដឹងឃើញជោគជ័យ។

តែប្រយ័ត្នត្រូវយកឈ្នះចិត្ត
ទោះបីប្រព្រឹត្តិការងារអ្វី
ត្រូវតែដាច់ខាតកុំប្រាស្រ័យ
កុំពាក់ព័ន្ធអីអបាយមុខ។
មានស្រីមានស្រាល្បែងពាលា
ថ្នាំញៀនយ៉ាម៉ាថ្នាំច្រើនមុខ
មានទាំងការដែលដើរលេងយប់
អ្វីៗសព្វគ្រប់នាំអន្តរាយ ។
ប្រសិនជាប់ចិត្តអបាយមុខ
ការងារគ្រប់មុខនឹងរំសាយ
លែងគិតការងារគួរឲ្យស្ដាយ
ច្បាស់ជាអន្តរាយគ្រប់ការងារ។
អធិប្បាយមកហើយនូវវិធី
របៀបរកស៊ីធ្វើការងារ
ដើម្បីចម្រើនប្រសើរជា
ត្រូវក្ដាប់ការងារឲ្យបានផង។
ឲ្យយល់បានច្បាស់ពីកិច្ចការ
ធ្វើទៅផ្លែផ្កាសមទំនង
តែបើពុំយល់កិច្ចការផង
លទ្ធផលគឺផ្សងព្រេងពេកហើយ។
ព្រោះធ្វើការងារច្របូកច្របល់
ធ្វើទាំងមិនយល់ដឹងអ្វីឡើយ
លទ្ធផលគឺពិតជានឹងខ្សោយ
គួរកុំធ្វើឡើយការដូច្នេះ។
បើសិនចៀសការច្របូកច្របល់
ធ្វើតែការយល់ដែលបានចេះ
លទ្ធផលនឹងកើតឡើងច្បាស់ចែស
លទ្ធផលល្អនេះកើតមង្គល។
សរុបទាំងបួនស្នួនបរិយាយ
លើកមកអធិប្បាយពីមង្គល
ចិញ្ចឹមពុកម៉ែថៃឲ្យដល់
ខ្វាយខ្វល់សង្គ្រោះកូនប្រពន្ធ។
ឲ្យបានរស់នៅល្អប្រសើរ
នៅក្នុងដំណើរនៃសង្គម
ដោយសមត្ថភាពខ្លួនដ៏ឧត្ដម
ធ្វើការហាក់ហំមានជោគជ័យ។
មិនធ្វើការណាច្របូកច្របល់
នាំឲ្យមានខ្វល់ខ្វះសិរី
ចាត់ចែងកិច្ចការឲ្យប្រពៃ
នាំសុខសួស្ដីស្រីមង្គល។

## ព្រះគាថាទី ៥

មាន ៤ មង្គល

**ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ**
**អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ។**

(បទសរភញ្ញ)

កិរិយាចេះបរិច្ចាគនូវទាន និងកិរិយាបានប្រព្រឹត្តិធម៌
មានចិត្តសប្បុរសល្អបវរ សង្គ្រោះដល់ពពួកញាតិមិត្រ។
មិនធ្វើការណាដែលមានទោស ដែលកេងយករស់គ្រោះជីវិត
ធ្វើតែការណាដែលសុចរិត នេះហើយគឺពិតជាមង្គល។

**សេចក្ដីសម្រាយ**

ការបរិច្ចាគទាន១ ការប្រព្រឹត្តិនូវធម៌១ សេចក្ដីសង្គ្រោះញាតិទាំងឡាយ១ ការងារទាំងឡាយដែលមិនមានទោស១ ទាំង៤ នេះជាមង្គលដ៏ឧត្តម។

**៥.១ ការបំពេញទាន** (ការឲ្យ ឬអំណោយ) មាន ពីរ ប្រភេទធំៗ

**ក.អាមិសទាន**

ការឲ្យទ្រព្យសម្បត្តិ និងបច្ច័យបួនផ្សេងៗ មាន ទានវត្ថុ១០យ៉ាង គឺៈ

បាយ ទឹក សំលៀកបំពាក់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេកទីសំណាក់អាស្រ័យ គ្រឿងប្រទីប (សម្រាប់ឧបត្ថម្ភផ្លូវកាយ)។

**ខ.ធម្មទាន**

ការឲ្យទានធម៌ បង្ហាញធម៌ បង្ហាញផ្លូវឲ្យអ្នកដទៃបាននូវសេចក្តីសុខ។ ធម្មទាននេះមានផលច្រើនជាងអាមិសទាន ព្រោះថា សត្វទាំងឡាយ ដែលមានសទ្ធាអាចធ្វើបុញ្ញកម្ម (បុណ្យ) ទាំងពួងបាន អាស្រ័យបានស្តាប់ធម៌ ជាហេតុដើម យល់ធម៌ យល់ផ្លូវហើយ ទើបមានសទ្ធា ឬមហាកុសល ចេះធ្វើបុណ្យទានជាក្រោយ មិនមែនមានអវិជ្ជា មហន្ធការ ងងឹតសូន្យសុង ហើយចេះធ្វើបុណ្យកើតនោះទេ។ ដូចព្រះអរហន្តទាំងឡាយ ដែលមានបញ្ញាច្រើន មានព្រះសារីបុត្រជាដើម លុះត្រាតែបានស្តាប់ធម៌ព្រះសាស្តា តាមរយៈព្រះអស្សជិហើយ ទើបសម្រេច សោតាបត្តិផលជាក្រោយ។ ដូច្នេះធម្មទានពិតជាឈ្នះអស់ទានទាំងពួង (ផ្លូវចិត្ត)។

**អានិសង្សនៃការឲ្យទានមាន៥ គឺ**

១. រមែងបានជាទីពេញចិត្ត ចូលចិត្តនៃជនដ៏ច្រើន

២. ជនជាសប្បុរសតែងរាប់រក

៣. កិត្តិយសល្បី ខ្ចរខ្ចារ

៤. នៅក្នុងទីណាៗ តែងក្លាហាន មិនអៀនប្រៀន ដាក់មុខសំយុងចុះ

៥. តែងបានសុគតិក្នុងបរលោក

**១៥. ទានញ្ញា** ការធ្វើទាន

**អត្ថបទកំណាព្យ** ( បទកាកគតិ )

| | | |
|---|---|---|
| បើសិនមានទ្រព្យ | ត្រូវតែខំអប់- | រំចិត្តឲ្យមាន |
| ចេតនាលះបង់ | ផ្ទង់ធ្វើនូវទាន | ហៅចិត្តល្អមាន |

សេចក្ដីសង្គ្រោះ។

ជួយទុរគតជន ជួយអ្នកខ្វះបុណ្យ ជួយជនរងគ្រោះ
ជួយអ្នកតោកយ៉ាក លំបាកទាំងនោះ ជួយដោយចិត្តស្មោះ
រំដោះញាតិមិត្ត។

រំដោះពីទុក្ខ ជួយឲ្យច្រើនមុខ មេត្តាពិតៗ
ជួយឲ្យនូវស្បៀង អាហារគាប់ចិត្ត ជួយទាំងញាតិជិត
រហូតដល់ឆ្ងាយ។

គ្នាមានវិបត្តិ គ្រោះវាមកកាត់ ធ្វើឲ្យអន្តរាយ
ខ្យល់ព្យុះបោកបក់ កំចាត់កំចាយ ផ្ដល់នូវមហន្តរាយ
ដោយអគ្គីភ័យ។

ឆេះផ្ទះសម្បែង ទ្រព្យធនក៏តែង ឆេះសល់តែដី
បើយើងមិនជួយ បាំងដៃធ្វើហី ឲ្យគ្នាពឹងអី
ភ័យណាស់លោកនេះ។

ព្រោះមិនជួយគ្នា ឲ្យគ្នាកំព្រា ចិត្តយើងសំគិះ
ដូចសត្វតិរច្ឆាន មិនដែលឃើញចេះ ចែកគ្នាឲ្យតេះ
ចំណីស៊ីសល់។

ដូច្នេះគួរគិត គួរមានគំនិត គួរគិតឲ្យយល់
ធ្វើបុណ្យធ្វើទាន ទាន់មានកុំឆ្ងល់ ប្រយ័ត្នវាដល់
ក្រតាំងស្ដាយក្រោយ។

បើចេះឲ្យទាន បុណ្យនឹងកើតមាន លោកនេះបណ្ដោយ
ត្រូវគេស្រឡាញ់ រាប់អានមុខក្រោយ រស់នៅល្ហែល្ហើយ
បានក្ដីសុខា។

មានញាតិមានមិត្ត ចុះចូលឆ្ងាយជិត ព្រោះតែកិរិយា
យើងចេះសន្ដោស មេត្តាករុណា សូម្បីវាចា

អ្នកណាក៏ស្អប់។

បើប្រព្រឹត្តិឆ្វេង ធ្វើឫកខែងរែង តែមិនចំណាប់
មិនស្គាល់បុណ្យទាន ចិត្តខ្មៅអួរអាប់ ជួនមិនទាំងរាប់
ឪពុកម្ដាយផង។

ហៅមិនធ្វើបុណ្យ មិនស្គាល់ទាំងគុណ ព្រះខ្លួនឯងផង
នេះហៅអភ័ព្វ មិនគាប់សោះហោង ញាតិមិត្តប្អូនបង
គេខ្ពើមរអើម។

ទោះមានយ៉ាងណា មានមិនបានការ មានតែគេឆ្អើម
គេមិនរាប់រក ព្រោះឫកសម្បើម រស់នៅល្បីឆ្នើម
ខាងមិនស្គាល់បុណ្យ។

មិនចេះឲ្យទាន ខ្លួនឯងអ្នកមាន មិនស្គាល់ទាំងគុណ
មានបានការអី មានតែទ្រព្យធន ដល់ស្លាប់ខំពុន
រែកយកទៅផង។

ធ្វើទានលោកថា ឲ្យដោយជ្រះថ្លា បានផលកន្លង
បន្ទុះពូជបុណ្យ បុណ្យល្អឥតហ្មង បុណ្យថ្លៃថ្លាផង
ឲ្យផលយ៉ាងខ្លាំង។

ព្រះពុទ្ធដីកាថា ឲ្យបាយទឹកណា គឺឲ្យកម្លាំង
ឯឲ្យសំពត់ ឲ្យគ្រឿងបិទបាំង ឲ្យគ្រឿងរារាំង
ការពារខ្លួនប្រាណ។

ឲ្យយានជំនិះ គឺឲ្យយានជិះ ទៅដោយក្សេមក្សាន្ត
ឯឲ្យពន្លឺ ឲ្យបំភ្លឺស្ថាន ភ្លឺភ្នែកគ្រប់ប្រាណ
កុំបីសង្ស័យ។

ឲ្យទីសំណាក់ ទីដេកទីដាក់ ថ្កើងថ្កានេះនៃ
ឲ្យថ្លៃលើសគេ ឲ្យអស់ទុក្ខភ័យ បរមសុខប្រពៃ

គឺឲ្យនូវធម៌។

នេះសុទ្ធជាទាន សទ្ធាដែលមាន ធ្វើទានតាមគួរ
មានទាំងអាមិស និងធម៌បវរ ឲ្យផលបន្ត
ទៅអនាគត។

បណ្ដានូវទាន ទាំងអាមិសមាន ធម្មទានផងនោះ
គឺថាធម្មទាន បើចាត់សង្គ្រោះ ផលប្រសើរហួស
លើសអាមិសទាន។

រីទានទាំងអស់ អានិសង្សខ្ពង់ខ្ពស់ មិនអាចប្រមាណ
ព្រោះឲ្យសុខគេ គេបានសុខសាន្ត អានិសង្សវិលថ្កាន
ឲ្យសុខយើងវិញ។

ឲ្យអ្វីដែលថ្លៃ បានវិញក៏ថ្លៃ ថ្លៃពេញចិត្តវិញ
ឲ្យរបស់ប្រសើរ បានប្រសើរវិញ ផលខ្លាំងចំណេញ
មិនខាតឡើយណា។

ឲ្យអ្វីប្រណីត អ្វីដែលគាប់ចិត្ត ជាទាននោះណា
បានប្រណីតវិញ ពិតជាសត្យា ផលក្រៃលែងណា
លើសពីឲ្យទាន។

បានរូបរាងល្អ វណ្ណៈបវរ សុខភាពក៏មាន
បានភោគសម្បត្តិ កិត្តិយសហំហាន អាយុថ្កើងថ្កាន
បានស្ថានសុខសួគ៌។

នេះហៅឲ្យទាន កម្លាំងផលមាន ដ៏ថ្លៃថ្លាល្អ
ផលហុចតាំងពី បច្ចុប្បន្នបន្ត ផលនេះវាហូរ
ទៅមិនដាច់ឡើយ។

**ប្រភេទនៃទាន** (អត្ថបទបន្ថែម)

| | | |
|---|---|---|
| រីការឲ្យទាន | សន្មតថាមាន | បីប្រភេទហើយ |
| ទីមួយអាមិស | ឲ្យប្រើបណ្តោយ | ទោះអ្វីក៏ដោយ |
| | គ្រាន់ឲ្យប្រើប្រាស់។ | |
| ទីពីរធម្មទាន | សទ្ធាដែលមាន | ខាងក្នុងចិត្តច្បាស់ |
| ឲ្យដំបូន្មាន | ទានធម្មសច្ចៈ | ឲ្យគេយល់ច្បាស់ |
| | បានសុខប្រាកដ។ | |
| ទីបីនោះណា | ពាក្យធ្លាប់ហៅថា | អភយទាននោះ |
| គឺចេះអត់ឱន | យោគយល់សង្គ្រោះ | មេត្តាដោយស្មោះ |
| | មិននាំទុក្ខភ័យ។ | |
| ឲ្យសព្វប្រការ | ឲ្យអ្វីនោះណា | ឲ្យទាំងអភ័យ |
| គឺមានន័យថា | ទោះយើងធ្វើអ្វី | កុំឲ្យគេភ័យ |
| | ឲ្យគេបានសុខ។ | |
| ន័យមួយទៀតថា | ល្អកាយវាចា | មានទាំងចិត្តស្មោះ |
| ទោះប្រព្រឹត្តិអ្វី | ឲ្យសុខទាំងអស់ | ភ័យមិនឲ្យសោះ |
| | ឲ្យគេបានរស់។ | |
| ម្យ៉ាងទៀតឲ្យទាន | សទ្ធាដែលមាន | ក្នុងចិត្តសប្បុរស |
| ចំណែកពាលវិញ | គេមិនធ្វើស្មោះ | ហៅទានសប្បុរស |
| | ឈ្មោះនេះត្រូវន័យ។ | |
| រីទានសប្បុរស | ទានដ៏ល្អនោះ | គឺទានប្រពៃ |
| ឲ្យដោយមេត្តា | ដោយបូជាក្តី | ជូនឲ្យក្នុងន័យ |
| | ករុណាសង្គ្រោះ។ | |
| ទានសប្បុរសណា | មានប្រាំប្រការ | បើរាប់មានឈ្មោះ |
| ទីមួយហៅទាន | ជាទានសង្គ្រោះ | ជួយដោយចិត្តស្មោះ |

ជួយយកអាសា។

ទីពីរនោះនៃ ឲ្យទានលកលែ ថ្ងៃតាមពេលា
កាលគ្នាត្រូវការ ឬរងវេទនា យើងក៏គាំពារ
ឲ្យដោយរូសរាន់។

ឯកបិនទាន សទ្ធាក៏មាន ធ្វើទានឲ្យទាន់
តាមកាលវេលា គ្រាកំណត់មុន គួរចេះយកបុណ្យ
ត្រូវកាលសព្វគ្រប់។

ទីបីនោះនៃ ទានដ៏ប្រពៃ គឺទានគោរព
មុននឹងធ្វើទាន ផ្ចិតផ្ចង់សព្វគ្រប់ បានល្អគ្រប់ដប់
ហើយក៏ធ្វើទាន។

មុនពេលធ្វើក្តី កំពុងធ្វើក្តី ធ្វើហើយចិត្តមាន
នូវក្តីចេតនា គោរពនូវទាន នេះពិតជាមាន
សេចក្តីជ្រះថ្លា។

ទីបួននោះណា ចិត្តស្អាតស្មោះថ្លា ឲ្យដោយសទ្ធា
ជឿថាធ្វើទាន គឺឲ្យសុខជា ដល់គេរាល់គ្នា
បានរស់ប្រពៃ។

ឲ្យគេបានសុខ ផលដែលល្អនោះ ត្រឡប់វិលវៃ
ខ្លួនក៏បានសុខ សុខនាលោកិយ អនាគតសុខក្រៃ
និស្ស័យល្អហើយ។

ទីប្រាំឲ្យទាន ចិត្តមិនបៀតបៀន អ្នកដទៃឡើយ
កុំគិតខ្លួនថា ឯងសម្បើមអីយ ទើបមានទ្រព្យឱ្យ
ដល់គេរាល់គ្នា។

មិនមើលងាយគេ មិនមានរិះរេ ថាអ្នកវេទនា
សុទ្ធតែពួកខ្ជិល តែទាំងអស់គ្នា ខ្លួនឯងទើបជា

អ្នកខ្លាំងដ៏ឆ្នើម។

គឺបានយល់ថា កម្មនោះរចនា ម្តងគេម្តងយើង
ម្តងសុខម្តងទុក្ខ ជួនកាលបានថ្កើង ជួនកាលវាឡើង
ជួនកាលវាចុះ។

## អានិសង្សនៃទាន

អានិសង្សនៃទាន ផលនោះនឹងបាន ផ្តល់មកវិញនូវ
សេចក្តីស្រឡាញ់ សុខសាន្តគ្រានទៅ គ្មានបារម្ភនៅ
មានក្តីទុក្ខា។

តែងបានសម្បត្តិ ភោគផលច្រើនក្តាត់ សម្រាប់អាត្មា
បានដោយសុចរិត ដោយធ្វើកិច្ចការ ការងារឯណា
សុទ្ធឱ្យផលល្អ។

បាននូវកេរ្តិ៍ឈ្មោះ ក្រអូបពីរោះ ឡើងខ្ពស់បវរ
បានជាសប្បុរស សព្វថ្ងៃចិត្តល្អ គេតែងគាំទ្រ
ព្រោះមានកុសល។

ពេលមរណកាល សតិភ្លឺច្រាល ស្មារតីឥតខ្វល់
មិនមានភ្លេចភ្លាំង បាំងដោយអកុសល តែងរលឹកដល់
នូវបុណ្យជាក់ស្តែង។

ហៅទានបារមី មង្គលសូត្រនេះនៃ ក៏ទ្រង់សម្តែង
បើចេះឱ្យទាន ទាននោះវាស្តែង ឱ្យសុខខែងរែង
មង្គលឧត្តម។

**៥.២ ធម្មចរិយា** ការប្រតិបត្តិធម៌

ការប្រតិបត្តិធម៌សំដៅលើកុសលកម្មបទ១០ គឺ:

ក.កម្មប្រកបដោយកាយមាន ៣

១. មិនសម្លាប់សត្វ

២. មិនលួចទ្រព្យអ្នកដទៃ

៣. មិនប្រព្រឹត្តិខុសក្នុងកាម

ខ.កម្មប្រកបដោយវាចាមាន ៤

១.មិននិយាយអាក្រក់ អសុរស ជេរប្រទេច

២.មិននិយាយចាក់ដោត ស៊កសៀត បំបែកបំបាក់

៣.មិននិយាយពាក្យឡេះឡោះ រោយរាយ ឥតខ្លឹមសារ

៤.មិននិយាយកុហក

គ.កម្មប្រកបដោយចិត្តមាន ៣

១. មិនគិតរំពៃល្មោភចង់បានទ្រព្យពីអ្នកដទៃ

២. មិនព្យាបាទអ្នកដទៃ

៣. មានសម្មាទិដ្ឋិយល់ត្រូវតាមសច្ចធម៌

អ្វីជាព្រះធម៌? អត្ថន័យមួយបែបភាសាបាលីថា: **បាបកេ អកុសលេ ធម្មេ ធុនាតីតិ ធម្មោ** សភាវៈណាដែលអាចកំចាត់បង់អំពើអាក្រក់លាមកចេញពីសន្តានចិត្ត របស់សត្វ សភាវៈនោះហៅថាព្រះធម៌។

**១៦. ធម្មចរិយា** ការប្រតិបត្តិធម៌

| **អត្ថបទកំណាព្យ** | (បទកាកគតិ) | |
|---|---|---|
| ហៅធម្មចរិយា | បើរៀនធម៌អាថ៌ | ពិចារណ៍ធម្មា |
| ឱ្យបានយល់ន័យ | ធម៌ព្រះភគវា | ធ្វើបដិបទា |
| | ដោយចេតនាស្មោះ។ | |
| អ្វីជាព្រះធម៌ | គឺកសាងល្អ | មិនធ្វើអាក្រក់ |

គំរង់លាមក ជាគ្រឿងកខ្វក់ ឱ្យបានដល់អស់
ចេញពីសន្តាន។

នៃសត្វទាំងឡាយ ឱ្យឈប់ខ្វល់ខ្វាយ ធ្វើបាបគ្រប់ប្រាណ
ផ្តាច់បាបឱ្យអស់ កុំធ្វើរំខាន ព្រោះបាបវាច្រាន
ឱ្យបានទុក្ខភ័យ។

គឺធម៌ព្រះពុទ្ធ ជាធម៌បរិសុទ្ធ មានសច្ចៈន័យ
ឱ្យបិទនូវបាប អកុសលចង្រៃ ឱ្យខំលកលៃ
សាងតែខាងល្អ។

បើសាងល្អហើយ បាបច្បាស់ជាស្បើយ ព្រោះកុសលធម៌
ធម៌ព្រះសម្ពុទ្ធ បើអនុវត្តល្អ ប្រយោជន៍បវរ
នាំក្តីសុខា។

ជាធម៌ធម្មជាតិ ដែលព្រះមុនីនាថ ស្តេចទ្រង់ទេសនា
ប្រាំបីម៉ឺនបួនពាន់ ធម្មក្ខ័ន្ធនោះណា សុទ្ធតែបានការ
នាំសុខប្រយោជន៍។

បានសុខទូទៅ សុខគ្រប់ទិសដៅ បានសុខរុងរោចន៍
បានប្រយោជន៍ល្អ មិននាំឱ្យខូច មិនមែនហិនហោច
ដោយសារព្រះធម៌។

មិនឱ្យអភិវឌ្ឍន៍ ដោយប្រឹងសង្កត់ ជាន់គេ ង ក
សន្សំក្តីសុខ ចំរាញ់យកមក៍ ឈរលើគំនរ
ទុក្ខអ្នកដទៃ។

ត្រូវឱ្យសុខគេ បានយើងផងដែរ បានសុខសិរី
មិនមែនរកសុខ ដោយធ្វើព្រៃផ្សៃ ធ្វើរឿងចង្រៃ
ឱ្យគេរាល់គ្នា។

គួរតែអនុវត្ត តាមន័យប្រាកដ នៃព្រះធម្មា

បើប្រតិបត្តិត្រូវ តាមនូវមាគ៌ា សួស្តីរមនា
បានទាំងយើងគេ។
យកសុខតែយើង ហើយប្រឌិតរឿង ទៅជាន់កគេ
នេះមិនមែនធម៌ ព្រះឈ្មះមារទេ ហៅថាធម៌រេ
ទៅតាមបក្ខពួក។
រេតាមសង្គម រេតាមនិយម រេតាមសក្តិយស
រេតាមប្រទេស ហៅថារេហួស រេរាំដូចពស់
រកឱកាសចឹក។
មិនប្រតិបត្តិធម៌ ព្រះធម៌ដ៏ល្អ ធម៌ព្រះធម្មិក
គិតតែមហិច្ឆតា ខ្លាំងក្លាសន្ធឹក ចេះត្រឹមតែនឹក
ចឹកយកប្រយោជន៍។
ក្នុងពុទ្ធសាសនា មានត្រៃសិក្ខា មាគ៌ារុងរោចន៍
ទុកឱ្យប្រតិបត្តិ កំចាត់ឱ្យខ្ជោច មិនឱ្យហិនហោច
ព្រោះអំពើបាប។
តែឧបនិស្ស័យ នៃសត្វទាំងឡាយ មិនព្រមបន្ទាប
ហើយធ្វើអាក្រក់ ឡើងខ្លាំងហួសហាប មិនព្រមបង្ក្រាប
ឱ្យអស់វេរា។
អ្នកនិស្ស័យល្អ ព្យាយាមសាទរ ដើរតាមធម្មា
ប្រតិបត្តិតាមធម៌ នៃព្រះភគវា ស្របតាមមាគ៌ា
នៃព្រះធម៌ពិត។
ខំប្រឹងប្រតិបត្តិ ព្យាយាមកំចាត់ អកុសលស្វាញស្វិត
ធ្វើអំពើល្អ តាមព្រះទ្រង់ឫទ្ធិ ដោយខំប្រព្រឹត្តិ
កុសលធម្មា។
អ្នកទាំងអស់នោះ ជាមនុស្សសប្បុរស កាន់ត្រៃសិក្ខា

ចិត្តលោកក៏ល្អ ល្អទាំងកិរិយា ល្អទាំងវាចា
ថ្លៃថ្លាវចី។

លោកមានមេត្តា ករុណាផងណា មុទិតាប្រពៃ
ឧបេក្ខាក៏ល្អ នឹងន់ហើៗ តែងអធ្យាស្រ័យ
ដល់គេរាល់គ្នា។

ជាមនុស្សទេវតា តែងតែរក្សា សីលបានល្អជា
មានធម៌ហិរិ ឱតប្បគ្រប់គ្រា មានធម្មមូលា
គឺធម៌កតញ្ញូ។

លោកមានខន្តី សោរច្ចៈផងនៃ មិនសូវគិតគូរ
មិនសូវអន់អាក់ ថ្នាំងថ្នាក់រអ៊ូ សព្វថ្ងៃអាសូរ
ឱ្យអភ័យគេ។

លោកតែងប្រយ័ត្ន មិនឱ្យភ្លេចបាត់ នូវសតិទេ
មិនមានប្រមាទ ប្រហែសធ្វេសទ្វេ សព្វថ្ងៃស្និទ្ធស្នេហ៍
តែនឹងព្រះធម៌។

នេះធម្មចរិយា ប្រតិបត្តិជ្រះថ្លា ល្អតាមព្រះធម៌
បានសុខសួស្តី សិរីបវរ បានមង្គលល្អ
នៅក្នុងជីវិត។

(**ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម្មោ សុចិណ្ណោ សុខមាវហាតិ ឯសានិសខ្យោ ធម្មេ សុចិណ្ណេ ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។** ធម៌រក្សាអ្នកដែលប្រព្រឹត្តិធម៌,ធម៌ដែលសន្សំមកក្នុងចិត្តនាំមកនូវសេចក្តីសុខ,អានិសង្សនៃការប្រតិបត្តិធម៌មិនបណ្តាលឲ្យធម្មចារីធ្លាក់ទៅក្នុងទុគតិឡើយ)។

### ៥.៣ ការសង្គ្រោះញាតិទាំងឡាយនោះ

បានដល់ការសង្គ្រោះទូទៅ ទាំងញាតិដែលជាប់ខ្សែស្រឡាយ និងមិនជាប់ខ្សែស្រឡាយ និយាយជារួមគឺ មនុស្ស សត្វទូទាំងពិភពលោក។

**១៧. ញាតកានញ្ច សង្គហោ** កិរិយាសង្គ្រោះញាតិទាំងឡាយ

**អត្ថបទកំណាព្យ** (បទកាកគតិ)

| | | |
|---|---|---|
| ការមានសទ្ធា | ជួយគ្នាគ្រប់គ្រា | ជួយញាតិប្អូនបង |
| ញាតិឆ្ងាយញាតិជិត | ញាតិជាប់របង | គឺមានបំណង |
| | ឱ្យគេបានសុខ។ | |
| នេះហៅចិត្តល្អ | មានសប្បុរសធម៌ | ស្ថិតនៅពីមុខ |
| មេត្តាករុណា | ថ្លៃថ្លាបរិសុទ្ធ | ជួយឲ្យបានសុខ |
| | ក្នុងន័យសង្គ្រោះ។ | |
| ឱ្យនេះឱ្យនោះ | ឱ្យដោយចិត្តស្មោះ | ព្រោះជួយរំលោះ |
| រំដោះភាពក្រ | លំបាកខ្លាំងហួស | នេះហៅមានឈ្មោះ |
| | យកអាសាគ្នា។ | |
| ខ្លះមានធុរៈ | គ្រោះថ្នាក់ឆេះផ្ទះ | ឆេះអស់ទ្រព្យា |
| ខ្លះត្រូវខ្យល់ព្យុះ | បោកបក់ពាធា | ឱ្យគ្នាវេទនា |
| | កើតក្តីអន្តរាយ។ | |
| ខ្លះក៏ពិការ | ទោះទៅទីណា | មិនបានស្រស់ស្រាយ |
| ពិការទាំងកូន | កំព្រាទាំងម្តាយ | ធ្វើអ្វីទាំងឡាយ |
| | មិនបានដូចចិត្ត។ | |
| ខ្វះនេះខ្វះនោះ | ខ្វះមិនចំពោះ | គឺខ្វះពិតៗ |
| ខ្វះបាយខ្វះទឹក | ខ្វះខាតទាំងព្រឹក | ជួនកាលបានព្រឹក |
| | នៅខ្វះដល់ល្ងាច។ | |
| គួរឱ្យអាសូរ | សព្វថ្ងៃតែងថ្ងូរ | ថ្ងូរព្រោះមិនអាច |

មិនអាចសុខបាន ឧបសគ្គវាកាច គាត់គ្មានអំណាច
យកឈ្នះវាបាន។
យើងកុំរអ៊ូ គួរតែតស៊ូ ជួយគ្នាកុំខាន
ជួយតាមសទ្ធា ទ្រព្យាយើងមាន ជួយឱ្យជាទាន
ជួយដោយសង្គ្រោះ។
បើយើងមិនជួយ ឱ្យសាសន៍ណាព្រួយ គេជួយជំនួស
បើយើងមិនជួយ ហាក់អាក្រក់ហួស មិនសមមានឈ្មោះ
ថាខ្មែរផងគ្នា។
នេះធម៌សង្គ្រោះ គឺជួយរំលោះ រំដោះទុក្ខគ្នា
ហៅថាចិត្តល្អ បវរសោភា ជួយគ្នាវេទនា
កំព្រាខ្លោចផ្សា។
ការជួយគ្នានេះ គឺថាហៅចេះ អនុវត្តធម្មា
ប្រតិបត្តិតាមធម៌ នៃព្រះភគវា ដោយក្ដីសទ្ធា
ជាអ្នកធ្វើបុណ្យ។
នឹងបាននូវផល បានដាក់បានដល់ នូវផលជាទុន
ធ្វើឱ្យអ្នកផង គោរពនូវគុណ ដែលយើងធ្វើបុណ្យ
ជួយដល់គ្នីគ្នា។
បានក្ដីសរសើរ ទោះធ្វើដំណើរ ទៅណាមកណា
អ្នកផងរាប់អាន ជួយយកអាសា ព្រោះតែកិរិយា
យើងល្អនឹងគេ។
បានបុណ្យកុសល អនាគតសោយផល បុណ្យសល់លើសទ្វេ
ល្អចិត្តល្អកាយ សប្បាយម្ល៉េះទេ ទ្រព្យមានហូរហៃ
ស្ថិតស្ថេរគង់វង្ស។

**កិច្ចការសង្គ្រោះញាតិមាន ៤ យ៉ាង ៖**

កិច្ចត្រូវសង្គ្រោះ បើរាប់ដោយឈ្មោះ មានបួនប្រការ
**ទីមួយគឺទាន** មានទ្រព្យឱ្យគ្នា របស់ភស្តុភារ
ចែកជូនញាតិផង។

ចែកដោយអាណិត យកអាសាពិត ញាតិមិត្របួនបង
ទាំងអ្នកដទៃ ហឫទ័យឥតឆ្គង ចែកក្នុងបំណង
អាណិតអាសូរ។

**ទីពីរគឺបិយ-** **វាចា**ល្អក្រៃ បញ្ចេញស័ព្ទសូរ
សៀងសមពីរោះ ជាពាក្យបន្ទូរ មិនមែនរអ៊ូ
ឱ្យកើតទោមនស្ស។

និយាយពាក្យល្អ ជាពាក្យស្មោះស មិនមានទ្រគោះ
មិនលើកតម្កើង ឱ្យខ្លួនខ្ពស់ហួស មិនអួតបញ្ឆោះ
គឺពោលគោរព។

**ទីបីនោះណា** **អត្ថចរិយា** កិរិយាល្អគ្រប់
ជួយឈឺឆ្អាលគ្នា គ្រាភពប្រសព្វ នឹងទុក្ខញឹកញាប់
ឬកើតរវល់។

មានទុក្ខធុរៈ ឈឺថ្កាត់តាមផ្ទះ មានកិច្ចអំពល់
ធ្វើបុណ្យធ្វើទាន ឬមានមង្គល សុទ្ធតែជួយខ្វល់
ជួយចាត់ជួយចែង។

**ទីបួន**នោះណា **សមានត្តតា** គឺចេះថ្លឹងថ្លែង
មិនតម្កើងខ្លួន មើលងាយញាតិឯង តែងតែកោតក្រែង
ដល់ញាតិដទៃ។

**អានិសង្សនៃការសង្គ្រោះញាតិ ៖**

ការដែលសង្គ្រោះ មានកិច្ចបួននោះ គឺកិច្ចប្រពៃ
សង្គ្រោះដល់ញាតិ បានជាប្រក្រតី ផលល្អវិលវៃ
បកឱ្យមកវិញ។

**ទី១ ញាតិមិត្រ** រាប់អានឆ្ងាយជិត ចូលចិត្តស្រឡាញ់
គេជួយការពារ គ្រប់វេលាវិញ រស់នៅពោរពេញ
ដោយក្ដីសុខសាន្ត។

**ទី២ កេរ្ដិ៍ឈ្មោះ** **ក្រអូបពីរោះ** ឧត្ដមថ្កើងថ្កាន
អ្នកផងតម្កើង លើកឡើងខ្ពស់បាន ក្នុងស្រុកភូមិឋាន
អ្នកណាក៏ស្គាល់។

**ទី៣ បានសុខ** **ចំរើនសព្វគ្រប់** មិនមានកង្វល់
បានក្ដីក្សេមក្សាន្ត សុខសាន្តមានដល់ សុខនេះឱ្យផល
នៅនាលោកិយ។

**ទី៤ មានទ្រព្យ** សន្ធឹកសន្ធាប់ អនេកច្រើនក្រៃ
ចេះតែរកបាន គ្មានខ្វះខាតអ្វី បានជាប្រក្រតី
មានសព្វមានគ្រប់។

**ទី៥ ស្លាប់ទៅ** **មានបុណ្យរុញទៅ** ដល់សុគតិភព
ស្ថានមនុស្សទេវតា បានសុខស្ងួគ៌សព្វ ព្រោះធ្លាប់សេពគប់
ធ្វើទានធ្វើបុណ្យ។

អធិប្បាយមកថា សង្គ្រោះកិរិយា ទំនុកបំរុង
ជួយអស់ញាតិមិត្រ ដែលគ្នាលិចលង់ យើងបានជួយស្រង់
ឱ្យគ្នារស់បាន។

នេះហៅចិត្តធម៌ ជាកិរិយាល្អ សែនល្អថ្កើងថ្កាន
បានសង្គ្រោះញាតិ ឱ្យគ្នាសុខសាន្ត យើងក៏នឹងបាន

សុខសាន្តឧត្តម។

**៥.៤ មិនធ្វើការណាដែលមានទោស**

ការងារណាដែលមិនមានទោសសំដៅយកការប្រតិបត្តិតាមមាគ៌ាទាំង៥ គឺ ៖

១.បាណាតិបាតា វេរមណី កិរិយាវៀរចាកការបៀតបៀនជីវិតសត្វ ។

២.អទិន្នាទានា វេរមណី កិរិយាវៀរចាកការកាន់យកទ្រព្យដែលមានម្ចាស់

៣.កាមេសុមិច្ឆាចារា វេរមណី កិរិយាវៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ

៤.មុសាវាទា វេរមណី កិរិយាវៀរចាកការពោលនូវពាក្យកុហក

៥.សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី កិរិយាវៀរចាកការផឹកនូវទឹកស្រវឹងនិងការវៀរចាកជំនួញ៥ ប្រការ ក៏ជាការមិនមានទោសដែរ។

**១៨. អនវជ្ជានិ កម្មានិ** មិនធ្វើការដែលមានទោស

**អត្ថបទកំណាព្យ** (បទកាកគតិ)

| | | |
|---|---|---|
| អ្វីការមានទោស? | ការងារនោះខុស | ខុសជាប្រក្រតី |
| ខុសខូចអាក្រក់ | ផ្តល់ក្តីចង្រៃ | ទង្វើអប្រិយ |
| | មិនប្រពៃធម៌។ | |
| ឱ្យគេលំបាក | ឱ្យគេតោកយ៉ាក | ឬឱ្យគេក្រ |
| ឱ្យគេរងទុក្ខ | ព្រោះតែរបរ | ដែលយើងរាប់រក |
| | រកខុសទំនង។ | |
| មិច្ឆាជីវៈ | ដែលគួរជឿជាក់ | ថាខុសមែនផង |
| ខុសពិតជាខុស | ប្រព្រឹត្តិឆ្កាំឆ្គង | ទោះបីប្អូនបង |
| | ក៏ជួយជៀលដែរ។ | |
| រកស៊ីឆបោក | រកស៊ីស្មោគគ្រោក | រកស៊ីហួរហែ |
| ជួញមនុស្សក្មេងស្រី | សម្ពីតាប៉ែ | ទាក់ទងដើរញ៉ែ |
| | គិតគួររកម៉ូយ។ | |
| អាក្រក់ខ្លាំងណាស់ | ទោះក្មេងទោះចាស់ | ឃើញសឹងបង្ហើយ |

គេមិនចង់ទុក ឱ្យនៅរស់ឡើយ រស់នៅនាំស៊យ
ដល់គេរាល់គ្នា។
គួរឱ្យអាសូរ ក្មេងស្រីយំថ្ងូរ ថ្ងូរចងវេរា
កូនគេកូនយើង មានទុក្ខដូចគ្នា គួរអាសូរគ្នា
មនុស្សម្នាយើងគេ។
ខ្លះជួញថ្នាំញៀន ខ្លះជួញអាភៀន ថ្នាំពុលផងដែរ
ផលិតថ្នាំពិស សុរាឬមេ- រ័យនោះផងដែរ
ព្រោះធ្វើខ្ញុំលុយ។
ឱ្យតែមានបាន ប្រឹងទាំងប្រថាន ប្រឹងទាំងប្រថុយ
សុខចិត្តខុសច្បាប់ ព្រោះតែរឿងលុយ តែជូនវាផ្ទុយ
ស៊ីព្រុយកន្ទេល។
ខ្លះដើរលួចឆក់ សព្វថ្ងៃហាត់ឆ្មក់ ឆក់តែជដែល
ឆក់តាមបេនឡាន គេចាប់បានក្រែល មុខតែជដែល
ថាគេមិនដឹង។
អួតឯងពូកែ ថាប៉ិនណាស់ដែរ អារឿងអញ្ចឹង
តែភ្លាត់ចំណាប់ គេចាប់ដៃរឹង អូសកទៅប្ដឹង
ប៉ូលីសដាក់ខ្នោះ។
សុទ្ធតែមិច្ឆា ជីវៈនោះណា រាប់មិនចេះអស់
តែអ្នកសប្បុរស ជៀសវាងបានស្មោះ មិនប្រព្រឹត្តិសោះ
អារឿងអស់ហ្នឹង។
គេមិនធ្វើខុស គេមិនមានទោស គ្មានអ្នកណាប្ដឹង
ព្រោះគេមិនធ្វើ អំពើបាបហ្នឹង សព្វថ្ងៃគេប្រឹង
ខំតែសាងល្អ។
ល្អកាយវាចា ចិត្តផងនោះណា តែងតែសាទរ

ប្រព្រឹត្តិតែល្អ ស្មោះសបវរ ចិត្តជាប់ដោយធម៌
ធម៌សសួស្តី។

**បញ្ជាក់ឡើងវិញពី មិច្ឆាជីវ** (ការចិញ្ចឹមជីវិតខុស)

ការដែលមានទោស ការនោះធ្វើខុស ឱ្យទោសជាក់ស្តែង
ឱ្យទុក្ខអ្នកផង ទាំងគេទាំងឯង ការខុសជាក់ស្តែង
មានដូចតទៅ ៖

**១- សស្ត្រវណិជ្ជា** ជួញសស្ត្រាវុធ

មួយជួញអាវុធ សម្រាប់ប្រយុទ្ធ សម្រាប់ប្រល័យ
ឬធ្វើអាវុធ ប្រើជាប្រក្រតី រិះរកកែច្នៃ
ជាយុទ្ធភ័ណ្ឌ។

**២- វិសវណិជ្ជា** ជួញថ្នាំពិស

ពីរជួញថ្នាំពិស ថ្នាំពុលផងនោះ សាហាវទាន់ហន់
ឬដាក់ថ្នាំពុល រហ័សរូសរាន់ ដាក់ជាបន្ទាន់
រហន់សម្លាប់។

**៣- មជ្ជវណិជ្ជា** ផលិតជួញស្រា

បីគ្រឿងស្រវឹង ថ្នាំញៀនញ៉ាមហ្នឹង ផឹកស៊ីអ៊ឹងអាប់
ផលិតលក់ដូរ រត់ពន្ធប្រញាប់ ហាក់ចង់សម្លាប់
តែមនុស្សគ្នាឯង។

**៤- សត្តវណិជ្ជា** ជួញមនុស្ស

បួនជួញទាំងមនុស្ស ជួញស្រីជួញប្រុស ជួនប៉ះគ្នាឯង
យកទៅលក់ដូរ ឱ្យបានជាល្បែង នៃពួកអ្នកលេង
ខាងកាមគុណស្និទ្ធ។

**៥- មំសវណិជ្ជា** ជួញសត្វមានជីវិត

ប្រាំជួញសត្វរស់ ដែលយើងចាំឈ្មោះ ថាមានជីវិត

យកទៅលក់ដូរ　　រកស៊ីតាមចិត្ត　　ឥតមានអាណិត
ខ្វះចិត្តសន្ដោស។
របរទាំងប្រាំ　　តាមយើងចំណាំ　　គឺពិតឱ្យទោស
មានខុសច្បាប់ធម៌　　មានខុសច្បាប់រដ្ឋ　　គឺពិតប្រាកដ
សន្មតថាខុស។

## ការងារមិនមានទោស ផ្ទុយនឹងការងារមានទោស

**អត្ថបទកំណាព្យ**　　(បទកាកគតិ)

ឯការត្រឹមត្រូវ　　មើលឃើញក្រឡៅ　　ថាមិនមានទោស
មិនខុសនឹងច្បាប់　　ដែលរដ្ឋសន្មត　　មិនខុសប្រាកដ
នឹងប្រពៃណី។
មិនខុសនឹងសីល　　ជំរះមន្ទិល　　សីលប្រាំប្រាំបី
មិនខុសនឹងធម៌　　ធម៌ព្រះជិនស្រី　　រស់នៅសព្វថ្ងៃ
គោរពគេឯង។

ប្រព្រឹត្តិតែល្អ　　ធ្វើទានបវរ　　ឱ្យគេឱ្យឯង
សង្គ្រោះញាតិមិត្ត　　ឬក៏រំអែង　　សាងអ្វីជាក់ស្ដែង
ជាសាធារណៈ។
មានធ្វើផ្លូវស្ពាន　　ចិត្តសប្បុរសមាន　　ឬជីកទាំងស្រះ
ឬជីកអណ្ដូង　　យកទឹកល្អល្អះ　　ជូនក៏ប្រទះ
សង់សាលារៀន។
សង់កុដិសាលា　　អគារសិក្សា　　ព្រោះចិត្តល្អមាន
ប្រគល់ជូនរដ្ឋ　　ជាសាធារណទាន　　ឬសទ្ធាមាន
ជូនដល់សាសនា។
បានស្គាល់ហើយថា　　គឺការងារណា　　ដែលមានទោសា

| | | |
|---|---|---|
| និងការងារល្អ | ធ្វើដោយជ្រះថ្លា | ប្រតិបត្តិកាលណា |
| | ឱ្យផលមិនខាន។ | |
| ព្រះពុទ្ធត្រាស់ថា | គួរធ្វើការណា | ដែលមិនរំខាន |
| ការមិនមានទោស | គួរធ្វើឱ្យបាន | នឹងបានសុខសាន្ត |
| | បាននូវមង្គល។ | |
| សរុបទាំងបួន | គាថាថែមស្ទួន | ឆ្លើយជាសេចក្តី |
| ទាំងទានចរិយា | ធម្មចរិយាក្តី | កិច្ចសង្គ្រោះនៃ |
| | ដល់ញាតកា។ | |
| ព្រមទាំងមិនធ្វើ | ការមិនប្រសើរ | ការមានទោសា |
| ប្រព្រឹត្តិអាក្រក់ | ក្រឡាប់ផ្កាប់ផ្ការ | អ្វីខុសតម្រា |
| | មិនល្អប្រពៃ។ | |
| គឺជាទង្វើ | សប្បុរសបានធ្វើ | ទាំងបួនករណី |
| ប្រតិបត្តិតែល្អ | ល្អដោយជោគជ័យ | ពិតជាសិរី |
| | មង្គលឧត្តម។ | |

## ព្រះគាថាទី ៦

មាន ៣ មង្គល

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**

**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ។**

(បទពាក្យ៧)

| | |
|---|---|
| កិរិយាមិនត្រេកអរក្នុងបាប | និងវៀរចាកបាបបានរឹងប៉ឹង |
| កិរិយាសង្រួមក្នុងទឹកស្រវឹង | គ្មានចេតនានឹងសេពសោយឡើយ។ |
| មិនមានប្រមាទក្នុងធម៌អាថ៌ | រស់នៅក្តីណាមិនបណ្តោយ |
| មិនឈ្លក់មិនភ្លេចសតិឡើយ | គឺបីនេះហើយជាមង្គល។ |

**សេចក្តីសម្រាយ**

ការមិនត្រេកអរក្នុងបាបនិងការវៀរចាកបាប១ សេចក្តីសង្រួមចាកការផឹកនូវទឹកស្រវឹង១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ១ ទាំង៣ នេះ ជាមង្គលដ៏ឧត្តម។

### ៦.១ ការមិនត្រេកអរក្នុងបាប និងវៀរចាកបាប

**អារតី** ប្រែថា មិនត្រេកអរនឹងបាប

**វិរតិ** ប្រែថា ការវៀរចាកបាប មាន៣ យ៉ាង

១.សម្បត្តិ វិរតិ :

ការវៀរចំពោះអ្វីដែលមកដល់ព្រមមិនទាន់ទាំងតាំងចិត្តផង គឺមិនទាន់បានសមាទានសីលទេ តែពិចារណាភ្លាមៗទៅយល់ថាពុំគួរធ្វើហើយក៏អាក់ខានមិនធ្វើនូវអំពើនោះតែម្តង។

២.**សមាទាន វិរតិ** ការវៀរបាបបានក្រោយពីបានសមាទានសីលហើយ

៣.**សមុច្ឆេទ វិរតិ** ការវៀរបាបបានដាច់ស្រឡះលែងវិលត្រឡប់ប្រព្រឹត្តិអាក្រក់វិញ។

### ១៩ - អារតី វិរតី បាបា កិរិយាមិនត្រេកអរនិងកិរិយាវៀរចាកបាប

**អត្ថបទកំណាព្យ** (បទកាកគតិ)

អ្វីៗអាក្រក់ អ្វីៗដែលខុស ប្រទូសគេឯង
ឱ្យទុក្ខអ្នកផង ឱ្យទុក្ខខ្លួនឯង អាក្រក់ជាក់ស្តែង
នោះហៅថាបាប។

បាបមានច្រើនយ៉ាង សូមលាតត្រដាង ខ្លះៗនូវបាប
សង្ខេបឱ្យតិច ដោយពាក្យសុភាព ដែលយើងបានរៀប
រៀងដូចតទៅ ៖

### ក- កាយទុច្ចរិត

មួយបាបផ្លូវកាយ គួរឱ្យសោកស្តាយ មានច្រើនពេកកួរ
វាយដំច្រំធាក់ ប្រព្រឹត្តិអាស្រូវ ជួនហួសដល់ទៅ
សម្លាប់ក៏មាន។

បៀតបៀនជីវិត ដល់អ្នកឆ្ងាយជិត គិតតែឱ្យបាន

លួចប្លន់ឆបោក យកទ្រព្យធនធាន ប្រព្រឹត្តិគ្រឿងញៀន
ផឹកទឹកស្រវឹង។
ខ្លួនសិស្សសាលា ក្រឡាប់ផ្កាប់ផ្ងារ បែបមិនសូវដឹង
ប្រព្រឹត្តិអាក្រក់ កខ្វក់ពេកហ្នឹង ហាក់ដូចគ្មានដឹង
ថាខ្លួនជាសិស្ស។
មិនគិតខំរៀន ប្រឹងតែបៀតបៀន ទន្រ្ទានខាងខុស
សព្វថ្ងៃចូលចិត្ត ដើរលេងកៀនកោះ ចិត្តសំដៅស្មោះ
ខាងអបាយមុខ។
ចេះស្រោចង់ស្រី ល្បែងពាលអប្រិយ យកជាត្រីមុខ
ប្រព្រឹត្តិខុសឆ្គង ល្បែងបីសព្វគ្រប់ ប៉ិនហើយប្រសប់
ខាងអំពើបាប។

## ខ- វចីទុច្ចរិត

ទីពីរវាចា ថាបាបនេះណា មានបួនប្រការ
និយាយកុហក ភរភូតមុសា មិនកាន់សត្យា
ចង់ថាឱ្យខុស។
និយាយអាក្រក់ សម្ដីគំរោះ គំរើយខ្លាំងនោះ
ប្រទេចផ្ដាសា ជេរហើយបញ្ជោះ ពោលពាក្យអសុរស
ផរុសវាចា។
និយាយអុជអាល ធ្វើឱ្យឈឺក្បាល ឈឺក្បាលខ្លាំងក្លា
និយាយចាក់ដោត ចាក់ដោតឈឺផ្សា កើតទោមនស្សា
បែកបាក់សាមគ្គី។
ពោលឥតប្រយោជន៍ ពោលតែអសោច គ្មានខ្មោចឡើយណា
ពោលតែផ្ដេសផ្ដាស សម្ផប្បលាបា ពោលឥតបានការ
ឥតប្រយោជន៍អ្វី។

ពោលហើយប្រឌិត រឿងមិនល្អពិត អាក្រក់អាក្រី
កំប្លុកកំប្លែង អាសអាភាសក្តី ប៉ិនខាងស្រដី
ចំអេសចំអាស។

### គ- មនោទុច្ចរិត

បីបាបផ្លូវចិត្ត ផ្តើមពីគំនិត ដែលពិតជាផ្តាស
ពិតជាអាក្រក់ យ៉ាងខ្លាំងហួសហាប ហើយក៏សង្វាត
ធ្វើបាបដោយចិត្ត។

### ១.អភិជ្ឈា

ចិត្តល្មោភលោភលន់ ចង់បានទ្រព្យធន អ្នកដទៃពិត
ក៏តាំងមានចិត្ត អាក្រក់គន់គិត កើតជាគំនិត
គិតយកទ្រព្យគេ។
ឃើញគេមានបាន ចិត្តចង់រំខាន នឹងរឿងផងគេ
ឃើញគេបានល្អ មិនសាទរទេ ក៏តាំងរិះរេ
គ្នាន់គ្នេរផ្ចាលផ្ចាញ់។
គឺអភិជ្ឈា ចិត្តមិនល្អជា ចិត្តកេងប្រវញ្ច
សំឡឹងទៅគេ កុំឱ្យដល់អញ ចិត្តម្ហូម៉ងក្នាញ់
ត្រឹមតែឯកឯង។

### ២.ព្យាបាទ

នេះព្យាបាទៈ កើតក្តីថ្នាំងថ្នាក់ អន់អាក់ម្នាក់ឯង
ហើយក៏គិតរក មធ្យោបាយស្វែង ដើម្បីសម្តែង
ឱ្យគេអន្តរាយ។
នេះហៅគុំគួន ឈ្នានីសមាំមួន គ្មានចិត្តរសាយ
ខឹងស្អប់ប្រទូស ឱ្យគេអន្តរាយ ខ្លួនឯងសប្បាយ
បើគេខាតបង់។

## ៣.មិច្ឆាទិដ្ឋិ

នេះចិត្តយល់ខុស យល់អ្វីៗនោះ ផ្ទុយនឹងបាបបុណ្យ
ថាបានគ្មានទេ បុណ្យគ្មានមកមុន គ្មានបាបគ្មានបុណ្យ
គ្មានជឿទាំងអស់។

គ្មានជឿទាំងគុណ មិនចេះធ្វើបុណ្យ មិនដឹងគុណសោះ
មិនយល់ថាគុណ មានក្នុងចិត្តស្មោះ ឯបុណ្យបាបនោះ
ក្នុងចិត្តដូចគ្នា។

មិនជឿព្រះធម៌ ជាធម៌ដ៏ល្អ មិនជឿពុទ្ធា
មិនជឿមានអ្នក ត្រាស់ដឹងធម្មា មិនជឿកម្មពៀរ
ថាឱ្យផលពិត។

បាបគឺធ្វើខុស ប្រព្រឹត្តិអាក្រក់ កាយវាចាចិត្ត
ផ្តល់ទុក្ខឱ្យគេ អាក្រក់ណាស់ពិត បើសិនផ្តេកផ្តិត
រឹតតែខុសខ្លាំង។

ឯពាក្យ **អារតី** ហើយនិង**វិរតី** មានន័យប្រឆាំង
ប្រឆាំងនឹងបាប គឺធ្វើល្អខ្លាំង មានចិត្តតតាំង
ប្រឆាំងអកុសល។

តទៅទៀតនេះ យើងនឹងត្រិះរិះ ផ្តល់នូវយោបល់
អារតី វិរតី កុំបីឡើយឆ្ងល់ អត្ថបទនឹងផ្តល់
មានដូចតទៅ។

## អត្ថបទបន្ថែម ការមិនខ្មាសអរ និងខ្លាចរចាកបាប

(បទសរភញ្ញ)

សប្បុរសស្រឡាញ់កុសលធម៌ និស្ស័យកើតមកស្អប់នូវបាប
កើតបានជាមនុស្សមិនចង់ឆ្អាប ខំលាងបន្សាបនូវវេរា។
យល់ឃើញប្រាកដនូវព្រះធម៌ ថាសត្វកើតមកតែងវេទនា
ទាំងរូបយើងគេក៏ដូចគ្នា ខ្លាចទុក្ខវេទនាតែរៀងខ្លួន។

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភយន្តិ មច្ចុនោ**
**អត្តានំ ឧបមំ កត្វា នហនេយ្យ នឃាតយេ។**

អ្នកណាក៏ខ្លាចនូវអាជ្ញា គ្រប់ទណ្ឌកម្មណាគ្មានគេស្នេហ៍
ខ្លាចស្លាប់ចំបងធំជាងគេ ទោះរូបយើងគេក៏ដូចគ្នា។
ដូច្នេះគួរតែកុំព្យាបាទ សង្ឃាតបៀតបៀនដល់គ្នីគ្នា
សព្វសត្វទាំងឡាយតែងប្រាថ្នា ចង់បានសុខាតែរៀងខ្លួន។
គេក៏ចង់សុខយើងក៏ចង់ គួរតែផ្ចិតផ្ចង់ចិត្តមាំមួន
ធ្វើអំពើល្អតែរៀងខ្លួន កុំបីរុកគួនឱ្យទុក្ខគ្នា។

**ហិរិឱតប្ប សម្បន្នា សុកធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេ។**

ប្រែថាអ្នកខ្មាស់អំពើបាប និងខ្លាចនូវបាបខ្លាំងអស្ចារ្យ
កាន់ធម៌សប្បុរសសល្អថ្លា អ្នកប្រាជ្ញលោកថាមានទេវធម៌។
គឺជាមនុស្សចិត្តទេវតា រស់នៅក្តីណាធ្វើតែល្អ
មិនប្រព្រឹត្តិអកុសលធម៌ សព្វថ្ងៃសាទរតែនឹងបុណ្យ។
មិនខ្មាសអរទេអំពើបាប និងរៀរចាកបាបមិនរែកពុន
ទោះបាបវាផ្តល់ឱ្យបានទុន លុយកាក់លើសលន់ក៏ពុំយក។
សុខចិត្តគាំទ្រអំពើល្អ ទោះលាភយសមកមានគគោក

មិនខ្ចីទទួលព្រោះស្មោគគ្រោក វាផ្តល់ទុក្ខសោកដល់គេឯង។
មិនទទួលទេសុខផ្ទាល់ខ្លួន ដែលវារុកគួនមិនកោតក្រែង
ដល់អ្នកដទៃឬញាតិឯង ស៊ូប្តូរត្រាំត្រែងទ្រាំលំបាក។
បើលាភយសនោះបានដោយធម៌ ព្យាយាមមកល្អមិនកំសាក
ព្រមទទួលយកដោយស្មោះស្ម័គ្រ ព្រោះមិនថ្នាំងថ្នាក់ក្នុងចិន្តា។
សព្វថ្ងៃគាំទ្រសច្ចៈធម៌ យុត្តិធម៌បវរហើយជ្រះថ្លា
ប្រតិបត្តិតាមធម៌ព្រះសាស្តា ធ្វើតែកិច្ចការដែលជាបុណ្យ។
នេះហើយមិនត្រេកអរក្នុងបាប និងវៀរចាកបាបបានជាមុន
ព្រោះចិត្តផ្តងជាប់តែនឹងបុណ្យ រក្សានូវគុណសេចក្តីល្អ។
មិនគាំទ្រទេអំពើបាប ធុំក្លិនតែឆ្អាបមិនយុត្តិធម៌
ចង់សុខខ្លួនឯងតែបង្ក ឱ្យកើតវឹកវរដល់គេឯង។
គាំទ្រតែការដ៏ប្រសើរ ដែលជាដំណើរល្អជាក់ស្តែង
ធ្វើទៅឱ្យសុខដល់គេឯង អ្នកផងសម្តែងចិត្តស្មោះស្ម័គ្រ។
ធ្វើតែអំពើសុខប្រយោជន៍ មិននាំហិនហោចអសោចជាក់
ធ្វើតែល្អៗគ្រប់ខណៈ រាល់ថ្ងៃជឿជាក់លើព្រះធម៌។
ព្រះធម៌រក្សាអ្នកប្រតិបត្តិ ព្រោះបានកំចាត់អកុសលធម៌
មិនបង្ករឿងល្អក់កករ នាំឱ្យវីវរឃ្លាតពីសុខ ។
អ្នកប្រព្រឹត្តិធម៌ធ្វើតែល្អ ដោយមិនត្រេកអរនឹងបាបសោះ
ចិត្តចង់វៀរចាកបាបទាំងអស់ ខំអប់រំស្មោះសាងកុសល។
តែងបានដល់នូវសុខសិរី សួស្តីប្រពៃគ្រប់មណ្ឌល
ដូចព្រះដីកាព្រះទសពល ជាឧត្តមមង្គលប្រសើរហោង។

## ៦.២ សង្រួមចាកការផឹកទឹកស្រវឹង

ទឹកស្រវឹង មានសុរា និងមេរ័យ ដែលនាំឲ្យអ្នកប្រព្រឹត្តិមានទោស៦ យ៉ាងគឺ:

| | |
|---|---|
| ១.វិនាសទ្រព្យទាន់ហន់ | ៤.នាំឲ្យអសោចកេរ្តិ៍ឈ្មោះ |
| ២.នាំបង្កជម្លោះ | ៥.ធ្វើឲ្យអាប់បញ្ញាស្មារតី ជួនកាលឆ្កួត |
| ៣.នាំឲ្យកើតរោគ | ៦.បាត់ចិត្តស្មោះ |

ស្រានាំខូចប្រាណ ស្រាហ៊ានហួសឋាន ស្រាបានខូចឈ្មោះ
ស្រានាំហិនទ្រព្យ ស្រាធ្លាប់ឲ្យឈ្លោះ ស្រាបាត់ចិត្តស្មោះ
ស្រាកោះចូលគុក។ (គឹម ងួនជា)

**២០. មជ្ជបានា ច សញ្ញមោ** សេចក្តីសង្រួមចាក(មិនផឹក)ទឹកស្រវឹង

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

វីទឹកស្រវឹងនោះឯងណា ឥទ្ធិពលខ្លាំងក្លាដូចថ្នាំញៀន
ដូច**ហេរូអ៊ីន**កុំសាករៀន តែដល់វាញៀនផ្តាច់មិនបាន។
និយាយពីស្រាអួតនោះហួស អួតក្នុងទូរទស្សន៍ថាសំខាន់
បង្កើនសុខភាពល្អមាំទាំ រឿងពិតមិនហំគឺហិនហោច។
គំនិតអស់នេះនាំយល់ខុស គំនិតប្រទូសនាំអសោច
ផឹកស៊ីច្រើនទៅនាំហិនហោច នាំឱ្យអាសោចខ្មែរគេឯង។
វាប្រឆាំងនឹងកុសលធម៌ ស្រវឹងឯកហើយសម្តែង
ផឹកស៊ីច្រើនទៅលែងចេះក្រែង ចេះតែសម្តែងក្តីអាក្រក់។
លែងដឹងទាំងខុសលែងដឹងត្រូវ ប្រព្រឹត្តិអាស្រូវរឿងកខ្វក់
បង្កបញ្ហាកករល្អក់ នាំឱ្យខ្វល់ខ្វក់ដល់គ្រួសារ។
ស្រវឹងជ្រុះខោជ្រុះទាំងអាវ សម្តីសាហាវឫកដូចខ្លា
តែរូបទោរទន់ដេកដួលផ្ងារ ឫកពារបាតផ្សារតែរាល់ថ្ងៃ។
ស្រែកជេរឡូឡាឡប់ក្នុងខ្លួន អ្នកណាដេកពួនមិនបានអី
គេដៀលគេត្មះរៀងរាល់ថ្ងៃ ឫកពារចង្រៃវានាំថោក។
នាំកើតទំនាស់ក្នុងគ្រួសារ បង្កើតហិង្សាយ៉ាងស្មោកគ្រោក

ឱ្យកូនប្រពន្ធមានវិប្បយោគ ព្រោះខ្លួនវាថោកដោយសារស្រា។
វានាំខូចកេរ្តិ៍ខូចទាំងឈ្មោះ ខូចកិត្តិយសព្រោះសុរា
ខូចអស់ទាំងទ្រព្យខូចថវិកា ខូចសុខភាពណាជាប្រក្រតី។
សុរាម្យ៉ាងទៀតចាត់ជាឃ្នាប បំផ្លាញសុខភាពរាល់ៗថ្ងៃ
រលាកក្រពះថ្លើមនោះនៃ ជួនកាលចង្រៃខូចសតិ។
កើតទាំងរោគសរសៃប្រសាទ បើមិនសង្វាតខំរិះរេ
ផ្ដាច់ស្រាឱ្យបានឆាប់នោះទេ វានឹងក្លាយប្រែឆ្កួតវង្វេង។
ស្រាវាចង្រៃខ្លាំងច្រើនណាស់ យកស្រាធ្វើម្ចាស់ស្រឡះធេង
លែងស្គាល់ប្រពន្ធឬកូនឯង មិនកោតមិនក្រែងភ្លេចនាទី។
ភ្លេចខ្លួនជាមនុស្សឬជាប្រុស ដែលត្រូវប្រឹងស្មុះត្រូវសំភី
ព្យាយាមធ្វើការសព្វញាំញី មានតួនាទីរ៉ាប់គ្រួសារ។
រវល់បណ្ដែតឬបណ្ដោយ លែងដឹងមុខក្រោយឥតបានការ
គ្រួសារដុនដាបខ្លាំងខ្លោចផ្សា ព្រោះតែចរិយាវាមិនខ្មេះ។
ព្រោះតែរវល់ញៀនសុរា ខំពីតបីតវាដល់តម្រិះ
ផលវាឱ្យវិញយ៉ាងសំគិះ រស់នៅមិនខ្មេះឬមិនខ្មោច។
មិនខូចតែម្នាក់ឯងទេណា ខូចទាំងគ្រួសារសែនអនោច
អាណិតកូនចៅគ្នាផ្សាខ្លោច វានាំឱ្យខូចខ្មែរផងគ្នា។
នេះគឺវិបត្តិនៃសុរា មានច្រើនណាស់ណាស្លេះពណ៌នា
ឱ្យទុក្ខឱ្យទោសឱ្យវេទនា ព្រោះតែជាប់ពៀរនឹងសុរា។
ដូច្នេះតទៅអនាគត បើនៅសន្មតលើកសុរា
តម្កល់តម្កើងអស់ជាតិស្រា សង្គមខេមរានឹងថយថោក។
ត្រូវតែកុំលើកកុំតម្កើង បង្អាប់វាឡើងថាស្មោកគ្រោក
កុំសាកកុំលវានាំថោក វាផ្ដល់ក្ដីសោកសង្រេងធំ។
កុំបីផ្ដួចផ្ដើមនូវគំនិត បបួលគ្នាគិតស្រាជាធំ

កុំបបួលក្មេងឱ្យលេងលាំ ឬក៏បង្ខំលស្រាឡើយ។
ត្រូវពន្យល់គ្នាថាជាតិស្រា ទាំងថ្នាំញៀនណាអស់នេះហើយ
ឱ្យទុក្ខឱ្យទោសខ្លាំងឥតស្បើយ ការពារឱ្យហើយកុំសាកវា។
វិបត្តិធំណាស់ព្រោះសុរា ឥទ្ធិពលខ្លាំងក្លានាំវេទនា
សប្បុរសតែងឆ្លាតយកឈ្នះវា មិនឱ្យជាប់ពៀរនឹងវាឡើយ។
សិក្ខាបទទីប្រាំនៃសីលប្រាំ ឱ្យយើងចំណាំចាំដៃរហើយ
ឱ្យចៀសផឹកស្រាកុំបណ្ដោយ ក្រែងវាញៀនហើយនាំហិនហោច។
**មជ្ជបាណា ច សញ្ញមោ** សប្បុរសចាក់សោឈ្នះស្រាហើយ
សង្រួមមិនផឹកដាច់ខាតឡើយ នេះហើយហៅថាមង្គលល្អ។

## ផលនៃការមិនសេពស្រា

ប្រសិនមិនសេពទឹកស្រវឹង ថ្នាំញៀនញ៉ាមហ្នឹងបានដោយល្អ
ផលនឹងផ្ដល់ឱ្យយ៉ាងបវរ អាចឱ្យបានល្អជាទូទៅ ៖
មិនមានខ្វះខ្វាយនូវប្រាក់កាស យកទៅប្រើប្រាស់ទិញស្រាក្ដៅ
មិនខាតទាំងពេលវេលាទៅ ណាត់គ្នាសំដៅទៅរកតៀម។
មិនបណ្ដាលឱ្យវិវាទគ្នា រស់នៅសាមគ្គាសាមគ្គីបាន
បានក្ដីក្សេមក្សាន្តក្នុងភូមិស្ថាន គ្រួសារសុខសាន្តគ្មានហិង្សា។
មិនមានកើតរោគព្រោះសុរា ព្រោះមិនសេពស្រាមិននឹកនា
មិនខូចក្រពះគ្រិនថ្លើមណា សុខភាពស្រស់ថ្លាជាធម្មតា។
មិនមានបាត់បង់កិត្តិយស ឱ្យបានខូចឈ្មោះដោយសារស្រា
ព្រោះមិនសេពគប់មកហើយណា មិនយកជាការជាតិស្រាឡើយ។
តែងតែបាននូវសតិល្អ មិនវង្វេងវរវីកសោះឡើយ
ធ្វើអ្វីមុតមាំច្បាស់លាស់ហើយ ធ្វើតាមបណ្ដោយតែកុសល។
មានទាំងបញ្ញាឆ្លាតវាងវៃ គិតគូរអ្វីៗនៅតែយល់
យល់នូវធម៌អាថ៌ព្រះទសពល កំចាត់ក្ដីឆ្ងល់ គឺ កង្ខា។

តែងតែមានចិត្តល្អទូលាយ មិនចេះមើលងាយអ្នកឯណា
មិនចេះប្រណែនគេរាល់គ្នា ចិត្តតែងល្អជាៗធម្មតា។
មិនមានវង្វេងក្នុងពេលចាស់ ព្រោះចិត្តនោះច្បាស់នឹងធម្មា
ដល់ពេលជិតស្លាប់ល្អដូចគ្នា តែងបានសុខនាអនាគត។
នេះ**មជ្ជបាណា ច សញ្ញមោ** ប្រតិបត្តិរៀងមកយ៉ាងហ្មត់ចត់
សុរាមិនសេពពិតប្រាកដ ព្រះពុទ្ធកំណត់ថាមង្គល។

## ៦.៣ ការមិនប្រមាទក្នុងធម៌ទាំងឡាយ

ប្រហែសក្នុងការប្រព្រឹត្តិធ្វើនូវអំពើជាកុសល និងអកុសល ប្រយ័ត្នបិទអកុសល ហើយប្រព្រឹត្តិតែអំពើជាកុសលតែម្យ៉ាង ក្នុងន័យនេះ កុំឲ្យយល់ថា បាបនេះតូចតាចទេ មិនអីទេ ធ្វើខ្លះៗក៏មិនអីដែរ ធ្វើខ្លះសិនទៅដើម្បីសម្រួលឆាកជីវិត ឲ្យបានសម្បូណ៌សប្បាយ ចាំចាស់សិន សុំផ្តាច់បាបទាំងអស់តែម្តង ឬយល់ថាបុណ្យនេះខ្សោយទេ មិនទាន់ធ្វើទេ (មិនទាន់ឲ្យទាន រក្សាសីល) ចាំពេលក្រោយ ឬចាស់បន្តិចទៀត ចាំធ្វើបុណ្យធំៗតែម្តង។

បណ្តាធម៌ទាំងពួងកើតឡើង ដោយមានធម៌មិនធ្វេសប្រហែសជាមូល ធម៌មិនធ្វេសប្រហែសជាកំពូលនៃធម៌ទាំងពួង។

## ២១. **អប្បមាទោ ច ធម្មេសុ** សេចក្តីមិនប្រមាទក្នុងធម៌

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

**អប្បមាទោ ច ធម្មេសុ** ប្រតិបត្តិឈ្មុលឈ្មុសនឹងព្រះធម៌
គោរពអនុវត្តបានយ៉ាងល្អ ដោយក្តីសាទរមិនប្រហែស។
ដឹងច្បាស់នូវគុណនៃព្រះធម៌ ថ្លៃថ្លាបវរព្រះធម៌នេះ
ថាមានប្រយោជន៍ខ្លាំងក្លាម្ល៉េះ និយ្យានិកធម៌នេះធម៌ព្រះពុទ្ធ។
ធម៌អាចស្រោចស្រង់សត្វនិករ ប្រមូលទៅរកស្ថានវិសុទ្ធ
ជាធម៌សច្ចៈហើយបរិសុទ្ធ នាំឱ្យបានសុខនិងប្រយោជន៍។

ហេតុនេះសប្បុរសដែលជ្រះថ្លា ប្រតិបត្តិធម៌អាចបានរុងរោចន៍
ព្យាយាមសន្សំយកប្រយោជន៍ កុំឱ្យខាតខូចពេលវេលា។
យល់ថាឱកាសតិចខ្លាំងណាស់ ប្រឹងរៀនរូតរះព្រះធម្មា
ប្រតិបត្តិហ្មត់ចត់បានល្អជា តាមព្រះភគវាទូន្មានថា។

**(យេ កេចិ កុសលា ធម្មា សព្វេតេ អប្បមាទមូលកា**
**អប្បមាទសមោសរណា អប្បមាទោ (តេសំ) អគ្គមក្ខាយតិ។**

បណ្ដាកុសលធម៌ទាំងឡាយមានអប្បមាទជាឫសគល់ សេចក្ដីមិនប្រហែសជាបង្អែកជាកំពូលនៃកុសលទាំងពួង)។

អប្បមាទប្រែថាមិនប្រហែស ជាហេតុនាំចេះសាងកុសល
អប្បមាទជាឫសឬជាគល់ ជាកំពូលកុសលផងទាំងឡាយ។
បើសិនជាធ្វេសប្រហែសដែរ មិនគិតដល់ទេនាំឱ្យស្ដាយ
បណ្ដែតបណ្ដោយមិនខ្វល់ខ្វាយ អកុសលទាំងឡាយនឹងជ្រៀតបាន។
កិច្ចប្រតិបត្តិល្អក៏រាថយ បណ្ដោយៗមិនប្រឹងប្រាណ
អកុសលក៏ឡើងមករំខាន ផលអវសានច្រានទៅយូរ (និព្វាន)។
ឫមួយខូចការខុសតែម្ដង ធ្វេសប្រហែសផងលែងគិតគូរ
ទ្រុស្ដសីលទ្រុស្ដធម៌មុខរមូ បែរទៅជាប្ដូរសន្សំបាប។
វិតតែនាំទុក្ខទោសចង្រៃ ពុំមាននិស្ស័យប្រល័យបាប
បានល្អខ្លះហើយប្រែជាឆ្អាប ក្រឡាស់ខ្វះខាតកុសលធម៌។
នេះក៏ហៅថាប្រហែសដែរ ចិត្តនោះវារេមិនហ្នឹងនរ
ម្ដងបានធ្វើល្អហើយប្រែយក៍ អាក្រក់វិញមកជំនួសល្អ។
ជួនកាលគិតថាមិនអីទេ បាបនោះតូចទេហើយត្រដរ
សម្ងំយកលាភមួយដុំមក៍ បាបតូចវាកកាន់តែច្រើន។
នេះក៏ហៅបានថាប្រហែស ឱ្យបាបដុះច្រេះកាន់តែកើន
មិនទាន់ឱ្យផលចេះតែផ្ដើន បាបក៏ឡើងច្រើនតាមល្បឿនសាង។

នេះសុទ្ធតែជាការប្រហែស គឺជាតម្រិះដែលកសាង
ភ្លេចភ្លាំងភ្លេចខ្លួនដូចមានអាង ចេះតែឡើងចាងភ្លេចសតិ។
មិនគិតថាកម្មខ្លាំងអស្ចារ្យ មានឫទ្ធិយ៉ាងណាក៏មិនឈ្នះ
កម្មខ្លាំងលើសគេតែងប្រលះ ប្រឡេះយកឈ្នះគ្រប់សព្វសត្វ។

( **នត្ថិ កម្មំ សមំ ពលំ** គ្មានកម្លាំងអ្វីស្មើកម្លាំងកម្ម )

**អធិប្បាយពីការប្រមាទ** (សេចក្ដីធ្វេសប្រហែស)

(បទកាកគតិ)

ឯការប្រមាទ ផ្ទុយនឹងអប្បមាទ មានច្រើនប្រការ
គួរតែបរិយាយ បើមិនពិស្ដារ ក៏គួរតែថា
ជាគោលសេចក្ដី។

**ក- ប្រមាទពេលវេលា**

មួយគឺប្រមាទ មិនគិតខ្លាចខាត ពេលវេលានៃ
បណ្ដែតបណ្ដោយ ធ្វើខ្សោយៗដៃ ធ្វើការអ្វីៗ
មិនមានម៉ឺងម៉ាត់។

ច្រើនឆ្លៀតឱកាស លំហែកាយណាស់ មិនសូវប្រយ័ត្ន
ដើរលេងយប់ថ្ងៃ សប្បាយអុងអាត់ មិនបានជាចាត់
ថាពេលវាថ្លៃ។

**ខ- ប្រមាទក្នុងវ័យ**

ទីពីរនោះណា ប្រមាទទៀតថា ប្រមាទក្នុងវ័យ
ថាខ្លួននៅក្មេង អាយុនៅខ្ចី កុំទាន់គិតអី
ចាំដល់វ័យចាស់។

មិនខំរៀនសូត្រ ធ្វើការមិនស្រួត មិនប្រឹងរូតរះ
ធ្វើការលេងៗ យល់ថាក្មេងណាស់ ចាំដល់ខ្លួនចាស់

ទើបខំមែនទែន។

**គ-ប្រមាទក្នុងការងារ**

ប្រមាទទីបី ប្រមាទនេះនែ ធ្វេសនឹងការងារ
មិនទាន់ចង់ទេ ប្រកបកិច្ចការ ចង់បានហ៊ឺហា
ទំនេរខ្លួនជាង។

ខ្ជិលធ្វើកិច្ចការ សព្វគ្រប់ផងណា ទោះធ្វើមិនទៀង
មិនមានប្រឹងប្រែង ធ្វើមិនប្រិតប្រៀង ហត់នឿយតែងរាង
លែងចង់ធ្វើទៀត។

ទោះបីបានធ្វើ ធ្វើទាំងល្ងើល្ងើ ធ្វើដោយចោលម្សៀត
ធ្វើយករួចខ្លួន គ្រវីសគ្រវាស ធ្វើទាំងមិនឈ្លាស
ឆ្លាតសោះឡើយណា។

**ឃ- ប្រមាទក្នុងការសិក្សា**

ទីបួនប្រមាទ មិនមានសង្វាត ក្នុងការសិក្សា
គិតតែដើរលេង ស៊ីចាយហ៊ឺហា អស់ប្រាក់ដុល្លារ
របស់ម៉ែឪ។

ខ្ជិលស្ដាប់ខ្ជិលសួរ ខ្ជិលធ្វើសំណួរ សរសេរអ្វីៗ
រៀនឱ្យតែរួច មិនសូវគិតអី ទោះមិនយល់ក្ដី
ក៏ធ្វើព្រងើយ។

**ង- ប្រមាទក្នុងធម៌**

ទីប្រាំនោះនែ ប្រមាទនេះស្ដី ពីប្រមាទធម៌
មិនខំប្រតិបត្តិ នូវអំពើល្អ ធ្វើតាមព្រះធម៌
នៃព្រះសាស្ដា។

ឬក៏ប្រមាទ ព្រះធម៌ល្អស្អាត នៃព្រះពុទ្ធា
ថាគ្មានប្រយោជន៍ មិនអាចប្រើការ យិតយោងអាត្មា

ឱ្យបានសុខា។

| | | |
|---|---|---|
| យល់ខុសទៀតថា | ព្រះធម៌នោះណា | មានត្រៃសិក្ខា |
| សម្រាប់មនុស្សចាស់ | ចំណាស់ទេណា | ខ្លួនមិនត្រូវការ |
| | ព្រោះនៅវ័យក្មេង។ | |
| នេះគឺប្រមាទ | ប្រហែសខូចខាត | ខូចខ្លាំងជាក់ស្តែង |
| បើផ្ទុយទៅវិញ | ប៉ិនចេះសម្តែង | អប្បមាទវិញឯង |
| | នឹងបានផលល្អ។ | |
| អប្បមាទក្នុងធម៌ | ថ្លៃថ្លាបវរ | គឺតាំងចិត្តល្អ |
| សព្វថ្ងៃខំសាង | តែកុសលធម៌ | នឹងបានផលល្អ |
| | សុខសាន្តប្រសើរ។ | |

**អត្ថបទកំណាព្យបន្ថែម** (បទសរភញ្ញ)

| | |
|---|---|
| នេះជាកំណាព្យកាព្យអធិប្បាយ | ដែលអភិប្រាយពីអប្បមាទ |
| បើអប្បមាទពិតជាស្អាត | ប្រែជាប្រមាទពិតជាស្អុយ។ |
| ស្អុយដូចបានរៀបរាប់មកហើយ | បើសិនបណ្តោយធ្វើខ្សុយៗ |
| កុសលនឹងជ្រុះបាត់រពុយ | អកុសលដុះព្រុយឡើងច្រូងច្រាង។ |
| គួរកាត់អកុសលដោយអប្បមាទ | ឥទ្ធិពលធម៌ស្អាតធំស្រឡាង |
| អប្បមាទឫសគល់នាំឱ្យសាង | កុសលសម្រាំងល្អអស់ថ្នាក់។ |
| កុំធ្វេសប្រហែស សតិហំ | ត្រូវប្រមូលផ្តុំសម្បជញ្ញៈ |
| ប្រយ័ត្នគ្រប់កាលៈទេសៈ | មានមនសិការៈល្អប្រពៃ។ |
| គួរតែសង្កត់អកុសល | កុំឱ្យវាជ្រុលនាំទុក្ខភ័យ |
| សន្សំកសាងផ្សំនិស្ស័យ | ប្រតិបត្តិជាញជ័យតាមព្រះធម៌។ |
| តាមព្រះឱវាទព្រះសាស្តា | មុនបរិនិព្វានរ៉ាទ្រង់សាទរ |
| ប្រទានឱវាទថ្លៃថ្លាល្អ | សម្តែងគាំទ្រអប្បមាទធម៌។ |

**ហន្ទទានិ ភិក្ខវេ**
**អមន្តិយាមិវោ**
**វយធម្មាសង្ខារា**
**អប្បមាទេនសម្បាទេថ។**

ថាហៃភិក្ខុផងទាំងឡាយ
ចូរអ្នកមកអាយយើងនឹងប្រាប់
ឱ្យអ្នកទាំងឡាយបានយល់ច្បាស់
ចាំជាក់ថាសង្ខារធម៌។
ដែលកើតមកហើយវិនាសវិញ
នេះហើយហៅពេញសច្ចៈធម៌
ច្នេះអ្នកទាំងឡាយត្រូវបន្ត
កសាងដោយល្អកុំប្រមាទ។
នេះគឺអប្បមាទបានចារចែង
ប្រយ័ត្នប្រយែងវានឹងស្អាត
ធ្វើល្អបានសុខបានត្រូវខ្នាត
មង្គលស្អាតបាតយ៉ាងជាក់ស្តែង។
សរុបទាំងបីក្នុងគាថា
ដែលព្រះសាស្តាបានសម្តែង
មិនត្រេកអរនឹងបាបមែនទែន
វៀរបាបនោះឯងកុំប្រព្រឹត្តិ។
មិនបានសេពនូវទឹកស្រវឹង
ថ្នាំញៀនញ៉ាមហ្នឹងកុំបីគិត
ប្រតិបត្តិអប្បមាទធម៌ពិត
ចិត្តតែងរិះគិតពីធម៌អាថ៌។
បើធ្វើយ៉ាងនេះនឹងបានសុខ
ពីនេះទៅមុខនឹងភ្លឺថ្លា
សិរីសួស្តីថ្កើងអស្ចារ្យ
មង្គលនោះណាល្អឧត្តម។

## ព្រះគាថាទី ៧

មាន ៥ មង្គល

**គារវោ ច និវាតោ ច   សន្តុដ្ឋី ច កតញ្ញុតា**

**កាលេន ធម្មស្សវនំ     ឯតម្មង្គលមុត្តមំ។**

(បទសរភញ្ញ)

សេចក្តីគោរពដល់បុគ្គល    ជាការគួរដល់ការគួរសម
សេចក្តីបន្ទាបខ្លួនរមទម្យ    និងការអប់រំតាំងចិន្តា។
ឱ្យចេះសន្តោសនឹងរបស់    ដែលខ្លួនមាននោះសមប្រាថ្នា
កិរិយាឃើញនូវគុណូបការ    ដែលអ្នកឯណាធ្វើដល់ខ្លួន។
កិរិយាបានស្តាប់ធម៌តាមកាល    ធម៌ទាំងអម្បាលយល់មាំមួន
ប្រាំនេះប្រព្រឹត្តិបានខ្ជាប់ខ្ជួន    មង្គលសមសួនឧត្តមខ្លាំង។

**សេចក្តីសម្រាយ**

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព១ សេចក្តីឱនលំទោន១ សេចក្តីត្រេកអរតាមមាន តាមបាន១ ភាពជាអ្នកដឹងឧបការៈដែលអ្នកដទៃធ្វើហើយ១ ការស្តាប់ធម៌តាមកាល១ ទាំង៥ នេះជាមង្គលដ៏ឧត្តម។

**៧.១ គារវោ** សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព មាន ៧ ប្រការ ៖

១.**ពុទ្ធគារវតា** គោរពក្នុងព្រះពុទ្ធ

២.**ធម្មគារវតា** គោរពក្នុងព្រះធម៌

៣.**សង្ឃគារវតា** គោរពក្នុងព្រះសង្ឃ

៤.**សិក្ខាគារវតា** គោរពក្នុងសិក្ខា

៥.**សមាធិគារវតា** គោរពក្នុងសមាធិ

៦.**អប្បមាទគារវតា** គោរពក្នុងអប្បមាទ

៧.**បដិសណ្ឋារគារវតា** គោរពក្នុងបដិសណ្ឋារ

**ម្យ៉ាងទៀតបុគ្គលដែលគួរគោរពមាន ៣ ពួក៖**

ក.**អាយុវុឌ្ឍោ** បុគ្គលដែលចម្រើនដោយអាយុ មានចាស់ព្រឹទ្ធាចារ្យជាដើម។

ខ.**គុណវុឌ្ឍោ** បុគ្គលដែលចម្រើនដោយគុណធម៌ មានមាតាបិតានិងអ្នកមានសីលជាដើម។

គ.**បុញ្ញវុឌ្ឍោ** បុគ្គលដែលចម្រើនដោយបុណ្យ មានព្រះមហាក្សត្រ មន្ត្រីដឹកនាំ (យសស័ក្តិខ្ពស់) ឬក៏ហៅថា វយវុឌ្ឍោ គុណវុឌ្ឍោ ជាតិវុឌ្ឍោ ក៏បានដែរ។

**លក្ខណៈគោរពមាន ៣ យ៉ាង**

១.**កាយបណាម** ការគោរពដោយកាយ មានសំពះឱនលំទោនជាដើម។

២.**វចីបណាម** ការពោលសរសើរដោយស្មោះ ទាំងចំពោះមុខ និងក្នុងទីកំបាំង។

៣.**មនោបណាម** គោរពដោយចិត្តស្មោះមិនប្រមាទ មិនលេងសើច។

**២២. គារវោ** កិរិយាគោរពដល់បុគ្គលដែលគួរគោរព

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

អ្វីទៅហៅថាគារវោ ច ឆ្លើយឡើងដោយស្ម័គ្រឬដោយសម

គឺការគោរពល្អសមរម្យ ធ្វើឬករមទម្យសមសោភា។

លើកដៃសំពះឬឱនកាយ    សម្ដីរូសរាយសមល្អជា
សមរូបសមរាងសមកិរិយា    សមទាំងវាចាពីរោះល្អ។
ទទួលរាក់ទាក់គួរកក់ក្ដៅ    ទឹកមុខមើលទៅស្រស់បវរ
ញញឹមញញែមភ្នែកថ្លាល្អ    ទឹកចិត្តត្រេកអរសោទរជាក់។
សរសើរលើកគុណអ្នកដទៃ    ស្មោះត្រង់ប្រពៃគ្មានថ្នាំងថ្នាក់
លើកតម្លៃពិតត្រង់សច្ចៈ    មិនមែនលើកដាក់បញ្ជើចទេ។
ការដែលគោរពអ្នកដទៃ    គឺឱ្យតម្លៃលើសយើងដែរ
យើងដាក់ខ្លួនទាបរាបស្លិតស្លេរ    ហើយតម្កើងគេឱ្យបានមុន។
មិនមែនអែបយកចំណេញទេ    លើកត្រង់ស្មោះដែរព្រោះស្គាល់គុណ
គុណលោកទាំងនោះធ្វើមកមុន    ប្រយោជន៍នៃគុណមានពិតហើយ។
ការដែលលើកគេឱ្យខ្ពស់ឡើង    ព្រោះចិត្តខាងយើងចេះបណ្ដោយ
បន្ថយមានះយើងបានហើយ    មុខក្រោយអប់រំចិត្តដូច្នេះ។
បើយើងគិតថាយើងគ្រាន់បើ    គ្មានអ្នកណាស្មើគ្មានអ្នកចេះ
គ្មានទេអ្នកលើសពីយើងនេះ    យើងក៏មិនចេះគោរពគេ។
ឬកពារយើងខ្ពស់ឆ្មើងកន្ទ្រើង    គ្មានអ្នកដល់យើងសោះនោះទេ
យើងដើរថយក្រោយមិនស្លិតស្លេរ    ព្រោះប្រកាន់តែនឹងមានះ។
គួរតែត្រូវចេះតម្កើងគ្នា    គោរពល្អជាពិតត្រង់ជាក់
លើកគុណវិសេសលោកឱ្យច្បាស់    ទើបយើងឈ្មោះអ្នកចេះស្គាល់គុណ។
ស្គាល់ហើយប្រណិបតន៍គុណគេដែរ    យើងក៏បានប្រែល្អលើសមុន
ព្រោះយើងពិសោធឃើញនូវគុណ    អស់លោកមានបុណ្យល្អលើសយើង។
រៀនតាមដំណើរលោកប្រព្រឹត្តិ    ដោយក្ដីសុចរិតល្អរុងរឿង
បានជាគតិសម្រាប់យើង    ប្រតិបត្តិឱ្យឡើងល្អទៅទៀត។
តើត្រូវគោរពអ្នកណាខ្លះ    គោរពដល់អ្នកដែលឆ្លាតឈ្លាស
មានយោនិសោមនសិការៈ    បានធ្វើឱ្យឈ្នះអស់កិលេស។

មានទាំងព្រះពុទ្ធបច្ចេកពុទ្ធ សាវ័កសង្ឃសុទ្ធព្រះអរិយៈ
ព្រះសង្ឃទាំងអស់គ្រប់ជាន់ថ្នាក់ និងអ្នកប្រតិបត្តិត្រៃសិក្ខា។
ព្រឹទ្ធាចារ្យចាស់ទុំផងទាំងឡាយ រៀមច្បងគ្រប់កាយផងនោះណា
ពុទ្ធបរិស័ទដែលជ្រះថ្លា ព្យាយាមសិក្សាជាប្រក្រតី។
លោកអ្នកដែលមានសីលសិក្ខា សមាធិបញ្ញាផងនោះនៃ
ដែលគួរប្រណិបតន៍ដោយប្រពៃ គួរលើកតម្លៃរបស់លោក។
មិនមែនគោរពអ្នកផឹកស្រា ស្រវឹងឡូឡាអ្នកលេងជោក
អួតអាងកាប់ចាក់អាក្រក់ថោក ពុតពាលស្មោគគ្រោកថោកចង្រៃ។
គោរពពិសេសអ្នកមានគុណ អ្នកធ្វើល្អមុនគុណល្អក្រៃ
ធ្វើល្អនឹងយើងជាប្រក្រតី គួរចេះលកលៃគោរពគុណ។
អ្នកបានជួយយើងក្នុងគ្រាក្រ ពេលអន់ត្រដរយើងស៊យស៊ុន
បានអ្នកខាងក្រៅមកជួយទាន់ មកជួយសម្រន់បង្អន់ទុក្ខ។
គួរកុំបំភ្លេចគោរពលោក កាលពេលយើងថោកបានលោកទប់
បានរុងរឿងវិញល្អសព្វគ្រប់ យើងគួរគោរពស្រឡាញ់វិញ។
ពិសេសប្រណិបតន៍ព្រះមាតា បិតាផងណាកុំទោម្នេញ
លើកតម្កើងលោកឱ្យបានពេញ- ចិត្តថ្លើមលោកវិញគ្រប់វេលា។
ផ្គាប់ផ្គុនទាំងកាយព្រមទាំងចិត្ត សម្រាំងសំរិតបានល្អជា
ឱ្យមាតុបិតា(៦)សុខរមនា ស្រស់ស្រាយគ្រប់គ្រានាជីវិត។
ព្រោះលោកចិញ្ចឹមយើងត្រង់ស្មោះ សន្មតថាស៊ូប្តូរជីវិត
ឱ្យតែកូនរស់បានល្អពិត ស៊ូប្តូរជីវិតដើម្បីកូន។
ចិត្តកូនមិនដល់ប៉ុណ្ណឹងទេ តែគួរមើលថៃឱ្យរលូន
ថៃទាំប្តូរផ្តាច់នឹងបានបុណ្យ អនេកអនន្តទៅមុខទៀត។
នេះគឺ គារវៈគ្រប់ថ្នាក់ជាន់ ធ្វើទៅបានបុណ្យឬបានលាភ
ប្រណិបតន៍គោរពដោយសុភាព តាមថ្នាក់ខ្ពស់ទាបនៃគុណធម៌។



៦.អាន ថា មាត បិតា

នេះហៅសាងបុណ្យកិត្តិយស លើកគេឱ្យខ្ពស់ៗលេចធ្លោ
ខ្ពស់ពិតទៅតាមនៃគុណធម៌ សាងមកបានល្អរៀងៗខ្លួន។
បន្ថយកិលេសគឺមានះ រូតរះយកឈ្នះលើចិត្តខ្លួន
ប្រណិបតន៍គោរពអ្នកមានគុណ នឹងបានផលបុណ្យកើតមង្គល។

**៧.២ និវាតោ** កិរិយាចេះបន្ទាបខ្លួន

ទាល់តែលះបង់នូវ ទិដ្ឋិ និងមានះទើបចេះបន្ទាបខ្លួនបាន (មានះ ការតម្កើងខ្លួន ទិដ្ឋិ ការយល់ខុស) កាលបើបុគ្គលប្រកបដោយទិដ្ឋិ និងមានះ រមែងដល់នូវសេចក្តីវិនាស ទាំងក្នុងបច្ចុប្បន្ន និងអនាគត ព្រមទាំងមិនជាទីចូលចិត្តនៃជននានា។ ការពិតទាល់តែបន្ទាបខ្លួនថាល្ងង់ទើបកើតបានជាអ្នកចេះដឹង ទាល់តែយល់ថាខ្លួនមិនទាន់បរិសុទ្ធ ទើបធ្វើឲ្យខ្លួនបរិសុទ្ធបាន។

ចេះបន្ទាបខ្លួនឯងដោយសុទ្ធចិត្ត គឺចេះបន្ថយនូវអត្តានុទិដ្ឋិ (គំនិតយល់ថាខ្លួនល្អខ្លួនគ្រាន់បើ) ហើយចេះទទួលស្គាល់គុណ គឺអំពើល្អរបស់អ្នកដទៃ ហើយរៀនសូត្រធ្វើអំពើល្អស្របចិត្តគ្នាតទៅ។

**២៣- និវាតោ** កិរិយាចេះបន្ទាបខ្លួនល្អ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

អ្វីទៅហៅថានិវាតោ គឺការដែលស៊ូបន្ទាបខ្លួន
ស្គាល់ពិតថាខ្លួនមិនមាំមួន ប្រឹងអប់រំខ្លួនតទៅទៀត។
បើមិនទទួលថាខ្លួនអន់ ច្បាស់ជាទំរន់មិនប្រុងស្មៀត
ព្យាយាមប្រឹងប្រែងតទៅទៀត ពិតជាមារយាទអន់មែនទែន។
ដូច្នេះអ្នកដាក់ខ្លួនថាអន់ ការពិតមិនដែលអន់មែនៗ
គឺពិតជាមនុស្សដែលខ្នះខ្នែង អភិវឌ្ឍន៍ខ្លួនឯងតែងថ្លៃថ្លា។
ដូចអ្នកខ្លះចូលចិត្តសិក្សា នូវវិជ្ជាការផងនានា
រៀននេះរៀននោះច្រើនវិជ្ជា ពណ៌នាថាចេះពុំដែលអស់។

រៀនតាំងពីក្មេងដល់ខ្លួនចាស់ ឃើញច្បាស់ថានៅមានចន្លោះ
ចំណេះអស់នោះមិនដឹងអស់ ចេះបានឆ្លោះៗមិនច្បាស់ឡើយ។
មិនហ៊ានអួតថាខ្លួនអ្នកចេះ ទោះបីជាចេះខ្លាំងក៏ដោយ
មានតែអ្នកផងគេអួតឱ្យ អួតខ្លួនឯងហើយពិតជាអន់។
មានតែអ្នកល្ងង់ដែលមិនចេះ ទើបរៀនតម្រិះដំបូងមុន
ដឹងតិចតួចសោះធ្វើបែបគ្រាន់ ក្រោយមកវាអន់ព្រោះអំនួត។
សប្បុរសតែងភ្ញាក់ខ្លួនបានច្បាស់ ដឹងខ្លួនស្រឡះច្បាស់រហូត
ភ្ញាក់ខ្លួនថាខ្លួននៅថយថោក ហើយក៏ខំស្រូតកសាងទៀត។
កសាងសន្សំនូវវិជ្ជា ធម៌អាថ៌នានាព្យាយាមឆ្លៀត
ស្វែងរកបញ្ញាតទៅទៀត តែងតែបន្ទាបខ្លួនថាខ្សោយ។
ម្ល៉ោះហើយប្រឹងប្រែងមិនប្រមាទ ហើយខំសង្វាតមើលមុខក្រោយ
រៀនសូត្របួរផ្តាច់មិនឱ្យឆ្ងាយ ដើរតាមបណ្តោយផ្លូវសប្បុរស។
តែងលើកតម្កើងអ្នកចេះដឹង មានគុណធម៌ហ្នឹងដោយត្រង់ស្មោះ
ហើយខ្លួនប្រតិបត្តិតាមដែរនោះ ព្យាយាមដើរឆ្ពោះផ្លូវអ្នកប្រាជ្ញ។
ដូច្នេះបន្ទាបខ្លួនឱ្យល្អ ជាឫកបវរនាំឱ្យអាច
ប្រតិបត្តិបានល្អរុងរឿងស្វាច ដើរតាមអ្នកប្រាជ្ញដើរតាមធម៌។
ប្រតិបត្តិយ៉ាងណាតាមសទ្ធា តាមព្រះឈ្មោះមារផ្សាយព្រះធម៌
គួរតែបន្ទាបខ្លួនឱ្យល្អ អនុវត្តគ្រាំទ្រតាមធម៌ព្រះ។
នឹងបានចេះដឹងគាប់ប្រសើរ ចេះធ្វើដំណើរបានល្អល្អះ
ជីវិតរស់នៅរុងរឿងឈ្នះ ប្រលះក្តីទុក្ខយកមង្គល។
រឿងនេះផ្ទុយនឹងអ្នកមានះ រឹងរូសយកឈ្នះជះឥទ្ធិពល
លើកកំពស់ខ្លួនមើលពុំយល់ ឈ្លួសឈ្មុលប្រកាន់នូវទិដ្ឋិ។
អួតអាងថាខ្លួនខ្លាំងពូកែ ខ្លួនចេះលើសគេលើលោកនេះ
អ្នកប្រាជ្ញទូន្មានក៏មិនចេះ ពិចារណ៍ត្រិះរិះអស់អាថ៌ឡើយ។

នៅតែមានះហើយប្រកាន់ បើយល់ជាក់ស្បាន់យ៉ាងណាហើយ
មិនព្រមលះបង់យល់ខុសឡើយ នៅតែធ្វើព្រងើយព្រោះកំហុស។
តែងតែប្រកបដោយទុក្ខា ព្រោះមានចេតនាធ្វើឲ្យខុស
កម្មកាចតែងផ្ដល់ផលចំពោះ ព្រោះអំពើខុសរបស់ខ្លួន។
មិនបន្ទាបខ្លួនស្ដាប់ឱវាទ ទោះគេសង្វាតជួយមាំមួន
ចចេសរឹងរូសខុសច្បាប់ក្បួន មង្គលសមសួនមកពីណា។

**ករណីនៃការបន្ទាបខ្លួន** (បទកាកគតិ)

**ក. វណ្ណៈត្រកូល**

| | | |
|---|---|---|
| ការបន្ទាបខ្លួន | បានល្អសមសួន | មានច្រើនករណី |
| ទីមួយត្រកូល | ពង្សផៅប្រាស្រ័យ | មិនតម្កើងអី |
| | ទុកស្មើគេឯង។ | |
| មិនលើកកំពស់ | ឲ្យឡើងខ្ពស់ហួស | ឲ្យគេកោតក្រែង |
| ទៅណាមកណា | តែងចេះសម្ដែង | បន្ទាបខ្លួនឯង |
| | ដូចអ្នកដទៃ។ | |

**ខ. ទ្រព្យសម្បត្តិ**

| | | |
|---|---|---|
| ទីពីរនោះណា | ទោះបីទ្រព្យា | មានច្រើនម្ដេចក្ដី |
| ធ្វើតែស្មើៗ | ស្មើជាប្រក្រតី | មិនអួតអាងអី |
| | ថាមានជាងគេ។ | |
| តែងចេះរូតរះ | រួសរាយរាក់ទាក់ | មិនមានគ្នាន់គ្នេរ |
| រាប់អានអ្នកក្រ | ឬអ្នកមានដែរ | ដូចតែគ្នាទេ |
| | មិនមានឆ្មើងឆ្មៃ។ | |

**គ. រូបសម្បត្តិ**

| | | |
|---|---|---|
| ទីបីរូបា | កើតមកស្រស់ថ្លា | ដោយបុណ្យប្រពៃ |

តែមិនរើសអើង តម្កើងខ្លួនអី រូបល្អម្ដេចក្ដី
មិនស្រវឹងឡើយ។

## ឃ. វិជ្ជាសម្បត្តិ

ទីបួននោះណា សម្បត្តិថ្លៃថ្លា គឺថាវិជ្ជា
រៀនចេះដឹងច្រើន ចេះទាំងធម្មា តែធ្វើហាក់ជា
សាមញ្ញធម្មតា។
រៀនតទៅទៀត សព្វថ្ងៃខំឆ្លៀត រៀនសព្វសិក្ខា
មិនអួតថាចេះ តម្រិះអស្ចារ្យ នៅចាត់ខ្លួនថា
ថាល្ងង់ដដែល។

## ង. យសបរិវារ

ប្រាំនោះមានយស កិត្តិយសខ្ពង់ខ្ពស់ មានទាំងបរិវារ
ក៏មិនអួតអាង តម្កើងចេស្ដា តែងតែរក្សា
ភាពជាប្រក្រតី។
នៅតែរាប់អាន ញាតិមិត្រព្រៀងលាន មិនចេះឆ្មើងឆ្មៃ
មិនចេះប្រមាថ ដល់អ្នកដទៃ ទោះធ្វើអ្វីៗ
ធ្វើដោយសុចរិត។
ចេះបន្ទាបខ្លួន ធ្វើឫកសមសួន មាំមួនល្អពិត
មិនមានអួតអាង មិនតម្កើងឫទ្ធិ មិនទាំងវាយឫក
ប្រព្រឹត្តិស្មោះស្មើ។
ទោះធំយ៉ាងណា ទោះខ្លាំងយ៉ាងណា ឬខ្ពស់ថ្នាក់លើ
ក៏នៅប្រព្រឹត្តិ ចរិតស្មោះស្មើ រាប់រកបណ្ដើរ
ស្មើគ្នាប្រាកដ។
ដូចបុរាណថា អ្នកមាននោះណា ចេះរក្សាក្សត់
ចំណែកឯប្រាជ្ញ មិនប្រាជ្ញសន្ទត គឺប្រាជ្ញប្រាកដ

ចេះរក្សាខ្លៅ។

បុរាណលោកប្រៀប ទៅតាមសភាព ថាដូចសំពៅ
ដឹកឥវ៉ាន់ធ្ងន់ ហើយចតទឹកជ្រៅ មិនអាចចូលទៅ
ត្រូវពឹងសំប៉ាន។

ចេះធ្វើប្រយោជន៍ មិនមែនហិនហោច ប្រយោជន៍ថ្កើងថ្កាន
ប្រយោជន៍ទាំងគេ ទាំងយើងក៏បាន ចេះបន្ទាបប្រាណ
ចេះទាំងសាមគ្គី។

## ផលនៃការបន្ទាបខ្លួន

ចំណែកអានិសង្ស អ្នកដែលផ្ចិតផ្ចង់ បន្ទាបខ្លួននៃ
បានទីមួយ**សុខ** សប្បាយប្រពៃ រស់រានសព្វថ្ងៃ
គ្មានសត្រូវឡើយ។

ទីពីរ**ញាតិមិត្ត** មានកល្យាណមិត្រ រាប់អានឥតស្បើយ
មិត្តនេះឲ្យសុខ សុខបានល្ហែល្ហើយ រស់មានកោះត្រើយ
សោយសុខមង្គល។

ទីបី**កិត្តិយស** ប្រសើរខ្ពង់ខ្ពស់ នាគ្រប់មណ្ឌល
គេលើកតម្កើង មិនឲ្យខ្វាយខ្វល់ ត្រូវគេតម្កល់
គោរពរាប់អាន។

ទីបួននោះណា នឹងកើតចលនា **សាមគ្គី**សុខសាន្ត
ព្រោះទុកចិត្តគ្នា ស្រឡាញ់ស្មោះស្មាន ធ្វើអ្វីតែងបាន
គិតដល់គ្នីគ្នា។

ប្រាំចុងបង្ហើយ អនាគតផ្តល់ឲ្យ មិនឲ្យវេទនា
ស្លាប់ទៅៗកើត នា**ស្ថានសុខា** ដោយសារកិរិយា
ចេះបន្ទាបខ្លួន។

**៧.៣ សន្តុដ្ឋី** សន្តោសចិត្តទៅក្នុងការប្រើប្រាស់វត្ថុផ្សេងៗ ឬ ចំពោះហេតុការណ៍ផ្សេងៗ សេចក្ដីត្រេកអរតាមមាន តាមបាន ចែកចេញជា ៣ គឺៈ

១- **យថា លាភ** **សន្តោស** ត្រេកអរតាមមានតាមបាននូវលាភផ្សេងៗ

២- **យថា ពល** **សន្តោស** សន្តោស តាមកម្លាំងខ្លួន

៣- **យថា សារូប** **សន្តោស** សន្តោស តាមឋានៈខ្លួន។

**២៤. សន្តុដ្ឋី** ចិត្តសន្តោសតាមមាន តាមបាន

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| សន្តុដ្ឋីមានន័យថាសន្តោស | គឺតាំងចិត្តនោះឲ្យបានស្រួល |
| ត្រូវចេះសំរបឬសម្រួល | ឲ្យចិត្តស្របស្រួលនឹងអ្វីៗ។ |
| ត្រូវចេះអប់រំសង្កត់ចិត្ត | កុំឲ្យគន់គិតនឹកមមៃ |
| អ្វីលើសសមត្ថភាពមិនប្រក្រតី | គួរតែលកលៃទុកមួយឡែក។ |
| បើមានត្រឹមកង់ចង់ម៉ូតូ | ហាក់មិនគិតគូរចង់តែប្លែក |
| បើខ្លួនវាក្រខំហែកមេឃ | ក្បាលខ្លួនទំពែកចង់ដុះសក់។ |
| កើតមកម៉ែក្រចង់ជិះឡាន | ខ្លួនឯងមិនបានរៀនសូត្រសោះ |
| តែខ្លួនចង់ធ្វើអ្នកប្រាជ្ញស្មោះ | ចង់តែទាំងអស់ធ្វើអីកើត។ |
| ឃើញដំរីជុះៗតាមវា | ចិត្តនោះពុំជាពុំកំណើត |
| ចេះតែនឹកទៅធ្វើពុំកើត | កើតតែសម្ដីស្ដីងាយៗ។ |
| សប្បុរសអ្នកដែលមាននិស្ស័យ | មានអធ្យាស្រ័យមិនពាយងាយ |
| យល់ធម៌បានច្បាស់ទាំងសម្ងាយ | មិនរវើរវាយសោះឡើយណា។ |
| យល់អ្វីមាំទាំហើយពិតៗ | គំនិតសច្ចៈមិនមុសា |
| តែងចេះសម្រួលនូវចិន្តា | មិនមានប្រាថ្នាអ្វីដែលគ្មាន។ |
| ទោះប្រើរបស់ទ្រព្យផ្សេងៗ | ចេះប្រើជាក់ស្ដែងតាមលំអាន |
| មិនមែនមានកង់ចង់ជិះឡាន | វានឹងខកប្រាណមិនខានឡើយ។ |

រស់នៅដោយធម៌ពិតប្រាកដ សន្ទុតជឿធម៌ពិតនោះហើយ
ទោះមានទុក្ខទោសមិនបណ្តោយ គិតទៅឃើញហើយទប់បានភ្លាម។
ព្រោះយល់ត្រៃលក្ខណ៍សច្ចៈពិត បានជាគំនិតមិនទីមទាម
យល់ច្បាស់ថាសត្វពិតជាមាន ទុក្ខទោសរវាមក្នុងជីវិត។
ព្រោះតែកម្មផលសាងបន្ត មានអាក្រក់ល្អជារឿងពិត
កម្មកម្លាំងខ្លាំងតែងវិចិត្រ ប្រឌិតការពិតនៃសង្ខារ។
ជួនក៏បានសុខជួនក៏ទុក្ខ មិនមានយល់មុខសត្វឯណា
ឲ្យតែកើតនាវដ្តសង្សារ គ្មានសត្វឯណានឹងសុខបាន។
យល់ឃើញតាមធម៌វិសេសលន់ នៃព្រះមានបុណ្យថ្លៃថ្លើងថ្កាន
ទុក្ខដែលខ្លាំងធ្ងន់ប្រែស្រាកស្រាន្ត បានសុខសំរាន្តព្រោះយល់ធម៌។
មិនមាននូវចិត្តតក់ក្រហល់ ចិត្តនោះមិនខ្វល់ខ្យល់ត្រដរ
សម្រួលចិត្តបានៗដោយធម៌ មិនសូវញាប់ញ័រអ្វីប៉ុន្មាន។
នេះហៅថាមានចិត្តសន្តោស សន្តុដ្ឋីនោះកើតឡើងបាន
កាត់ក្តីប្រាថ្នាខ្លះឲ្យខាន ចិត្តបានស្រាកស្រាន្តមិនវិលវល់។
បើមិនយល់ធម៌តែងយកទុក្ខ មកទុកស្មាញស្មុគនាំឲ្យខ្វល់
គ្រោះថ្នាក់ស្លាប់កូនទុក្ខអំពល់ ធ្វើឲ្យខ្វាយខ្វល់ឆ្កួតវង្វេង។
ខ្លះគ្រាន់តែសង្សារបែកចិត្ត ធ្លាប់តែស្នេហ៍ស្និទ្ធនៅក្មេងៗ
ក៏តាំងកើតទុក្ខខ្លាំងខ្លួនឯង យកគ្រោះប្រឡែងនឹងជីវិត។
ទៅសម្លាប់ខ្លួនឃើញស្តែងៗ មិនគិតកោតក្រែងស្តាយជីវិត
មកពីយល់ឃើញខុសគំនិត ថាពិតជាអស់សង្ឃឹមហើយ។
ខ្វះអីអ្វីៗច្រើនគគោក អ្វីៗកើតមកមានមុនក្រោយ
មកប៉ះយើងគេហូរហែហើយ គួរចេះបណ្តោយទៅតាមធម៌។
ទុក្ខសុខម្តងគេហើយម្តងយើង ត្រូវគិតលើកឡើងឲ្យបានល្អ
ម្តងនេះគេមានឯយើងក្រ ម្តងទៀតគេក្រយើងរុងរឿង។

ថ្ងៃនេះយើងទុក្ខព្រាត់កូនម្នាក់ ក្រោយទុក្ខវាធ្លាក់ដល់គេឡើង
ស្លាប់កូនគេម្នាក់ដូចតែយើង ម្តងគេម្តងយើងស្លាប់ដូចគ្នា។
មានអ្នកណាម្នាក់ថាមិនស្លាប់ ឥទ្ធិពលចំណាប់កម្រិតណា
ក៏នៅតែស្លាប់សូន្យអសារ រឿងអីទុក្ខាតែម្នាក់ឯង។
កិច្ចសន្តោសខ្លះបានបរិយាយ មកអធិប្បាយឬសម្តែង
ឲ្យយើងបានយល់ឃើញស្តែងៗ ឲ្យចេះពីល្បែងនៃជីវិត។
បើចេះសន្តោសដូចប្រោសខ្លួន ចៀសទុក្ខធ្ងួនៗតាមធម៌ពិត
បានកាត់បន្ថយមួយកម្រិត ទុក្ខនឹងស្រាលពិតពីចិត្តខ្លួន។
បើចេះសន្តោសប្រោសផ្លូវចិត្ត ហាក់ដូចចេះគិតបានមាំមួន
ពង្រឹងផ្លូវចិត្តបានសមសួន កុំឲ្យរុកគួនដោយលោភៈ។
កិច្ចសន្តោសមានច្រើនប្រការ សង្ខេបទៅណាឲ្យឃើញជាក់
ចេះសម្រួលចិត្តតាមឧបសគ្គ ដែលមានប្រត្យក្សដូចតទៅ ៖

**ក. យថា លាភ សន្តោស** សន្តោសក្នុងលាភ

ហៅ **យថា លាភ សន្តោសៈ** សម្រួលក្នុងថ្នាក់ប្រាថ្នាលាភ
ដែលគួរធ្វើចិត្តឲ្យរាបទាប ស្វះស្វែងរកលាភតាមការគួរ។
លាភត្រូវតែបានតាមឋានៈ កាលៈទេសៈដ៏សមគួរ
អ្វីដែលបានធ្វើទុកមុនយូរ ធ្វើដោយតស៊ូទើបអាចបាន។
មិនមែនធ្វើស្រែមួយហិកតា តែចិត្តប្រាថ្នាចង់ទិញឡាន
រអ៊ូរទាំនាំរំខាន ព្រោះចិត្តចង់បានមិនស្មានខ្លួន។
គួរតែពេញចិត្តនឹងរបស់ ដែលខ្លួនមាននោះទើបសមសួន
បើចង់បានមែនគួរខ្ជាប់ខ្ជួន ធ្វើឲ្យមាំមួនយកជោគជ័យ។
មិនគួរអង្គុយច្រណែនគេ ត្រូវតែរិះរេគិតរំពៃ
ត្រូវខំប្រព្រឹត្តិគ្រប់ករណី ទើបបានមានជ័យមានលាភដែរ។

**ខ. យថា ពល សន្តោស** សន្តោសទៅតាមកម្លាំងខ្លួន

| | |
|---|---|
| យថា ពល សន្តោសៈ | សម្រួលតាមថ្នាក់កម្លាំងខ្លួន |
| ធ្វើអ្វីគួរគិតឲ្យមាំមួន | តាមកម្លាំងខ្លួនអាចធ្វើបាន។ |
| កម្លាំងគួរអូសរ៉ឺម៉កទេ | ម្ដេចក៏ទៅបែរជាអូសឡាន |
| ធ្វើអ្វីលើសពីសមត្ថភាពប្រាណ | នោះត្រូវតែបានបរាជ័យ។ |
| អ្នករកស៊ីក៏ដូច្នេះដែរ | ទោះបីអ្នកស្រែអ្នកក្រុងក្ដី |
| ធ្វើលើសកម្លាំងជាប្រក្រតី | លទ្ធផលនោះនៃទៅជាខ្សោយ។ |

**គ. យថា សារុប្ប សន្តោស** សន្តោសតាមគុណធម៌របស់ខ្លួន

| | |
|---|---|
| **យថា សារុប្ប សន្តោសៈ** | សម្រួលតាមថ្នាក់ឧបនិស្ស័យ |
| គុណធម៌ប្រតិបត្តិរៀងរាល់ថ្ងៃ | តើបានលកលៃល្អឬទេ។ |
| គួរដឹងថាល្អកម្រិតណា | ថាតើចាស់ក្លាហើយឬទេ |
| អាក្រក់តើអាក្រក់ម្ដេចវិញដែរ | គួរតែរិះរេឲ្យដឹងខ្លួន។ |
| កុំច្រឡំឲ្យសោះថាគ្រាន់បើ | ថាខ្លួនប្រសើរឬមានបុណ្យ |
| ទៅណាមកណានិយាយមុន | អួតខ្លួននូវគុណល្អជាងគេ។ |
| ល្អទាំងសីលទានឬភាវនា | តាមពិតកំព្រាអ្វីម៉្លេះទេ |
| សន្សំរកទ្រព្យមិនទំនេរ | មិនថាទ្រព្យគេទ្រព្យសាសនា។ |
| នេះគឺមិនមែនសន្តោសៈ | ប្រតិបត្តិមិនច្បាស់តាមធម្មា |
| ប្រព្រឹត្តិគុណធម៌មិនល្អថ្លា | ធ្វើតែកិរិយាកេងប្រយោជន៍។ |

**៧.៤ កតញ្ញុតា** ភាពជាអ្នកដឹងគុណ

អ្នកដឹងគុណអ្នកដទៃ ដែលគេធ្លាប់មានឧបការៈដល់ខ្លួន ហៅថា អ្នកមានធម៌កតញ្ញូ។ អ្នកចេះតបគុណអ្នកដទៃ ដែលធ្លាប់មានឧបការៈដល់ខ្លួន ហៅថា អ្នកមានកតវេទិតាធម៌។

សរុបទាំងការដឹងគុណ និងចេះតបគុណផង ហៅថា មាន កតញ្ញូកតវេទិតាធម៌

គុណគឺអំពើល្អដែលបុគ្គលដទៃធ្វើចំពោះយើងមាន ៖

- គុណ ព្រះសម្មាសម្ពុទ្ធ - គុណ ព្រះធម៌ - គុណ ព្រះសង្ឃ
- គុណ មាតា បិតា - គុណ គ្រូឧបជ្ឈាយាចារ្យ - គុណ ជីដូន ជីតា
- គុណ ញាតកា ជាដើម ។

**២៥- កតញ្ញុតា** ភាពជាមនុស្សកតញ្ញូ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

កតញ្ញូមានន័យប្រាកដថា ដែលអ្វីនោះណាសម្រួលយើង
ជួយជាប្រយោជន៍ឲ្យថ្កុំថ្កើង យើងដឹងច្បេះឡើងធ្វើតបវិញ។
ធ្វើល្អតបតនឹងអ្វីនោះ ទោះបីជាមនុស្សសត្វនោះមុិញ
សម្ភារៈត្រូវប្រើដែលយើងពេញ- ចិត្តឥតទោម្នេញធ្លាប់ប្រើមក។
ធ្លាប់បានផ្លែស្វាយថែដើមស្វាយ បើចង់ហូបបាយស្វែអង្ករ
ធ្លាប់ប្រើទឹកស្រះបើយកល្អ ត្រូវតែត្រងរថែឲ្យស្អាត។
មិនត្រូវបន្ទោរបង់ដាក់ស្រះ គួរតែរូតរះខំសង្វាត
ប្រាប់អស់ក្មេងក្មាងឲ្យសំអាត ធ្វើឲ្យស្អាតបាតទឹកស្រះផង។
បើប្រើសត្វគោឬក្របី សេះឬដំរីថែវាផង
វាឲ្យប្រយោជន៍ច្រើនកន្លង បើសិនឆ្ងាំឆ្គងមានបាបខ្លាំង។
ព្រះត្រៃបិដកថ្នក់វិន័យ ធម៌ព្រះជិនស្រីក៏គួរចាំ
យកមករៀនសូត្រកុំប្រចាំ គោរពថែទាំឲ្យបានល្អ។
តម្កល់តម្កើងថ្កើងរៀបរយ កុំបីបណ្តោយឲ្យព្រះធម៌
រកេតរកូតទុកមិនល្អ ហាក់មិនសាទរធម៌ព្រះពុទ្ធ។
និយាយទាំងមនុស្សម្នាគ្រប់គ្នា ប្រព្រឹត្តិឲ្យជាប្រយោជន៍ពិត
ផ្តល់នូវផលល្អយ៉ាងប្រណីត ឲ្យសុខយើងពិតក្នុងលោកនេះ។

ហៅបានថាជាអ្នកមានគុណ ធ្វើល្អមកមុនច្រើនឬតិច
យើងតបលោកវិញកុំបីគេច ហៅថាកុំភ្លេចដឹងគុណលោក។
ជាអាទិមាតានិងបិតា គុណធំអស្ចារ្យច្រើនគគោក
និងបុគ្គលផ្សេងគួររិះរក តបគុណដល់លោកកុំខ្ជីខ្ជា។

**កតញ្ញុតា ធម្ម មូលា** **កតញ្ញុតា បធានតា**

ព្រះពុទ្ធត្រាស់ដឹងនូវធម៌អាថ៌ ទ្រង់បានត្រាស់ថាជាសេចក្ដី។
ថាការដឹងគុណជាធម៌ដើម ជាធម៌ផ្ដួចផ្ដើមផ្ដុំនូវន័យ
ជាឫសជាគល់ធម៌ដទៃ ជាប្រធាននៃធម៌ទាំងពួង។
បើសិនមិនដឹងគុណមាតា បិតាផងណាជាចំបង
មិនអាចធ្វើល្អអ្វីកើតផង ព្រោះវារំលងកតញ្ញូនេះ។
កូនបានដឹងស្រាប់ហើយមកថា តាំងពីកុមារដឹងក្ដីម្ល៉េះ
តើអ្នកណាទៅដែលលោកចេះ ថៃទាំកូននេះរហូតមក។
មិនគឺមាតានិងបិតា អភិបាលរក្សាមុនប្រសូត្រ
កូនកើតមកហើយថៃរហូត ថៃតាំងពីតូចរហូតធំ។
ថៃនេះហៅថៃៗម្ល៉េះទេ ថៃគ្មានទំនេរលើសពីខ្ញុំ
បំរើដាច់ថ្លៃឥតបង្ខំ ថៃទាំសន្សំឲ្យកូនសុខ។
ថៃនេះហៅថៃគ្មានទំនេរ ថៃខ្លាំងម្ល៉េះទេថៃទៅមុខ
ថៃមិនធួនល្មមថៃសព្វគ្រប់ ថៃថ្ងៃថៃយប់ទល់មរណា។
នេះគឺជាចិត្តពុកនិងម៉ែ យើងរកគ្មានទេលើលោកា
ស្រឡាញ់យើងស្មើមាតុបិតា មើលសព្វទិសាពុំមានឡើយ។
កូនចៅរាល់រូបគួរតែដឹង គុណលោកខ្លាំងម្ល៉ឹងកុំបណ្ដោយ
គួរតបគុណលោកកុំកន្តើយ កុំឲ្យធ្លស់ធ្លោយគួរសង្វាត។
គុណម៉ែមិនដែលចេះតបសោះ តែចេះហួសស្មោះហើយឱហាត
បើធ្វើបុណ្យខួបជូនស្រីស្អាត នោះខំខ្មីឃ្មាតចេញលុយឲ្យ។

កូនល្ងង់ចម្លួតឆ្គួតព្រោះស្រី ប្រព្រឹត្តិអប្រិយឲ្យថ្លោះធ្លោយ
ម៉ែឪចាស់ៗចំណាស់ហើយ ម្តេចក៏បណ្តោយធ្វើមិនដឹង។
ម្តេចមិនចិញ្ចឹមថែរក្សា មាតាបិតាខ្លួនអញ្ចឹង
រាល់ថ្ងៃរាល់ខែធ្វើមិនដឹង ឲ្យម៉ែរំពឹងម្តេចនឹងបាន។
នេះហៅថាកូនអកតញ្ញូ មិនចេះគិតគូរតែងរំខាន
បើមានធុរៈទើបប្រែប្រាណ រត់មកសំរាន្តឲ្យម៉ែជួយ។
ប្រសិនបានសុខលែងគិតម៉ែ គិតតែស្រីស្នេហ៍យ៉ាងរលួយ
ភ្លេចអស់បងប្អូនមិនចេះជួយ នាំតែទុក្ខព្រួយឲ្យសាច់ញាតិ។
កូននេះជាកូនឈ្មោះថាក្រ រស់នៅត្រដរក្រមារយាទ
ទោះរៀនចេះដឹងច្រើនទៅទៀត តែចិត្តមារយាទមិនចេះឡើយ។
មិនយល់មិនស្គាល់អំពើល្អ កតញ្ញូតាធម៌ម្តេចសោះឡើយ
សព្វថ្ងៃរស់នៅសោះអង្គើយ ធ្វើឈ្លើយនឹងលោកអ្នកមានគុណ។
ក្មេងៗធុនហ្នឹងមានច្រើនដែរ កូនយើងកូនគេដែលគ្មានបុណ្យ
មិនបានយល់ដឹងអស់នូវគុណ ឬយល់ថាគុណតៗគ្នា។
មិនគិតថាគុណមានក្នុងចិត្ត លោកតែងអាណិតចិត្តមេត្តា
ករុណា មុទិតា ឧបេក្ខា សន្តោសប្រោប្ធាឲ្យកូនសុខ។
ស្មានថាគុណនោះត្រឹមតែទ្រព្យ ម៉ែឪប្រសប់រកទ្រព្យទុក
ហើយចែកឲ្យកូនទ្រព្យច្រើនមុខ ទើបគេចាត់ទុកថាមានគុណ។
បើម៉ែឪក្រគ្មានទ្រព្យទេ គេតែងគ្នាន់គ្នេរថាគ្មានគុណ
មិនបានការសោះឪធុនអន់ ម៉ែក៏ទម្រន់អន់ដូចគ្នា។
កូនគិតដូច្នេះពិតជាខុស គឺជាកំហុសខុសសទ្ធា
ធម្មតាមនុស្សលោកមិនដូចគ្នា ខ្លះមានទ្រព្យាខ្លះក៏ក្រ។
មិនសុទ្ធតែមានគ្រប់គ្នាទេ ម្តងយើងម្តងគេមិនបានល្អ
ខ្លះជាអ្នកមានខ្លះក៏ក្រ ខ្លះរស់ត្រដររមានទុក្ខធំ។

គ្រប់ពេលពុទ្ធខ្លាំងច្រើនថាគ្មាន ចំណែកអ្នកមានក៏នៅយំ
ភាគច្រើនគឺបានសុខផ្សំៗ ហើយក៏សម្ញុំមិនថាធ្ងន់។
ជាផលវិបាករបស់កម្ម ប្រព្រឹត្តិលាយឡំក្រោយនិងមុន
អញ្ជឹងពួកកូនដែលថាគ្រាន់ ម្ដេចក៏រហន់មកចង់កើត។
មកកើតជាមួយនឹងអ្នកម្ដាយ រស់មិនសប្បាយគ្មានកំណើត
បើយើងអួតថាខ្លួនឯងឆើត ម្ដេចមិនទៅកើតស្ថានផ្សេងទៅ។
នេះពិតគឺបាបហើយនិងបុណ្យ យើងធ្វើមកមុនវាបានដៅ
គួរពិចារណាឲ្យបានជ្រៅ កុំបីធ្វើខ្លៅយល់ខាងខុស។
បើសិនកើតនឹងម៉ែអ្នកមាន ជិះឡានទៅរៀនហើយមានគ្រោះ
បុកគ្នាស្លាប់ព្រោះតែឡាននោះ តើត្រូវបន្ទោសម៉ែដែរទេ។
ឬបើកើតមកហើយស្លាប់ភ្លាម គេរស់រវាមយើងមិនស្ទេរ
តើគួរបន្ទោសអ្នកណាដែរ ខុសអ្នកណាគេបានជាស្លាប់។
រឿងនេះគួរគិតឲ្យវែងឆ្ងាយ ត្រូវប៉ិនបកស្រាយឲ្យចំណាប់
កុំធ្វើល្ងីល្ងើចេះតែសាប់ ដាប់ម៉ែឪខ្លួនទោសធ្ងន់ណាស់។
គួរប្រែក្រឡាស់ខំធ្វើល្អ ត្រូវតែសាទរម៉ែពុកម្ចាស់
ព្រះពុទ្ធថាម៉ែឪជាព្រះ ចិត្តលោកធ្ងន់ណាស់មានគុណធំ។
មាតាបិតាជាព្រះព្រហ្ម ជាគ្រូដើមមុនបង្ហាត់ហំ
ជាព្រះអរហន្តសែនសក្តិសម អ្នកមានគុណធំសម្រាប់បុត្រ។
កូនណាតបគុណមាតុបិតា ដោយក្ដីជ្រះថ្លាបរិសុទ្ធិ
ហៅបុណ្យធំក្រៃថ្លៃមោះមុត នឹងមិនស្រយុតក្នុងជីវ៉ា។
តែងបានមង្គលសុខសួស្ដី ដូចព្រះជិនស្រីមានពុទ្ធដីកា
កូនចេះដឹងគុណមាតាបិតា ផលអនន្តារាប់ពុំបាន។

៧.៥ ការស្តាប់ធម៌តាមកាលជាមង្គលដ៏ឧត្តម

ការស្តាប់នូវធម៌តែងនាំឲ្យកើតការត្រិះរិះពិចារណា ការពិចារណាតាមហេតុផលតែងនាំឲ្យដឹងខុសត្រូវ ការយល់ដឹងតែងតែកែប្រែការប្រព្រឹត្តិអាក្រក់។ ពេលដែលគួរស្តាប់នូវធម៌ គឺ

-ព្រះសង្ឃសម្តែងធម៌ -មាតាបិតាទូន្មាន

-គ្រូពន្យល់ -ព្រឹទ្ធាចារ្យដាស់តឿន

**ប្រយោជន៍នៃការស្តាប់**

១.ទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀត

២.ចំណេះដឹងណាដែលបានរៀនហើយ ក៏កាន់តែជាក់ច្បាស់ឡើង

៣.បាត់នូវសេចក្តីសង្ស័យ

៤.យល់បានត្រឹមត្រូវតាមហេតុផលច្បាស់លាស់

៥.បង្កើនសមត្ថភាពខ្ពស់ក្នុងចំណេះដឹង

**២៦. កាលេន ធម្មស្សវន** ការស្តាប់ធម៌តាមកាល

**ក**.គួរស្តាប់អ្នកណា? ស្តាប់អ្វីខ្លះ?

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

ការស្តាប់ចាត់ជាការសិក្សា ស្តាប់នូវធម៌អាចំការទាំងឡាយ
ស្តាប់ដំបូន្មានគេអភិប្រាយ គេបានអធិប្បាយឲ្យឱវាទ។
ដូច្នោះគួរស្តាប់អ្នកណាខ្លះ ស្តាប់ដោយរូតរះកុំឲ្យខាត
ស្តាប់សង្ឃទេសនាដោយសង្វាត អាចយល់អស់អាថ៌នូវព្រះធម៌។
ស្តាប់គ្រូពន្យល់ក្នុងសាលា ខំស្តាប់សិក្សាឲ្យបានល្អ
ស្តាប់មាតុបិតាប្រដៅមក៏ ចង់ឲ្យកូនល្អបានរុងរឿង។
ស្តាប់ព្រឹទ្ធាចារ្យឬរៀមច្បង ប្រសប់សាសងប៉ងឲ្យថ្កើង
លើកនូវពាក្យល្អប្រសើរឡើង ឲ្យយើងឈានឡើងតទៅទៀត។

លោកមានចេតនាឲ្យយើងសុខ ពីនេះទៅមុខឲ្យមានស្មៀត
អប់រំឫកពារនិងមារយាទ ប្រតិបត្តិគ្រប់ស្មៀតឲ្យឃ្លាតទុក្ខ។
ឲ្យយើងប្រព្រឹត្តិអំពើល្អ កុំឲ្យបង្ករឿងស្មាញស្មុគ
ចៀសវាងអំពើស្អុយគគ្រុក អកុសលផ្ដល់ទុក្ខទោសចង្រៃ។
សុត្តៈ ក៏មានន័យថាស្ដាប់ ស្ដាប់ពាក្យសារស័ព្ទអ្នកដទៃ
ស្ដាប់ហើយយល់ច្បាស់នូវអត្ថន័យ ហើយគួរលកលៃពិចារណា។
បើសិនស្ដាប់ទៅវាមិនល្អ ពាក្យល្អក់កករនាំទុក្ខា
ពាក្យគ្មានប្រយោជន៍ឥតបានការ គួរប្រញាប់រ៉ាចោលភ្លាមទៅ។
បើសិនជាបានស្ដាប់ពាក្យល្អ ស្មោះសបវរល្អពេកកូវ
ពាក្យមានប្រយោជន៍មិនអាស្រូវ ពាក្យនោះយើងត្រូវចាំឲ្យល្អ។
ដូច្នេះគួរចេះមានគំនិត ត្រូវតែខំគិតស្ដាប់ព្រះធម៌
ស្ដាប់សព្វស្ដាប់គ្រប់គតិល្អ យកឧទាហរណ៍ក្នុងជីវិត។
បើបានយល់ហើយនូវព្រះធម៌ វិជ្ជាល្អៗនៃជីវិត
វិជ្ជាធម៌នោះផ្លូវពិសិដ្ឋ ដឹកនាំជីវិតពិតថ្លៃថ្លា។
ស្ដាប់តមកទៀតស្ដាប់អ្នកណា ស្ដាប់ទៅបានការបានផ្លែផ្កា
បានសុខសួស្ដីសិរីវឌ្ឍនា គួរស្ដាប់អ្នកណាបានការន៎?
យើងគួរតែខំប្រឹងប្រែងស្ដាប់ អ្នកប្រាជ្ញចំណាប់សប្បុរសធម៌
ប្រតិបត្តិធ្វើតាមពាក្យល្អៗ ជាពាក្យគាំទ្រឲ្យបានសុខ។
ប្រយ័ត្នកុំស្ដាប់តាមពាក្យពាល ពោលពាក្យរោលរាលនាំមានទុក្ខ
រស់នៅរាល់ថ្ងៃមិនបានសុខ បើយើងសំរុកសេពគប់ពាល។
ត្រូវខំសេពគប់ស្ដាប់បណ្ឌិត ស្ដាប់ពាក្យលោកពិតភ្លឺរន្ទាល
ជីវិតយើងបានសុខវិសាល រស្មីភ្លឺប្រាលល្អគួរគាប់។

## ខ. ផលនៃការស្តាប់

យកល្អគួរធ្វើធម្មស្សវនៈ ស្តាប់ធម៌ឲ្យជាក់យល់ធម្មា
ហើយគួរពិនិត្យពិចារណា ប្រតិបត្តិជ្រះថ្លាបានសុខៈ។
គួរតែខំស្តាប់ឲ្យញឹកញាប់ ស្តាប់ឲ្យបានជាប់បានជឿជាក់
ចេះធម៌ចេះអាចកាន់តែច្បាស់ ស្គាល់ក្តៅត្រជាក់ស្គាល់ថ្នាក់ផ្នើរ។
ស្គាល់អស់សព្វគ្រប់មធ្យោបាយ ស្គាល់កិច្ចទាំងឡាយសព្វសារពើ
ស្គាល់ផ្លូវល្អៗដែលគួរធ្វើ ហើយគួរសើរើកាត់អកុសល។
កំចាត់អកុសលដែលផ្តេសផ្តាស មានច្រើនពេញពាសដែលសេសសល់
ជំរះឲ្យអស់ផ្តាច់ឫសគល់ ដោយសារស្តាប់យល់ន័យព្រះធម៌។
ក្លាយខ្លួនជាអ្នកភ្ញាក់រលឹក ព្រោះស្តាប់ល្ងាចព្រឹកស្តាប់ដោយល្អ
បានអានិសង្សថ្លៃបវរ នាំចិត្តឲ្យល្អមានបញ្ញា។
ប្រសិនអប់រំចិត្តល្អហើយ មិនមានបណ្តោយតែងល្អជា
របររកស៊ីអ្វីនានា តែងប្រសើរជាសព្វកិច្ចការ។
មិនមានចេតនាធ្វើអាក្រក់ មិនមានប្រទូសជននានា
បានសុខខ្លួនឯងឲ្យសុខជា ឲ្យគេរាល់គ្នាបានសុខសាន្ត។
មិនចេះតែចង់បានក្តីសុខ ដោយផ្តល់ក្តីទុក្ខឲ្យសន្តាន
មិនធ្វើអាក្រក់ចិត្តសាមាន្យ ឲ្យតែមានបានម្នាក់ឯងឡើយ។
រមែងតែងតែចេះជួយគ្នា សាមគ្គីសាមគ្គាមិនព្រងើយ
ឃើញគេមានទុក្ខក៏មិនល្ងើយ តិចតួចក៏ដោយសង្គ្រោះគ្នា។
ដូច្នេះការស្តាប់នូវព្រះធម៌ អានិសង្សដ៏ល្អចេះធម្មា
ចេះហើយប្រតិបត្តិបានល្អជា បានសុខរមនាគ្មានខ្វាយខ្វល់។
ម្យ៉ាងទៀតបើធ្វើធម្មស្សនៈ យកចិត្តទុកដាក់នឹងបានផល
បានយល់ធម៌ចាស់ដែលមិនយល់ ព្រោះមុនវាខ្វល់ស្តាប់តិចណាស់។
បានយល់ធម៌ថ្មីមិនធ្លាប់ស្គាល់ បញ្ញារុញដល់ឡើងមួយថ្នាក់

បើបានស្តាប់ទៀតកើនឥតអាក់ នឹងយល់ប្រត្យក្សច្បាស់ក្នុងធម៌។
ចេះច្រើនបំបាត់ការសង្ស័យ មានជាប្រក្រតីពីមុនមក
មានឆ្ងល់ជាច្រើននូវព្រះធម៌ ឥឡូវផលល្អអស់កង្ខា។
អាចយល់នូវធម៌ពិតស្រឡះ ពិសោធន៍ឃើញច្បាស់ដោយបញ្ញា
ហើយប្រតិបត្តិល្អតាមសិក្ខា ព្រោះក្តីជ្រះថ្លាមានសទ្ធា។

**ការស្តាប់ដោយល្អ**

គួរតែព្យាយាមស្តាប់ព្រះធម៌ ដោយកិច្ចដ៏ល្អគ្រប់រូបា
**ទីមួយមិនមើលងាយធម៌អាថ៌** ថាធម៌នេះណាងាយពេកណាស់។
ឬក៏យល់ថាមិនបានការ ហើយស្តាប់នោះណាបែបប្រហែស
មិនប្រុងប្រយ័ត្នស្តាប់ឲ្យចេះ ស្តាប់ដោយតម្រិះបែបខ្ជីខ្ជា។
**ពីរមិនមើលស្រាលអ្នកសម្តែង** ថាគ្រូនេះឯងខ្ជីវស្សា
មិនទាន់ចេះដឹងនូវធម៌អាថ៌ ការពិសោធន៍ណាក៏នៅតិច។
**ទីបីមិនមើលស្រាលដល់ខ្លួន** ថាស្តាប់ផ្ទួនៗតែងតែភ្លេច
មិនបានចេះចាំជាប់ជានិច្ច យកល្អគួរគេចចេញឲ្យឆ្ងាយ។
**ទីបួនបើស្តាប់កុំវាយមាយ** រវើរវាយកេះរៀងអាយ
និយាយលេងសើចបែបសប្បាយ ធ្វើឲ្យអន្តរាយដល់ការស្តាប់។
ថែមទាំងរំខានដល់គេឯង មិនចេះកោតក្រែងគេប្រុងស្តាប់
គួរខំធ្វើចិត្តឲ្យចំណាប់ យកចិត្តទុកដាក់នឹងស្តាប់ធម៌។
**ទីប្រាំស្តាប់ហើយពិចារណា** ឲ្យបានជ្រះថ្លាយល់ព្រះធម៌
យល់ហើយប្រតិបត្តិឲ្យបានល្អ ហៅថាគាំទ្រធម៌ព្រះពុទ្ធ។
ដូច្នេះការស្តាប់នូវព្រះធម៌ អានិសង្សដ៏ល្អធម៌វិសុទ្ធ
យល់ធម៌ចាស់ថ្មីថ្លៃមុះមុត បដិបត្តិយកសុខយកប្រយោជន៍។
ហេតុនេះព្រះពុទ្ធទ្រង់ត្រាស់ថា ធម្មស្សវនៈណាមិននាំហោច
បើស្តាប់ដោយល្អមានប្រយោជន៍ នាំឲ្យរុងរោចន៍កើតមង្គល។

## **ព្រះគាថាទី ៨**

មាន ៤ មង្គល

**ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ**
**កាលេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ។**

(បទសរភញ្ញ)

សេចក្តីប្រសើរចេះអត់ធន់ ភាវៈជាជនប្រដៅងាយ
បានឃើញសមណៈផងទាំងឡាយ ចូលចិត្តបកស្រាយសាកច្ឆា។
សន្ទនាសាកសួរពីធម៌ពិត ប្រចាំជីវិតគ្រប់ៗគ្នា
បួនកិរិយានេះប្រសើរជា ចាត់ជាមង្គលឧត្តមខ្លាំង។

### **សេចក្តីសម្រាយ**

សេចក្តីអត់ធន់១ ភាវៈនៃបុគ្គលដែលប្រដៅងាយ១ ការជួបប្រទះនូវសមណៈទាំងឡាយ១ ការសន្ទនាទៅវិញទៅមកនូវធម៌តាមកាល១ ទាំង៤ នេះជាមង្គលដ៏ឧត្តម។

## ៨.១ សេចក្តីអត់ធន់

មនុស្សក្នុងលោកយើងនេះមិនអាចជួបតែអ្វីៗដែលជាទីស្រឡាញ់ពេញចិត្តនិងសមទៅតាមតម្រូវការរបស់ខ្លួនរៀងរហូតនោះឡើយ។ ពេលខ្លះសុខ ពេលខ្លះទុក្ខ ជាធម្មតារបស់មនុស្សសត្វ។ ដូច្នេះមនុស្សម្នាក់ៗត្រូវចេះអត់ធ្មត់ រាល់ហេតុការណ៍ទាំងឡាយដែលបានកើតឡើង។

### ប្រភេទនៃសេចក្តីអត់ធន់

.សេចក្តីអត់ធន់ចំពោះ សេចក្តីលំបាកប្រព្រឹត្តិតាមផ្លូវកាយ ដែលកើតឡើងពីរដូវ រងា ក្តៅ ត្រជាក់ ហេវហត់ អស់កម្លាំង ព្រមទាំងការបៀតបៀនពីអ្នកដទៃ។

.សេចក្តីអត់ធន់ចំពោះ សេចក្តីលំបាកប្រព្រឹត្តិតាមផ្លូវចិត្ត

.សេចក្តីអត់ធន់ក្នុងការងារទាំងឡាយ

.សេចក្តីអត់ធន់ក្នុងការសិក្សា

## ២៧.ខន្តី សេចក្តីអត់ធន់

### អត្ថបទកំណាព្យ

ខន្តីមានន័យថាសង្កត់ ព្យាយាមអំណត់នឹងអារម្មណ៍
ស៊ូទ្រាំត្រាំត្រែងចិត្តហៅហំ យកឈ្នះអារម្មណ៍អនិដ្ឋា។
ដូចទ្រាំត្រជាក់ឬរងា ទ្រាំឈឺវេទនាទុក្ខខ្លោចផ្សា
ទ្រាំហត់ទ្រាំនឿយគ្រប់កិរិយា ទ្រាំអ្វីៗណាដែលពិបាក។
នេះគឺខន្តីស្រដីថា អត់ធន់កាយាទ្រាំលំបាក
អត់អន់តាំងចិត្តមិនកំសាក អត់ធន់យកឈ្នះនូវអ្វីៗ។
ខន្តីបើរៀបរាប់ថ្លាថ្លែង សម្តែងថាមានច្រើនយ៉ាងក្តី
ដូច្នេះយើងលើកយកខន្តី មករាយសេចក្តីដូចតទៅ។

### ក.១. ខន្តីទប់ទល់នឹងសេចក្តីក្រោធ

ខន្តីទប់ទល់នឹងអំពើអាក្រក់ ខន្តីទប់ទល់នឹងសម្តីអាក្រក់

ខន្តីបើនឹងស្រដីថ្លែង ចារចែងរៀបរាប់ដោយកាព្យ
អន់ឱនលួសលោះមិនកោធា កុំឲ្យមានពៀរតទៅទៀត។
ចេះខន្តីប្រាជ្ញស្រដីថា ពិតជាមនុស្សាមានមារយាទ
ឈ្នះគ្រប់ឧបសគ្គចងអាឃាត ខន្តីជាស្នៀតទប់យកសុខ។
ខន្តីប្រៀបបានទឹកអម្រិត ប្រោះព្រំសក្តិសិទ្ធិលប់លាងមុខ
ធ្វើឲ្យស្រស់ស្រាយសប្បាយសុខ បន្សាត់អស់ទុក្ខឲ្យសុខស្ពេរ។

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ។** (បិដក ៥២.ទំព័រ ៦៨)

ប្រែថាឈ្នះខឹងដោយមិនខឹង ឈ្នះអាក្រក់ហ្នឹងមិនតតាំង
ប្រព្រឹត្តិឲ្យល្អកាន់តែខ្លាំង អ្នកដែលប្រឆាំងសុំព្រមព្រៀង។
ឈ្នះពាក្យអាក្រក់ដោយស្ដីល្អ ពោលតែស្មោះសពិតទៀងៗ
ធ្វើឲ្យអ្នកផងស្ដាប់ប្រិតប្រៀង ហើយក៏ឈប់រាងតសម្ដី។
ប្ដូរប្រើពាក្យល្អវិញហូរហែ ទាំងយើងទាំងគេល្អវថី
នឹងបានរីករាយជាប្រក្រតី ព្រោះចេះខន្តីប្រណីគ្នា។

**ក.២. ខន្តី**ទប់ទល់នឹងការលំបាកនៃការងារ

ខន្តីទប់ទល់នឹងកិច្ចការ ដែលត្រូវឧស្សាហ៍ធ្វើគ្រប់គ្រា
មិនខ្លាចនឿយហត់ក្ដៅរងា ត្រូវតែពុះពារទាន់នៅក្មេង។
ចង់បានសម្រេចលទ្ធផលល្អ ត្រូវតែត្រដររមិនលេងធេង
មិនដែលមានម្រិគលោតកញ្ជេង ចូលមាត់លេងៗសត្វសិង្ហណា។
ទាល់តែសត្វសិង្ហខំរកស៊ី ព្យាយាមសំភីរកអាហារ
ឯមនុស្សវិញនោះត្រូវធ្វើការ ទើបបានផលាគាប់ចិត្តខ្លួន។

**ក.៣. ខន្តី** អត់ធន់នឹងការសិក្សា

ខន្តីមួយទៀតស៊ូសិក្សា ប្ដេជ្ញាឧស្សាហ៍មិនទំរន់
អត់ធន់រករៀនវិជ្ជាមន្ត ដើម្បីជាទុនលៀងជីវិត។

រៀនធម៌រៀនអាចរៀនវិជ្ជា មិនឲ្យកំព្រាមានគ្នាពិត
វិជ្ជានេះគឺកល្យាណមិត្រ ដឹកនាំជីវិតឲ្យសុខា។
មិនមែនរៀនត្រឹមតែមួយថ្ងៃ តស៊ូអស់ដៃច្រើនឆ្នាំណា
ទំរាំបានចេះគ្រាន់ប្រើការ វិជ្ជាណាៗក៏ដូចគ្នា។
ស៊ូទ្រាំលំបាកព្រោះខ្វះខាត ជួនខំសង្វាតរកការងារ
បានប្រាក់តិចតួចគ្រាន់សិក្សា សោហ៊ុយសោដាត្រូវការច្រើន។
ខំរៀនសូត្រផងធ្វើការផង ទ្រាំទ្រស៊ូរងលំបាកច្រើន
ព្រោះចង់បានចេះចំណេះកើន ចង់បានចុំថ្កើងក្នុងជីវិត។
សង្ឃឹមមាតានិងបិតា តោកយ៉ាកខ្លោចផ្សាដល់កម្រិត
តែចិត្តលោកវិញប្រសើរពិត លោកតែងតែគិតដល់រូបកូន។
តែលទ្ធភាពលោកមិនមានសោះ បានត្រឹមស្រណោះអាណិតកូន
ត្រឹមលើកទឹកចិត្តឲ្យរលួន ចង់ណាស់ឲ្យកូនបានចេះដឹង។
ខ្លះទ្រាំមិនបាននៅគ្រហស្ថ ក៏ដាច់ចិត្តបួសជាព្រះសង្ឃ
បួសហើយក៏តាំងត្រាច់ត្រិបត្រង់ តម្រង់រកស្ថានរៀនសូត្រទៀត។
ក្លាយជាសមណសិស្សសិក្សា សោហ៊ុយសោដាល្មមត្បិតត្បៀត
បិណ្ឌបាតផ្សេផ្សំរិះរកស្មៀត បានរៀនទៅទៀតដល់ថ្នាក់ខ្ពស់។
នេះហៅតស៊ូប្ដូរប្ដេជ្ញា ព្រោះក្ដីមនសិការចិន្ដានោះ
ចង់កសាងខ្លួនឲ្យបានខ្ពស់ រស់ក្នុងកិត្តិយសខ្ពស់ឧត្ដម។

**ឝ.៤. ខន្តី** អត់ធន់យកឈ្នះខ្លួនឯង ឬអប់រំចិត្ត

ខន្តីមួយទៀតធំអស្ចារ្យ អត់ធន់នឹងការកែចរិយា
កែប្រែចិត្តខ្លួនឲ្យរាបសា ពិតជាកិរិយាថ្លៃថ្លាល្អ។

**ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ**
**ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ។** (បិដក ៥២.ទំព័រ ៦៣)

ប្រែថាអ្នកឈ្នះតែងបានពៀរ អ្នកចាញ់វេទនាបាននូវទុក្ខ
អ្នកពីរនាក់នេះមិនបានសុខ ឯអ្នកបានសុខគ្មានចាញ់ឈ្នះ។
ឈ្នះអ្នកដទៃកម្រិតណា មិនសូវបានការគ្រាន់ថាឈ្នះ
ឈ្នះមុនប៉ុណ្ណោះតែដល់ផ្លាស់ មានចាញ់មានឈ្នះតទៅទៀត។
ព្រោះអ្នកដែលចាញ់មិនព្រមស្ងៀម ខំប្រឹងរវាមរកនូវស្នៀត
កូនចៅគេច្រើនប្រឹងប្រែងជ្រៀត គុំចងអាឃាតតទៅទៀត។
**អត្តាហវេ ជិតំ សេយ្យោ** អង្គព្រះពុទ្ធោជាលោកនាថ
ថាឈ្នះខ្លួនឯងទើបជាស្នៀត ទើបជាមារយាទល្អលើសគេ។
ថាឈ្នះខ្លួនឯងឈ្នះអកុសល ឈ្នះកិច្ចឈ្នះកលទ្រុស្តរៀចវេរ
ឈ្នះទាំងកិលេសដែលជាប់ស្ពេរ ស្អិតមិនទំនេរសង្សារវដ្ត ។
តស៊ូលះកាត់នូវតណ្ហា ខំប្រតិបត្តិការណ៍ពិតប្រាកដ
ធ្វើទានសីលភាវនាម៉ត់ចត់ តាមផ្លូវកំណត់អរិយមគ្គ។
ផ្លូវកណ្ដាលនេះមិនលេងធេង ទាល់តែខ្នះខ្នែងយ៉ាងស្មោះស្ម័គ្រ
ខន្តីអត់ធន់ខ្លាំងអស់ថ្នាក់ ទើបបានថាជាក់ឈ្នះខ្លួនឯង។
ខន្តីច្រើនទៀតរាប់មិនអស់ នៅមានចន្លោះពិតជាក់ស្តែង
បើអត់ធន់ល្អវារមែង តែងតែឲ្យបាននូវជោគជ័យ។
ឈ្នះអស់ឧបសគ្គផងទាំងឡាយ ចុងក្រោយរីករាយសុខសួស្តី
ព្រោះចេះខន្តីដ៏ប្រពៃ អ្វីៗកែច្នៃដូចប្រាថ្នា។
ជីវិតរុងរឿងល្អឧត្តម សក្តិសមនឹងចិត្តដែលហានក្លា
ខំស៊ូខន្តីគ្រប់កិរិយា អ្នកប្រាជ្ញចាត់ថាជាមង្គល។

## ៨.២ ភាពជាអ្នកត្រូវប្រដៅងាយ

- ជាអ្នកចេះលះបង់នូវមានះ
- ប្រតិបត្តិតាមសេចក្តីល្អ
- ចង់ធ្វើខ្លួនឲ្យល្អ
- ចង់ស្តាប់សប្បុរស
- ចង់សេពគប់សប្បុរស

អនាគតនឹងក្លាយជាមនុស្សល្អ ប្រកបដោយសុខចំរើន

**លក្ខណៈរបស់មនុស្សប្រដៅងាយ**

-មិនចេះតែប្រើសម្តី បិទបាំងកំហុសខ្លួន

-ប្រឹងប្រែងកែកំហុស ពេលគេទូន្មាន

-មិនសម្លឹងទោសកំហុសអ្នកដទៃ

-គោរពធ្វើតាម និងសម្តែងការអរគុណដល់អ្នកប្រាប់កំហុស

-ជាអ្នកមានការអត់ធន់

**មនុស្សចចេសមានបីប្រភេទ**

-ចចេសព្រោះល្ងង់ខ្លៅ -ចចេសព្រោះទិដ្ឋិមានះ -ចចេសព្រោះខឹងក្រោធ

## ២៨. សោវចស្សតា

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| អ្វីដែលជាសោវចស្សតា | ជនមានកិរិយាប្រដៅងាយ |
| គឺជាលក្ខណៈជនទាំងឡាយ | ចូលចិត្តចង់ក្លាយជាមនុស្សល្អ។ |
| កិរិយានឹងធឹងស្លូតសុភាព | ហាក់ពិតជារាបសាបវរ |
| តែគ្មាល្ងង់ទេកន្លងមក | មិនធ្លាប់រៀនរកសព្វវិជ្ជា។ |
| តែចិត្តចង់ធ្វើខ្លួនឲ្យល្អ | តែងតែសាទរនៅគ្រប់គ្រា |
| បានជួបសប្បុរសពេលសន្ទនា | តែងតែពុះពារស្តាប់ឱវាទ។ |
| ចូលចិត្តប្រាស្រ័យនឹងចាស់ទុំ | រួបរុំជួបជុំហើយសង្វាត |
| ស្តាប់ពាក្យល្អៗជាដើមអាទិ | មិនមែនឲ្យខាតពេលវេលា។ |
| ចរិយាស្លូតបូតមិនឆ្មើងឆ្មៃ | តែងអធ្យាស្រ័យហើយលោះលា |
| មិនសូវប្រកាន់គេផងគ្នា | ឫកសមសោភាជាប្រក្រតី។ |
| មិនច្រឡោងខាមកាងមានះ | ប្រព្រឹត្តិផ្តេសផ្តាសមិនគប្បី |
| តែងបង្អោនខ្លួនជាប្រក្រតី | ឲ្យអ្នកដទៃគេមេត្រី។ |

អ្នកណាក៏គេតែងចូលចិត្ត ចរចូលទៅជិតគិតប្រាស្រ័យ
ចង់ឲ្យឃោបល់ល្អប្រពៃ ដោយមាននិស្ស័យចង់រាប់អាន។
ហើយជនដែលត្រូវប្រដៅងាយ តែងតែរួសរាយមិនរំខាន
ទទួលញាតិមិត្រទាំងប៉ុន្មាន ព្រមទទួលបានទាំងសម្តី។
យកទៅពិចារណាហ្មត់ចត់ ច្បាស់ហើយអនុវត្តដោយសេរី
កាត់ក្តីអាក្រក់មិនសំចៃ លកលៃកែច្នៃយកកុសល។
អនាគតអាចក្លាយជាមនុស្សល្អ ជោគជ័យបវរនឹងមានដល់
ព្រោះតែចរិតមិនអំពល់ មិនប្រកាន់ដល់គេទូន្មាន។
គិតឃើញពុទ្ធពាក្យណាប្រសើរ គួរដើរត្រូវដើរតាមលំអាន
ចំណែកពាក្យណាមិនសំខាន់ នាំឲ្យរំខានទាត់ចោលទៅ។
ចិត្តល្អធម្មតាតែដូច្នោះ មិនតប្រទូសធ្វើចិត្តក្តៅ
សព្វថ្ងៃត្រងត្រាប់ពាក្យប្រដៅ យកតាមសំណៅជនបណ្ឌិត។
ប្រតិបត្តិសាងល្អជាបណ្តើរ មិនដែលចេះធ្វើស្រេចនឹងចិត្ត
មុននឹងធ្វើអ្វីតែងចេះគិត តែងតែប្រតិបត្តិតាមព្រះធម៌។
ព្រះធម៌ដឹកនាំឲ្យសាងល្អ ចិត្តល្អកាយល្អវាចាល្អ
ឲ្យសាងតែសប្បុរសធម៌ បានជាមនុស្សល្អដ៏ប្រសើរ។
នេះហៅថា សោវចស្សតា ដំបូងនោះណាមិនគ្រាន់បើ
តែឫករាបទាបតាមដំណើរ ស្លូតបូតប្រសើរមិនអុងអាត់។
ចិត្តស្លូតសុភាពគ្មានមានះ តែងតែរូតរះប្រុងប្រយ័ត្ន
ស្តាប់ប្រាជ្ញទូន្មានដោយម៉ឺងម៉ាត់ ប្រតិបត្តិលះកាត់អកុសល។
ក្លាយជាមនុស្សល្អដ៏ប្រសើរ ដំណើរជីវិតបានមង្គល
ព្រោះចរិតល្អជាប់កុសល ចិត្តនោះដាក់ដល់**សោវចស្សតា**។

## ៨.៣ ប្រភេទនៃការឃើញសមណ

១.ឃើញរូបសមណ  ដែលលះបង់ការលំអរូបសម្ផស្សមានការស្លៀកសំពត់កាសាវពស្ត្រ និងកោរសក់ជាដើម។

២. ឃើញកាយវិការសមណ សុភាពស្លូតបូត

៣. ឃើញការប្រតិបត្តិ  តាមកាយវាចានិងចិត្តល្អ

៤. ឃើញមានអារម្មណ៍ពេញចិត្តនឹងសមណ

៥. មានសទ្ធាមាំទាំនឹងពុទ្ធសាសនា

៦. ប្រតិបត្តិត្រឹមត្រូវខ្លួនឯង

៧. ក្លាយជាមនុស្សល្អមានមង្គលក្នុងជីវិត។

**២៩. សមណានញ្ច ទស្សនំ** កិរិយាបានឃើញសមណៈ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| កិរិយាបានឃើញនូវសមណៈ | ឃើញនោះប្រត្យក្សដោយភ្នែកសាច់ |
| ឯឃើញម្យ៉ាងទៀតឃើញដោយធ្មេច | ឃើញដោយការគិតក្នុងអារម្មណ៍។ |
| ឃើញផ្សេងៗទៀតដោយបញ្ញា | ពិចារណាពិស្តារដោយសច្ចសម |
| បញ្ញាត្រិះរិះប្រមូលផ្តុំ | ដៅយ៉ាងសំណំឆ្ពោះសមណៈ។ |
| ឃើញរូបសមណៈរៀបរយល្អ | ទ្រទ្រង់ចីវរកាសាវពស្ត្រ |
| សក់នោះកោរកាត់មិនមានសោះ | មើលរូបសម្ផស្សគួរទុកចិត្ត។ |
| សង្កេតកាយវិការពួកសមណៈ | ទោះដេកដើរដាក់គួរចូលចិត្ត |
| សុភាពស្លូតបូតល្អពិតៗ | កបដោយចរិតស្មោះត្រង់ល្អ។ |
| ឃើញការប្រតិបត្តិនៃសមណៈ | កាយវាចាជាក់ចិត្តស្មោះស |
| ប្រព្រឹត្តិបែបណាឃើញថាល្អ | មិនមានវីវរនឹងអ្វីឡើយ។ |
| សមណៈមិនមានចេះលួចប្លន់ | មិនមានបន្លំអ្វីៗឡើយ |
| មានតែកាន់សីលច្បាស់លះហើយ | ទោះធ្វើអ្វីដោយមានកំណត់។ |
| អាជីវបារិសុទ្ធិសីល | ពីររយម្ភៃប្រាំពីរសិក្ខាបទ |

| | |
|---|---|
| ព្រមទាំងអាបត្តិតែងកំណត់ | ប្រតិបត្តិហ្មត់ចត់គួរជ្រះថ្លា។ |
| ប្រតិបត្តិផ្លូវចិត្តក៏ល្អឯក | អភិជ្ឈាចម្លែកដែលឫស្យា |
| ព្យាបាទ ទិដ្ឋិ ក៏សម្មា | ប្រឹងប្រតិបត្តិការណ៍តែកុសល។ |
| ដីកាល្អឯកប្លែកពីរោះ | វាចាទ្រគោះមិនឲ្យយល់ |
| ពោលតែពាក្យល្អដែលឲ្យផល | ឲ្យនូវសុខសល់ប្រសើរណាស់។ |
| សព្វថ្ងៃខំរៀនធម៌សាសនា | ធ្វើតាមពុទ្ធដីកាសាស្តាម្ចាស់ |
| ជួយទាំងសង្គមតាមផ្លូវព្រះ | និងខំរូតរះជួយសាសនា។ |
| ប្រតិបត្តិបានសុខទាំងខ្លួនឯង | ព្រមទាំងកោតក្រែងអស់មនុស្សម្នា |
| ប្រតិបត្តិឲ្យសុខគេគ្រប់គ្នា | ដើរតាមមាគ៌ាព្រះសាសនា។ |
| អំពើដ៏ល្អនៃសមណៈ | អ្នកណាឃើញជាក់តែងជ្រះថ្លា |
| ចូលចិត្តសរសើរហើយបូជា | ដោយមានសទ្ធាជានិរន្តរ៍។ |
| សទ្ធាដល់ទៅពុទ្ធសាសនា | ពុទ្ធ ធម៌ សង្ឃា ជា**សរណំ** |
| ប្រិតប្រៀងសាងធម៌ជាប្រចាំ | បានសុខសួស្តីសមក្នុងលោកនេះ។ |
| អញ្ចឹងបានជាមានពុទ្ធដីកា | ថាគឺកិរិយាឃើញសមណៈ |
| បើបានឃើញហើយមានចិត្តស្ម័គ្រ | ប្រតិបត្តិជឿជាក់កើតមង្គល។ |

**៨.៤ ការប្រជុំពិភាក្សា សន្ទនា បញ្ចេញនូវទស្សនៈ តាមកាល** ជាមង្គលដ៏ឧត្តម អង្គប្រកបនៃអ្នកជជែក

-និយាយពាក្យពិតត្រង់ មិនមូលបង្កាច់យកឈ្នះចាញ់

-និយាយពាក្យពីរោះ ផ្អែមល្ហែម មិនគំរាមកំហែងអ្នកដទៃ

-និយាយដោយចិត្តមេត្តា មិនមើលងាយអ្នកដទៃ

-និយាយតាមកាលៈទេសៈ

## ៣០. **ភាគលេខ ធម្មសាកច្ឆា** កិរិយាសន្ទនាធម៌តាមកាល

**ក**. ការសន្ទនាធម៌និងចេតនានៃអ្នកសន្ទនា

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

អ្វីទៅហៅធម្មសាកច្ឆា? គឺជាកិរិយាសន្ទនាធម៌
សន្ទនានេះស្ថិតលើជំហរ អ្នកសន្ទនាធម៌ជាមួយគ្នា។
បើអ្នកសន្ទនាទាំងអស់នោះ មានសទ្ធាស្មោះនិងចេតនា
ចង់ចេះចង់ដឹងគ្រប់ៗគ្នា នោះកិច្ចសន្ទនាមានប្រយោជន៍។
បើខ្លះបកស្រាយមិនទាន់ច្បាស់ មិនបានស្រឡះច្បាស់រុងរោចន៍
មួយជួយតម្រូវឲ្យប្រយោជន៍ មិននាំឲ្យខូចការសន្ទនា។
គួរប្រើពាក្យល្អដោយមេត្តា មានសោមនស្សានឹងធម្មា
មេត្តាគ្រប់គ្នាអ្នកសន្ទនា ប្រែក្លាយពេលាជាមនោរម្យ។
ធ្វើល្អទើបហៅសាកច្ឆា រួមពិភាក្សានូវព្រះធម៌
បើសួរផ្ចាញ់ផ្ចាលគឺមិនល្អ នាំកើតវឹកវរមានទោសា។
ខុសន័យនឹងធម្មសាកច្ឆា និយាយធម៌អាចគ្មានជ្រះថ្លា
មិនទាន់បានល្អដោយចេតនា គឺជាសាកច្ឆាដោយថ្នាំងថ្នាក់។
បើធ្វើធម្មសាកច្ឆា គឺពិចារណាដោយត្រជាក់
ដោយមានសទ្ធាចិត្តស្មោះស្ម័គ្រ ផលល្អប្រត្យក្សផ្តល់ឲ្យច្រើន។

**ខ. ផលនៃការសន្ទនាធម៌**

ផលនៃធម្មសាកច្ឆា ញឹកញាប់ផងណាបានចំរើន
នាំស្គាល់ព្រះធម៌កាន់តែច្រើន នឹងបានជឿនលឿនហើយជ្រះថ្លា។
នាំឲ្យយល់ច្បាស់នូវធម៌ចាស់ មុននោះមិនច្បាស់ដោយបញ្ញា
ថែមទាំងឲ្យចេះធម៌ថ្មីណា ព្រមទាំងធម៌អាចជាច្រើនទៀត។
ឲ្យបានយល់ច្រើននូវព្រះធម៌ ជាមាគ៌ាល្អដែលមានស្មៀត
ចេះចាំបានច្បាស់មិនរវៀត ចិត្តមិនឲ្យឃ្លាតពីព្រះធម៌។

| | |
|---|---|
| ចេះហើយប្រតិបត្តិបានល្អជា | ធម៌ព្រះឈ្នះមារដ៏បវរ |
| កំទេចអកុសលគ្រឿងកករ | កុំឲ្យវាមកបានដោយពិត។ |
| នឹងបានក្ដីសុខដ៏ប្រសើរ | នៅក្នុងដំណើរនៃជីវិត |
| ព្រោះសាកច្បាយល់ធម៌ពិត | ញុំាងឲ្យជីវិតកើតមង្គល។ |

## កំណាព្យ ពណ៌នាពីសារៈខ្លះនៃព្រះធម៌

**ក.សព្វទានំ ធម្មទានំ ជិនាតិ** បណ្ដាទានទាំងឡាយ ការឲ្យទានធម៌ឈ្នះអស់ទានទាំងពួង

(បទកាកគតិ)

| | | |
|---|---|---|
| ធម៌ព្រះសម្ពុទ្ធ | ថ្លៃថ្លាវិសុទ្ធ | ជំរះកិលេស |
| លាមកស្មោកគ្រោក | នៃមនុស្សលោកនេះ | ដើម្បីឲ្យចេះ |
| | ប្រព្រឹត្តិខាងល្អ។ | |
| ចៀសវាងអកុសល | កុំបីខ្វាយខ្វល់ | នឹងទុច្ចរិតធម៌ |
| សាងចិត្តសាងកាយ | វាចាឲ្យល្អ | នេះគឺគាំទ្រ |
| | ដល់ធម៌ព្រះពុទ្ធ។ | |
| ចេះធ្វើនូវទាន | សព្វថ្ងៃតែងមាន | សទ្ធាមោះមុត |
| ប្រព្រឹត្តិនូវសីល | ភាវនាបរិសុទ្ធ | បំរុងផ្គង់ផ្គត់ |
| | ទាំងបច្ច័យបួន។ | |
| ឧបត្ថម្ភសាសនា | ព្រះធម៌សង្ឃា | គ្រប់ទិសទាំងបួន |
| ចិញ្ចឹមមាតា | បិតានៃខ្លួន | ធ្វើល្អផ្ទួនៗ |
| | តាមព្រះពុទ្ធធម៌។ | |
| ធ្វើទាំងធម្មទាន | សទ្ធានោះមាន | យល់ធម៌បវរ |
| ប្រិតប្រៀនប្រឹងស្ដាប់ | សិក្សាដោយល្អ | ព្យាយាមបង្ក |
| | ការសន្ទនា។ | |

ធ្វើសាកច្ឆា សន្ទនាធម៌អាថ៌ ពិចារណ៍ធម្មា
តាមពុទ្ធតម្រាស់ មិនឲ្យឃ្លាតឃ្លា ខំអារាធនា
ធម៌មកសម្ដែង។

មកបរិយាយ មកអធិប្បាយ ឲ្យបានជាក់ស្ដែង
បង្ហាញផ្លូវល្អ លើកមកសម្ដែង ច្បាស់ដូចសូរ្យសែង
បំភ្លឺមាគ៌ា។

ធម៌ព្រះរះហើយ កុំបីកន្តើយ គួរតែពុះពារ
ប្រតិបត្តិតាមធម៌ នៃព្រះភគវា នោះជាមាគ៌ា
ថ្លៃថ្លាឧត្ដម។

បង្ហាញព្រះធម៌ មាគ៌ាដ៏ល្អ បវរសក្ដិសម
គឺធ្វើធម្មទាន ផ្ដល់ស្ថានឧត្ដម បានឆ្លងជួបជុំ
ទៅបរមសុខ។

ការឲ្យនូវធម៌ ជាអំពើល្អ គឺឲ្យនូវសុខ
ឲ្យបានប្រតិបត្តិ ចៀសវាងនូវទុក្ខ បច្ចុប្បន្នក៏សុខ
ទៅមុខដូចគ្នា។

ព្រះពុទ្ធដីកា ថាឲ្យធម៌អាថ៌ គឺឲ្យមាគ៌ា
ទៅបរមសុខ អមតធម្មា ដូចព្រះភគវា
បានត្រាស់មកថាៈ

**អមតន្ទទោ ច សោ ហោតិ យោ ធម្មនុស្សា សតិ** ការឲ្យនូវធម៌គឺឲ្យនូវអមតមហានិព្វាន។

**ខ. សព្វរសំ ធម្មរសោ ជិនាតិ** រសព្រះធម៌ឈ្នះអស់រសទាំងពួង

(បទកាកគតិ)

រឹងអាហារ ចំណីភោគ្គា សព្វគ្រប់ទាំងឡាយ

តែងមានរសប្លែក ប្លែកដោយបរិយាយ ត្រូវអធ្យាស្រ័យ
ខ្លះក៏ខុសចិត្ត។

ខ្លះល្វីងខ្លះជូរ ខ្លះចត់ខ្លះប្លូរ ប្រែជាផ្អែមពិត
ខ្លះសាបខ្លះប្រៃ ខ្លះឈ្ងុយប្រណីត ខ្លះក៏ត្រូវចិត្ត
ខ្លះក៏ត្រូវមាត់។

រសអ្វីយ៉ាងណា ទោះឆ្ងាញ់ពិសារ វាមិនប្រាកដ
ជួនឆ្ងាញ់មិនឆ្ងាញ់ តាមគេកំណត់ គេបានសន្មត
ដោយចិត្តទីទៃ។

រីឯព្រះធម៌ រសល្អបវរ សែនហៅប្រពៃ
បង្ហាញផ្លូវសុខ សិរីសួស្តី ធម៌ព្រះជិនស្រី
ធម៌ថ្លៃសច្ចៈ។

ធម៌នាំឲ្យសុខ ពេលនេះទៅមុខ បានសុខប្រត្យក្ស
បាននូវប្រយោជន៍ បានក្តីសុខៈ បើសិនជឿជាក់
តាមព្រះធម្មា។

តាមព្រះធម៌ហើយ ពិតជាមិនឆ្លោយ ឈ្លើយខុសមាត្រា
នឹងបាននូវបុណ្យ សក្តិសមសោភា បរិស័ទគ្រប់គ្នា
រមនាសុខសាន្ត។

នេះរសព្រះធម៌ នាំគ្នាឈ្នះឈ្នះ ប្រតិបត្តិគ្រប់ប្រាណ
នឹងបានក្តីសុខ គ្មានក្តីរំខាន ជនគ្រប់ៗប្រាណ
បានសុខសិរី។

ព្រះធម៌ឲ្យសុខ ប្រតិបត្តិទៅមុខ បានជាប្រក្រតី
ហៅរសព្រះធម៌ ឈ្នះអស់រសអ្វី រសក្នុងលោកិយ
គ្មានរសអ្វីស្មើ។

## គ. ពន្លឺព្រះធម៌ឈ្នះអស់ពន្លឺនានា (បទបឋ្យាវ័ត)

រីឯចង្កៀង ប្រិតប្រៀងបញ្ឆោះ អុជទៅវាចេះ ជះនូវពន្លឺ
ពន្លឺភ្លើងគប់ អុជឡើងស៊ីៗ បានជាពន្លឺ ទ្រោលបង្អើលសត្វ។
ពន្លឺប្រទីប និងអគ្គិសនី គេបានសំភី ធ្វើមកមធ្យត
យកមកប្រើជា ពន្លឺផ្វែលឆ្វាត់ ដែលគួរឲ្យចាត់ ថាគ្រាន់បើមែន។
ពន្លឺសុរិយា ពន្លឺចន្ទ្រា ផ្កាយច្រើនគណនា ទាំងពាន់ម៉ឺនសែន
ភ្លឺតិចភ្លឺខ្លាំង សុទ្ធមានព្រំដែន អ្នកប្រាជ្ញវាស់វែង ដឹងខ្លះៗបាន។
ពន្លឺទាំងនោះ កំចាត់អន្ធការ បានភ្លឺមែនណា ដូចមានសូរ្យឆាន
រះបំភ្លឺលោក គួរឲ្យថ្កើងថ្កាន គួរតែសុខសាន្ត ជានិច្ចតទៅ។
តែគ្រាន់តែភ្លឺ វាមិនបានសុខ សត្វរស់ក្នុងទុក្ខ ទុក្ខសែនសោកសៅ
ទុក្ខនេះហៅទុក្ខ អន្លង់ជ្រោះជ្រៅ ទុក្ខធ្លាប់ស្ថិតនៅ នាវដ្តសង្សារ។
ព្រះពុទ្ធបានត្រាស់ នូវព្រះធម្មា តួអង្គភគវា បានផ្សាយសាសនា
សម្តែងព្រះធម៌ ចែងចាំងអត្ថា កំចាត់អន្ធការ គឺអវិជ្ជា។
ព្រះធម៌រះហើយ ពន្លឺចុងរោចន៍ គ្មានអ្វីភ្លឺដូច ដូចព្រះធម្មា
បើកបង្ហាញសត្វ នូវហេតុនានា ដែលនាំវេទនា វេរាទុក្ខា។
បង្ហាញនូវហេតុ ដែលនាំមានទុក្ខ បង្ហាញគ្រប់មុខ នូវទុក្ខនានា
បង្ហាញបញ្ច- ក្ខន្ធាទុក្ខា បង្ហាញអស់អាថ៌ នាំឲ្យផុតទុក្ខ។
ធម៌បង្ហាញផ្លូវ ទៅសុខនិព្វាន ធម៌ព្រះទ្រង់ញាណ ទ្រង់ជាប្រមុខ
អដ្ឋង្គិកមគ្គ ជាផ្លូវនាំសុខ នាំចូលសំរុក និព្វានសុខា។
ព្រះធម៌នេះហើយ មានពន្លឺខ្លាំង ធម៌ព្រះរះចាំង លើដែនលោកា
អាចទ្រោលបំភ្លឺ ឲ្យបានសុខា គ្មានពន្លឺណា ឲ្យភ្លឺដូចធម៌។
មានតែពន្លឺ ព្រះធម៌ជាម្ចាស់ ពិតជាភ្លឺច្បាស់ ជំរះកង្ខា
កំចាត់អវិជ្ជា មារមោហន្ធការ ទើបអាចហៅថា ភ្លឺឈ្នះលើសគេ។

សរុបទាំងបួន ស្ងួនព្រះគាថា ខន្តីនោះណា សោវចស្សតា
ឃើញទាំងសមណៈ និងសាកច្ឆា សន្ទនាធម៌អាថ៌ សិក្សាជាក់ស្តែង។
សិក្សាប្រតិបត្តិ បួនចំណុចនៃ ធម៌ព្រះជិនស្រី ដែលទ្រង់សម្តែង
នឹងបានសួស្តី សិរីក្រៃលែង ព្រះពុទ្ធទ្រង់ថ្លែង ថាជាមង្គល។

## ព្រះគាថាទី ៩

មាន ៤ មង្គល

**តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ**
**និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ។**

(បទពាក្យ៧)

សេចក្តីព្យាយាមដុតបាបធម៌ កិរិយាដ៏ល្អប្រសើរខ្លាំង
ប្រតិបត្តិនូវធម៌ជា**សរណំ** វិសេសក្លាខ្លាំងអចិន្ត្រៃយ៍។
កិរិយាឃើញនូវអរិយសច្ចៈ មិនមានស្រពិចស្រពិលន័យ
កិរិយាបានផលដ៏ក្រៃក្រៃ ជាក់ច្បាស់នូវន័យព្រះនិព្វាន។
កិរិយាបួននេះប្រសើរគាប់ ដែលគួរតែអប់រំឲ្យមាន
មានហើយទើបបានទៅជាយាន ឈានដល់មង្គលល្អស្ថិតស្ថេរ។

### សេចក្តីសម្រាយ

សេចក្តីព្យាយាមដុតនូវបាបធម៌១ ការប្រព្រឹត្តិនូវធម៌ដ៏ប្រសើរ១ ការឃើញនូវអរិយសច្ចទាំងឡាយ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន១ នេះជាមង្គលដ៏ឧត្តម។

**៩.១ សេចក្តីព្យាយាមដុតនូវបាបធម៌** មានលោភៈទោសៈមោហៈជាមូល

អកុសលទាំងអស់នេះមាននៅក្នុងសន្តានចិត្តមនុស្សគ្រប់រូប ព្រះសម្មាសម្ពុទ្ធទ្រង់បានប្រៀនប្រដៅយើង ឲ្យព្យាយាមលះបង់អកុសលធម៌ ខំសន្សំកុសលឲ្យដល់ព្រម កុំប្រមាទ (ធ្វេស)ក្នុងទីទាំងពួង។

ដើម្បីលះបង់អកុសលធម៌ដែលមាននៅក្នុងសន្តានចិត្ត ដោយធ្វើអាការៈបែបនេះ

-ការឲ្យទាន

-រក្សាសីល

-ចម្រើនភាវនា

**៣១. តបោ** ការដុតនូវបាបធម៌ អត្ថបទកំណាព្យ (បទបង្សាវត)

| | | | |
|---|---|---|---|
| អំពើអាក្រក់ | ដក់នៅក្នុងចិត្ត | កាយវាចាពិត | មានជាប្រក្រតី |
| មិនងាយលះកាត់ | ទេនូវអ្វីៗ | ជារឿងអប្រិយ | មិនប្រណីគ្នា។ |
| មានក្នុងសត្វលោក | ច្រើនគគោកម្លេះ | ដែលគួរត្រិះរិះ | ឲ្យបានគ្រប់គ្រា |
| កំទេចឲ្យអស់ | វានាំវេទនា | ដល់សត្វគ្រប់គ្នា | ឈ្មោះវាថាបាប។ |
| អំពើបាបនោះ | មានឈ្មោះអ្វីខ្លះ | យើងគួររូតរះ | រៀបរាប់រៀងរៀប |
| រាប់ឲ្យបានដឹង | ហើយខំបន្សាប | កុំធ្វើនូវបាប | ដូចតទៅនេះ។ |
| មានលួចមានប្លន់ | មានចាក់មានកាប់ | មានទាំងសម្លាប់ | យកតែពីឈ្នះ |
| រំលោភឈ្លានពាន | ឲ្យតែពើបពះ | កុហកប្រោកប្រាស | ប្រព្រឹត្តិខុសឆ្គង។ |
| បើរកស៊ីវិញ | រកស៊ីខុសច្បាប់ | ភ្នែកចាក់ក្រឡាប់ | ហាក់ខុសទំនង |
| មិនជួញអ្វីល្អ | ជួញថ្នាំញៀនផង | តែងផ្លោះរបង | ប៉ូលីសដេញចាប់។ |
| ជួញស្រីជួញស្រា | ជួញអ្វីតែខុស | ធ្វើឲ្យប្រទូស | អាក្រក់អួរអាប់ |
| បើលក់ថ្នាំខ្មែរ | លក់ថ្នាំបោកប្រាស | បានលក់អ្វីខ្លះ | ស៊ីភ្នែកជញ្ជីង។ |
| ចូលចិត្តលេងល្បែង | ល្បែងអបាយមុខ | ស៊ីសងសព្វគ្រប់ | ជួនចាញ់រលីង |
| ក៏តាំងលួចឆក់ | របស់គេឯង | គ្មានក្តីកោតក្រែង | ច្បាប់រដ្ឋឡើយណា។ |
| កាយក៏មិនល្អ | វាចាអាក្រក់ | កិត្តិយសកខ្វក់ | មិនចេះរាបសា |
| ចិត្តជួយោរយៅ | កំឡៅឫស្យា | ព្យាបាទផងណា | ចងអាឃាតគេ។ |

| | | | |
|---|---|---|---|
| ចេះតែច្រណែន | ចេះតែនិន្ទា | នឹងគេរាល់គ្នា | នៅមិនសុខទេ |
| បើយ៉ាងហោចណាស់ | ក៏តែងរិះរេ | និយាយដើមគេ | មិនដាច់ពីមាត់។ |
| អំពើអាក្រក់ | កើតពីកិលេស | ដែលមនុស្សបានចេះ | ធ្វើយ៉ាងប្រាកដ |
| កិលេសច្រើនយ៉ាង | ខ្លាំងក្លាអំណត់ | តែបើសន្មត | ហៅថាអាសវៈ។ |
| អាសវៈកិលេស | ចេញពីលោភៈ | ទោសៈមោហៈ | កំពូលអស់ថ្នាក់ |
| គឺជាមូលហេតុ | នៃអាសវៈ | ដែលយើងស្គាល់ជាក់ | មានច្បាស់ក្នុងធម៌។ |
| ហៅថា តបោ | គឺដុតកិលេស | ពួកអាសវៈនេះ | ដុតវាឲ្យមរណ៍ |
| កំចាត់លោភៈ | ទោសៈមោហោ | ត្រូវប្រតិបត្តិយក | តាមធម៌ព្រះពុទ្ធ។ |
| ម្យ៉ាងទៀតតបោ | កំចាត់ឲ្យអស់ | អំពើអាក្រក់ | វានាំទោសទុក្ខ |
| ហើយសាងកុសល | ដែលផ្តល់នូវសុខ | ពីនេះទៅមុខ | បាននូវមង្គល។ |

## ៩.២ ការប្រតិបត្តិនូវធម៌ដ៏ប្រសើរ

ព្រហ្មចរិយធម៌ មកពី ព្រហ្ម + ចរិយ + ធម៌ = ការប្រព្រឹត្តិធម៌ដ៏ប្រសើរ អំពើល្អទាំងអស់សុទ្ធតែជាធម៌ដ៏ប្រសើរ តែអ្នកប្រាជ្ញលោកលើកឲ្យឃើញច្បាស់ហើយ លេចធ្លោឡើងគឺមានកាមរាគៈ ព្រោះមិនងាយសត្វណាអាចរំលងបាន ដូច្នេះ បានជាក្នុង សីល ៨ មានសិក្ខាបទថា អព្រហ្មចរិយា វេរមណី បានសេចក្តីថា វៀរចាកការប្រព្រឹត្តិធម៌មិនប្រសើរគឺ កាមរាគ ក្នុងន័យនេះគ្រហស្ថដែលជាអ្នកចេញចាកកាមដោយប្រព្រឹត្តិ សីល ៥ ឬ សីល ៨ ឬ សីល ១0 លោកចាត់ថាជាអ្នកប្រតិ-បត្តិព្រហ្មចរិយធម៌ ជាន់ទាបនិងជាន់កណ្តាល។ ចំណែកអ្នកបួស (ភិក្ខុ សាមណេរ) ដែលចេញចាកកាមពិតប្រាកដ នោះគឺជាអ្នកដែល ប្រតិបត្តិនូវព្រហ្មចរិយធម៌ ជាន់ខ្ពស់បំផុត ព្រហ្មចរិយៈ ចែកចេញជា ៖

### ១. សាសនព្រហ្មចរិយ

សាសនាទូន្មានធម៌ដ៏ប្រសើរបំផុត ជាសាសនាបង្ហាញធម៌វិន័យ ដើម្បីដឹកនាំសត្វឲ្យធ្វើល្អចៀសអំពើអាក្រក់ និងពន្យល់ឲ្យនឿយណាយក្នុងសំសារវដ្ត។ មានគោលដៅ ចុងបញ្ចប់សម្រេចដល់ស្ងប់ផុតទុក្ខទោសទាំងពួង គឺដល់ព្រះនិព្វានជាទី

អវសាន។ សាសនានេះដឹកនាំបង្ហាញទោសនៃសេចក្តីសុខបណ្តោះអាសន្នក្នុងលោកដែលប្រកបដោយ រាគៈ ទោសៈ មោហៈ និងកំចាត់បង់នូវសេចក្តីទុក្ខទោមនស្ស សេចក្តីចង្អៀតចង្អល់គ្រប់បែបយ៉ាង។ ការទូន្មានដូច្នេះមានតែពុទ្ធសាសនាដែលជាសាសនាបង្ហាញផ្លូវដ៏ប្រសើរ ដើម្បីសម្រេចយកបរមសុខ ផ្លូវនោះហៅថា មគ្គព្រហ្មចរិយៈ។

## ២. មគ្គព្រហ្មចរិយៈ

មគ្គដ៏ធំចំបងក្នុងពុទ្ធសាសនាជាផ្លូវដ៏ប្រសើរ ឈ្មោះថាអរិយមគ្គ គឺជាមាគ៌ាប្រាំបីប្រការ។ ផ្លូវប្រាំបីប្រការនេះឈ្មោះម្យ៉ាងទៀតថា ជានិរោធគាមិនី បដិបទា អរិយសច្ចៈ ជាផ្លូវប្រតិបត្តិដើម្បីរំលត់នូវសេចក្តីទុក្ខ។ ផ្លូវទាំងប្រាំបីប្រការសរុបឲ្យខ្លីមាន ៣ គឺ **សីល សមាធិ** និង **បញ្ញា** ដែលពុទ្ធសាសនិកព្យាយាមប្រតិបត្តិ។ ចំណែកពុទ្ធសាសនិកជាអរិយបុគ្គលដែលមាន ឧបនិស្ស័យកសាងសន្សំ អំពើល្អយូរយាមកហើយ (ច្រើនជាតិ) ដែលបានប្រតិបត្តិដល់ អធិសីល, អធិចិត្ត, អធិបញ្ញា អាច សំរេចមគ្គផល មាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគា-មិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផលច្រើនជាអនេក កន្លង មកហើយ។

ប្រភេទនៃព្រហ្មចរិយធម៌

**-ព្រហ្មចរិយថ្នាក់ទាប** បានដល់គ្រហស្ថ អ្នកគ្រប់គ្រងផ្ទះ មានបុត្រ ភរិយា ឲ្យទាន រក្សាលីល ៥ មិនប្រព្រឹត្តិផិតក្បត់ ភរិយាស្វាមី។

**-ព្រហ្មចរិយថ្នាក់កណ្តាល** បានដល់គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ រក្សាសីល ៨ ក្នុងថ្ងៃ ឧបោសថ សីល ចម្រើនភាវនា អប់រំចិត្ត។

**-ព្រហ្មចរិយថ្នាក់ខ្ពស់** បានដល់បព្វជិត និងគ្រហស្ថ បើគ្រស្ថជាអ្នករក្សាសីល៨អស់មួយជីវិត។

## ៣២. **ព្រហ្មចរិយ** ការប្រព្រឹត្តិនូវព្រហ្មចរិយធម៌

**អត្ថបទកំណាព្យ ព្រហ្មចរិយធម៌** (បទកាកគតិ)

នេះព្រហ្មចរិយា ប្រតិបត្តិជ្រះថ្លា តាមធម៌ព្រះពុទ្ធ
ជាធម៌ដ៏ល្អ ធម៌ថ្លៃវិសុទ្ធ ប្រតិបត្តិមោះមុត
បានក្តីសុខា។

ល្អទាំងកាយចិត្ត វាចានោះពិត ពីរោះណាស់ណា
ទោះប្រព្រឹត្តិអ្វី តែងសោមនស្សា មិនដែលព្នថា
ឲ្យទុក្ខគេឯង។

ល្អសីលល្អសម ចិត្តនោះរមទម្យ ចេះកោតចេះក្រែង
ចិត្តសល្អស្អាត វាចាសម្តែង កាយក៏រអែង
ធ្វើតែខាងល្អ។

ព្រហ្មចរិយធម៌ មានធម៌បវរ ជាគូសម្តែង
ធម៌គូនឹងសីល ជាធម៌ល្អឯង ធម៌នោះក៏តែង
ឲ្យគេបានសុខ។

បាណាតិបាត មានធម៌ល្អស្អាត ដែលបាននាំមុខ
មេត្តាករុណា សុទ្ធតែឲ្យសុខ ពីនេះទៅមុខ
ឈប់សម្លាប់ទៀត។

អទិន្នាទាន លួចគេគឺគ្មាន បំណងចង់ឆ្លៀត
ព្រោះមានមេត្តា មិនលោភរកស្មៀត បើចង់យកទៀត
ទាល់តែគេឲ្យ។

កាមេសុមិច្ឆា បន្ថយកាមា ឲ្យស្រោលស្ទើងហើយ
កាមាទីនវៈ ធម៌នេះដឹងហើយ គួរគិតមុខក្រោយ
កុំបណ្តោយខ្លួន។

មុសាវាទៈ កុហកបោកប្រាស់ ផ្ដាច់វាឲ្យហើយ
ព្រោះធម៌សច្ចៈ នៅជិតបង្កើយ បើប្រុងភរហើយ
ឲ្យនឹកសច្ចៈ។

**សុរាមេរ័យ** ផឹកស៊ីរាល់ថ្ងៃ ត្រូវផ្ដាច់ឲ្យខះ
នឹកធម៌អប្បមាទ ឲ្យឃើញប្រត្យក្ស វាផ្ដល់គ្រោះថ្នាក់
ឲ្យទុក្ខគេឯង។

មេត្តាករុណា **អប្បមាទធម្មា** ព្រះទ្រង់សម្ដែង
ធម៌ផ្សេងៗទៀត គួរតែរអែង ប្រតិបត្តិល្អស្ដែង
តាមព្រះសាសនា។

នេះហៅសាសនះ ព្រហ្មចរិយៈ គឺជាសាសនា
សាសនាព្រះពុទ្ធ មានគុណករុណា ចាំយកអាសា
អស់សំសារសត្វ។

សត្វមានសទ្ធា ជឿជាក់គ្រប់គ្នា ល្អពិតប្រាកដ
ប្រតិបត្តិជាក់ស្ដែង មាំមួនហ្មត់ចត់ ច្បាស់មិនកំសត់
បានរួចទុក្ខភ័យ។

រួចទាំងលោកនេះ មិនមានសំគិះ សុខទាំងដល់ព្វ-
បរលោកនាយ ក៏គ្មានទុក្ខអ្វី បានសុខក្រាស់ក្រៃ
ដល់សុខនិព្វាន។

ព្រោះមានមាគ៌ា កំចាត់គ្រប់គ្រា នូវទុក្ខឈ្លានពាន
ព្រោះធ្វើតែល្អ មិនឡើយបំពាន ធ្វើតែអ្វីមាន
នូវកម្មកុសល។

កុសលកម្ម ពិតជារង់ចាំ ឲ្យវិបាកផល
ឲ្យនូវផលសុខ ដរាបដាក់ដល់ សុខអស់កង្វល់
អំពល់នឹងទុក្ខ។

ព្រោះតែមាគ៌ា អរិយមគ្គសោភា ឥទ្ធិពលនាំមុខ
សត្វប្រតិបត្តិតាម ច្បាស់ជួបនឹងសុខ នឹងមិនស្មាញស្មុគ
ក្នុងសង្សារសត្វ។

ប្រតិបត្តិនោះណា តាមត្រៃសិក្ខា ជ្រះថ្លាអនុវត្ត
បានអធិសីល អធិចិត្តសុទ្ធ ឆ្លាតឈ្លាសប្រាកដ
អធិបញ្ញា។

នឹងបានឲ្យដល់ លោកុត្តរផល មគ្គផលថ្លៃថ្លា
ផ្តើមពីសោតា បត្តិមគ្គនោះណា ប្រសើរអស្ចារ្យ
លើសបានអ្វីៗ។

ដូចមានដីកា ព្រះពុទ្ធត្រាស់ថា សច្ចៈវចី
យើងអាចយល់បាន មិនហួសវិស័យ តាមអត្ថន័យ
នៃព្រះគាថា។

**បថព្យា ឯករជ្ជេន សគ្គស្ស គមនេន វា**
**សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ។**

ការបានឯករាជ្យ ប្រសើរអង់អាច ឥស្សរមាំទាំ
នៅលើផែនដី បានសុខស្ងួត់សម អធិបតីហ៊ឹហាំ
នៅលើលោកា។

មិនអាចនឹងស្មើ ដល់ផលប្រសើរ គឺផលសោតា
ដែលអរិយបុគ្គល សម្រេចនោះណា មគ្គផលថ្លៃថ្លា
វិសេសឆើតឆាយ។

ព្រោះសោតាមគ្គ ផ្លូវនាំទៅដាក់ ដាក់ដល់ប្រឡាយ
ហូរចូលនិព្វាន បានសុខស្រស់ស្រាយ បរមសុខសប្បាយ
អស់នូវទុក្ខភ័យ។

| | | |
|---|---|---|
| អស់មានឧបសគ្គ | អ្វីធ្វើឲ្យស្លាក់ | រារាំងនោះអី |
| ទោះបបញ្ចធម៌ | អំណាចខ្លាំងក្រៃ | មិនអាចបំភ្លៃ |
| | សោតាមគ្គឡើយ។ | |
| ច្បាស់ជានឹងអាច | ពិតមានអំណាច | សម្រេចដល់ត្រើយ |
| យ៉ាងយូរប្រាំពីរ | ជាតិជាចុងក្រោយ | បញ្ចប់បង្ហើយ |
| | បានអមតធម៌។ | |
| បានដល់និព្វាន | បរមសុខសាន្ត | រុងរឿងបវរ |
| រលត់អស់ទុក្ខ | សោកភ័យតែងមរណ៍ | អស់អ្វីត្រដរ |
| | រំខានឡើយណា។ | |
| ព្រហ្មចរិយធម៌ | ប្រតិបត្តិបានល្អ | ធម៌ពុទ្ធសាសនា |
| ជាធម៌ប្រសើរ | សិរីវឌ្ឍនា | ដែលព្រះសាស្តា |
| | ត្រាស់ថាមង្គល។ | |

៩.៣ កិរិយាបានឃើញនូវអរិយសច្ចៈ អរិយសច្ចៈ គឺសេចក្តីពិតដែលបុគ្គលដ៏ប្រសើរបានឃើញ

**អរិយសច្ចៈ មាន៤យ៉ាង ៖**

**១.ទុក្ខអរិយសច្ចៈ** (ទុក្ខ+អរិយ+សច្ចៈ)

សេចក្តីទុក្ខជាមេនៃសច្ចៈ ឬមេទុក្ខ ដែលព្រះអរិយបានឃើញ

**២.ទុក្ខសមុទយអរិយសច្ចៈ** (ទុក្ខ+សមុទយ+អរិយ+សច្ចៈ)

មេហេតុដែលនាំឲ្យមានទុក្ខពិតប្រាកដ(គឺតណ្ហា)

**៣.ទុក្ខនិរោធអរិយសច្ចៈ**

(ទុក្ខ+និរោធ+អរិយ+សច្ចៈ) មេសច្ចៈដែលនាំដល់ការរំលត់ទុក្ខ គោលដៅរបស់ព្រះអរិយៈ ដើម្បីទៅដល់គោលដៅមេ ដែលនាំឲ្យរំលត់ទុក្ខគឺព្រះនិព្វាន

## ៤.ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ

(ទុក្ខ+និរោធ+គាមិនី+បដិបទា+អរិយ+សច្ចៈ) មេផ្លូវដែលនាំឲ្យរំលត់ទុក្ខ ផ្លូវដ៏ប្រសើរដែលនាំឲ្យរំលត់ទុក្ខគឺអរិយមគ្គ

### ១. -ទុក្ខអរិយសច្ច

មេទុក្ខមាន១២កងមានតាំងពីជាតិទុក្ខគឺទុក្ខព្រោះកំណើតកើតមករស់នៅក្នុងជីវិតប្រកបដោយទុក្ខច្រើនយ៉ាងរាប់ពុំបានរហូតដល់ស្លាប់វិញគឺ មរណៈទុក្ខ។ ទុក្ខទាំង១២កងនេះ កើតឡើងអាស្រ័យមានខ័ន្ធប្រាំទើបបណ្តាលឲ្យមានទុក្ខដូច្នេះបើអញ្ជឹងទុក្ខទាំងអស់នេះព្រះពុទ្ធជាម្ចាស់ទ្រង់ហៅបង្រួមមកថាជា**ឧបាទានក្ខ័ន្ធទុក្ខ** ជាមេទុក្ខដែលត្រូវកំណត់ដឹងថាសត្វទាំងឡាយវិលក្នុងសំសារវដ្តនេះតែងតែមានទុក្ខអញ្ជឹងគ្មានអ្នកណាមានអានុភាពធ្វើឲ្យឈ្នះបានក្រៅពីសម្មាសម្ពោធិញ្ញាណ ឬថាចេះមុនការត្រាស់ដឹងធម៌របស់ព្រះពុទ្ធនោះទេ។

### ២. ទុក្ខសមុទយអរិយសច្ច

មេហេតុដែលនាំឲ្យមានទុក្ខ គឺតណ្ហា មានកាមតណ្ហា, ភវតណ្ហា និង វិភវតណ្ហា។ ព្រះពុទ្ធបានត្រាស់ដឹងនូវធម៌ភ្លាមទ្រង់បានឧទានជាបឋមពុទ្ធវចនថាៈ

**អនេកជាតិ សំសារំ សន្ធាវិស្សំ អនិព្វិសំ គហការំ គវេសន្តោ ទុក្ខា ជាតិបុនប្បុនំ គហការក ទិដ្ឋោសិ បុន គេហំ នកាហសិ សព្វេ តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ វិសង្ខារ គតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា។**

ប្រែថាៈ នែតណ្ហា អ្នកឯងនេះហើយជាមេជាង ដែលធ្លាប់តាក់តែង អត្តភាពឲ្យយើង អន្ទោលក្នុងសំសារវដ្តនេះជាអនេកជាតិ ប្រកបដោយទុក្ខរាប់ពុំបានតែពេលនេះយើងបានត្រាស់ដឹងនូវធម៌ហើយ យើងស្គាល់អ្នកហើយឥឡូវនេះ គ្រឿងក្រៅរបស់អ្នក (ច្បាប់ខ្លះថាឆ្អឹងជំនីរ ខ្លះថារទូតរនាប) គឺកិលេសទាំងអស់យើងកាច់

បំបាក់អស់ហើយ ទាំងកំពូលផ្ទះគឺអវិជ្ជាយើងកំទេចចោលហើយ អ្នកមិនអាចញ៉ាំង អត្តភាពនេះឲ្យកើត បានទៀតឡើយ ជាតិនេះជាទីបំផុតនៃយើងហើយ ។ ក្នុងព្រះឧទាននេះព្រះអង្គបានបញ្ជាក់ច្បាស់ថា តណ្ហានេះជាមេជាងដែលតាក់តែងអត្តភាពឲ្យកើតបន្តមិនចេះចប់ តណ្ហានេះបានរួមផ្សំជាមួយអវិជ្ជា ហើយបង្កើតចង្វាក់នៃសេចក្តីទុក្ខក្នុងសំសារវដ្ត ហៅថា ធម៌ បច្ចយាកា ឬ បដិច្ចសមុប្បាទធម៌ ជាធម៌ដែលកើតប្រទាក់ពាក់ព័ន្ធគ្នាពីមួយទៅមួយបន្ត រហូតមិនចេះចប់គឺៈ

**អវិជ្ជា បច្ចយា សង្ខារា** អវិជ្ជា ជាបច្ច័យនាំឲ្យកើត សង្ខារ

**សង្ខារប្បច្ចយា វិញ្ញាណំ** សង្ខារ ជាបច្ច័យនាំឲ្យកើតវិញ្ញាណ

**វិញ្ញាណប្បច្ចយា នាមរូបំ** វិញ្ញាណ ជាបច្ច័យនាំឲ្យកើត នាមរូប

**នាមរូបប្បច្ចយា សាឡាយតនំ** នាមរូបជាបច្ច័យនាំឲ្យកើតសាឡាយតនៈ

**សាឡាយតនប្បច្ចយា ផស្សោ** សាឡាយតនៈជាបច្ច័យនាំឲ្យកើត ផស្សៈ

**ផស្សប្បច្ចយា វេទនា** ផស្សៈជាបច្ច័យ នាំឲ្យកើត វេទនា

**វេទនប្បច្ចយា តណ្ហា** វេទនាជាបច្ច័យនាំឲ្យកើត តណ្ហា

**តណ្ហាបច្ចយា ឧបាទានំ** តណ្ហាជាបច្ច័យនាំឲ្យកើតឧបាទាន

**ឧបាទានប្បច្ចយា ភវោ** ឧបាទានជាបច្ច័យនាំឲ្យកើតភព

**ភវប្បច្ចយា ជាតិ** ភពជាបច្ច័យនាំឲ្យកើតជាតិ

**ជាតិប្បច្ចយា ជរាមរណំ** ជាតិជាបច្ច័យនាំឲ្យកើតជរា មរណៈ និងទុក្ខសោក ព្រួយទោមនស្សចង្អៀតចង្អល់ ជាច្រើនអនេក។

**៣. ទុក្ខនិរោធអរិយសច្ច**

គោលដៅនៃការរំលត់ទុក្ខ គឺព្រះនិព្វាន ដើម្បីបានដល់ព្រះនិព្វានទាល់តែមានមធ្យោបាយរំលត់តណ្ហា ដែលជាហេតុនាំឲ្យកើតទុក្ខ។

**៤. ទុក្ខនិរោធ គាមិនី បដិបទា អរិយសច្ចៈ**ផ្លូវប្រតិបត្តិដែលនាំទៅដល់ការរំលត់ទុក្ខមានអដ្ឋង្គិកមគ្គជាផ្លូវប្រកបដោយអង្គ ៨ គឺៈ

ក.**សម្មាទិដ្ឋិ** យោបល់យល់ឃើញត្រូវតាមធម៌ពិតគឺយល់ច្បាស់តាមអរិយសច្ចៈ

ខ.**សម្មាសង្កប្ប** សេចក្តីត្រិះរិះចង់ចេញចាកកាមត្រូវតាមអរិយសច្ចៈ
គ.**សម្មាកម្មន្ត** ការងារត្រូវគឺមិនធ្វើកាយទុច្ចរិត
ឃ.**សម្មាវាចា** និយាយតែល្អវៀរចាកវចីទុច្ចរិត
ង.**សម្មាអាជីវ** ចិញ្ចឹមជីវិតត្រូវ
ច.**សម្មាវាយាម** ព្យាយាមធ្វើកុសលកម្មហើយបំបាត់អកុសល
ឆ.**សម្មាសតិ** រលឹកត្រូវៗតាមអរិយសច្ចៈ
ជ.**សម្មាសមាធិ** តម្កល់ចិត្តត្រូវបានដល់ចិត្តស្អាតលះនីវរណធម៌បាន។

**៣៣. អរិយសច្ចានទស្សនំ** កិរិយាបានឃើញនូវអរិយសច្ចៈ

**អត្ថបទកំណាព្យ ចតុរារិយសច្ច** (បទកាកគតិ)

| | | |
|---|---|---|
| **អរិយសច្ចៈ** | ការពិតនោះច្បាស់ | ជាសច្ចៈធំ |
| ជាមេសច្ចៈ | កម្លាំងខ្លាំងមាំ | ដែលព្រះបរម |
| | ទ្រង់បានទេសនា។ | |
| មេសច្ចៈបួន | ឥទ្ធិពលមាំមួន | ទ្រង់បានត្រាស់ថា |
| **ទីមួយទុក្ខៈ** | អរិយសច្ចណា | នេះហៅទុក្ខា |
| | ខ្លាំងក្លាកន្លង។ | |
| ទុក្ខនេះទុក្ខខ្លាំង | មិនងាយឃាត់ឃាំង | ទុក្ខដប់ពីរកង |
| រួមជាឧបាទាន- | ក្ខ័ន្ធទុក្ខចំបង[៧] | ទុក្ខក្រៃលែងផង |
| | មិនងាយផ្តាច់បាន។ | |
| **ទីពីរសមុទយៈ** | **ទុក្ខអរិយៈ** | **សច្ចៈ**នោះមាន |
| នូវតួនាទី | ប្របមប្រធាន | មេហេតុឲ្យមាន |
| | នូវសេចក្តីទុក្ខ។ | |
| ព្រះពុទ្ធត្រាស់ថា | មេហេតុនោះណា | វាជាប្រមុខ |
| វាឈ្មោះតណ្ហា | ក្លិនស្អុយគគ្រុក | វាដើរនាំមុខ |



៧.អានថា ខាន់ទុក

ឲ្យកើតទុក្ខធំ។

វាតាក់វាតែង វាតែងវអែង ប៉ិនខាងផ្សែផ្សំ
ឲ្យសត្វទៅកើត ភពតូចភពធំ វាបានសន្សំ
ឲ្យទុក្ខគ្រប់ជាតិ។

តណ្ហាក្លាខ្លាំង វាមានកម្លាំង ហើយវាមានស្មៀត
ទៅចងសាមគ្គី អវិជ្ជាមួយទៀត មិនងាយនឹងវៀត
វើខ្លួនបានឡើយ។

សត្វចង់បានសុខ ត្រូវច្បាំងសំរុក កុំបីកន្តើយ
ច្បាំងនឹងតណ្ហា កុំបីបណ្ដោយ ទោះមុនទោះក្រោយ
ត្រូវតែបានឈ្នះ។

បើឈ្នះតណ្ហា ទើបបានសុខា ឈ្នះដោយវិរិយៈ
អស់នូវទុក្ខសោក វិប្បយោគអួលអាក់ **បានឯកន្តៈ**[៨]
បរមសុខនិព្វាន។

ចាត់ជាទីបី បរមសុខនោះនៃ អស់ទុក្ខឈ្លានពាន
ព្រោះបានច្បាំងឈ្នះ តណ្ហាដែលមាន វាឈប់រុករាន
ទន្ទ្រានទៀតបាន។

តែដើម្បីបាន ត្រូវស៊ូប្ដូរប្រាណ តាមព្រះទ្រង់ញាណ
ដើរតាមអរិយមគ្គ ទុកដូចជាស្ពាន ព្យាយាមរុករាន
ឈានឲ្យបានដល់។

អរិយមគ្គនោះណា ផ្លូវល្អថ្លៃថ្លា ផ្លូវព្រះទសពល
**សច្ចៈទីបួន** ទ្រង់បានចង្អុល ឲ្យសត្វបានយល់
ប្រតិបត្តិដល់ត្រើយ។

អរិយមគ្គនោះ គួរផ្ចិតផ្ចង់ស្មោះ កុំប្រមាទឡើយ
ដើរឲ្យបានត្រង់ នឹងឆាប់ដល់ត្រើយ តែបើវាងហើយ



៨.អានថា អេ កន់ តាក់

ច្បាស់ជាយូរយា។

| | | |
|---|---|---|
| ដើរដូចម្ដេចណា | តាមត្រៃសិក្ខា | ដែលព្រះពុទ្ធា |
| ទ្រង់បានបង្ហាញ | ឲ្យសត្វនានា | បានជាមាគ៌ា |
| | ថ្លាថ្លៃប្រសើរ។ | |
| នេះហើយអរិយសច្ច | បើឃើញច្បាស់ស្រេច | ហើយព្យាយាមដើរ |
| ធ្វើឲ្យបានត្រូវ | តាមពុទ្ធដំណើរ | នេះហើយប្រសើរ |
| | មង្គលសួស្ដី។ | |

៩.៤ **កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន** ព្រះនិព្វានមានអត្ថច្រើនយ៉ាង ក្នុងទីនេះលើកន័យខ្លះៗថាៈ និព្វានមានអត្ថថា "**វិរាគ**" គឺអស់ទៅនូវតំរេក **អសវក្ខយោ** គឺអស់ទៅនូវកិលេស **និរុទ្ធោ** គឺអស់ទៅនូវទុក្ខ **និរោធោ** គឺរលត់ទាំងអស់គ្មានសល់ ។ល។ និព្វានមាននៅពេលណា?

លើកយកអត្ថ ដែលស្រង់ពីអភិសវាចារបស់ព្រះពោធិសត្វ ដែលបានប្រសូត្រមកភ្លាមចេះនិយាយថាៈ

| | |
|---|---|
| **១.អគ្គោ ហមស្មិ លោកស្ស** | យើងជាកំពូលលើលោក |
| **២.ជេដ្ឋោ ហមស្មិ លោកស្ស** | យើងជាច្បងគេលើលោក |
| **៣.សេដ្ឋោ ហមស្មិ លោកស្ស** | យើងប្រសើរជាងគេលើលោក |
| **៤.អយមន្តិមា ជាតិ** | ជាតិនេះជាជាតិចុងក្រោយបំផុត |
| **៥.នត្ថិទានិ បុនព្ភវោតិ** | តទៅគ្មានជាតិទៀតឡើយ |

ពិចារណាទៅឃើញព្រះគាថាទី៤ បង្ហាញថាជាតិនេះជាជាតិចុងក្រោយហើយព្រះគាថាទី៥ ថាអំណឹះតទៅទៀតគ្មានជាតិទៀតឡើយ។ បានសេចក្ដីថា ការអស់ជាតិអស់កំណើតលែងកើតមកទៀត នេះគឺជាព្រះនិព្វាន ដូច្នេះព្រះនិព្វានមានពិតតែគ្មានស្ថានទីដែនកើតតែមានពេលវេលាមួយក្រោយដែលព្រះអរិយៈបានកសាងគ្រប់គ្រាន់សម្រេចជាព្រះអរហន្តភ្លាមនោះគឺចិត្តព្រះអរហន្តដំបូងនេះ គឺកើតព្រះនិព្វានតែម្ដង ហៅថា ឧបាទិសេសនិព្វានជានិព្វានដែលព្រះអរហន្តបានធ្វើឲ្យជាក់

ច្បាស់នៅក្នុងចិត្តក្នុងពេលរស់នៅនេះ។ ដល់ពេលព្រះអរហន្តទ្រង់ចូលទីវង្គត រំលាយអស់ខន្ធទៅ ហៅថា អនុបាទិសេសនិព្វាន តពីនេះគ្មានអ្វីកើតទាំងអស់គឺរលត់គ្មានសល់គ្មានត្រឡប់ គឺអស់អ្វីៗទាំងអស់ តែម្តង។ បើគ្មានអ្វីតែទាំងអស់ដូច្នេះតើទុក្ខមានមកពីណា ? ខ្លះយល់ថា បើនិព្វានសូន្យឈឹងគ្មានអ្វីទាំងអស់អញ្ចឹងតើប្រាថ្នាទៅធ្វើអ្វី ? វាអត់សប្បាយ ?

អ្នកយល់ដូច្នោះ គឺគេយល់ថាទាល់តែមានកំណើតមានរូបទើបបានសប្បាយគឺវាផ្ទុយនឹងសព្វញ្ញុតញ្ញាណដែលព្រះអង្គតែងសម្តែងថា គឺឧបាទានក្ខ័ន្ធនេះហើយដែលនាំឲ្យមានទុក្ខអនេកអនន្តគ្រប់ជាតិក្នុងសំសារវដ្តនេះ បើនិយាយពីទឹកភ្នែកយំសោកនោះច្រើនជាងទឹកមហាសមុទ្រទៅទៀត ប្រសិនបើមាននរណាគេចេះធ្វើឲ្យអស់ភពកំណើតនេះ សូម្បីគេត្រូវការចាក់រូបយើងមួយថ្ងៃ ប្រាំមួយរយលំពែងក៏សុខចិត្តប្តូរដែរ។

**៣៤. និព្វានសច្ឆិកិរិយា** កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន

**អត្ថបទកំណាព្យ និព្វាន** (បទសរភញ្ញ)

| | |
|---|---|
| និព្វានគ្មានសោះនូវអ្វីៗ | គឺស្ងប់ប្រពៃបរមសុខសាន្ត |
| និព្វានគ្មានរូបគ្មានទាំងស្ថាន | គ្មានទីសម្រាន្តកំសាន្តកាយ។ |
| និព្វានគ្មានទុក្ខគ្មានទាំងភ័យ | គ្មានក្តីប្រាស្រ័យអ្នករៀងអាយ |
| និព្វាននៅជិតឬនៅឆ្ងាយ | មិនគួរបរិយាយឆ្ងាយជិតឡើយ។ |
| គឺនិព្វាននេះអស់ទាំងអស់ | រលត់គ្មានសោះសល់អ្វីឡើយ |
| ក្រោយជាតិព្រះអរហន្តជាតិបង្ហើយ | ដល់និព្វានហើយកុំបីឆ្ងល់។ |
| អ្នកដែលប្រាថ្នាទៅនិព្វាន | និស្ស័យគេមានមិនចង់ខ្វល់ |
| មិនចង់កើតទៀតនាំរវល់ | ភពជាតិអំពល់តែទុក្ខា។ |
| ធម្មតាបើមានជាតិកំណើត | វាតែងតែកើតហើយមរណា |
| ស្លាប់កើតៗនាំអសារ | មានក្តីទុក្ខារាប់ពុំបាន។ |
| វិលវល់វង្វេងក្រឡាប់ចក្រ | ក្នុងសំសារវដ្តគ្មានអវសាន |

ព្រោះមានរូបនាមតែងរំខាន ទុក្ខឥតស្រាកស្រាន្តគួរសង្វេគ។
ចង់ឲ្យចប់ទៅបានរហ័ស ព្រោះឃើញទុក្ខច្បាស់ជាក់ណាស់ពេក
យល់អរិយសច្ចច្បាស់ក្រឡែត ឥតមានអល់ឯកក្នុងចិន្តា។
យល់ច្បាស់ដោយការបានសន្សំ ប្រមែប្រមុំនូវបញ្ញា
បានយល់នូវធម៌ព្រះសាស្តា មិនមានកង្ខាសោះឡើយនែ។
ចង់ដល់និព្វានក៏ខិតខំ កសាងសន្សំនូវនិស្ស័យ
ធ្វើតែល្អៗគ្រប់ករណី តាមព្រះជិនស្រីទ្រង់ទូន្មាន។
ប្រតិបត្តិដើរតាមអរិយមគ្គ អនាគតនាំជាក់ដល់និព្វាន
តែមុនពេលដល់ផលឲ្យបាន នូវក្តីសុខសាន្តជរាបទៅ។

## ព្រះគាថាទី ១០

មាន ៤ មង្គល

**ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**
**អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ។**

(បទពាក្យ៧)

| | |
|---|---|
| ភាវៈជាបុគ្គលមិនញាប់ញ័រ | ទោះប៉ះលោកធម៌ប្រចាំថ្ងៃ |
| មិនមានរំភើបក្នុងហឫទ័យ | មានចិត្តប្រល័យសេចក្ដីសោក។ |
| ក្ស័យទាំងធូលីគឺរាគៈ | បានក្សេមក្សាន្តជាក់អាក់វិប្បយោគ |
| វិមុត្តិសុខនឹងមានមក | យកជាមង្គលក្នុងជីវ៉ា។ |

### សេចក្ដីសម្រាយ

ចិត្តនៃបុគ្គលណា ដែលលោកធម៌ទាំងឡាយ ពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ១ ការមិនមានសេចក្ដីសោក១ ធុលី គឺរាគៈទៅប្រាសហើយ១ ចិត្តក្សេមក្សាន្ត១ នេះជាមង្គលដ៏ឧត្តម។

## ១០.១ ចិត្តដែលមិនកម្រើកញាប់ញ័រដោយលោកធម៌

លោកធម៌ មាន ៨ គឺ

| | | | |
|---|---|---|---|
| -បានលាភ | -ឥតលាភ | -បានយស | -ឥតយស |
| -បានសុខ | -បានទុក្ខ | -បានសរសើរ | -បាននិន្ទា |

ធម៌ទាំង៨ប្រការនេះ ដែលមនុស្សគ្រប់រូបតែងជួបប្រទះមិនអាចជៀសវាងបានឡើយ សូម្បីព្រះសម្មាសម្ពុទ្ធក៏មានការសរសើរ និងការនិន្ទាពីជនទាំងឡាយ។ យើងទាំងអស់គ្នាកុំឲ្យវង្វេង តាមលោកធម៌ទាំងនេះឡើយ។

**៣៥- ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ**

ចិត្តជាបុគ្គលដែលឈប់រវល់ ញាប់ញ័រនឹងលោកធម៌ផ្សេងៗ

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| បុគ្គលមានចិត្តបរិសុទ្ធថ្លា | មិនមានប្រាថ្នាការអ្វីឡើយ |
| តាំងចិត្តបាននឹងន់ល្អហើយ | តែងតែបណ្ដោយតាមហេតុការណ៍។ |
| អ្វីដែលត្រូវកើតវានឹងកើត | វាមានកំណើតតាមកម្មា |
| បើកើតមកនោះក៏ធម្មតា | ឥតគិតប្រាថ្នាធំដុំឡើយ។ |
| បើបានលាភយសសុខសរសើរ | ក៏នៅតែដើរធ្វើព្រងើយ |
| មិនត្រេកត្រអាលនឹងអ្វីឡើយ | ច្រើនតែបណ្ដោយតាមហេតុការណ៍។ |
| បើសិនទទួលផលវិបាក | បាត់លាភយសខាតសព្វកិច្ចការ |
| ឬគេតេះដៀលបែបយ៉ាងណា | ចិត្តនៅធម្មតាធ្វើហ៊ីៗ។ |
| មិនមានទោសៈពុះកញ្ជ្រោល | ក្ដៅទៅតាមដោយពាក្យសម្ដី |
| ទោះអ្នកណាគេនិន្ទាស្ដី | អាក្រក់អាក្រីខ្លាំងក្ដីណា។ |
| មិនចេះតម្លើងនូវមានះ | ខំទៅរូតរះសួរតវ៉ា |

| | |
|---|---|
| អ្នកណាប៉ិនថាក៏ឲ្យថា | តាមគេត្រូវការធ្វើព្រងើយ។ |
| មិនចេះគុំគួនហើយព្យាបាទ | មិនមានសង្វាតចង់ឈ្នះឡើយ |
| ប្រតិបត្តិយកឈ្នះខ្លួនឯងហើយ | មិនមានបណ្តោយធ្វើខាងបាប។ |
| អ្នកចិត្តល្អនេះរស់ជាសុខ | ពីនេះទៅមុខសុខដរាប |
| សុខតាមផ្លូវចិត្តសុខសុភាព | ព្រោះចិត្តរាបទាបមិនញាប់ញ័រ។ |
| មិនចេះរំភើបព្រោះព្រឹត្តការណ៍ | អ្វីកើតនោះណានៅនឹងន់ |
| តែប៉ិនដោះស្រាយដោយជំហរ | បញ្ញាយល់ល្អមានជោគជ័យ។ |
| ហេតុនេះបានជាព្រះសាស្តា | បានត្រាស់មកថាអ្នកនេះនៃ |
| តែងមានចិត្តហ្នឹងល្អប្រពៃ | តែងសុខសិរីថ្លៃឧត្តម។ |

## ១០.២ មិនមានសេចក្តីសោក

សេចក្តីសោក មានន័យថា អស់សង្ឃឹម ក្តុកក្តួល អួលណែន ខកចិត្ត ខូចចិត្ត ព្រោះមិនបានរបស់ដែលជាទីប្រថ្នារបស់ខ្លួន។ សេចក្តីសោកកើតពីសេចក្តីស្រឡាញ់ ហើយសេចក្តីស្រឡាញ់នេះ គឺជាជ័រស្អិត ដែលធ្វើឲ្យចិត្តជាប់ជំពាក់។

ធម្មតាបុគ្គល (ឬព្រះអរិយៈ) ដែលបានអប់រំចិត្តល្អស្អាតស្រឡះ មិនមានជាប់ជំពាក់នឹងអ្វីៗទាំងអស់ទោះបីអ្វីនោះវិនាសបាត់ទៅ ក៏មិនអាចឲ្យមានអានុភាព ធ្វើឲ្យបុគ្គលនោះសោកសៅ ក្តៅក្រហាយឡើយ។ ព្រោះតែចិត្តអស់នូវសេចក្តីប្រកាន់ ហៅថាឧបាទានដែល ជាគូនឹង ក្តីស្រឡាញ់ដូចមានព្រះគាថាថា:

| | |
|---|---|
| **បេមតោ ជាយតេសោកោ** | ក្តីស្រឡាញ់នាំឲ្យមានសោក |
| **បេមតោ ជាយតេភយំ** | ក្តីស្រឡាញ់នាំឲ្យមានភ័យ |
| **បេមតោ វិប្បមុត្តស្ស** | បើអស់នូវក្តីស្រឡាញ់ហើយ |
| **នត្ថិ សោកោ កុតោ ភយំ** | សោកនិងភ័យក៏គ្មានដែរ |

បើនិយាយឲ្យផ្ទុយពីនេះទៅវិញ មនុស្សភាគច្រើនដែលមិនទាន់បានអប់រំចិត្ត នោះបែរជាសោកសៅកន្ទក់កន្ទេញយ៉ាងខ្លាំងក្នុងពេលដែលអ្វីៗជាទីស្រឡាញ់ជាប់ចិត្តនោះបាត់បង់ទៅដូចជាបាត់បង់កូនបាត់បង់ទ្រព្យបាត់បង់សេចក្ដីស្នេហា។

**៣៦. អសោកំ** គ្មានក្ដីសោក

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

| | |
|---|---|
| អ្នកអប់រំចិត្តបានស្រឡះ | មិនជាប់ជំពាក់នឹងអ្វីៗ |
| ចិត្តមានឥទ្ធិពលមានសេរី | ទោះបីអ្វីៗវាបាត់បង់។ |
| ចិត្តនោះគ្មានស្ដាយគ្មានសោកា | ព្រោះគ្មានប្រាថ្នាតាមចិត្តចង់ |
| តែងពិចារណាចេះគិតគន់ | តាមបាបតាមបុណ្យតាមកម្មផល។ |
| មិនចេះស្រឡាញ់ដោយផ្ដាប់មុខ | នឹងអ្វីៗនោះនាំអំពល់ |
| តែងចេះគិតគូរដឹងហេតុផល | មិនមានខ្វាយខ្វល់រវល់ឡើយ។ |
| ប្រសិនបើយើងបានស្រឡាញ់ | អ្វីៗនោះពេញចិត្តយើងហើយ |
| អ្វីនោះវាបាត់ទៅបណ្ដោយ | ចិត្តយើងស្ដាយក្រោយជាមិនខាន។ |
| យើងនឹងកើតទុក្ខកើតសោកសៅ | ហើយក៏សែនក្ដៅពន់ប្រមាន |
| អ្វីដែលស្រឡាញ់វាប្រាសប្រាណ | វាមិនបានថ្កានថ្កើងស្ថិតស្ថេរ។ |
| សុភាសិតមួយបានចែងថា | ឲ្យពិចារណាកុំទំនេរ |
| នូវក្ដីស្រឡាញ់ទាំងយើងគេ | គួរតែរិះរេដោយសម្រាំង។ |

**កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ**
**កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ**

| | |
|---|---|
| ការដែលស្រឡាញ់នាំឲ្យសោក | ស្រឡាញ់នាំមកនូវទុក្ខភ័យ |
| បំបាត់ស្រឡាញ់ឲ្យអស់ន័យ | សោកព្រមទាំងភ័យមិនមានឡើយ។ |
| ច្នេះហើយទើបមានពុទ្ធដីកា | មង្គលនេះណាចារមកហើយ |
| ថា៉អសោកំ៉គឺមិនសោកឡើយ | ព្រោះចិត្តរួចហើយអស់ជំពាក់។ |

អ្នកនោះតែងបាននូវសិរី បានសុខសួស្តីមិនអន់អាក់
ជាឧត្តមមង្គលប្រសើរជាក់ ព្រោះចិត្តដល់ថ្នាក់អស់នូវសោក។

**១០.៣ មិនមានរាគៈ**

បុគ្គលដែលបានអប់រំកសាងសន្សំបុណ្យមកយូរហើយបានសម្រេចធម៌ជាន់ខ្ពស់ បានជាបុគ្គលដែលមានអធិចិត្ត អធិសីល និង អធិបញ្ញាសិក្ខា ជាអ្នកឈ្លាសឆ្លាតក្នុងធម៌ ឃើញច្បាស់នូវធម៌មានមធ្យោបាយធ្វើឲ្យរីងស្ងួតនូវកិលេសមានរាគៈជាដើម (អាសវក្ខយញ្ញាណ) ហើយក៏ឈប់ប្រាថ្នា នូវអ្វីៗទាំងអស់តែងបាននូវសេចក្តីសុខប្រយោជន៍តទៅ។ ឫសគល់នៃកិលេស មាន រាគៈ ទោសៈ មោហៈ ដែលឋិតក្នុងសន្តានចិត្ត សត្វលោក។ កិលេសទាំងបីនេះ ចែកជា១០តម្រូវតាមភូមិដែលសត្វទៅកើតៈ

**រាគៈ**

- **កាមរាគ** នាំឲ្យប្រាថ្នាចង់សុខ ក្នុងកាមភព
- **រូបរាគ** នាំឲ្យប្រាថ្នាចង់សុខ ក្នុងរូបភព
- **អរូបរាគ** នាំឲ្យប្រាថ្នាចង់សុខ ក្នុងអរូបភព

**ទោសៈ**

- **បដិឃ** ការថ្នាំងថ្នាក់ឬទាស់ចិត្ត
- **មានះ** ការតម្កើងខ្លួន

**មោហៈ**

- **សក្កាយទិដ្ឋិ** ចិត្តជំពាក់នឹងអត្តាតួខ្លួន
- **វិចិកិច្ឆា** សង្ស័យមិនជ្រះស្រឡះ
- **សីលព្វត្តបរាមាស** ធ្វើសីលឬវត្តខុស
- **ឧទ្ធច្ច កុក្កុច្ច** ងោកងុយ រវើរវាយ
- **អវិជ្ជា** មិនដឹងធម៌

សត្វព្រោះតែប្រកបដោយកិលេសទាំងអស់នេះទើបនៅតែកើតទុក្ខវិលវល់ក្នុង សំសារវដ្តនេះផ្ទុយពីព្រះអរហន្ត ច្បាស់ហើយនូវអធិបញ្ញាច្រានចោលអស់នូវកិលេស មានរាគៈជាអាទិ បានក្នុងទីអវសាន។

**៣៧- ទិរជំ** មិនមានរាគៈ

**អត្ថបទកំណាព្យ កិលេស** (បទបន្ទោល)

| | | | |
|---|---|---|---|
| អ្វីជាកិលេស | គឺច្រេះតណ្ហា | ដែលសត្វប្រាថ្នា | សម្រាប់តែខ្លួន |
| ដោយមានអត្តា | ឲ្យរស់សមខ្លួន | ចង់បានសុខខ្លួន | ស្ថានផុតទុក្ខា។ |
| កិលេសនេះឯង | កិលេសគ្រោតគ្រាត | កិលេសមានស្មៀត | ដោយកាយវាចា |
| និងកិលេសល្អិត | ក្នុងចិត្តនោះណា | សុទ្ធមានចលនា | បំពេញចំណង់។ |
| សុទ្ធតែចង់ល្អ | ស្អាតបាតស្រុះស្រួល | ចង់បានសម្រួល | ចង់ល្អផូរផង់ |
| ជាអាទិលាភយស | សរសើរយ៉ាងខ្ពង់ | ចំពោះដល់អង្គ | អត្តាឲ្យស្រួល។ |
| ចង់បានប្រណីត | សំរិតសម្រាំង | ចង់បានឲ្យខ្លាំង | សម្រាំងឲ្យស្រួល |
| ចង់បានស្រើបស្រាល | រំជើបរំជួល | ចង់តែសុខស្រួល | កាយចិត្តរហូត។ |
| ប៉ុន្តែយល់ខុស | គំនិតវាខ្លី | យល់មិនដឹងអី | យល់ខ្លីរបូត |
| តែតាមពិតនោះ | កិលេសវាស្រួត | វាខំបង្ហូត | ឲ្យតែទុក្ខា។ |
| ជូនវាឲ្យសុខ | បណ្ដោះអាសន្ន | គ្រាន់តែសម្រន់ | បន្តិចទេណា |
| តែតាមពិតនោះ | បើភ្លេចកាយា | មច្ចុខ្លាំងក្លា | ចាំប្រហារយើង។ |
| ប្រៀបដូចជាគេ | ចិញ្ចឹមជ្រូកលក់ | ឲ្យបាយកន្ទក់ | ឲ្យជ្រូកធំឡើង |
| កាលណាជ្រូកធំ | ជ្រូកនឹងបះជើង | ព្រោះគេចាប់ឡើង | យកជ្រូកទៅកាប់។ |
| ដូច្នេះបើមាន | សទ្ធាធ្វើបុណ្យ | ធ្វើក្រោយធ្វើមុន | ធ្វើឲ្យចំណាប់ |
| កុំបីប្រាថ្នា | តណ្ហាអ្នកអ័ព្ទ | កុំឲ្យច្រេះចាប់ | ចាប់ជាប់កិលេស។ |
| ប្រាថ្នាជាប់ចិត្ត | ជាប់នឹងតណ្ហា | នោះវដ្តសង្សារ | នៅតែដូច្នេះ |
| វិលចុះវិលឡើង | មិនងាយរបេះ | ព្រោះចិត្តចាក់ស្រេះ | ជាប់នឹងអត្តា។ |
| អង្គអរហន្តា | ព្រះខីណាស្រព | ព្រះអង្គប្រសប់ | ចេញពីតណ្ហា |

| | | | |
|---|---|---|---|
| កំចាត់កិលេស | អាសវក្ខនោះណា | ឲ្យអស់ចេស្តា | ជារៀងរហូត។ |
| ព្រោះការកសាង | សន្សំបារមី | នៃព្រះអរិយ | តរហូតមក |
| កសាងល្អសុទ្ធ | មិនប្រាថ្នាយក | តណ្ហានោះមក | ជាឧបនិស្ស័យ។ |
| ជាតិនេះជាតិក្រោយ | អស់ហើយនូវភព | តទៅចូលម្លប់ | និព្វានជាញជ័យ |
| ផុតអស់ទុក្ខទោស | ស្មោកគ្រោកគួរភ័យ | អ្វីៗមានន័យ | ជានិរោធោ។ |
| ហេតុនេះបានជា | អង្គព្រះសាស្តា | ទ្រង់មានដីកា | សច្ចៈវាទោ |
| ថាលះកិលេស | ឲ្យអស់លែងយក៏ | ច្បាស់ជាបានមក៏ | មង្គលឧត្តម។ |

(**អសេចក្ខយោ សព្វទុក្ខោ ជិនាតិ**)

**១០.៤ ខេមៈចិត្តក្សេម**

ជាចិត្តដែលផុតចាកកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ។ ធម្មតាសត្វលោក តែងស្ថិតនៅទាំងកាយទាំងចិត្ត ក្នុងអន្លង់ទុក្ខទាំងបួនគឺៈ

**១.អន្លង់កាម** ហៅថា **កាមោឃៈ**

**២.អន្លង់ភព** ហៅថា **ភវោឃៈ**

**៣.អន្លង់ទិដ្ឋិ** ហៅថា **ទិដ្ឋោឃៈ**

**៤.អន្លង់អវិជ្ជា** ហៅថា **អវិជ្ជោឃៈ**

ទាល់តែសត្វព្យាយាមកសាងល្អដោយខ្លួនឯង ទើបរួចពីអន្លង់ទាំងបួននេះបាន ហើយមានស្ថេរភាពពិតប្រាកដ ដែលនាំទៅដល់ខេមៈនោះ។

**៣៨. ខេមំ** ក្សេមក្សាន្ត

**អត្ថបទកំណាព្យ ខេមៈ** ក្សេមក្សាន្ត (បទបញ្ជាវ័ត)

| | | | |
|---|---|---|---|
| អន្លង់ទាំងបួន | សត្វធ្លាប់ពួននៅ | ជាអន្លង់ជ្រៅ | ប្រមាណមិនបាន |
| សត្វធ្លាប់មានទុក្ខ | ទុក្ខសែនរំខាន | មិនដឹងជាបាន | ពេលណានឹងរួច។ |

១.**កាមោឃ** អន្លង់គឺកាម

ទីមួយឈ្មោះថា ជាកាមោឃៈ អន្លង់កាមៈ អន្លង់រលួយ
សត្វត្រេកត្រអាល ហាក់គ្មានខ្វល់ព្រួយ តែសត្វណាមួយ ក៏តែងមានទុក្ខ។
មានទុក្ខមានទោស ដោយសារកាមា វាផ្ដល់ផ្លែផ្កា កើនក្ដៅគគុក
នាំទុក្ខនាំទោស បញ្ហាគ្រប់មុខ ជំពាក់ស្មាញស្មុគ ដោះស្រាយពុំចេញ។
កាមឲ្យកំណើត គ្រប់សព្វសត្តា ដែលសត្វនោះណា កើតដូចម្ដេចមិញ
កើតនៅក្នុងភព រស់នៅពាសពេញ ហើយតែងទោម្នេញ ព្រោះក្ដីទុក្ខទោស។
ដោយសារកាមា បញ្ហាជាច្រើន សត្វតែងចំរើន បង្កើនប្រទូស
សត្វតូចសត្វធំ ដណ្ដើមគ្នារស់ ហើយប្រឹងប្រឈ្លោះ យកតែចាញ់ឈ្នះ។
សម្លាប់គេឯង យកជាចំណី គ្រាន់តែរឿងឆី បញ្ហាធំណាស់
រឿងផ្សេងៗទៀត សុទ្ធតែរូតរះ យកចាញ់យកឈ្នះ ប្រណាំងប្រជែង។
គំនុំគុំគួន ផ្ទុះរឿងធំឡើង ឫកពារឆ្មៃឆ្មើង ក៏តាំងខ្ទះខ្ទែង
រកមធ្យោបាយ កំចាត់គេឯង អាក្រក់ស្ដែងៗ ព្រោះតែកាមា។
បើសិនផ្ដាច់កាម មិនទាន់បានទេ គួរតែរិះរេ ប្រតិបត្តិបែបណា
រកសុខប្រយោជន៍ នៅលើលោកា ឲ្យគេយើងណា បានសុខដូចគ្នា។
គឺកាន់សីលប្រាំ ប្រចាំរាល់ថ្ងៃ ទាត់ក្ដីស្រមៃ ដែលជាមហិច្ឆតា
អភិវឌ្ឍន៍ខ្លួនចុះ តែកាន់សីលា ត្រូវបែរចិន្តា គិតគេឯងផង។
មិនគួររកសុខ ប្រយោជន៍តែឯង ហើយមិនមានក្រែង រអែងអ្នកផង
រកសុខខ្លួនឯង ដោយខុសគន្លង ផ្ដល់ទុក្ខទោសផង ឲ្យគេរាល់គ្នា។
ពិតជាមានបាប ឆ្អាបតែរាល់ថ្ងៃ បាបនេះវាថ្លៃ ឲ្យនូវវេរា
ផ្ដល់ទុក្ខជាតិនេះ ឬឲ្យទុក្ខា អនាគតនោះណា រឹតតែមានទុក្ខ។

២. **ភវោឃ** អន្លង់គឺភព

អន្លង់ទីពីរ គឺភវោឃៈ ភពហាក់ត្រជាក់ ចូលចិត្តណាស់ណា
ចូលចិត្តកើតទៀត តែសុំប្រាថ្នា សុំឲ្យសុខា គ្រប់ៗតែជាតិ។

ចង់កើតស្ថានសុខ ស្ថាននោះសប្បាយ អ្វីជិតរៀងអាយ ឲ្យល្អព្រោងព្រាត
សូម្បីអាហារ ឲ្យមានឱជា ទោះអ្វីនានា ឲ្យសុខសប្បាយ។
ភ្លេចគិតថាមាន ភពជាតិកំណើត ឲ្យតែវាកើត មុខជាសោកស្តាយ
តែកើតមកហើយ មានរូបនាមកាយ តែងមានអន្តរាយ ជាប់នឹងជីវិត។
មានជីវិតនេះ គឺមានបញ្ហា ព្រោះវាត្រូវការ សម្រាប់ជីវិត
បើកើតមកហើយ នៅស្ងៀមពុំគិត ថាតើជីវិត នឹងជាយ៉ាងណា?
ធម្មតាជីវិត បើកើតមកហើយ កុំភ្លេចសោះឡើយ ថាបានសុខា
បើសិនបានសុខ វាល្ងួងចិន្តា បន្លំមួយគ្រា រួចឲ្យទុក្ខទោស។
មានរោគមានចាស់ មានឈឺមានស្លាប់ មានរឿងឈឺចាប់ ដែលត្រូវអនុវត្ត
ពិបាកខ្លាំងណាស់ រឿងនេះប្រាកដ មិនមែនសន្មត ថាសុខនោះទេ។

៣. **ទិដ្ឋោឃ** អន្លង់គឺទិដ្ឋិ

អន្លង់ទីបី គឺទិដ្ឋោឃៈ សត្វតែងជំពាក់ មានចិត្តស្និទ្ធស្នេហ៍
ជាប់នឹងទិដ្ឋិ ទាំងយើងទាំងគេ បើយល់ឃើញវេ- បែរទៅខាងណា។
ក៏តាំងមានះ ថាខ្លួនឯងត្រូវ ទោះបីសំណៅ គេត្រូវយ៉ាងណា
នៅតែប្រកាន់ ថាមិនត្រូវការ ទិដ្ឋិឯងណា ទើបថាត្រឹមត្រូវ។
ទិដ្ឋិមេធំ ត្រណំខ្លាំងណាស់ បើយល់ត្រូវច្បាស់ ទើបប្រតិបត្តិត្រូវ
បើទិដ្ឋិខុស ធ្វើខុសគោលដៅ នាំប្រតិបត្តិទៅ ចង្រៃខ្លាំងណាស់។
បើយល់ខុសធម៌ ប្រតិបត្តិខុសធម៌ យល់ថាពាលល្អ ពិតជាអប្បលក្ខណ៍
បើឃើញអ្នកប្រាជ្ញ ថាខ្លៅអស់ថ្នាក់ ឃើញស្មូមប្រត្យក្ស ថាជាសេដ្ឋី។
បើយល់ខុសច្នេះ ប្រព្រឹត្តិក៏ខុស ប្រទះប្រទូស ធ្វើខុសគោលដៅ
ព្រោះតែទិដ្ឋិ ទិដ្ឋិនោះខ្លៅ នឹងអនុវត្តទៅ ឲ្យទុក្ខអន្តរាយ។
ទិដ្ឋិទាំងនេះ ក្នុងពុទ្ធសាសនា ឥទ្ធិពលខ្លាំងក្លា មិនបានអធិប្បាយ
គ្រាន់តែលើកឡើង ក្នុងកិច្ចបរិយាយ គួរឲ្យសោកស្តាយ គឺមិច្ឆាទិដ្ឋិ។

៤. **អវិជ្ជោឃ** អន្លង់គឺអវិជ្ជា

| | | | |
|---|---|---|---|
| អន្លង់ទីបួន | គឺអវិជ្ជោឃៈ | អន្លង់គ្រោះថ្នាក់ | ខ្លាំងក្លាណាស់ដែរ |
| បើមានអវិជ្ជា | មិនអាចរិះរេ | គិតគូរអ្វីទេ | ឲ្យត្រូវឡើយណា។ |
| ព្រោះអវិជ្ជានេះ | នាំឲ្យងងឹត | មានស្បៃបាំងជិត | រូបរិតអន្ធការ |
| មើលទៅមិនយល់ | ទោះខំឧស្សាហ៍ | ពិនិត្យយ៉ាងណា | ក៏មិនយល់ស្ដែង។ |
| អវិជ្ជាគឺការ | មិនយល់ធម៌ពិត | ធម៌ព្រះទ្រង់ឫទ្ធិ | ដែលបានសម្ដែង |
| មិនស្គាល់ទាំងទុក្ខ | ជាទុក្ខស្ដែងៗ | មិនមានចេះក្រែង | ប្រតិបត្តិល្អជា។ |
| មិនយល់មែនៗ | មិនយល់អរិយសច្ច | បង្ហាញសព្វខ្ទេច | ពីទុក្ខនានា |
| បង្ហាញតណ្ហា | ហេតុឲ្យទុក្ខា | បង្ហាញកិរិយា | ធ្វើឲ្យផុតទុក្ខ។ |
| សព្វសត្វជាច្រើន | នៅតែពុំយល់ | ព្រោះសត្វកង្វល់ | ពីរឿងគ្រប់មុខ |
| សព្វថ្ងៃរស់នៅ | មិនសូវបានសុខ | ព្រោះមោហ៍បាំងមុខ | គឺអវិជ្ជា។ |
| សរុបអន្លង់ | អន្លង់ទាំងបួន | គួរតែកុំពួន | កុំពឹងជាគ្នា |
| គួរតែរលាស់ | ទើបអស់ទុក្ខា | ដែលព្រះសាស្ដា | ចាត់ថាខេមៈ។ |

## អធិប្បាយសរុប មង្គលគាថាទី ១០

(បទសរភញ្ញ)

ទាំងបួនចំណុចនៃគាថា　　ដែលព្រះសាស្ដាបានសម្ដែង
ក្នុងមង្គលនេះឃើញស្ដែងៗ　　ទ្រង់បានថ្លាថ្លែងមានមកថាៈ
ទីមួយបុគ្គលដែនបានសាង　　ចិត្តល្អភ្លឺស្វាងយ៉ាងអស្ចារ្យ
ចិត្តនោះសស្អាតបាតជ្រះថ្លា　　គ្រប់លោកធម៌ណាពាល់មិនបាន។
ចិត្តមានជំហរនឹងន់ស្រួល　　មិនមានប្រែប្រួលព្រោះគេប្រាន
ទោះជាបានអ្វីឬមិនបាន　　មិនមានរំខានដោយសារអ្វី ។
ទីពីរមិនមាននូវក្ដីសោក　　អស់ទុក្ខវិប្បយោគបានសុខក្រៃ
អស់ក្ដីប្រកាន់ក៏ធ្វើហី　　ក្ដីស្រឡាញ់ក្ដីឈប់មានហើយ។

បើសិនអស់ក្តីស្រឡាញ់នេះ ទុក្ខសោកក៏មិនចេះកើតឡើយ
មានតែក្តីសុខៗល្ហែល្ហើយ សុខព្រោះអស់ហើយអស់ជំពាក់។
ទីបីបុគ្គលអស់កិលេស អ្វីៗក៏ជ្រះល្អស្រឡះ
អស់ចេះអស់ចង់អស់ថ្នាំងថ្នាក់ បានជ្រះស្រឡះអស់រលីង។
អស់មានប្រាថ្នាចង់បានអ្វី កាមគុណលោកិយចាក់ចោលផ្ទឹង
គ្រវាត់បោះចោលស្អាតរលីង ចិត្តនេះស្អាតធេងព្រោះក្តីស្ងប់។
ទីបួនបុគ្គលដែលបានសាង បុណ្យល្អស្អិតស្អាងដោយគោរព
សន្សំមគ្គផលយ៉ាងប្រសព្វ តែងបានឆ្លងផុតជ្រោះទុក្ខភ័យ។
តែងបាននូវក្តីសុខក្សេមក្សាន្ត ព្រោះប្រតិបត្តិបានល្អប្រពៃ
ឆ្លងអន្លង់បួនដោយជោគជ័យ ព្រោះមាននិស្ស័យកសាងបុណ្យ។
បុណ្យនេះហៅបុណ្យធំអស្ចារ្យ ព្រះអរហន្តាទ្រង់សន្សំ
សន្សំសាងមកច្រើនដោយគុណ ដែលបានពីបុណ្យនោះឲ្យផល។
បានជូននូវផលផ្តល់ចុងក្រោយ ជាតិចុងបង្ហើយក៏បានយល់
សម្រេចធម៌គ្រប់ឈប់អំពល់ តទៅអស់ខ្វល់បានសុខា។
ហេតុនេះបានជាព្រះសាស្តា ទ្រង់មានដីកាទូន្មានថា
អ្នកសាងសន្សំបួនប្រការ បានក្តីសុខាមានមង្គល។
ចប់អស់មង្គលសាមប្រាំបី ដែលព្រះជិនស្រីទ្រង់សម្តែង
ទ្រង់បានបន្ថែមគាថាផ្សេង ដែលមានចារចែងជាកាព្យ។

## ព្រះគាថាបញ្ចប់

**ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា**
**សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។**

នេះជាព្រះពុទ្ធនិគមវចនៈដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជាក់សរុបរួមនូវមង្គលទាំងអស់ដោយមានន័យថា ៉ទេវតានិងមនុស្សទាំងឡាយធ្វើនូវមង្គលទាំងឡាយ

ប្រាកដដូច្នេះហើយជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង នេះជាមង្គលដ៏ឧត្តមរបស់ទេវតានិងមនុស្សទាំងឡាយ នោះ។

**អត្ថបទកំណាព្យ** (បទសរភញ្ញ)

បើសិនទេវតាមនុស្សទាំងឡាយ ប្រតិបត្តិមិនឆ្ងាយពីមង្គល
នឹងមិនចាលចាញ់គ្រប់មណ្ឌល តែងបាននូវផលសុខសិរី។
ចូរអ្នកប្រកាន់ហើយជឿថា មង្គលនេះណាសាមប្រាំបី
មានមិនសេពគប់ជនពាលក្តី នឹងផុតទុក្ខភ័យជ័យជោគហោង។

**មតិបញ្ចប់នៃស្នេរ**

ចប់អស់មង្គលសាមប្រាំបី ដែលព្រះជិនស្រីជាសាស្តា
ទ្រង់បានប្រទានធម៌ទេសនា សម្តែងគាថាទុកទូន្មាន។
ជាបែបជាបទសរភញ្ញ ពីរោះពិតពេញចិត្តសន្តាន
ហៅមង្គលសូត្រធម៌ថ្កើងថ្កាន គួរយើងគ្រប់ប្រាណខំសិក្សា។
ខ្ញុំបានលើកយកមង្គលសូត្រ មកសិក្សាត្រួតតាមបញ្ញា
រំគាយសេចក្តីជាកាព្យា ពណ៌នាបានចប់អស់សេចក្តី។
ប្រសិនបើមានការខុសឆ្គង រម្លស់រំលងអត្ថន័យ
ក្រែងមិនចំច្បាស់ព្រះធម៌ថ្លៃ ឬខុសអ្វីក្តីសុំមេត្តា។
សូមទានខន្តីអភ័យទោស ដល់ខ្ញុំដែលស្មោះមានចេតនា
ចារចែងកំណាព្យកាព្យធម៌អាថ៌ គាំទ្រសាសនាព្រះជិនស្រី។
ចង់ទាញសទ្ធាអ្នកសិក្សា ដែលស្និទ្ធស្នេហាកំណាព្យក្តី
ឲ្យបានអានធម៌ឬវិន័យ ដែលរាយសេចក្តីជាកំណាព្យ។
ផលល្អនឹងបានទាំងពីរផ្លូវ នេះជាគោលដៅសុំទានជ្រាប
សូមលោកអ្នកអានបានសន្តិភាព មង្គលរៀងរាបដរាបហោង។

# បត្តិទានវាចារបស់ស្មេរ

(បទបប្យាវ័ត)

| | | | |
|---|---|---|---|
| យើងខ្ញុំជាស្មេរ | សរសេរធម្មទាន | ព្យាយាមយើងមាន | ធ្វើស្រេចបាច់ហើយ |
| សុំឧទ្ទិសផល | បញ្ជូនទៅឲ្យ | មិនអែអរង់ទ្បើយ | ជូនអ្នកមានគុណ។ |
| មានជាបឋម | ម្តាយខ្ញុំនិងពុក | ដែលកូនចាំទុក | ថាមានគុណធ្ងន់ |
| អញ្ជើញទទួល | ផលបុណ្យជាមុន | កូនសូមតបគុណ | គុណលោកមហិមា។ |
| បន្តទៅទៀត | សូមឆ្លៀតជូនផល | ចំពោះទៅដល់ | ជីដូនជីតា |
| ព្រមទាំងលោកគ្រូ | ឧបជ្ឈាយាចារ្យ | និងញាតកា | ក្នុងសង្សារវដ្ត។ |
| ព្រមទាំងអ្នកអាន | ពុទ្ធបរិស័ទ | ដែលខំប្រតិបត្តិ | ក្នុងសាសន៍ពុទ្ធរតន៍ |
| សូមបានសួស្តី | ជោគជ័យប្រាកដ | បានសុខវិវឌ្ឍន៍ | ដល់អនាគត។ |
| លោកអ្នកជ្រះថ្លា | គ្រប់ៗអង្គា | ដែលបានបូជា | កម្លាំងកាយចិត្ត |
| ជួយកិច្ចធម្មទាន | ឲ្យសម្រេចពិត | សូមផលដូចចិត្ត | ស្មើយើងខ្ញុំណា។ |
| សូមលោកគ្រប់ប្រាណ | ឆាប់បានសម្រេច | ឲ្យបានកាត់ផ្តាច់ | វាលវដ្តសង្សារ |
| ឆាប់បានរំដោះ | រួចខ្មោះតណ្ហា | អធិចិត្តក្លា | ដល់ព្រះនិព្វាន។ |
| ពិសេសលើសគេ | សូមពុទ្ធសាសនា | ស្ថិតស្ថេរថ្លៃថ្លា | គង់ជាធរមាន |
| ដឹកនាំសព្វសត្វ | ដល់សុខនិព្វាន | គ្រប់ពុទ្ធស័កមាន | ប្រាំពាន់វស្សា។ |

ខ្ញុំព្រះករុណាខ្ញុំបាទ ឧបាសក **ឆាយ មាស**

ខ្ញុំព្រះករុណា អាត្មាភាព បញ្ញាវរោ **ឆេន ចន្ទសេដ្ឋា**

# បត្តិទានវាចានៃអ្នកចូលរួមក្នុងកិច្ចការធម្មទាន

យើងខ្ញុំទាំងអស់គ្នាត្រូវជា កូន កូនប្រសារ ចៅ ចៅទួត ស្វាមី ភរិយា បង ប្អូន ញាតិទាំងឡាយ ដែលបានរួមចំណែកក្នុងកិច្ចការធម្មទាននេះ សូមឧទ្ទិសមហាកុសលជូនចំពោះ វិបាកវិញ្ញាណ នៃបុព្វការីជនទាំងឡាយ មាន មាតាបិតា ជីដូន ជីតា កុងម៉ា និងញាតិទាំងឡាយក្នុងសង្សារវដ្ត ដែលបានចែកឋានទៅហើយនោះ សូមឲ្យទទួលបាននូវចំណែកនៃមហាកុសលទាំងឡាយរបស់យើងខ្ញុំទាំងអស់គ្នា។

មួយចំណែកទៀត សូមលើកយកមហាកុសលទាំងឡាយនេះ ជូនចំពោះលោកអ្នកទាំងឡាយដែលបានចូលរួមធ្វើឧបការគុណដល់យើងខ្ញុំ សូមទទួលបាននូវចំណែកនៃបុណ្យឲ្យបានស្មើៗគ្នា ទីបំផុតព្រះពុទ្ធទ្រង់ត្រាស់ដឹងនូវធម៌ណា សូមឲ្យបានសម្រេចក្នុងចំណែកនៃព្រះធម៌នោះ គ្រប់ៗគ្នា អនុមោទនា...!។

# សន្លឹកចង្អុលបង្ហាញ មង្គលគាថា

## សន្លឹកចង្អុលបង្ហាញមង្គលគាថា មិនមែនជាមាតិកាទេ


| | | |
|---|---|---|
| ព្រះគាថាផ្ដើម ពហូទេវា | ទេវតាព្រមទាំងមនុស្សដ៏ច្រើន | 1 |
| ព្រះគាថាទី១ មាន៣ មង្គល | ១ អសេវនា ច ពាលានំ កិរិយាមិនសេពគប់នូវបុគ្គលពាល | 3-6 |
| | ២ បណ្ឌិតា នញ្ច សេវនា កិរិយាសេពគប់នូវបណ្ឌិត | |
| | ៣ បូជា ច បូជានីយានំ បូជាដល់បុគ្គលដែលគួរបូជា | |
| ព្រះគាថាទី២ មាន៣ មង្គល | ១ បដិរូបទេសវាសោ កិរិយារស់នៅក្នុងប្រទេសដ៏សមគួរ | 9-18 |
| | ២ បុព្វេ ច កតបុញ្ញតា កិរិយាបានធ្វើបុណ្យទុកមក | |
| | ៣ អត្តសម្មាបណីធិ កិរិយាតម្កល់ខ្លួនបានល្អប្រពៃ | |
| ព្រះគាថាទី៣ មាន៤ មង្គល | ១ ពាហុ សច្ចញ្ច រៀនសូត្រច្រើន | 25-33 |
| | ២ សិប្បញ្ច សិល្បសាស្ត្រល្អ ឬការងារឈ្លាសវៃ | |
| | ៣ វិនយោ ច សុសិក្ខិត្តោ អប់រំវិន័យបានល្អ | |
| | ៤ សុភាសិតា ច យា វាចា  ប្រើសម្ដីពីរោះ | |
| ព្រះគាថាទី៤ មាន៤ មង្គល | ១ មាតា ឧបដ្ឋានំ កិរិយាបម្រើមាតា | 37-46 |
| | ២ បិតុ ឧបដ្ឋានំ កិរិយាបម្រើបិតា | |
| | ៣ បុត្តទារស្ស សង្គហោ   សង្គ្រោះកូនប្រពន្ធ | |
| | ៤ អនាកុលា ច កម្មន្តា មិនធ្វើការច្របូកច្របល់ | |
| ព្រះគាថាទី៥ មាន៤ មង្គល | ១ ទានញ្ច ការធ្វើទាន | 50-65 |
| | ២ ធម្មចរិយា ការប្រតិបត្តិធម៌ | |
| | ៣ ញាតកានញ្ច សង្គហោ កិរិយាសង្គ្រោះញាតិ | |
| | ៤ អនវជ្ជានិ កម្មានិ មិនធ្វើការដែលមានទោស | |
| ព្រះគាថាទី៦ មាន៣ មង្គល | ១ អារតី វិរតី បាបា កិរិយាមិនត្រេកអរនិងកិរិយាវៀរចាកបាប | 71-80 |
| | ២ មជ្ជបាណា ច សញ្ញមោ កិរិយាសង្រួមក្នុងទឹកស្រវឹង | |
| | ៣ អប្បមាទោ ច ធម្មេសុ មិនប្រមាទក្នុងធម៌ | |
| ព្រះគាថាទី៧ មាន៥ មង្គល | ១ គារវោ កិរិយាគោរពដល់បុគ្គលដែលគួរគោរព | 87-103 |
| | ២ និវាតោ កិរិយាចេះបន្ទាបខ្លួនល្អ | |
| | ៣ សន្តុដ្ឋី សម្រប ឬសន្ដោសចិត្តទៅក្នុងការប្រើ | |
| | ៤ កតញ្ញុតា ភាពជាមនុស្សកតញ្ញូ | |

| | | |
|---|---|---|
| | ៥ កាលេន ធម្មស្សវន កិរិយាស្តាប់ធម៌តាមកាល | |
| ព្រះគាថាទី៨ មាន៤ មង្គល | ១ ខន្តី សេចក្តីអត់ធន់ | 108-115 |
| | ២ សោវចស្សតា  ភាពជាអ្នកត្រូវប្រដៅងាយ | |
| | ៣ សមណានញ្ច ទស្សនំ កិរិយាបានឃើញសមណៈ | |
| | ៤ កាលេន ធម្មសាកច្ឆា កិរិយាសន្ទនាធម៌តាមកាល | |
| ព្រះគាថាទី៩ មាន៤ មង្គល | ១ តបោ សេចក្តីព្យាយាមដុតនូវបាបធម៌ | 122-134 |
| | ២ ព្រហ្មចរិយញ្ច ការប្រព្រឹត្តិនូវព្រហ្មចរិយធម៌ | |
| | ៣ អរិយសច្ចានទស្សនំ កិរិយាបានឃើញនូវអរិយសច្ចៈ | |
| | ៤ និព្វានសច្ឆិកិរិយា  កិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន | |
| ព្រះគាថាទី១០ មាន៤ មង្គល | ១ ផុដ្ឋស្ស លោកធម្មេហិ ចិត្តជាបុគ្គលដែលឈប់រវល់ | 136-141 |
| | ២ អសោកំ  គ្មានក្តីសោក | |
| | ៣ វិរជំ  មិនមានរាគៈ | |
| | ៤ ខេមំ ក្សេមក្សាន្ត | |
| ព្រះគាថាបញ្ចប់ | ឯតាទិសានិ កត្វាន បើសិនទេវតាមនុស្សទាំងឡាយ ប្រតិបត្តិ | 147 |

# នាមពុទ្ធបរិស័ទមានសទ្ធាបោះពុម្ពសៀវភៅនេះ

| គោត្តនាម-នាម | ប្រាក់ | គោត្តនាម-នាម | ប្រាក់ |
|---|---|---|---|
| ឧ.សិ នួន សុខឆេង Ellis និងស្វាមី ព្រមទាំងបុត្រ | $១៥០ | ឧ.ស តែ ហន និងកូនចៅ | ៣៥ ០០០៛ |
| ភិក្ខុ ឆេន និស្សិត ព្រមទាំងពុទ្ធបរិស័ទ ក្រចេះ | ៣៥០ ០០០៛ | លោក សុ សិលា អ្នកស្រី យូ រីតា ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| ឧ.សិ ប្រាក់ ស៊ីថា ឧ.សិ ប៊ីន រឿន ព្រមទាំងកូន | ៣៥៧ ៥០០៛ | ឧ.សិ ឆេង គៀម | ៣៥ ០០០៛ |
| ឧ.សិ ស៊ុន សោភា កូនស្រី ថុង សោភាវត្ថិ | | លោក ជា ប៊ុន អ្នកស្រី ឆេង ស៊ីង ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| លោកជា អេង អ្នកស្រី ឆេង ស៊ីម ព្រមទាំងបុត្រ | ១០៥ ០០០៛ | លោក ម៉ៅ ហេង អ្នកស្រី ឆេង ហៀង ព្រមទាំងកូន | ៣៥ ០០០៛ |
| ឧ.ស គង់ សុខម៉េង ឧ.សិ ថោងពេញ ព្រមទាំងកូនចៅ | ១០៥ ០០០៛ | លោក ហួត វឌ្ឍនា អ្នកស្រី ជា សុខហេង ព្រមទាំងកូន | ៣៥ ០០០៛ |
| ព្រះមហា ឆយ ឆៃលឿត | ១០០ ០០០៛ | អ្នកស្រី ឆេង ហួ និងស្វាមី ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| ជុវជន គា ពន្លឺ អ្នកមាយ ម៉ែន គុន ព្រមទាំងបងប្អូន | ៧០ ០០០៛ | អ្នស្រី ជា ស្រី មុំ និង កូនស្រី នីតា | ៣៥ ០០០៛ |
| ឯកឧត្តម ជាម អ៊ុន លោកជំទាវ ថាប់ ជឿន | ៧០ ០០០៛ | អ្នកស្រី តែ ស៊ីណា ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| ឧ.សិ ផេង សុខា | ៥៣ ០០០៛ | ឧ.សិ ប្អូ រឿង ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| ឧ.សិ ចិន មុំ ព្រមទាំងកូនចៅ | ៤៥ ០០០៛ | ឧ.ស តែ ហន ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| លោក ឆេង ស្រេង អ្នកស្រី ខាំ ថាវី ព្រមទាំងកូនចៅ | ៤២ ០០០៛ | ឧ.សិ ព្រាប លួម ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| ឧ.សិ ឈីវ វ៉ារី | ៤០ ០០០៛ | ឧ.សិ ស៊ិន សារុន ព្រមទាំងកូនចៅ | ៣៥ ០០០៛ |
| ឧ.សិ ឈីវ វណ្ណនី | ៤០ ០០០៛ | លោក ទូច សុខា អ្នកស្រី លួង សុខឃីម និងបុត្រ | ៣៥ ០០០៛ |
| ក. អាឡា ទួលតាឯក | ៤០ ០០០៛ | ឧ.សិ ធឹង លឿត និងក្រុមគ្រួសារ | ៣៥ ០០០៛ |
| លោក តែ ស៊ីវុត្ថា និង ភរិយា ព្រមទាំងបុត្រ | ៤០ ០០០៛ | ឧ.សិ ធឹង សម្បត្តិ និងក្រុមគ្រួសារ | |
| ព្រះមហា ស៊ាន សារ៉េត | ៣៥ ០០០៛ | ឧ.សិ ធឹងសម្បូរ | |
| ឧ.ស សូ សុត និង ក្រុមគ្រួសារ | ៣៥ ០០០៛ | ឧ.សិ ទុន ពៅ | ២១ ០០០៛ |
| ឧ.សិ យ៉ាន់ ជឿន ព្រមទាំងកូនចៅ | ២៧ ៥០០៛ | លោក កែ ផាបូរិន និងភរិយា ព្រមទាំងបុត្រ | ២១ ០០០៛ |
| ឧ.ស អ៊ុន ឆា ឧ.សិ អ៊ុក សាយឿម ព្រមទាំងកូនចៅ | ២៧ ៥០០៛ | ដូនជី ពេជ្ជ សារឿន ព្រមទាំងកូនចៅ | ២១ ០០០៛ |
| ឧ.សិ អ៊ុន សំ | ២៥ ៥០០៛ | ដូនជី មុត រ័ត្ន ព្រមទាំងកូនចៅ | ២១ ០០០៛ |
| ឧ. សឹម សំអាង ព្រងទាំងកូនចៅ | ២៥ ៥០០៛ | លោក កង ចំរើន អ្នកស្រី ហែម សាន ព្រងទាំងកូនចៅ | ២១ ០០០៛ |
| ឧ.សិ សំ រិទ្ធកញ្ញា | ២៥ ០០០៛ | ឧ.សិ ឌួង សាវ៉ាត | ២១ ១០០៛ |
| ឆាយ រក្សា និង អ៊ុំវណ្ណៈ | ២០ ០០០៛ | ឧ.ស កែវ ហ៊ន ព្រមទាំងកូនចៅ | ២០ ០០០៛ |
| ឆាយ រ៉ាសនា | ២០ ០០០៛ | ឧ.សិ កែម ចាន់ថុល ព្រមទាំងកូនចៅ | ២០ ០០០៛ |
| មាច យន់ ព្រមទាំងក្រុមគ្រួសារ | ២០ ០០០៛ | ផ្លូវជាតិ ៥ ធ្វើឡាន | ២០ ០០០៛ |
| ឆោម ណារិន | ២០ ០០០៛ | អ្នកស្រី យ៉ាន់ ពឿន និង កូន យ៉ាន់ វិសាល | ១២ ៥០០៛ |
| ឧ.ស ព្រាប សាហាល់ | ២០ ០០០៛ | វ៉ាន់ បូយ៉ា យក់ កញ្ញា | ១២ ០០០៛ |
| ឧ.សិ ចែត ញិន ព្រមទាំងកូនចៅ | ១៧ ៥០០៛ | លោក រឿន វ៉ាត និងអ្នកស្រី ស៊ាន ស៊ត ព្រមទាំងបុត្រ | ១០ ៥០០៛ |
| ឧ.សិ គឹម ស្រី និងស្វាមី ព្រមទាំងបុត្រ | ១៧ ៥០០៛ | ឧ.សិ ឈាន ណែត | ១០ ៥០០៛ |
| ឧ.សិ សាន សុភ័ណ | ១៧ ៥០០៛ | ផល លីហេង | ១០ ៥០០៛ |
| ឧ.សិ ហង់ សន | ១៧ ៥០០៛ | Mr. Leo Christina អ្នកស្រីជ័យ សុភ័ណ | ១០ ៥០០៛ |
| ឧ.សិ សុខ ចិន្តា | ១៧ ៥០០៛ | ហែម រិទ្ធី និងជ័យ សំអាត ព្រមទាំងបុត្រ | ១០ ៥០០៛ |
| ឧ.ស ប៉ង់ ប៉ុក ឧ.សិ រស់ ហេន ព្រមទាំងកូនចៅ | ១៧ ៥០០៛ | យ៉ុង ប៊ិច | ១០ ៥០០៛ |
| ឧ.សិ ហ៊ន គឹម ហ៊ាង និង កូនហន ចិត្រា | ១៧ ៥០០៛ | ឧ.សិ ប្អូ ឆឹង | ១០ ៥០០៛ |
| ឧ.សិ ជៀម ផៃ | ១៧ ៥០០៛ | យុវជន ច្រឹម | ១១ ០០០៛ |

| | | | |
|---|---|---|---|
| ឧ.សិ ផាវ ស៊ាន ព្រមទាំងកូនចៅ | ១៧ ៥០០ ៛ | ឧ.សិ គុណ សកុណា | ១០ ៥០០ ៛ |
| ឧ.សិ ហួត សុខខុន | ១៧ ៥០០ ៛ | ឧ.សិ ធួក ណៃហួយ | ១០ ៥០០ ៛ |
| អ៊ុច ផាន | ១០ ៥០០ ៛ | វ៉ាន់ទូច និងស្វាមី ព្រមទាំងបុត្រ | ១០ ៥០០ ៛ |
| ឡុង សាមិ ព្រមទាំងកូនចៅ | ១៥ ០០០ ៛ | អ្នកស្រី ភិន ហុន | ១០ ០០០ ៛ |
| ជុជ ឡៃស៊ីម | ១០ ៥០០ ៛ | ឧ.សិ ជឿម អាត | ១០ ០០០ ៛ |
| ឧ.សិ យី សូត្រ | ១០ ០០០ ៛ | អាត់ យឹម | ១០ ០០០ ៛ |
| ដូនជី ទុង សុខា និងពុទ្ធបរិស័ទ | ១០ ០០០ ៛ | ម៉ន ថុង | ១០ ០០០ ៛ |
| ឧ.សិ សុខ ហៀក | ១០ ០០០ ៛ | ឧ.សិ អ៊ឹម វ៉ាន់ថា ព្រមទាំងកូនចៅ | ១០.០០០ ៛ |
| ភិក្ខុ គង់វាសនា | ៧ ៥០០ ៛ | ឧ.សិ ញ៉េប វ៉ន | ៧ ០០០ ៛ |
| លោក សួន ផេន អ្នកស្រី វ៉ាត ចន្ទសិរី ព្រមទាំងបុត្រ | ៧ ០០០ ៛ | សាន ខាត់ | ៧ ០០០ ៛ |
| លោក សាំង សុជាត និងអ្នកស្រី វ៉ាត សុជីវី | ៧ ០០០ ៛ | ចាន់ណា ព្រមទាំងស្វាមិ និងបុត្រ | ៧ ០០០ ៛ |
| អ្នកស្រី រិទ្ធ ពៅ | ៧ ០០០ ៛ | យុវជន ចក់ ហៅ ឌ្យង | ៧ ០០០ ៛ |
| កញ្ញា សយ រក្សា កញ្ញា សយ ពិសី | ៧ ០០០ ៛ | ឧ.សិ ឪ វ៉ាន និង កូន | ៧ ០០០ ៛ |
| អ្នកស្រី សូ គឹមរី | ៧ ០០០ ៛ | សាមណេរ ង៉ាន សិរីវឌ្ឍន៍ | ៧ ០០០ ៛ |
| ឧ.សិ ម៉ាន់ រី | ៧ ០០០ ៛ | ឧ.សិ ទុន ចាន់ស៊ី | ៧ ០០០ ៛ |
| កញ្ញា ស ស្រីរ័ត្ន | ៧ ០០០ ៛ | ឧ.សិ រស់ ស៊ីម | ៧ ០០០ ៛ |
| ឧ.សិ ជួន ហឿប ព្រមទាំងកូនចៅ | ៧ ០០០ ៛ | ឧ.សិ ហៃ ភី | ៧ ០០០ ៛ |
| ឧ.សិ ថោង ហូ ព្រមទាំងកូនចៅ | ៦ ០០០ ៛ | លោក ព្រាប សូនី | ៥ ០០០ ៛ |
| ញោម ឈូក (បូជាសព) | ៦ ០០០ ៛ | ឧ.សិ ជាប យឿន | ៥ ០០០ ៛ |
| ប៉ែន រ៉ុម | ៥ ០០០ ៛ | ឧ.សិ វ៉ាន់ គុណ | ៥ ០០០ ៛ |
| គុយ សម្រេច | ៥ ០០០ ៛ | អ្នកស្រី ព្រាប ចាន់និមល | ៥ ០០០ ៛ |
| ធុក ចន្ទ្រា | ៥ ០០០ ៛ | ឧ.សិ ថោង ហោ ព្រមទាំងកូនចៅ | ៥ ០០០ ៛ |
| សេង សុខា ព្រមទាំងបុត្រ | ៥ ០០០ ៛ | លោក វួន ស៊ាងវ៉ាន និង ភរិយា | ៥ ០០០ ៛ |
| ឧ.ស យឹម ពុំ | ៥ ០០០ ៛ | អ្នកស្រី ស៊ិន ផល្លី | ៥ ០០០ ៛ |
| អ្នកស្រី នឹម ទូច | ៥ ០០០ ៛ | ឧ.សិ រស់ហេង | ៥ ០០០ ៛ |
| តន់ សារេត | ៤ ០០០ ៛ | ឧ.ស ខន ឧ.សិ លី | ៤ ០០០ ៛ |
| សំ សានី | ៤ ០០០ ៛ | វ៉ាន់ តូម៉ា | ៤ ០០០ ៛ |
| ក. ចាន់ វ៉ាន់នី | ៤ ០០០ ៛ | អ្នកស្រី ង៉ែត យ៉ូ | ៤ ០០០ ៛ |
| ប៊ិច ប៊ុន | ៣ ៥០០ ៛ | ក. ស៊ុន សោភ័ណ | ៤០០០ ៛ |
| ប៊ិច ស្រី និងស្វាមី | ៣ ៥០០ ៛ | ឧ.សិ រូ វណ្ណា | ៣ ៥០០ ៛ |
| នាង ភាព | ៣ ៥០០ ៛ | ឧ.សិ អ៊ឹម អេង | ៣ ៥០០ ៛ |
| ប៊ិចណាវ៉ាណា និងស្វាមី | ៣ ៥០០ ៛ | ឧ.សិ សន ហុងធីម | ៣ ៥០០ ៛ |
| យាយ ថង | ៣ ៥០០ ៛ | ឧ.សិ ហៀង យ៉ាត | ៣ ៥០០ ៛ |
| ពេជ្រ សារឿន និងភរិយា | ៣ ៥០០ ៛ | ឧ.សិ ហេង | ៣ ៥០០ ៛ |
| យ៉ារី | ៣ ៥០០ ៛ | ឧ.សិ គឹម អេង | ៣ ៥០០ ៛ |
| អែម បញ្ញា | ៣ ៥០០ ៛ | ឧ. សិ ឈឹម សារ៉េត និងបុត្រ | ៣ ៥០០ ៛ |
| ឧ.សិ ផៀង សុខ | ៣ ៥០០ ៛ | យាយ ចុង ភៅ វត្ត | ៣ ៥០០ ៛ |
| សាយ យុទ្ធី | ៣ ៥០០ ៛ | ឧ.ស សូ សុត ឧ.សិ អ៊ិន គេល និងកូនចៅ | ៣ ៥០០ ៛ |
| ចន្ទ សុភី | ៣ ៥០០ ៛ | លោក ធីប វណ្ណា | ៣ ៥០០ ៛ |

| | |
|---|---|
| ឈឹម សុភាព | ៣ ៥០០ ៛ |
| ម៉ាក លំអង | ៣ ៥០០ ៛ |
| ម៉ាក ម៉ារី ព្រមទាំងស្វាមិ និងបុត្រ | ៣ ៥០០ ៛ |
| សាង យុទ្ធា | ៣ ៥០០ ៛ |
| អែម លំអង | ៣ ៥០០ ៛ |
| ជួន ឌី | ៣ ៥០០ ៛ |
| លី ឡេង | ៣ ៥០០ ៛ |
| គឹមហ៊ួរ ដាណេ | ៣ ៥០០ ៛ |
| សាង ផល្លី | ៣ ៥០០ ៛ |
| ម៉ាក់ នីកា ព្រមទាងស្វាមី និង បុត្រ | ៣ ៥០០ ៛ |
| អែម ឧស្សាហ៍ | ៣ ៥០០ ៛ |
| អ៊ា ស៊ាងហុង | ៣ ៥០០ ៛ |
| ឧ.សិ រស់ ហាន | ៣ ៥០០ ៛ |
| យុវតី សុគន្ធ | ៣ ៥០០ ៛ |

| | |
|---|---|
| ឧ.សិ មីន ហៃ ឧ.សិ នឿម | ៣ ៥០០ ៛ |
| ឧ.សិហ៊ុល ហុង | ៣ ៥០០ ៛ |
| ឧ.សិ កែវ ថាង | ៣ ៥០០ ៛ |
| ទូច ស៊ីមលី | ៣ ៥០០ ៛ |
| ដួនជី វ៉ាន់ដានី | ៣ ៥០០ ៛ |
| អ្នកស្រី អ៊ូច សុភ័ណ និងស្វាមី ព្រមទាំងបុត្រ | ៣ ៥០០ ៛ |
| ឧ.ស វ៉ាន់ ដាណេ និងក្រុមគ្រួសារ | ៣ ៥០០ ៛ |
| អ្នកស្រី ចន្ធូ | ៣ ៥០០ ៛ |
| អ្នកស្រី ឌុម សុផា | ៣ ៥០០ ៛ |
| ពុទ្ធបរិស័ទចូលរួម ថវិកា ៣០០០ ៛ | ១៥ នាក់ |
| ពុទ្ធបរិស័ទចូលរួម ថវិកា ២៥០០ ៛ | ៤ នាក់ |
| ពុទ្ធបរិស័ទចូលរួម ថវិកា ២០០០ ៛ | ៥១ នាក់ |
| ពុទ្ធបរិស័ទចូលរួម ថវិកា ១ ៥០០ ៛ | ៤ នាក់ |
| ពុទ្ធបរិស័ទចូលរួម ថវិកា ១ ០០០ ៛ | ៥៨ នាក់ |
| ពុទ្ធបរិស័ទចូលរួម ថវិកា ៥០០ ៛ | ៩ នាក់ |

សូមអធ្យាស្រ័យចំពោះការបាត់បង់ឈ្មោះ

ព្រះសម្មាសម្ពុទ្ធគឺជាមនុស្សជាតិពិត បុត្រក្សត្រ នៅប្រទេសឥណ្ឌា ។

ការបានសម្រេចនូវប្រយោជន៍ដ៏ប្រសើរបំផុត មិនអាស្រ័យទៅដោយអំណាចខាងក្រៅឡើយ

មនុស្សគឺជាម្ចាស់ជោគវាសនារបស់ខ្លួន សមដូចពុទ្ធភាសិតក្នុងបិដក ៥២, ទំព័រ៥៥ ថា

អត្តា ហិ អត្តនោ នាថោ ខ្លួនជាទីពឹងនៃខ្លួន ។




## គតិធម៌ដំណើរជីវិត

វីគតិធម៌ លំអជីវិត ដំណើរធម៌ពិត ជីវិតប្រពៃ

ជីវិតរស់នៅ ប្រសើរថ្លាថ្លៃ គឺវាអាស្រ័យ ចេះច្នៃប្រឌិត ។

ភិក្ខុ ឆេន ចន្ទសេដ្ឋា

រោងពុម្ព ម៉ៅ ផុន
MAO PHON Printing House